ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ហេតុអ្វីបានជាខ្ញុំជ្រើសរើសស្រ្តីជាអ្នករចនាប្លង់វិទ្យាស្ថានស្លឹករឹត
- កម្មាភិបាលស្រីរៀបរាប់ពីការរំលូតកូន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៧ ខែមីនា ឆ្នាំ២០១៧

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២០៧ ខែមីនា ឆ្នាំ២០១៧


## មាតិកា


◆ ហេតុអ្វីបានជាខ្ញុំជ្រើសរើសស្ត្រីជាអ្នករចនាប្លង់វិទ្យាស្ថានស្លឹករឹត? ..........១

**ផ្នែកឯកសារ**

◆ សកម្មភាពក្បត់របស់ ផន ចយ ប្រធានរោងជាងជួសជុលត្រាក់ទ័រ..........៤

◆ ស្មារតីប្រយុទ្ធរបស់យុវកម្មករដឹកជញ្ជូនជើងទឹក ..............................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ប៉ែ ម៉ុន ៖ អតីតកងឈ្លបក្រោមការគ្រប់គ្រងរបស់ តាអាន .............២២

◆ យឿម ៖ ខ្ញុំមិនចង់ឃើញសង្គ្រាមម្ដងទៀតទេ ................................២៤

◆ អ៊ីៗ ដើម្បីអង្គការ ..........................................................................២៦

◆ ការមិនបានរៀនសូត្រពីរឿងរ៉ាវឪពុកម្ដាយនៅតែជាការបារម្ភ ............២៩

**ផ្នែកច្បាប់**

◆ ក្មួយប្រុសរបស់ ប៉ុល ពត ចូលផ្ដល់សក្ខីកម្ម ................................៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ កម្មាភិបាលស្រីរៀបរាប់ពីការរំលូតកូន .........................................៣៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ គ្រួសារខ្ញុំដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម.......................................៤៣

◆ ប្រវត្តិរូបរបស់ ខៀវ សេងរ៉ា និងរូបថតនៅទួលស្លែង ....................៤៥

◆ កេរដំណែលដេះដង់សល់ពីរបបខ្មែរក្រហម.....................................៤៧

◆ "សល់មួយគ្រាប់" ...................................................................................៥៥




ប្លង់របស់វិទ្យាស្ថានស្លឹករឹត គូរដោយស្ថាបត្យករ ហ្សាហា ហាឌីត


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ចៅ ព្រហស្បតិ៍, ស្ងួន ពិជិត, សុខ វណ្ណៈ, ចាន់ លីខា, ហែម ចិន្តា, ម៉ែន ពិចិត្រ, លីអូនី គីដេស្ដី, លន់ ប៊ុនណាត, ខៀវ សុខន, សៀវ សុផុន, ហែម សុវណ្ណារិទ្ធិ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ និង ឆេង រ៉េង **អ្នកបកប្រែ ៖** ឈឹម អមរ័ត្ន និង ឯម សីលា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង រ៉េង និង សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org, www.truthcambodia.com**

# ហេតុអ្វីបានជាខ្ញុំជ្រើសរើសស្ត្រីជាអ្នករចនាប្លង់វិទ្យាស្ថានស្លឹករឹត?

## *ការរចនា ការជ្រើសរើសស្ថាបត្យករ និងការពិចារណាអំពីវប្បធម៌*

### *១) ធ្វើការកែលម្អលើស្ថាបត្យកម្មនៃបូជនីយដ្ឋានស្តីពីអំពើប្រល័យពូជសាសន៍បែបបុរាណ*

ស្ថាបត្យកម្មនៃបូជនីយដ្ឋានស្តីពីអំពើប្រល័យពូជសាសន៍តែងតែធ្វើឡើងដោយស្ថាបត្យករជនជាតិជ្វីពដែលជាបុរស ដូចដែលបានធ្វើឡើងនៅសារមន្ទីរសម្រាប់ការចងចាំអំពីការសម្លាប់រង្គាលនៅអឺរ៉ុបដែលហៅថា ហូឡូខសត៍ នៅក្នុងរដ្ឋធានីវ៉ាស៊ីនតោនដែលត្រូវបានរចនាឡើងដោយ ជេមស៍ អ៊ីងហ្គូ ហ្វ្រីដ ។ បូជនីយដ្ឋានរំឭកអំពីការសម្លាប់ជនជាតិជ្វីព នៅក្នុងទ្វីបអឺរ៉ុប ដែលរចនាឡើងដោយ ភីធី អេសិនមេន និងសារមន្ទីរនៃជនជាតិជ្វីពនៅទីក្រុងប៊ែកឡាំង ដែលរចនាឡើងដោយ ដានីញែល លីបេស្គីនដ៍ ។ បែបបទនៃការរចនារបស់ស្ថាបត្យករជាបុរសទាំងនេះ បង្ហាញនូវលក្ខណៈរួមមួយក្នុងកម្រិតផ្សេងពីគ្នា ។ ជាឧទាហរណ៍ ការរចនារបស់ លីបេស្គីនដ៍ បង្ហាញនូវរូបភាពមួយនៃចម្រៀកផ្លេកបន្ទោរ ដែលពុះជ្រែកទិដ្ឋភាពនៃសេចក្ដីស្លាប់ និងវិនាសកម្ម ។ នៅផ្នែកខាងក្នុងរូបភាពនេះត្រូវបានផ្គុំឡើងដោយការប្រើប្រាស់នូវបង្អួច ដែលសាងសង់ឡើងពីអំបែងកញ្ចក់ដ៏មុតស្រួច ។

ស្ថាបត្យកម្មបុរសទាំងនេះ មានទម្រង់សន្ធប់ ងងឹត និងមុំមុតស្រួច ដែលរចនាឡើងដោយប្រើប្រាស់នូវថ្ម ដែក និងកញ្ចក់ ក្នុងគោលបំណងបង្ហាញពីការបំផ្លិចបំផ្លាញ និងសភាពរឹងរូសដែលរំលេចពីភាពឃោរឃៅនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ស្ថាបត្យករបុរសទាំងនេះប៉ុនប៉ងបង្ហាញ និងញ៉ាំងឲ្យអ្នកទស្សនាមានភាពថប់អារម្មណ៍ សោកសៅ និងធ្លាក់ទឹកចិត្ត ។ អារម្មណ៍ទាំងនេះកើតមានដោយសារតែអារម្មណ៍របស់អ្នកទស្សនាត្រូវបានកម្ទា ហើយរូបភាពដែលបានបង្ហាញទាំងនោះបានជំរុញឲ្យអ្នកទស្សនាកើតមានភាពសោកសៅ ។ ប្រតិកម្មទាំងអស់នេះ ធ្វើឲ្យមានភាពជិតដាន និងដក់ជាប់នៅក្នុងគំនិត និងអារម្មណ៍របស់អ្នកទស្សនា ហើយបង្កើតឲ្យមានការប្ដេជ្ញាក្នុងការការពារប្រឆាំងនឹងការកកើតជាថ្មីនៃព្រឹត្តិការណ៍ដែលនាំទៅរក និងបង្កជាសោកនាដកម្មនៃការបាត់បង់ជីវិតនេះ ។

កន្លែងដែលផ្ដោតលើផលអវិជ្ជមាននៃ ហូឡូខសត៍ និងសមត្ថភាពរបស់មនុស្សក្នុងការបំផ្លិចបំផ្លាញមនុស្សជាតិរបស់ខ្លួន នៅតែត្រូវបានផ្ដោតលើ ក៏ប៉ុន្តែនេះមិនបានឆ្លុះបញ្ចាំងអំពីទិសដៅ ឬគោលបំណងក្នុងការបង្កើតជាបូជនីយដ្ឋានមួយ ឆ្ពោះទៅកាន់ការចងចាំអំពីជនរងគ្រោះនៃរបបខ្មែរក្រហម នៅក្នុងប្រទេសកម្ពុជានោះទេ ។ ដោយសារតែហេតុផលនេះ ខ្ញុំបាទមានការយកចិត្តទុកដាក់ក្នុងការជ្រើសរើសស្ថាបត្យករជំនាញលំដាប់ពិភពលោកដែលខ្ពស់បំផុត ហើយដែលមានស្នាដៃស្ថាបត្យកម្មខុសពីទម្រង់មុតស្រួច ក៏ដូចជាបែបបទស្រដៀងនឹងអ្វីដែលបានរៀបរាប់ និងជំរុញឲ្យមានសេចក្ដីហ្មងសៅ ដូចទៅនឹងគំរូបូជនីយដ្ឋានរំឭកពីអំពើប្រល័យពូជសាសន៍នៃជនជាតិជ្វីព ។ នេះមិនមែនជាការទិះតៀន ឬបន្តុះបង្អាប់លើសំណង់ទាំងនេះទេ ផ្ទុយទៅវិញ នេះគឺដើម្បីបញ្ជាក់ថា តាមរយៈវប្បធម៌ និងទំនៀមទម្លាប់សាសនារបស់កម្ពុជា យើងត្រូវតែឆ្ពោះទៅមុខក្នុងទិសដៅផ្សេង និងវិជ្ជមានមួយ ។

កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងាររបស់ខ្ញុំបាទ ក្នុងការជ្រើសរើសស្ថាបត្យករនេះឆ្លុះបញ្ចាំងអំពីតម្លៃផ្សេង ខណៈដែលការផ្ដល់តម្លៃដល់អតីតកាល គឺធ្វើការផ្ដោតជាសំខាន់ចំពោះការធានានូវបទពិសោធន៍ដែលវិជ្ជមានជាងមុន ប្រសើរជាងមុន និងខ្ពង់ខ្ពស់ទៅកាន់អនាគតល្អជាងបច្ចុប្បន្ន ។ ទោះបីជាអ្នកមកទស្សនានៅវិទ្យាស្ថានស្លឹករឹតអគារក្នុងទីក្រុងភ្នំពេញនេះ នឹងទទួលបានបទពិសោធអំពីភាពឃោរឃៅ និងព្រៃផ្សៃហួសពីការស្មាននៃរបបខ្មែរក្រហម និងវិនាសកម្មនៃរបបនេះដែលបានបន្សល់ទុកដល់ប្រជាជនកម្ពុជាយ៉ាងណាក៏ដោយ អ្នកទាំងអស់ក៏អាចទទួលបាននូវតម្លៃដែលផ្សារភ្ជាប់ជាមួយនឹងការចងចាំអំពីជនរងគ្រោះក្នុងជំហរមនុស្សជាតិដែលមិនយល់ព្រមទទួលយកនូវគ្រោះថ្នាក់នៃសង្គ្រាម

មនោគមន៍វិជ្ជាជ្រុលនិយម និងភាពមិនសមហេតុសមផល ។ មិនតែប៉ុណ្ណោះ អ្នកទស្សនាអាចរួមចំណែកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការធានារារាំងចំពោះការកើតមាននៃស្ថានភាពទាំងនោះនៅក្នុងកម្រិតក្នុងស្រុក តំបន់ និងអន្តរជាតិ ។ លើសពីនេះទៅទៀត អ្នកទស្សនានឹងដឹងថាតើតម្លៃដែលផ្សារភ្ជាប់ជាមួយនឹងចំណេះដឹង ការផ្សះផ្សា និងការយោគយល់ ត្រួសត្រាយផ្លូវមួយទៅកាន់អនាគតដ៏ត្រចះត្រចង់មួយ បានយ៉ាងមានប្រសិទ្ធភាព និងវិជ្ជមានដោយរបៀបណា ។ អ្នកទស្សនាក៏នឹងដឹងអំពីវិធីសាស្ត្រក្នុងការដាក់បញ្ចូលព្រឹត្តិការណ៍ដែលបង្កឡើងដោយរបបខ្មែរក្រហមនេះ ទៅក្នុងបរិបទទូលាយជាងមុននៃប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់កម្ពុជា និងមូលហេតុដែលបណ្តាលឲ្យបរិបទនោះមានតម្លៃក្នុងការទទួលយក ។

**២) ឃ្លាតចេញពីទំនៀមទម្លាប់នៃស្ថាបត្យកម្មទាក់ទងនឹងអំពើប្រល័យពូជសាសន៍ដែលរចនាឡើងដោយបុរស ដោយជ្រើសរើសស្ថាបត្យករជាស្ត្រី៖**

សមិទ្ធផលនៃស្នាដៃបុរស លើស្ថាបត្យកម្មនានាដែលបានរៀបរាប់ ចំពោះខ្ញុំបាទគិតថាលក្ខណៈទាំងនេះមិនសមស្របចំពោះនេះទេ ។ ខ្ញុំបាទជឿជាក់ថាគឺដល់ពេលដែលគួរតែមានការចូលរួមពីអ្នកជំនាញផ្នែកស្ថាបត្យកម្មលំដាប់ពិភពលោកហើយដែលជាស្ត្រីដ៏អស្ចារ្យម្នាក់ ដើម្បីបញ្ជាក់ថាកិច្ចខិតខំប្រឹងប្រែងក្នុងការរចនាអាចរួមផ្សំ និងដាក់បញ្ចូលតម្លៃ និងគោលគំនិតបែបវិជ្ជមាន និងផ្តោតលើអនាគតជាងនេះ ។ ខ្ញុំបាទត្រូវបានជំរុញដោយកត្តានេះ ហើយដែលនឹងផ្តល់ឲ្យអ្នកទស្សនានូវបទពិសោធន៍ដែលមានទម្ងន់ដូចគ្នា ក៏ប៉ុន្តែមិនសូវពិបាកទទួលយក មានគុណភាពជាង និងប្រសើរជាង ។ កេរដំណែលដែលសមសួននេះ ពោរពេញដោយអំណាចរបស់លោកស្រី ហ្សាហា ហាឌីដ ផ្តោតលើខ្សែបន្ទាត់ពត់ពេន ដែលខុសពីទម្រង់ធរណីមាត្រនឹងថ្កល់ ជ្រុងប្រសព្វនៃទម្រង់អគារដែលបត្តុបលើគ្នា មានសក្តានុពលក្នុងការបម្លែងទម្រង់អគារស្ថាបត្យកម្មដែលមានការរចនាបង្ហាញពីផលអវិជ្ជមាននៃឧក្រិដ្ឋកម្មសង្គ្រាម ឲ្យទៅជាទម្រង់ថ្មីសន្ទាង និងមានទិសដៅវិជ្ជមាន ។ លើសពីនេះទៀត ដោយសារតែជនរងគ្រោះស្ទួតត្រង់នៃឧក្រិដ្ឋកម្មសង្គ្រាម ភាគច្រើនគឺជាស្ត្រី និងកុមារ ដែលភាគច្រើនទាមទារការយកចិត្តទុកដាក់ខ្ពស់ពីសង្គម ដូច្នេះ គឺដល់ពេលដែលស្ត្រីត្រូវតែដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការរចនានេះ ដើម្បីទទួលស្គាល់ការបាត់បង់ជារួមរបស់ខ្លួន ។

**៣) កាត់បន្ថយទំនាក់ទំនងជាតិសាសន៍ និងទំនាក់ទំនងដទៃទៀត រវាងស្ថាបត្យករ និងជនរងគ្រោះ**

ការរចនាស្ថាបត្យកម្មស្តីពីអំពើប្រល័យពូជសាសន៍ តាំងពីដើមមក ត្រូវបានដឹកនាំដោយស្ថាបត្យករដែលមានជាតិសាសន៍ ឬមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងជនរងគ្រោះនៃគម្រោងរចនារបស់ខ្លួន ។ មានការអះអាងគាំទ្រ ក៏ដូចជាជំទាស់នឹងទំនាក់ទំនងនេះ ។ ខ្ញុំបាទពុំចង់វិនិច្ឆ័យលើដំណើរការក៏ដូចជាគំនិតណាមួយដែលនាំឲ្យមានការលើកឡើងនេះទេ ។ សម្រាប់គម្រោងរចនាវិទ្យាស្ថានស្លឹករឹតនេះ យ៉ាងណាមិញ ខ្ញុំប្តេជ្ញាថា ឥទ្ធិពលនៃគម្លាតខុសគ្នាដ៏សំខាន់នេះ បើប្រៀបទៅនឹងគម្រោងដែលមានទំនាក់ទំនងគ្នា គឺមានគុណសម្បត្តិដែលនឹកស្មានមិនដល់ ។ លោកស្រី ហាឌីដ គឺជាជនជាតិអ៊ីរ៉ាក់ ដែលពុំមានទំនាក់ទំនងជាតិសាសន៍ សាសនា ឬទំនាក់ទំនងដទៃទៀត ជាមួយនឹងប្រជាជនកម្ពុជាដែលជាជនរងគ្រោះក្នុងរបបខ្មែរក្រហមទេ ។ ក្នុងករណីនេះ លោកស្រីមានសម្ពាធតិចក្នុងការលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរចនានេះ ហើយខ្ញុំបាទមានភាពសោមនស្សចំពោះដំណើរការពោរពេញដោយភាពច្នៃប្រឌិតដែលលេចរូបរាងឡើងតាមរយៈគម្លាតនេះ ។ ទន្ទឹមនឹងនេះ លោកស្រីយល់យ៉ាងច្បាស់អំពីផលប៉ះពាល់ដ៏ព្រឺព្រួចនៃឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងប្រទេសមួយ ដែលបង្កឡើងដោយអ្នកដឹកនាំនៃប្រទេសនោះ ប្រឆាំងនឹងក្រុមជនជាតិជាក់លាក់ណាមួយ ដោយរួមបញ្ចូលនូវការគ្រប់គ្រងយ៉ាងកាចសាហាវ ការកាប់សម្លាប់ និងការបំផ្លិចបំផ្លាញ ។ សង្គ្រាមនៅក្នុងប្រទេសអ៊ីរ៉ាក់នាពេលថ្មីៗនេះ ក៏ដូចជាភេរវកម្មក្រោយជម្លោះ ដែលបន្តយាយីប្រទេសនេះ ព្រមទាំងការរស់នៅរបស់គ្រួសារលោកស្រី បង្កជាបញ្ហាស្មុគស្មាញដែលគួរតែរួមបញ្ចូលទៅក្នុងការរចនាបូជនីយដ្ឋានរំឭកអំពីជនរងគ្រោះ ។

**៤) ដាក់បញ្ចូលទៅក្នុងការរចនានូវកេរដំណែលសម្បត្តិវប្បធម៌ និងស្ថាបត្យកម្មរបស់ប្រជាជនកម្ពុជា៖**

សម្បត្តិវប្បធម៌ តែងតែត្រូវបានផ្សារភ្ជាប់ជាមួយនឹងភាពអច្ឆរិយៈនៃស្ថាបត្យកម្មបែបបុរាណរបស់អង្គរ ជាពិសេសបំណែកដ៏អស្ចារ្យនៃបណ្តុំប្រាសាទអង្គរវត្ត ជានិមិត្តរូបនៃកេរដំណែលដ៏ថ្លៃ

ថ្នាំរបស់ប្រទេសកម្ពុជា ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ ដោយសារតែបូជនីយដ្ឋានរំឭកពីជនរងគ្រោះនៃរបបខ្មែរក្រហមនេះ មានទំហំតូចជាងគម្រោងដ៏ស្កឹមស្កៃនានា ហើយដោយសារតែបូជនីយដ្ឋាននេះ ប៉ុនប៉ងរួមបញ្ចូលនូវតម្លៃ និងអត្ថប្រយោជន៍សម្រាប់មនុស្សយ៉ាងទូលាយ បើប្រៀបទៅនឹងចំណុចដទៃទៀត ខ្ញុំបាទបានធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រក្នុងការភ្ជាប់ទំនាក់ទំនងនៃកិច្ចខិតខំប្រឹងប្រែងរចនាទៅនឹងអតីតកាល នោះគឺមិនមែនបណ្តុំអង្គរវត្តទាំងស្រុងទេ ក៏ប៉ុន្តែទៅនឹងបណ្តុំប្រាសាទដែលមិនសូវល្បីរន្ទឺហើយមានទំហំតូចជាងនោះគឺ ប្រាសាទបន្ទាយស្រី ឬហៅម្យ៉ាងទៀត "បន្ទាយរបស់ស្ត្រី" ឬ "បន្ទាយនៃសម្រស់" ស្ថិតនៅប្រមាណជាង១០គីឡូម៉ែត្រ ខាងជើងប្រាសាទអង្គរវត្ត ។ ខុសប្លែកពីប្រាសាទនានានៅក្នុងបណ្តុំប្រាសាទបន្ទាយស្រី មិនមែនជាប្រាសាទរបស់រាជវង្ស ក៏ប៉ុន្តែគឺជាស្នាដៃដ៏ឯករាជ្យមួយ ។ ដោយសារតែកម្រិតរបស់ចំណុចលម្អិតបែបសិល្បៈ មានលក្ខណៈពិសិដ្ឋ និងល្អិតល្អន់ស័ក្តិសមជាបូជនីយដ្ឋានរំឭកមួយ ប្រាសាទបន្ទាយស្រីតែងតែត្រូវបានចាត់ទុកថាជា "គ្រឿងលម្អដ៏មានតម្លៃនៃវប្បធម៌ខ្មែរ" នៅក្នុងអក្សរសិល្ប៍ ។ ខ្ញុំបាទជឿជាក់ថា កេរដំណែលនៃប្រាសាទដែលតូចតែពោរពេញដោយសិល្បៈនេះ អមជាមួយនឹងការរួមបញ្ចូលនូវរឿងព្រេងប្លែក ក៏ដូចជាហោជាង និងខឿន គឺជាគំរូដ៏ស័ក្តិសមបំផុតសម្រាប់កិច្ចខិតខំប្រឹងប្រែងនៃការរចនាបូជនីយដ្ឋានរំឭក និងសារមន្ទីរ ។

### ៥) រំលេចនូវគោលគំនិតរចនាទាំងមូលៈ

តាមការមើលឃើញ រាល់សាសនាទាំងអស់ រួមបញ្ចូលនូវជំនឿជាមូលដ្ឋាននៃការសិក្សាអំពីសាសនារបស់ខ្លួន ជួនកាលក៏មានការលើកឡើងអំពីរឿងព្រេង ពោលគឺ វត្ថុមាន និងសារសំខាន់នៃឋានសួគ៌ និងឋាននរក ។ ការបកស្រាយ និងការពិពណ៌នាអំពីធាតុផ្ទុយគ្នាទាំងពីរនេះ គួបផ្សំនូវភាពប្លែកពីគ្នា ដែលនៅពេលខ្លះខុសគ្នាយ៉ាងខ្លាំង ពីការនិទានក្នុងសាសនាមួយ ទៅសាសនាមួយទៀត ។ ពុំមានការបកស្រាយបែបសាសនាណាមួយនៃឋានសួគ៌ និងឋាននរកដែលធ្វើឲ្យព្រេងនិទានទាំងនេះមានភាពស្មុគស្មាញ និងបញ្ឈរក់ដោយគ្រុបខណ្ឌនៃទេវកថាវិទ្យា និងនរវិទ្យាស្តីពីព្រះទេពធីតា និងព្រះក្រោមបង្គាប់ ព្រមទាំងសភាវៈប្រឆាំង ដូចទៅនឹងសាសនាព្រះពុទ្ធរបស់អាស៊ី និងសាសនាហិណ្ឌូ ដែលជាទំនៀមទម្លាប់សាសនាចម្បងរបស់ប្រទេសកម្ពុជាទេ ។ ភាពសម្បូរបែបនៃទេវកថា និងការសិក្សាពីសាសនាដ៏ល្អឥតខ្ចោះ ការផ្តល់ឲ្យនៃទំនៀមទម្លាប់ទាំងពីរនេះ គឺមានលក្ខណៈថ្មីសន្លាងចំពោះបទដ្ឋានរបស់បស្ចិមប្រទេស ព្រមទាំងជះឥទ្ធិពលលើទំនៀមទម្លាប់សាសនាក្មេងវ័យរបស់អ្នកទាំងនេះ ដែលរួមមាន សាសនាជ្វីព សាសនាគ្រិស្ត និងសាសនាអ៊ីស្លាម ។ ព្រេងនិទានស្តីពីឋានសួគ៌ និងឋាននរកក្នុងពុទ្ធសាសនា និងសាសនាហិណ្ឌូ មានលក្ខណៈចាំបាច់យ៉ាងខ្លាំងក្នុងការទទួលស្គាល់ និងយល់ដឹងអំពីវិធីសាស្ត្រ និងមូលហេតុដែលធ្វើឲ្យការកំណត់ និងការឆ្លើយតបរបស់ប្រជាជនកម្ពុជាចំពោះសោកនាដកម្មដែលបន្សល់ពីជំនាន់ខ្មែរក្រហម ខុសពីការឆ្លើយតបរបស់ប្រជាជននៅបស្ចិមប្រទេស ដែលមានសភាពធ្ងន់ជាង ប៉ុនប៉ងដាក់ទោស និងពោរពេញដោយកំហឹង ។ ខ្ញុំបាទបានដឹកនាំកិច្ចពិភាក្សាមួយអំពីបញ្ហាទាំងនេះ ដើម្បីជម្រាបជាព័ត៌មាន និងពង្រឹងការយល់ដឹងរបស់ក្រុមរចនាប្លង់វិទ្យាស្ថានស្ថាបត្យកម្មស្ទីករីតរបស់លោកស្រី ហាឌីដ អំពីភាពខុសគ្នាដ៏សំខាន់នេះ ។

### ៦) រួមបញ្ចូលគោលគំនិតរួមសំខាន់ទាំងពីរ ពោលគឺធ្វើអតិបរិមាកម្ម ការប្រើប្រាស់អគារ និងសោភ័ណភាពៈ

ខ្ញុំបាទរំពឹង និងសង្ឃឹមទុកនូវគម្រោងអគារវិទ្យាស្ថានស្ទីករីតមួយដែលមានតួនាទីបម្រើដល់ការជំរុញ និងពង្រឹងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការលើកកម្ពស់ការយល់ដឹងនឹងចំណេះដឹងរបស់សាធារណជន អំពីវិនាសកម្ម ក៏ដូចជាដើម្បីផ្តល់ឲ្យសង្គមនូវអត្ថប្រយោជន៍នៃការផ្សះផ្សា តាមរយៈការអប់រំ ការចូលរួម និងការពិភាក្សា ដោយផ្អែកលើការចងចាំ និងការប្តេជ្ញា ។ ទន្ទឹមនឹងនេះដែរ ខ្ញុំបាទរំពឹង និងសង្ឃឹមទុកនូវបូជនីយដ្ឋានមួយដែលមានសោភ័ណភាពល្អប្លែក និងជាអត្តសញ្ញាណដែលសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពច្នៃប្រឌិតដ៏មានថាមពលរបស់លោកស្រី ហាឌីដ ដែលប្លែកពីស្នាដៃនានានៅក្នុងសហគមន៍ស្ថាបត្យកម្មនាក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមក ។ ខ្ញុំបាទមានមោទនភាព និងការដឹងគុណចំពោះការដែលលោកស្រី និងក្រុមរចនាប្លង់របស់លោកស្រី ដែលបានចូលរួមជាមួយក្រុមការងាររបស់ខ្ញុំបាទនៅក្នុងគម្រោងនេះ ។ **ឆាំង យុ**

# សកម្មភាពក្បត់ ផន ចយ ប្រធាន រោងជាងជួសជុលត្រាក់ទ័រ តំបន់៥ ពាយ័ព្យ

*ដកស្រង់ចេញពីឯកសារលេខ៥៤៤ បបគខ*

ផន ចយ អាយុ២៨ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) ភេទប្រុស ជនជាតិខ្មែរ មានគ្រួសារ មានស្រុកកំណើតនៅភូមិកណ្ដាលដើម ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ចយ ជាប្រធានរោងជាងជួសជុលត្រាក់ទ័រ តំបន់៥ ភូមិភាគពាយ័ព្យ ។ តាំងពីតូច ចយ រស់នៅជាមួយឪពុកម្ដាយនៅស្រុកកំណើត ដោយរកស៊ីធ្វើស្រែ និងឡើងត្នោត ។ រហូតដល់ឆ្នាំ១៩៦៣ ឪពុកម្ដាយបាននាំ ចយ និងបងប្អូនទៅនៅភូមិទួលតាចុន ឃុំជ្រៃ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ដោយរកស៊ីជួលដីគេធ្វើស្រែ ។



បូជនីយដ្ឋាន តម្កល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម នៅខេត្តបន្ទាយមានជ័យ

នៅខែមេសា ឆ្នាំ១៩៧០ ចយ បានសុំអង្គការតំបន់៤ ចូលធ្វើយោធានៅក្នុងអង្គភាពលេខ ១០៩ តំបន់៤ ។ ពីរខែក្រោយមក បងស៊ុយ និង បងស៊ូ (គណៈតំបន់៤) បានបញ្ចូល ចយ ជាសម្ព័ន្ធយុវកក ។ បន្ទាប់មកបង ស៊ុយ បានចាត់តាំង ចយ ឲ្យធ្វើជាអនុក្រុមក្នុងកងលេខ១០៩ តំបន់៤ ។

នៅចុងខែមិថុនា ឆ្នាំ១៩៧០ អង្គការបានប្រគល់កងលេខ ១០៩ ទៅឲ្យតំបន់៥ គ្រប់គ្រងវិញ ដោយកាលនោះមានឈ្មោះ នៅ ជាអ្នកក្ដាប់រួម ។ ពេលនោះដោយមានការខ្វះខាតក្នុងអង្គភាព នៅ បានអប់រំ ចយ ជាបន្តបន្ទាប់ឲ្យឃើញពីការធ្វើបដិវត្តន៍មានការលំបាក ។ ដោយពិនិត្យឃើញ ស្ថានភាព ជាក់ស្ដែង ចយ បានយល់ស្របតាមការលើកឡើងរបស់ នៅ ។

នៅចុងខែកញ្ញា ឆ្នាំដដែល នៅ បានខទ្ទេសនាម ចយ ឲ្យចូលធ្វើជា សេ.អ៊ី.អា ដោយមានឈ្មោះ ហ៊ីង គណៈតំបន់៥ ជាអ្នកទទួលស្គាល់ និងមានអ្នកចូលមួយចំនួនទៀត ដូចមានរៀបរាប់ខាងក្រោម ៖

១) រស់ នាទីមេក្រុម នៅកងអនុសេនាធំ១០៩ តំបន់៥ (បច្ចុប្បន្ន ទទួលខុសត្រូវរោងជាងជួសជុលត្រាក់ទ័រ ភូមិភាគពាយ័ព្យ នៅភូមិអូរស្នួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី តំបន់៣) ។

២) ឈឿង នាទីមេពួក នៅកងអនុសេនាធំ១០៩ តំបន់៥ (បច្ចុប្បន្ន ជាប្រធានវរសេនាធំ៣១៧ តំបន់៣) ។

៣) ឡូត នាទីនីរសារតំបន់៥ (បច្ចុប្បន្ន សមាជិកស្រុកភ្នំស្រុក តំបន់៥) ។

៤) ធឿម នាទីប្រធានកងតូច កងអនុសេនាធំ១០៩ តំបន់៥ (បច្ចុប្បន្ន សមាជិកស្រុកថ្មពួក តំបន់៥) ។

៥) ប៉ូច នាទីជាមេក្រុម កងអនុសេនាធំ១០៩ តំបន់៥ (បច្ចុប្បន្នទទួលខុសត្រូវរោងជាងជួស ជុលឡាន នៅស្រុកមង្គលបូរី តំបន់៣ ភូមិភាគពាយ័ព្យ) ។

៦) យ៉ូន នាទីមេពួក កងអនុសេនាធំ១០៩ (បច្ចុប្បន្ន នៅកងកាំភ្លើងធំ កងពលទី២ នៅបន្ទាយចម្ការគ ។

៧) ភី មេក្រុម នៅកងអនុសេនាធំ១០២ តំបន់៥ (បច្ចុប្បន្នប្រធានវរសេនាតូច៣១៥ តំបន់៥) ។

៨) ទុយ នាទីមេពួក នៅកងអនុសេនាធំ១០៩ តំបន់៥ (បច្ចុប្បន្ន ប្រធានវរសេនាតូច៤២៥ តំបន់៥) និងឈ្មោះ ធន

ប្រធានអនុសេនាធំ១០៩ តំបន់៥ (បច្ចុប្បន្ន ប្រធានចម្ការកប្បាស នៅតាក្រាម ស្រុកភ្នំសំពៅ តំបន់៣) បានចូលរួមជាភ្ញៀវ ។

នៅឆ្នាំ១៩៧២ អង្គភាព១០៩ ត្រូវបានចាត់តាំងឲ្យឡើងទៅត្រៀមនៅឃុំថ្មី ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ពេលនោះ នៅ បានដាក់ផែនការឲ្យ ចយ, រស់, ប៉ូច បំផុសយុវជនក្នុងកង១០៩ ឲ្យរត់ចូលបន្ទាយខ្មាំង នៅកំពង់ថ្កូវ ស្រុកក្រឡាញ់ អស់ចំនួន៥នាក់ រួមមានឈ្មោះ ៖ ១) ឡួយ យុវជនអនុសេនាធំ១០៥ តំបន់៥ (ក្រោយមកស្លាប់) ។ ២) លី យុវជន អនុសេនាធំ១០៥ តំបន់៥ (ឆ្នាំ១៩៧៣ បានត្រឡប់មកនៅជាមួយអង្គការវិញ ហើយចូលធ្វើនីរសារតំបន់៥) ។ ៣) ឡេក យុវជន អនុសេនាធំ១០៥ តំបន់៥ (នៅឆ្នាំ១៩៧៣ បានត្រឡប់មកនៅជាមួយអង្គការវិញ ហើយចូលធ្វើនីរសារតំបន់៥ ។ ៤) មៅ យុវជនអនុសេនាធំ១០៥ តំបន់៥ ។ ៥) ត្រុំ យុវជន អនុសេនាធំ១០៥ តំបន់៥ ។

ចុងឆ្នាំ១៩៧២ អង្គភាព១០៩ តំបន់៥ បានមកបោះទីតាំងនៅរលំស្វាយ ឃុំដង្កៀសដៃ ស្រុកក្រឡាញ់ ពេលនោះ នៅ បានណែនាំ ចយ, រស់ និង ប៉ូច ឲ្យទាក់ទងទាហានស័ក្តិ២ ឈ្មោះ ដាន់ នៅបន្ទាយប្រាសាទ៥ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ដើម្បីឲ្យធ្វើសកម្មភាពវាយបកមកលើកងទ័ពបដិវត្តន៍ ។ ចយ រួមជាមួយ រស់ និង ប៉ូច ឡើងទៅទាក់ទងប្រជាជនភូមិពង្រ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ដើម្បីនាំទៅជួបឈ្មោះ លី ធ្វើជាជីទប់ (បច្ចុប្បន្នជាប្រធានចម្ការបន្លែតំបន់៥) ។

រយៈពេលខ្លះខែក្រោយមក ចយ, រស់ និង ប៉ូច បាននាំគ្នាទៅផ្ទះ លី ដើម្បីហៅមកជួបគ្នានៅក្រោមដើមពោធិ៍ ខាងត្បូងផ្ទះ ដើម្បីសម្រេចរៀបចំទាក់ទងគ្នាតាមរយៈតេអូ ដោយកំណត់យកលេខ៦២-១៧ ដើម្បីធ្វើសកម្មភាពវាយមកលើកងទ័ពបដិវត្តន៍ ។ ប្រជុំចប់ ចយ, រស់ និង ប៉ូច បានត្រឡប់មករាយការណ៍ប្រាប់ នៅ ។ បន្ទាប់មក នៅ បានបែងចែកកងអនុសេនាធំ១០៩ ឲ្យទៅឈរជើងនៅភូមិទន្សាយពង, ភូមិគោកឃិន និង ភូមិអន្លង់ ឃុំថ្មី ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ រំលងបានបីថ្ងៃ នៅ បាននិយាយតាមតេអូជាមួយស័ក្តិ២ ដាន់ នៅបន្ទាយប្រសាទ៥ ឲ្យហៅយន្តហោះមកទម្លាក់គ្រាប់បែក និងបាញ់រះមកលើកងទ័ពបដិវត្តន៍ដែលកំពុងសម្រាកនៅភូមិទន្សាយពង ស្លាប់អស់៥នាក់ និងរបួសមួយចំនួន ។

នៅឆ្នាំ១៩៧៣ កងទ័ពអនុសេនាធំ១០៩ របស់តំបន់៥ មកបោះទីតាំងនៅក្នុងព្រៃខាងកើតភូមិតាម៉េង ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ពេលនេះ នៅ បានហៅ ចយ, ប៉ូច និង រស់ មកណែនាំ និងដាក់ផែនការឲ្យទៅទំនាក់ទំនងស័ក្តិ៤ ឈ្មោះ សន់ គូ ចៅហ្វាយស្រុកភ្នំស្រុក តាមរយៈឈ្មោះ ហ៊ាន ប្រជាជននៅភូមិរោង, ឃុំស្ពានស្រែង ត្រូវជាឪពុកមារបស់ស័ក្តិ៤ សន់ គូ ។ អ្នកទាំងបីបានធ្វើការអប់រំ ហ៊ាន ឲ្យឃើញច្បាស់ពីបញ្ហារបស់ខ្លួននៅក្នុងបដិវត្តន៍ និងត្រូវកម្ទេចចលនាបដិវត្តន៍ចោល ពេលនោះ ហ៊ាន ក៏បានឯកភាព (ឆ្នាំ១៩៧៣ដដែល ហ៊ាន បានស្លាប់ដោយសារគ្រាប់បាញ់ពីយន្តហោះ) ។

កន្លះខែក្រោយមក នៅ បានទាក់ទង សន់ គូ តាមតេអូឲ្យហៅយន្តហោះបេ-៥២ មកទម្លាក់នៅក្នុងព្រៃខាងកើតភូមិតាម៉េង ស្លាប់អ្នកធ្វើការនៅក្នុងក្រុមសេដ្ឋកិច្ច កងអនុសេនាធំ១០៩ អស់ចំនួន១០នាក់ និងរបួស៣នាក់ ។

ពាក់កណ្តាលឆ្នាំ១៩៧៣ នៅ បានចាត់តាំង ចយ ឲ្យធ្វើជាអនុកងតូច ក្នុងកងអនុសេនាធំ១០៩ តំបន់៥ ចំណែក រស់ ត្រូវបានដកឲ្យទៅនៅខាងសិល្បៈតំបន់០៥វិញ (បច្ចុប្បន្ន រស់ ទទួលខុសត្រូវរោងជាងជួសជុលត្រាក់ទ័ររបស់ភូមិភាគពាយ័ព្យ នៅភូមិអូរស្លួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី តំបន់៣ ហើយ ប៉ូច ត្រូវបានដកឲ្យទៅធ្វើជាអនុកងធំ១០៥ តំបន់៥ (បច្ចុប្បន្នប៉ូច ទទួលខុសត្រូវរោងជាងជួសជុលឡាន ស្រុកមង្គលបូរី តំបន់៣ ភូមិភាគពាយ័ព្យ ។ ស្របពេលនោះ ធឿម និង យ៉ូន ត្រូវបានបញ្ជូលមកនៅក្នុងកងតូចជាមួយ ចយ នៅកងអនុសេនាធំ១០៩ វិញ ។

បន្ទាប់មក ចយ បានធ្វើការអប់រំកសាងបានកម្លាំងពីរនាក់នៅក្នុងកង១០៥ ជាមួយ ប៉ូច រួមមានឈ្មោះ ៖ ១) សាញ់ ជាប្រធានកងតូច ក្នុងកង១០៥ តំបន់៥ (បច្ចុប្បន្ន សាញ់ ជាប្រធានកងធំ កងវរសេនាតូច៥១៣ តំបន់៥ ។២) យួម ជាអនុកងតូចក្នុងកង១០៥ តំបន់៥ (បច្ចុប្បន្នយួម ជាអនុប្រធានកងធំ កងវរសេនាតូច៥១៣ តំបន់៥) ។

ដោយសារ ចយ បានបង្ហាញពីពីការខ្វះខាតរបស់បដិវត្តន៍ ទើបអ្នកទាំងពីរនេះដែលមានទំនាស់លើបញ្ហានេះស្រាប់ផង ក៏បាន

យល់ស្របជាមួយការឃោសនារបស់ ចយ ។

នៅឆ្នាំ១៩៧៤ កងអនុសេនា១០៩ របស់ ចយ បានឡើងទៅបោះទីតាំងនៅភូមិផ្កាំ ឃុំផ្កាំ ស្រុកថ្មពួក តំបន់៥ ។ រយៈពេលមួយខែក្រោយមក ឈ្មោះ ហ៊ីង បានហៅកងអនុសេនាធំ១០៩ មកប្រជុំនៅភ្នំផ្កាំ ដែលមានសមាជិកទាំងអស់២១នាក់ រួមមាន ៖ ឈ្មោះ ហ៊ីង គណៈតំបន់៥ ជាប្រធានអង្គប្រជុំ, នៅ, ធន, រស់, ប៉ូច, ឈឿង, សាញ់, ឃួម, ភី, ទុយ, យ៉ូន, ឡូត, ធឿម, សុត សមាជិកកងធំ១០២ តំបន់៥ (បច្ចុប្បន្នសមាជិកស្រុកសេរីសោភណ្ឌ តំបន់៥), រ៉ុត ប្រធានសេដ្ឋកិច្ច តំបន់៥ (បច្ចុប្បន្នអនុលេខាសេដ្ឋកិច្ចតំបន់៥), សន អនុវរសេនាតូច៥១៣ តំបន់៥ (បច្ចុប្បន្ន លេខាស្រុកសេរីសោភណ្ឌ តំបន់៥), មៅ៉ង ប្រធានវរតូច៥១៣ (បច្ចុប្បន្នលេខាស្រុក ព្រះនេត្រព្រះ តំបន់៥), ហាត់ លេខាស្រុកភ្នំស្រុក, ហួត គណៈឃុំស្ពានស្រែង (បច្ចុប្បន្ន លេខាស្រុកថ្មពួក តំបន់៥), អ៊ួន អនុកងធំនៃកងវរសេនាតូច៤១៥ តំបន់៥ (បច្ចុប្បន្ន ប្រធានកងធំ កងកាំភ្លើងក្នុងកងពលទី២ របស់ភូមិភាគពាយ័ព្យ) និង ចយ ។

ក្រោយពីប្រជុំចប់ នៅ បានណែនាំ ចយ, ធឿម និង យ៉ូន ឲ្យទៅទាក់ទងទាហាននៅបន្ទាយភាស ឈ្មោះ ជី ពាក់ស័ក្តិ៣ (បច្ចុប្បន្ននៅប្រទេសថៃ) ដើម្បីភ្ជាប់ខ្សែបំផ្លាញកម្លាំងបដិវត្តន៍ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៤ កងអនុសេនាធំ១០៩ ត្រូវបានបញ្ចូលទៅក្នុងវរៈសេនាតូច៤១៥ តំបន់៥វិញ ។ ចំណែកឈ្មោះ នៅ ឡើងជាប្រធានកងវរសេនាតូច៤១៥ ហើយ ចយ ឡើងនាទីជាប្រធានកងតូច កងពិសេស នៃកងអនុសេនាធំទី១ វរសេនាតូច៤១៥ តំបន់៥ ។

នៅដើមឆ្នាំ១៩៧៥ កងវរសេនាតូច៤១៥ មកបោះទីតាំងនៅភូមិតាដូ ឃុំតាដូ ស្រុកថ្មពួក តំបន់៥ ។ មកដល់ខែកុម្ភៈ ១៩៧៥ ហ៊ីង ក៏បានចាត់តាំង ចយ ជាសមាជិកវរសេនាតូច៣១៥ តំបន់៥ វិញ ចំណែក ភី ឡើងជាប្រធានវរសេនាតូច៣១៥ តំបន់៥ និង ទុយ ជាអនុវរសេនា តូច៣១៥ តំបន់៥ ។

នៅខែមិថុនា ១៩៧៥ ក្រោយរំដោះ បង ហ៊ីង បានចាត់តាំង ចយ ជាប្រធានរោងជាងជួសជុលត្រាក់ទ័រ របស់តំបន់៥ នៅវត្តស្វាយ ។ បន្ទាប់មក បង ហ៊ីង ក៏បានហៅ ចយ មកប្រជុំនៅផ្ទះរបស់គាត់នៅខាងត្បូងផ្សារស្វាយស៊ីសុផុន ដែលសមាជិកសរុបទាំងអស់នៅអង្គប្រជុំចំនួន១២នាក់ ៖

១) រស់ ទទួលខុសត្រូវរោងជាងជួសជុលត្រាក់ទ័ររបស់ភូមិភាគពាយ័ព្យ នៅភូមិអូរស្ងួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី តំបន់៣ ។

២) ប៉ូច ទទួលខុសត្រូវរោងជាងជួសជុលឡានរបស់ភូមិភាគពាយ័ព្យ នៅស្រុកមង្គលបូរី តំបន់៣ ។

៣) លឿម ប្រធានរោងជាងក្រឡឹង ភូមិភាគពាយ័ព្យ នៅស្រុកមង្គលបូរី តំបន់៣ ។

៤) គួន អនុប្រធានរោងជាងជួសជុលឡានរបស់ភូមិភាគពាយ័ព្យ ស្រុកមង្គលបូរី តំបន់៣ ។

៥) សាវ៉ាត ប្រធានពាណិជ្ជកម្ម តំបន់៥ ។

៦) រីម ប្រធានរោងម៉ាស៊ីនកិនស្រូវ តំបន់៥ ។

៧) វ៉ាន់ ប្រធានសន្តិសុខ តំបន់៥ ។

៨) ឡេង ប្រធានចម្ការកប្បាស តំបន់៥ ។

៩) លាំ ប្រធានកសិកម្ម តំបន់៥ ។

១០) វ៉ាល់ ប្រធានកងចល័ត តំបន់៥ ។

១១) ហ៊ីង គណៈតំបន់៥ ជាប្រធានអង្គប្រជុំ ។

១២) ចយ ។

នៅខែសីហា ឆ្នាំ១៩៧៥ បង ហ៊ីង បានចាត់តាំង ចយ ឲ្យទៅចូលរួមជាមួយ ភី ប្រធានវរសេនាតូច៣១៥ តំបន់៥, ទុយ អនុវរសេនាតូច៣១៥ តំបន់៥ និង ឈឿង ប្រធានវរសេនាធំ៣១៧ តំបន់៣ ដើម្បីទៅរកទាក់ទងភ្ជាប់ខ្សែជាមួយ អ៊ិន តាំ នៅតាមព្រំដែនខ្មែរ-ថៃ ដើម្បីបញ្ចេញប្រជាជន ១៧ មេសា ដែលមានសមាសភាពជា ប៉ូលីស ទាហាន ទៅឲ្យ អ៊ិន តាំ សម្រាប់រៀបចំអ្នកទាំងនេះទៅជាកងទ័ព ។

ចយ, ទុយ, ភី និង ឈឿង បាននាំគ្នាចេញទៅភូមិយៀង ឃុំសឹង ស្រុកស៊ីសុផុន ដោយពេលនោះបានជួបប្រជាជនខ្មែរម្នាក់ឈ្មោះ វ៉ា ។ ចយ បានសាកសួរ វ៉ា រកកន្លែងរស់នៅរបស់ឈ្មោះ ជី, ផាន់ និង សន់ គូ ហើយ វ៉ា ក៏បានប្រាប់ថា ជី បានមកនៅភូមិថ្មី (ក្នុងដីថៃ) ឯ ផាន់ និង សន់ គូ មិនដឹងនៅកន្លែងណានោះទេ ។ បន្ទាប់មក ចយ, ទុយ, ភី និង ឈឿង ក៏បានផ្តាំ វ៉ា ឲ្យនាំឈ្មោះ ជី មកជួបគ្នានៅ

ភូមិគោកស្វាយខាងកើត ឃុំយៀង ហើយ រ៉ា ក៏បានយល់ស្រប ។ រយៈពេល១០ថ្ងៃក្រោយមក ចយ, ទុយ, ភី និង ឈឿង បានធ្វើដំណើរទៅភូមិគោកស្វាយខាងកើត ឃុំយៀង ក៏បានជួប ជី និងបក្ខពួកពីរនាក់ទៀត គឺឈ្មោះ ស៊ីង អតីតពាក់ស័ក្តិ៣ និង អ៊ីង អតីតពាក់ស័ក្តិ៣ ។ បន្ទាប់ពីជួបគ្នាបានបីថ្ងៃ ចយ, ទុយ, ភី និង ឈឿង បាននាំយកកម្លាំងរបស់ឈ្មោះ ជី ដែលប្រមូលបានចំនួន១១នាក់ នៅភូមិគោកស្វាយ រួមមាន៖ ឈ្មោះ រ៉េន, ត្រុំ, មៅ, ឈិន, លឿ, សំ, ព្រឹត, ខូ, ស្រួច, មៅ និង សំអាត មកបង្កប់នៅតាមមុខព្រួញរបស់ខ្លួន ។

ដើមឆ្នាំ១៩៧៦ កម្លាំងទាំង១១នាក់ ដែលបង្កប់នៅតាមមុខសញ្ញាក៏បានធ្វើសកម្មភាពទាក់ទងអ្នក ១៧ មេសា ដែលអតីតជាប៉ូលីស ទាហានរត់ចេញទៅនៅប្រទេសថៃជាបន្តបន្ទាប់ និងបាននាំកម្លាំងខ្លះ មកវាយឆ្មក់កងទ័ពបដិវត្តន៍ដូចជា នៅបន្ទាយចម្ការគរ និងនៅតាមផ្លូវវាលយន្តហោះ ក្នុងស្រុកថ្មពួក ។

នៅខែមីនា ១៩៧៦ ចយ បានអប់រំកម្លាំងបានពីរនាក់ថែមទៀត មានឈ្មោះ ឈឿម និង អឿង ។ បន្ទាប់មកទៀត ចយ បានទៅជួបឈ្មោះ វ៉ាន់ និង ឡេង និងបានសាកសួរពីការកសាងកម្លាំង ។ វ៉ាន់ បានប្រាប់ថា ខ្លួនកសាងបានឈ្មោះ សាក់ ជាអនុប្រធានរោងជាងជួសជុលត្រាក់ទ័រ តំបន់៥ ចំណែក ឡេង ក៏បានប្រាប់ថា ខ្លួនកសាងបានកម្លាំងម្នាក់ដែរឈ្មោះ ហ៊ាន ជាប្រធានជាងចំណុះអង្គភាពជួសជុល តំបន់៥ ។

នៅចុងខែមីនា ១៩៧៦ ចយ, សារ៉ាត, វ៉ាន់, រឹម និង ឡេង បានពិភាក្សាគ្នានៅមន្ទីរពាណិជ្ជកម្ម តំបន់៥ នៅផ្សារស៊ីសុផុន ដើម្បីរកវិធីបំផ្លាញសម្ភារក្នុងអង្គភាពពាណិជ្ជកម្ម ហើយសកម្មភាពនេះត្រូវបានអនុវត្តជាបន្តបន្ទាប់ ដោយមានឈ្មោះ សារ៉ាត ជាអ្នកដឹកនាំផ្ទាល់ ។ ក្រោយមក ចយ បានហៅ សារ៉ាត, ឡេង, រឹម, វ៉ាន់, ឈឿម, អឿង, ហ៊ាន និង សាក់ មកប្រជុំ គ្នានៅលើកុដិវត្តស្វាយស៊ីសុផុន ក្នុងខ្លឹមសារថា ឲ្យខិតខំធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍នៅតាមមុខសញ្ញារៀងខ្លួន ។

នៅខែកញ្ញា ឆ្នាំ១៩៧៦ បង ហ៊ីង បានហៅខ្មែររយៈទាំងអស់ទៅប្រជុំនៅផ្ទះរបស់គាត់ នៅខាងត្បូងផ្សារស្វាយស៊ីសុផុន ដែលមានសមាជិកសរុបទាំងអស់ ១១នាក់ រួមមាន៖ ហ៊ីង, ឈឿង, ភី, ទុយ, ម៉ៅង ជាលេខាស្រុកព្រះនេត្រព្រះ, សន ជាលេខាស្រុកស្វាយស៊ីសុផុន, ធន ជាអនុតំបន់៥ (បច្ចុប្បន្ននៅចម្ការកប្បាសគាត្រាម តំបន់៣, នៅ ជាបញ្ជាការកងពលទី១ ភូមិភាគពាយ័ព្យ, ហាត់ ជាលេខាស្រុកភ្នំស្រុក, ជី អតីតពាក់ស័ក្តិ៣ នៅបន្ទាយភាស និង ចយ ។ នៅក្នុងខ្លឹមសារនៃអង្គប្រជុំនេះ គឺលើកឡើងពីផែនការនៅខែធ្នូ ឆ្នាំ១៩៧៦ ខាងមុខ ដែលត្រូវវាយយកភាគខាងជើងខេត្តបាត់ដំបង មានស្រុកស៊ីសុផុន, ថ្មពួក, ភ្នំស្រុក, ព្រះនេត្រព្រះ, មង្គលបូរី និងស្រុកបរិលេ ។ ផែនការនេះ ហ៊ីង ចាត់តាំងឲ្យ ចយ យកទៅផ្សព្វផ្សាយឲ្យកម្លាំងនៅខាងក្រោមបានដឹង ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ហ៊ីង បានហៅ ចយ និង សន មកប្រាប់ម្តងទៀតថា ផែនការដែលយើងបានលើកនោះត្រូវផ្អាកសិន ព្រោះអង្គការចាប់កម្លាំងយើងបានហើយ ហើយអង្គការកំពុងស្រាវជ្រាវរកខ្មែររយៈ ។ បន្ទាប់ពី ហ៊ីង ប្រាប់រួចហើយ ចយ និង សន ក៏ត្រឡប់ទៅអង្គភាពវិញ ។

នៅខែឧសភា ឆ្នាំ១៩៧៧ ហ៊ីង បានចាត់តាំង ចយ មកជួយមើលការខុសត្រូវផ្នែកឡានដឹកជញ្ជូន និងផ្នែកត្រាក់ទ័រ នៅអាងទឹកត្រពាំងថ្ម ស្រុកភ្នំស្រុក តំបន់៥ ។ ចំណែក សារ៉ាត ត្រូវ ហ៊ីង ចាត់តាំងឲ្យទទួលខុសត្រូវខាងដឹកស្បៀង ដែក និងស៊ីម៉ង់ត៍ យកមកដាក់នៅអាងទឹកត្រពាំងថ្ម ។ រំលងបានបីថ្ងៃ ឈ្មោះ វ៉ាល់ ជាប្រធានកងចល័តតំបន់៥ ទទួលខាងធ្វើទ្វារទឹកអាងត្រពាំងថ្ម បានហៅ ចយ មកប្រជុំនៅវត្តត្រពាំងថ្ម ដែលមានសមាជិកទាំងអស់ ៥នាក់ រួមមាន៖ ឈ្មោះ វ៉ាល់, សារ៉ាត, ឈឿម និង អឿង ។ ក្នុងខ្លឹមសារប្រជុំនោះ គឺដើម្បីរកវិធីធ្វើឲ្យស្ទះផែនការធ្វើទ្វារទឹករបស់អង្គការ ហើយពេលនោះអង្គប្រជុំបានឯកភាពគ្នាឲ្យ សារ៉ាត ស្តុកប្រេងទុក១០ភាគ ដោយឲ្យបញ្ចេញយកមកប្រើប្រាស់តែពីរភាគប៉ុណ្ណោះ ។

សកម្មភាពនេះ បានធ្វើជាបន្តបន្ទាប់ បណ្តាលឲ្យខ្វះប្រេងចាក់ឡានដឹកជញ្ជូនសម្ភារ ហើយផែនការសង់ទ្វារទឹកនៅអាងទឹកត្រពាំងថ្មរបស់អង្គការក៏មានភាពយឺតយ៉ាវ ។ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួន ចយ, សារ៉ាត, វ៉ាល, ម៉ៅង, សន និង ឡេង តែម្តង ។

**ចៅ ព្រហស្បតិ៍**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthsodavy.u@dccam.org* ។





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង : អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង : ម៉ែន ពិចិត្រ ទូរសព្ទលេខ : ០២៣ ២១៨ ០០៩ អ៊ីម៉ែល : truthmpechet@dccam.org*

# ស្មារតីប្រយុទ្ធរបស់យុវកម្មករដឹកជញ្ជូនជើងទឹក

*ដកស្រង់ចេញពីឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ១-២ ខែមករា-កុម្ភៈ ឆ្នាំ១៩៧៧ D២១៣៩៨*

១៧ មេសា ១៩៧៥ ជាថ្ងៃមហាជ័យជម្នះ ជាប្រវត្តិដ៏មហាអស្ចារ្យរបស់បដិវត្តន៍កម្ពុជា ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ក្នុងការរំដោះប្រទេសជាតិ រំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីការជិះជាន់ ឈ្លានពានយ៉ាងឃោរឃៅហ្វាស៊ីសរបស់ចក្រពត្តិ-បរិវារ វណ្ណៈសក្តិភូមិ នាយទុន និងវណ្ណៈជិះជាន់ផ្សេងទៀត បានទាំងស្រុង និងជាស្ថាពរ បន្ទាប់ពីបានឆ្លងកាត់នូវការតស៊ូបដិវត្តន៍ ដែលពោរពេញទៅដោយការប្រយុទ្ធតឹងរ៉ឹង ស្លាប់រស់លំបាកវេទនាស្មុគស្មាញ បត់បែនអស់រយៈជាច្រើនឆ្នាំកន្លងមក ។ ក្រោយសង្គ្រាមឈ្លានពានដ៏កំណាចឃោរឃៅនេះ ប្រទេសជាតិ មាតុភូមិយើង ប្រជាជនយើង ត្រូវខ្ទេចខ្ទាំហិនហោចខ្ទេចខ្ទាំនៅគ្រប់ទីកន្លែង ។ ផ្ទះសម្បែង ភូមិករ ស្រែចម្ការ ច្បារដំណាំ ត្រូវក្លាយទៅជាផេះផង់ស្ទើរអស់រលីង ។

នៅក្រោមពន្លឺមាគ៌ាដ៏ភ្លឺស្វាង និងត្រឹមត្រូវនៃបក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្មករ កសិករ កងទ័ពបដិវត្តន៍យើង បាន និងកំពុងបន្តប្រពៃណីប្រយុទ្ធ តស៊ូលះបង់គ្រប់បែបយ៉ាងតទៅទៀត ក្នុងមហាចលនាស្តារសេដ្ឋកិច្ច កសាងប្រទេស និងការពារប្រទេសយ៉ាងខ្លាំងក្លា សស្រោកសស្រាំជារៀងរាល់ថ្ងៃ ។ ទន្ទឹមនឹងចលនាវាយសម្រុកបង្កបង្កើនផល នៅតាមគ្រប់សហករណ៍ កម្មករ និងកងទ័ពបដិវត្តន៍យើង ក៏បានវាយសម្រុកជួសជុលរោងចក្រ ជួសជុលផ្លូវគមនាគមន៍ គោក ដែក ទឹក ច្នៃប្រឌិតផលិតសម្ភារ ឧបករណ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនផ្សេងៗ សម្រាប់បម្រើជីវភាពប្រជាជន និងកិច្ចការពារ កសាងប្រទេស ឲ្យបានសម្បូររុងរឿងយ៉ាងឆាប់រហ័ស ។ នៅគ្រប់មុខព្រួញការងាររបស់បងប្អូន តែងតែមានការលំបាកស្មុគស្មាញ ។ តែចំពោះបងប្អូនយើងវិញ ការណាដែលលំបាកស្មុគស្មាញខ្លាំង បងប្អូនក៏កាន់តែប្រយុទ្ធខ្លាំង តស៊ូមានះព្យាយាម ឈ្មុះឈ្មុលប្រឡូកធ្វើការងារនោះ ទាល់តែសម្រេចជោគជ័យជូនបក្ស បដិវត្តន៍ ប្រជាជន និងប្រទេសជាតិជាបន្តបន្ទាប់ ដោយគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនកាន់កាប់វាសនាប្រទេសជាតិ បដិវត្តន៍ខ្លួនយ៉ាងរឹងប៉ឹងបំផុត ។

កម្ពុជាមាតុភូមិជាទីស្នេហារបស់យើង កំពុងបើកទំព័រប្រវត្តិសាស្ត្រថ្មី កំពុងបង្ហាញអត្តភាព និងកិត្យានុភាពរបស់ខ្លួនយ៉ាងខ្ពស់ត្រដែត ដោយស្នាដៃនៃកុលបុត្រ កុលធីតាបដិវត្តន៍កម្ពុជាក៏អង់អាចក្លៀវក្លា ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ។

ខាងក្រោមនេះ ជាកម្រងរឿងមួយ ក្នុងបណ្តារឿងរ៉ាវច្រើនរាប់មិនអស់ ស្តីពីចលនាវាយសម្រុកបំពេញភារកិច្ចរបស់យុវកម្មករបដិវត្តន៍យើង ដែលពីសម័យសង្គមចាស់ យុទ្ធមិត្តយើង សុទ្ធតែកូនចៅប្រជាជនក្រីក្រ មិនដែលស្គាល់ម៉ាស៊ីន ស្គាល់គ្រឿងចក្រយ៉ាងម៉េចផង ។

នៅក្រោយថ្ងៃមហាជ័យជម្នះ ជាប្រវត្តិថ្ងៃ១៧ មេសា ១៩៧៥ អង្គភាពយើងខ្ញុំត្រូវទទួលការចាត់តាំងឲ្យនៅបោះប្រចាំការនៅប៉ែកខាងជើងរដ្ឋធានីភ្នំពេញ ដើម្បីរួមបោសសម្អាតទីក្រុង និងការពារសន្តិសុខក្នុងទីក្រុង ។ ក្នុងរយៈកាលបំពេញភារកិច្ចនេះ អង្គភាពយើងខ្ញុំ ក៏បាននាំគ្នាជម្រះស្មៅ រានដីមួយកន្លែងធ្វើស្រែ និងដាំដំណាំ បន្លែបង្ការ ឧបត្ថម្ភខ្លួន ដោយឯករាជ្យ ម្ចាស់ការ ។

នៅថ្ងៃមួយនោះ យើងនាំគ្នាកាប់ដីយ៉ាងញាប់ដៃ ។ ថ្ងៃរះខ្ពស់ផុតចុងឈើហើយ ។ ញើសជោកអស់ខោអាវ ខ្លួនប្រាណយើងដូចទទឹកភ្លៀង ។ តែបរិយាកាសក្នុងការងារ នៅតែមានសភាពអ៊ូអរ សប្បាយរីករាយ ពោរពេញទៅដោយសំណើច និងការ

ជជែកពីនេះពីនោះ ឆ្លើយឆ្លងគ្នាទៅវិញទៅមក ។ ឯដៃជើងរបស់យើងវិញ ក៏នៅតែមានចលនាជាប់ជានិច្ច ធ្វើឲ្យដីដែលនៅមុខយើងរបើកទាំងផ្ទាំងៗ យ៉ាងរហ័សដែរ ។ មិត្ត សន និយាយថា «នៅសល់តែបន្តិចទៀតទេ យើងវាយផ្តាច់ឲ្យហើយព្រឹកនេះទៅ៍»

មែនហើយ មិត្តយើង ៍ យើងប្រញាប់ដាំល្ងាចនេះផង ។ មិត្តរិត នាំអាទ័សួរទៅមិត្តយើងទាំងអស់គ្នាថា ៈ «មិត្តទាំងអស់ដឹងទេ ដីនេះជាដីខ្មៅ មានដីជាតិល្អ ហេតុអីក៏ពួកអាក្បត់ វាបែរជានាំគ្នាដាំស្មៅ សុកមម៉ុកទៅវិញ? »

ខ្ញុំបានឆ្លើយទៅមិត្តរិត វិញថា «ពួកវាស៊ីស្មៅនេះណាមិត្ត៍ ហើយពួកចក្រពត្តិអាមេរិក ជាអ្នកឃ្វាលវារាល់ថ្ងៃ» ។ ទាំងអស់គ្នាសើចគិលឡើង ។

បន្តិចក្រោយមក មិត្តប្រធានក្រុមយើង ដែលចេញទៅធ្វើការជាមួយអង្គការតាំងពីព្រឹក ក៏ត្រឡប់មកវិញ នៅចំពេលដែលយើងឈប់សម្រាកហើយដែរ ។ មិត្តប្រធាន ក៏ហៅយើងមកជួបជុំគ្នា ។ មិត្តបានលាន់មាត់ថា «ធ្វើការនេះ លឿនមែន៍ តែមួយព្រឹកសោះ ដីដ៏ធំនេះ យើងកាប់ហើយស្រេច៍» មិត្តឈប់មួយសន្ទុះទើបបន្តទៀតថា «ខ្ញុំមានការមួយ ដើម្បីនាំមកជម្រាបសមមិត្តយើងនៅពេលនេះឲ្យហើយដែរ ទម្រាំដល់ពេលយើងហូបបាយ ។ គឺថានៅពេលយើងចប់ការងារនៅទីនេះ អង្គការនឹងផ្លាស់ប្តូរកន្លែងយើង ដើម្បីទៅបំពេញភារកិច្ចថ្មីមួយទៀត ។ ខ្ញុំលើកនេះ ដើម្បីឲ្យសមមិត្តយើង ត្រៀមសតិអារម្មណ៍ជាមុនឲ្យហើយ ។ ភារកិច្ចថ្មីដែលអង្គការនឹងប្រគល់ជូនយើងនៅពេលខាងមុខនេះ ក៏គ្មានអ្វីប្លែក គ្មានអ្វីស្មុគស្មាញ ដែលនាំឲ្យយើងបំពេញមិនបាននោះទេ វានៅតែជាភារកិច្ចបដិវត្តន៍ដ៏ថ្លៃថ្លា ខ្ពង់ខ្ពស់ ដែលបក្សមានជំនឿជឿជាក់លើសមត្ថភាពរបស់សមមិត្តយើងទាំងអស់ ថាប្រាកដជានឹងអាចសម្រេចបានដោយជោគជ័យជូនបក្សបដិវត្តន៍ និងប្រជាជនយើងជាច់ខាត ។ ដូច្នេះ យើងត្រូវខិតខំប្រយុទ្ធ សម្រេចផែនការនៅទីនេះ ឲ្យបានឆាប់រហ័ស ។ ខ្ញុំសូមបញ្ចប់មតិប៉ុណ្ណេះ៍ ។

មិត្តយើងទាំងអស់ ឋិតក្នុងសភាពស្ងាត់ស្ងៀមមែន តែសតិអារម្មណ៍ ទស្សនៈ គោលជំហរនៃយើងទាំងអស់គ្នា ឯកភាពគ្រប់ការ



យោធាខ្មែរក្រហម នៅសមរភូមិមុខ កំពុងវាយឆ្មក់ដើម្បីរំដោះប្រជាជន និងភូមិ ដែលគ្រប់គ្រងដោយកងកម្លាំងរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់

ណែនាំ គ្រប់ការចាត់តាំងរបស់បក្សជានិច្ច ។ យើងនាំគ្នាដើរទៅហូបបាយ ក្នុងបរិយាកាសសប្បាយរីករាយ សាមគ្គីភាព ភាតរភាពបដិវត្តន៍ដូចសព្វមួយដង ។

ជារៀងរាល់ថ្ងៃ យើងសម្រុករៀបចំសម្អាតផ្ទះ សម្អាតផ្លូវតាមក្រុង ហើយពេលខ្លះ យើងនាំគ្នីគ្នាទៅមើលថែទាំ ការពារស្រូវយើង ដែលបែកគុម្ពចេញស្លឹកបៃតងស្រងាត់ ទៅមើលគ្រប់ ស្រែ ដែលកំពុងលូតលាស់ល្អណាស់ ។ យើងខំឆ្លៀតលើករងដាំដំឡូងជ្វាលើដីដែលសល់ទំនេរថែមទៀត ។ យើងរីករាយណាស់ ដោយឃើញដំណាំរបស់យើងដុះលូតលាស់ល្អនៅលើដី ដែលកាលពីសង្គមចាស់ពួកអាក្បត់វាមិនដែលរវីរវល់អើពើ និងកិច្ចការដាំដុះនេះទេ ។ មិត្តរិត ដែលមានកំណើតកើតជាធ្លាប់រស់នៅម្តុំនេះដែរ បានដំណាលប្រាប់យើងខ្ញុំថា ដីនេះ ខ្មាំងវាហួងហែង ហាមឃាត់ពលករ កសិករក្រីក្រយើង មិនឲ្យប្រកបការងារដាំដុះចិញ្ចឹមជីវិតឡើយ ។ តែមកដល់សម័យបដិវត្តន៍ នៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា កន្លែងណាក៏ដោយ កៀនកោះណាក៏ដោយ ក៏មានដំណាំគ្រប់ប្រភេទ ដុះលូតលាស់ទ្រុប់ទ្រុល នៅជនបទក៏ដូចជានៅទីក្រុង តាមវាលក៏ដូចជានៅតាមផ្ទះ តាមរោងចក្រ តាមរោងជាងបដិវត្តន៍នានាដែរ ។

ពីរថ្ងៃក្រោយមក យើងទាំងអស់គ្នា ក៏ចេញដំណើរទៅបំពេញភារកិច្ចថ្មីនៅកន្លែងមួយទៀត ដោយមានស្ពាយស្បោងដាក់ខោអាវមួយម្នាក់ ។ អង្គភាពយើងខ្ញុំ ធ្វើដំណើរសំដៅទៅទិសខាងកើត ដោយទឹកមុខរីករាយ ។ យើងដើរបណ្តើរ មើលទៅចម្ការនិងក្រឡេកទៅស្រែនៅឆ្វេងដៃបណ្តើរ ឃើញស្លឹកស្រូវពណ៌បៃតងស្រងាត់ ចាំងផ្លេកៗ តាមពន្លឺថ្ងៃលិចនៅឆ្ងាយដាច់កន្ទុយភ្នែកយើង ។ ចម្ការ និងស្រែទាំងនេះ យើងបានប្រគល់ជូនទៅពុកម៉ែប្រជាជនសហករណ៍ ដែលរស់នៅជិតនោះដោយទឹកចិត្តរីករាយជ្រះថ្លា ។

នៅពេលព្រលប់ យើងទៅដល់កន្លែងកំណត់ ។ យើងបានជួបយុទ្ធមិត្ត ជាយុវជនក៏មាន ជាយុវនារីក៏មាន ដែលមកពីអង្គភាពផ្សេងៗ ហើយដែលក្នុងចំណោមនោះ មានយុទ្ធមិត្តភាគច្រើន ធ្លាប់បានសហការគ្នា វាយខ្មាំងនៅតាមសមរភូមិធំៗនានា ពិសេស ក្នុងពេលប្រយុទ្ធស៊ុតស្វាញ ស្លាប់រស់នៅក្នុងលេណដ្ឋានជាមួយគ្នានៅសមរភូមិពាយ័ព្យភ្នំពេញ ។ យើងចាប់ដៃគ្នា ឱបរឹតគ្នា សម្តែងនូវការនឹករឭកគ្នាទៅវិញទៅមក យ៉ាងអស់ពីពោះពីពុង ។ រួចហើយ យើងនាំគ្នាទៅសម្រាកក្នុងផ្ទះធំមួយដែលជាការដ្ឋាន ដែលយើងនឹងរួមគ្នាបំពេញភារកិច្ចបដិវត្តន៍ថ្មីនៅទីនេះ ។ នៅក្នុងផ្ទះយើងឃើញតុ កៅអី បះដើងគរប្រចេងប្រចាង ម៉ាស៊ីននៅរាត់រាយបាក់បែកអស់ ។ ឯកូនសោ ឡោស៊ី គ្រឿងបន្ទាស់ផ្សេងៗ នៅរគាត់រគាយលើដី លើតុ លើម៉ាស៊ីន ហ៊ុមព័ទ្ធដោយសំណាញ់សំបុកពីងពាងប្រែងភ្លើង ធំក្លិនស្អុយ ឆ្អេះឆ្អាប ជះក្លិនភាយៗ មកប៉ះច្រមុះយើង ។ នៅកណ្តាលបរិយាកាសយ៉ាងនេះ យើងមិនអង្គុយបុឈរស្ងៀមឡើយ ។ យុទ្ធមិត្តយើងទាំងអស់ ដែលមានសរសៃញាក់គិតគូរការស្អាតបាត និងសណ្តាប់ធ្នាប់ល្អ បានរួមគ្នាមួយដៃមួយជើងម្នាក់បោសសម្អាតកន្លែងនេះ និងរៀបចំទុកដាក់សម្ភារផ្សេងៗដែលនៅរាត់រាយ ឲ្យមានសណ្តាប់ធ្នាប់ទាំងយប់ងងឹតព្រិលៗ ។

បន្ទាប់មក យើងនាំគ្នាមកអង្គុយជួបជុំគ្នា នៅក្រោមពន្លឺចង្កៀងមួយ ។ ពេលនោះ បងអ្នកទទួលខុសត្រូវនៅទីនេះ ដែលមានទឹកមុខញញឹមជាប់ និយាយមកកាន់អង្គប្រជុំ ដោយសំដីទន់ភ្លន់រាបសាថា “តាមមតិណែនាំរបស់អង្គការ សមមិត្តយើងទាំងអស់ដែលមកកាន់ទីនេះ គឺត្រូវទទួលបំពេញភារកិច្ចបដិវត្តន៍ក្នុងផ្នែកមួយដែលអង្គការសម្រេចប្រគល់ជូនសមូហភាពយើង ។ យើងទាំងអស់គ្នា ជាកម្មករបដិវត្តន៍ផ្នែកក្រសួងដឹកជញ្ជូនជើងទឹក ។ ក្រសួងយើង ក៏មានតួនាទីសំខាន់ ក្នុងការរួមចំណែកដឹកជញ្ជូនផលិតផលនានា ដើម្បីកែប្រែជីវភាពប្រជាជនយើង និងរួមចំណែកស្តាសេដ្ឋកិច្ចកសាង និងការពារប្រទេសដែរ ។ ដូចសមមិត្តយើងបានរៀនសូត្រតាមរយៈការអប់រំរបស់បក្ស ជាបន្តបន្ទាប់មកហើយ គឺបក្សយកចិត្តទុកដាក់លើការដឹកជញ្ជូនជើងទឹកខ្លាំងណាស់ ។ ព្រោះការដឹកជញ្ជូនតាមជើងទឹកនេះ យើងចំណាយទុនតិច ហើយដឹកជញ្ជូនបានច្រើន សមស្របទៅតាមលក្ខណៈប្រទេសជាតិយើង ។ ការលើបញ្ហាក់ពីសារសំខាន់របស់វាឡើងវិញនេះ គឺដើម្បីឲ្យសមមិត្តយើងមើលឃើញ ហើយមានមោទកភាពជាតិ មោទកភាពបដិវត្តន៍ចំពោះភារកិច្ចរបស់យើងនេះ ហើយខិតខំវាយសម្រុកសម្រេចភារកិច្ចនេះ ឲ្យបានជោគជ័យជូនបក្សដាច់ខាត ។ យើងខ្ញុំក៏សូមជម្រាបជូនបណ្តាសមមិត្តយើងទាំងអស់ ឲ្យបានជ្រាបផងដែរថាពេលនេះ យើងគ្មានអីជាមូលដ្ឋាន ដើម្បីចាប់ដំណើរការការងារ

យើង ក្រៅពីកម្លាំងនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ដែលបក្សបានបំពាក់បំប៉នឲ្យយើងទេ ។ ដូច្នេះ ឈរលើកម្លាំងនេះ យើងចាប់ផ្ដើមកសាងក្រសួងនេះ ពីបាតដៃទទេ ដូចជំនាន់បងៗ យើង ចាប់ផ្ដើមកសាងកម្លាំងបដិវត្តន៍ វាយខ្មាំងពីបាតដៃទទេដែរ ។ តែទោះបីយ៉ាងណា ក៏វាមិនលំបាកស្មុគស្មាញដូចជំនាន់បងៗ យើងដែរ ព្រោះថ្ងៃនេះ យើងមានរដ្ឋអំណាចនៅដៃស្រាប់ មានសិទ្ធិគ្រប់គ្រាន់ និងចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិជាតិ ទៅតាមផលប្រយោជន៍បដិវត្តន៍ ផលប្រយោជន៍ប្រទេសជាតិ និងប្រជាជនកម្ពុជាហើយ ។ ហេតុនេះ សំណូមពររបស់អង្គការយើង គឺឲ្យយើងប្រយុទ្ធប្រឡូកធ្វើជាក់ស្ដែង រៀនបណ្ដើរ ធ្វើបណ្ដើរ ដោយសុទិដ្ឋិនិយមបដិវត្តន៍ជាប់ជានិច្ច ប្រកាន់ឋានៈជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងបដិវត្តន៍ខ្លួនដោយខ្លួនឯង ។

បន្ទាប់មក បងទទួលខុសត្រូវ ក៏បានចែកការកិច្ចតាមមុខព្រួញផ្សេងៗ ដែលចំបាច់ចំពោះមុខ ប្រគល់ជូនមិត្តយើងគ្រប់ៗគ្នា ។ ចំណែកខ្លួនខ្ញុំ ត្រូវទទួលភារៈខាងដើរប្រមូលកាណូតកប៉ាល់ ដែលលិច និងខូចខាតពេលសង្គ្រាម ។

ថ្ងៃបន្ទាប់មក ខ្ញុំ និងយុទ្ធមិត្តយើងមួយចំនួន បានឡើងជិះកាណូតមួយគ្រឿង បើកតាមដងទន្លេសាបចុះទៅមេគង្គក្រោម ។ ខ្យល់ដំនោរព្រឹកព្រហាមត្រជាក់ណាស់ ។ ទឹកទន្លេហូរបែករលកអន្ទាញ់ៗ ហើយមានសំណល់កម្ទេចកម្ទីអណ្ដែតព្រោងព្រាតពីជើងទៅត្បូងតាមខ្សែទឹក ។ ខ្ញុំនៅអង្គុយជិតមិត្តអ្នកបើកបរកាណូត ។ ពេលខ្ញុំងាកមើលចំមុខមិត្តនោះភ្លាម ស្រាប់តែខ្ញុំភ្ញាក់ព្រើត ។ ខ្ញុំនឹកទៅដល់ពេលកាលយើងវាយខ្មាំង នៅលើសមរភូមិពាយ័ព្យភ្នំពេញ នឹកឃើញកាលគាត់បើកឡានអូសកាំភ្លើងធំធុន១០៥លី ដែលរឹបអូសយកបានពីខ្មាំង ទៅវាយបុកខ្សែត្រៀមខ្មាំងយ៉ាងអង់អាចក្លាហាន ឆ្លងកាត់ក្រោមគ្រាប់បែក និងគ្រាប់ផ្លោងខ្មាំង ដែលបាញ់ស្រោចពីមុខផងពីលើផង ។ មកដល់ពេលនេះទៀតគាត់នៅអង្គុយកាច់ចង្កូតកាណូតយ៉ាងស្ទាត់ជំនាញ និងយ៉ាងស្ងៀមស្ងាត់ទៀត ។

ដោយឃើញខ្ញុំចេះតែលួចសម្លឹងទៅគាត់ពេក គាត់ក៏ងាកមកនិយាយប្រាប់ខ្ញុំថា «កាណូតនេះ យើងទើបជួសជុលម៉ាស៊ីនវាហើយប៉ុន្មានថ្ងៃនេះទេ ហើយយើងប្រើប្រាស់វា ដឹកជញ្ជូនអីវ៉ាន់បានពីរបីជើងមកហើយ ជាមួយកាណូតមួយទៀត ។ ថ្ងៃនេះ យើងប្រើប្រាស់វា ដើម្បីសណ្ដោងកប៉ាល់ កាណូតដែលលិចពេលសង្គ្រាម» ។

ខ្ញុំបានសួរគាត់ថា «មិត្តមកដល់ទីនេះយូរហើយឬ?» ។ គាត់ឆ្លើយមកកាន់ខ្ញុំវិញថា «ទើបមកដល់ប្រមាណជាងមួយអាទិត្យមុននេះប៉ុណ្ណោះ ។ ពេលមកដល់ ទាំងខ្ញុំ ទាំងសមមិត្តយើងដទៃទៀត ដូចម៉ាស៊ីនកាណូតកប៉ាល់នេះ គឺថ្មីសុទ្ធសាធ ថ្វីត្បិតមិត្តយើងខ្លះធ្លាប់បើកឡាន និងចេះជួសជុលម៉ាស៊ីនបន្តិចបន្តួចហើយក៏ដោយ ។ តែដោយសារគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ក្នុងឋានៈជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ យើងក៏ប្ដេជ្ញាប្រយុទ្ធរៀនជួសជុលវា បញ្ជាវា ហើយឆ្លៀតរៀនជួសជុល រៀនបើកបរ នៅពេលជាមួយគ្នានេះតែម្ដងទៅ» ។

កាណូតយើងចេះតែទៅមុខ ជ្រែកកាត់ទឹក បែករលកខ្វាយ លាន់សូរសន្ធឹករលកលប់អស់ស្នូរម៉ាស៊ីន ។ ពេលនោះ យើងក្រឡេកមើលទៅខាងមុខ ឃើញគូកប៉ាល់បីគ្រឿង ចតសន្ធឹងកណ្ដាលទន្លេ ។ មិត្តអ្នកបើកបរ បាននិយាយប្រាប់ខ្ញុំថា «នុះ! ជាកប៉ាល់នៃកងទ័ពជើងទឹកបដិវត្តន៍យើង ។ យុទ្ធជននៃកងទ័ពនេះ ពីដើមក៏ជាយុទ្ធជនកងទ័ពថ្មើរជើងដូចយើងដែរ ហើយដែលថ្មីថ្មោងដូចតែយើងដែរទេ ។ យើងនឹងចូលរួមជាមួយមិត្តយើង ធ្វើការស្ទាក់កប៉ាល់តូចធំដែលលិចនៅទីនេះ» ។ កាណូតយើងក៏បើកទៅជិតនោះ ហើយឈប់ចតក្បែរមាត់ច្រាំងទន្លេ ។ យើងឃើញកប៉ាល់ធំៗបីគ្រឿង បោះយុថ្កា ចតនៅកណ្ដាលទន្លេតែម្ដង ។ កប៉ាល់មួយជាកប៉ាលស្ទូច ឬសាឡង់ស្ទូច ដែលទំពក់ស្ទូចរបស់វា ធ្លាក់សំយុងបាត់ទៅក្នុងទឹករួចស្រេច ។ ចំណែកកប៉ាល់ពីរគ្រឿងទៀត ចតនៅទន្ទឹមគ្នា អមសងខាងដែកស្ទូច ឃ្លាតគ្នាប្រហែលដប់ម៉ែត្រ ។ យុទ្ធមិត្តដែលនៅលើកប៉ាល់ទាំងពីរនេះ កំពុងទាញទុយយោទឹកធំៗ យ៉ាងសកម្មប្រយុទ្ធ ។ ឃើញដូច្នេះ មិត្តអ្នកបើកបរកាណូត ក៏នាំយើងខ្ញុំឡើងទៅលើកប៉ាល់ទាំងពីរនេះ ដើម្បីរួមធ្វើការងារជាមួយយុទ្ធមិត្តខាងកងទ័ពជើងទឹក ។ ខ្ញុំទៅឈរកាន់ទុយយោនៅលើកប៉ាល់ម្ខាង ដើម្បីបូមទឹកបញ្ចូលកប៉ាល់នោះឲ្យលិច ។ មុនដំបូងខ្ញុំឆ្ងល់ដែរ តើមិត្តយើងបូមទឹកបញ្ចូលកប៉ាល់ដែលអណ្ដែតលើទឹកស្រាប់ ឲ្យវាលិចបន្តិចម្ដងៗ យ៉ាងនេះ មានប្រយោជន៍យ៉ាងម៉េចដែរ? ហើយកប៉ាល់ឯណោះ ក៏ដូចគ្នាដែរ ។

ពេលជាមួយគ្នានេះ យើងឃើញសាឡង់ស្ទូច កំពុងស្ទូចកប៉ាល់មួយគ្រឿងចេញពីក្នុងទឹក ។ ព្រមជាមួយគ្នានោះ មានយុទ្ធមិត្តប្រាំនាក់លេចខ្លួនឡើងចេញពីក្នុងទឹក ។ យុទ្ធមិត្តទាំងនោះ បានមុជទៅក្នុងបាតទន្លេ ដើម្បីចុះទៅចងត្លុកកប៉ាល់នោះឲ្យសាឡង់ស្ទូចឡើង ដោយស្មារតីតស៊ូមានះព្យាយាមស្វិតស្វាញបំផុត ។ ការណ៍នេះ ធ្វើឲ្យខ្ញុំកាន់តែមានការគោរពកោតសរសើរ និងរៀនសូត្រជំហរប្រយុទ្ធស្រួចស្រាវពីយុទ្ធមិត្តយើងកាន់តែខ្លាំងឡើង ។ ក្នុងពេលជាមួយគ្នានោះ យើងបានបញ្ចូលទឹកពន្លិចកប៉ាល់ដែលយើងឈរធ្វើការ លិចអស់ពាក់កណ្ដាលត្លួវាហើយ ។ យើងក៏លែងបញ្ចូលទឹកវាត្រឹមនេះ ។ បន្ទាប់មក កប៉ាល់ខ្ញុំ និងកប៉ាល់ម្ខាងទៀត ក៏ខិតចូលគ្នា មកកៀកកប៉ាល់ដែលលិចភ្លាមដែរ ។ ពេលកប៉ាល់ដែលលិច វាឡើងស្មើគ្នានឹងកប៉ាល់ជំនួយហើយ យើងក៏ចាប់ផ្ដើមបូមទឹកបញ្ចេញពីកប៉ាល់ទាំងបីនោះវិញ ។ មិត្តយើងម្នាក់ៗ រវាសរវៃដើងណាស់ គ្មានអែអង់ទេ ហើយប្រុងប្រយ័ត្នបដិវត្តន៍ជាប់ជានិច្ច ។ យើងធ្វើយ៉ាងនេះ គឺដើម្បីជួយគ្រៀកកប៉ាល់ដែលលិច ឲ្យវាឡើងត្រង់តាមទម្ពក់ស្ទូច ។ កប៉ាល់ទាំងបីលេចត្លួឡើងសន្សឹមៗ ហើយអណ្ដែតលើផ្ទៃទឹកព្រមៗគ្នា ។ ឯយុទ្ធមិត្តខាងផ្សារក្នុងទឹក ក៏លោតចុះទៅក្នុងទន្លេ ដោយកាន់ប្រដាប់ផ្សារដែកទៅជាមួយផង ។ ទឹកទន្លេបែកពពុះស្កុលចេញផ្សែងហុយៗ ក្លិនឈ្ងួលច្រមុះ តាមគែមបាតកប៉ាល់ និងពីក្នុងកប៉ាល់ ។ យុទ្ធមិត្តយើងប្រយុទ្ធផ្សារកន្លែងដែលធ្លុះធ្លាយ បានយ៉ាងឆាប់រហ័ស និងយ៉ាងស្ទាត់ជំនាញបំផុត ។

ធាតុអាកាសរងាររមែនា យើងម្នាក់ៗ ដោកអស់ខោអាវខ្លួនប្រាណ ដៃជើង និងសក់ក្បាល ។ ឯកម្លាំងមិត្តយើងម្នាក់ៗ ក៏ហត់ហេវខ្លាំងណាស់ដែរ ។ តែឆន្ទៈប្រយុទ្ធនៅតែរឹងប៉ឹង ស្រួចស្រាវខ្លាំងក្លាជានិច្ច ។ អ្នកមុជទឹក ធ្វើការនៅបាតទន្លេរាប់ម៉ោង មមាញឹកជាប់ ដើម្បីចងកប៉ាល់ និងបោះម៉ាស៊ីនកប៉ាល់ដែលលិចនោះ ។ ចំណែកយើងវិញ ខំកាយទប់ទុយយោ ទោះបីកម្លាំងទឹកធាក់ខ្លាំងយ៉ាងណាក៏ដោយ ក៏យើងឥតដួលដែរ ។ យើងទាំងអស់គ្នា ប្ដេជ្ញាប្រើអស់កម្លាំងកាយ កម្លាំងចិត្ត វាយសម្រុកបំពេញភារកិច្ចនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងបរិយាកាសសាមគ្គីភាព ភាតរបដិវត្តន៍ រវាងសហជីពកម្មករយើង និងកងទ័ពបដិវត្តន៍កម្ពុជាយើង ។ ឡានស្ទូច និងសាឡង់ស្ទូច ដោយមានយុទ្ធមិត្តអ្នកបើកបរបញ្ជាម៉ាស៊ីនដ៏ក្មេងខ្ចី ក៏កំពុងរួមចំណែកស្ទាកប៉ាល់ កាណូត ជួយសម្រាលកម្លាំងយើងបានមួយកម្រិតធំដែរ ។ យើងធ្វើការ រួមរស់នៅហូបចុក ប្រជុំពិភាក្សា និងដកពិសោធការងារ ជាមួយយុទ្ធមិត្តកងទ័ពជើងទឹកបដិវត្តន៍យើងជាប់រាល់ថ្ងៃ ។ យើងរៀនសូត្រពីគ្នាទៅវិញទៅមក ។

ក្នុងរយៈប៉ុន្មានថ្ងៃ ប៉ុន្មានយប់នេះ យើងប្រយុទ្ធស្ទាកប៉ាល់ កាណូត តូចធំ គ្រប់ធុនបានជាច្រើនគ្រឿង ដែលភាគច្រើនសុទ្ធតែខូចខាតទាំងត្លួកប៉ាល់ ទាំងផ្នែកម៉ាស៊ីន ហើយមានកប៉ាល់មួយចំនួន គឺខូចខាតដោយខ្មាំងវាបំផ្លាញ វាញាត់ខ្សាច់គោក្នុងម៉ាស៊ីន ពន្លិចក្នុងទឹកទន្លេចោល មុនពួកវាត្រូវបរាជ័យ ។ បន្ទាប់មក យើងត្រូវសណ្ដោងកប៉ាល់ខូចទាំងនោះ មកជួសជុលកែកុននៅរោងជាង ។ យើងបានដឹងពីខាងដើមរួចមកហើយថា ផ្នែកដឹកជញ្ជូនជើងទឹកយើងនេះ គឺគ្មានអីទេ ។ មធ្យោបាយដឹកជញ្ជូនក៏គ្មាន រោងជាងក៏គ្មាន ។ ដូច្នេះហើយ បានជាបក្សបានណែនាំ និងចាត់តាំងការងារផ្សេងៗឲ្យយើងធ្វើ ដើម្បីជំរុញការកសាងផ្នែកយើងឲ្យដំណើរការទៅបាន ដោយឯករាជ្យម្ចាស់ការតទៅអនាគតទៀត ។ ខ្ញុំ និងមិត្តខ្លះ ក៏នាំគ្នាស្រង់កប៉ាល់ កាណូតដែលខូចខាតលិចក្នុងពេលសង្គ្រាម ។ មិត្តខ្លះទៀត ដើរប្រមូលម៉ាស៊ីន គ្រឿងបន្លាស់ ឈើ និងដែកតាមរោងជាងតូចៗ ។ ទន្ទឹមនេះ មិត្តខ្លះទៀត ក៏ដំណើរការជាបណ្ដើរៗ ជួសជុលកែកុនម៉ាស៊ីនខូចៗ ប៉ះប៉ុន ផ្សារ និងលាបថ្នាំត្លួកប៉ាល់ កាណូតចាស់ៗ ដែលធ្លុះធ្លាយបាក់បែកកន្លងមក ហើយខ្លះដំណើរការបើកបរវាដឹកជញ្ជូនអីវ៉ាន់អីវ៉ាន់ជាបណ្ដើរៗដែរ ។

មួយរយៈក្រោយមក យើងក៏មានរោងជាងជួសជុលកប៉ាល់ កាណូតមួយសមរម្យ ដោយមានម៉ាស៊ីនក្រឡឹងធ្វើគ្រឿងបន្លាស់ ខ្នៅខ្វងផ្សេងៗ មានផ្នែកជួសជុលម៉ាស៊ីន និងដំឡើងម៉ាស៊ីនកប៉ាល់ កាណូត មានផ្នែកអគ្គិសនី រហូតមានផ្នែកស្លដែក ដែលអាចស្លដែកម្ដងបាន២០០គីឡូ ។ ឯសមត្ថភាពបច្ចេកទេសរបស់មិត្តកម្មករយើងទាំងអស់ ក៏មានការរីកចម្រើនមួយកម្រិតដែរ ដែលដំបូងទាំងយើងខ្ញុំ ទាំងមិត្តដទៃទៀត ក៏ដូចបងប្អូនយុទ្ធជន យុទ្ធនារី នៅតាមរោងចក្រ តាមការដ្ឋាន ក្រសួង មន្ទីរបដិវត្តន៍ដទៃទៀតដែរ និយាយរួម យើងទាំងអស់គ្នាសុទ្ធតែមិនដែលស្គាល់ មិនដែលដឹង មិនដែលពាល់គ្រឿងចក្រយ៉ាងម៉េចទេ ។ តែពេលនេះ យើងអាចដំណើរការធ្វើវា ជួសជុលវា បញ្ជាវាដោយឯករាជ្យម្ចាស់ការ បានមួយកម្រិត

ដែលអាចបម្រើសេចក្តីត្រូវការចាំបាច់នៅក្នុងក្រសួងបានជាបន្តបន្ទាប់ សមស្រប និងការទុកចិត្តរបស់បក្សមកលើយើងទាំងអស់គ្នា ។

បន្ទាប់ពីចប់ការងារស្តាកប៉ាល់ កាណូតដែលលិចហើយ ខ្ញុំត្រូវទទួលការចាត់តាំងចូលទៅខាងផ្នែកជួសជុលកែកុនម៉ាស៊ីន ។ ទទួលការចាត់តាំងនេះភ្លាម ខ្ញុំក៏បានទៅចូលរួមរើម៉ាស៊ីនកប៉ាល់មួយជាមួយយុទ្ធមិត្តពីរបីនាក់ទៀត ដែលមានមិត្តខ្លះ ធ្លាប់ចេះជួសជុលម៉ាស៊ីនតាំងពីសម័យសង្គ្រាមដែរ ។ តែពេលនេះ គឺយើងទាំងអស់គ្នាធ្វើដោយរាវៗ ដោយកត់ចំណាំក្នុងខួរក្បាលរៀងៗខ្លួន ហើយចំណាំកន្លែងពេលមូលខ្ចៅចេញ ។ មិត្តលក ដែលមានបច្ចេកទេសចេះជួសជុលឡានខ្លះមកហើយ បានបង្ហាញឲ្យយើងឃើញនូវប្រព័ន្ធទាំងឡាយ ដែលទាក់ទងក្នុងម៉ាស៊ីននេះ ។ មកដល់កន្លែងមួយ មិត្តក៏លាន់មាត់ថា "យី យ៉ាងម៉េចអីចេះ?" តែទឹកមុខមិត្តនៅតែរីករាយ ដោយនិយាយមកកាន់យើងថា "ស្នើមិត្តជួយចាំខ្ញុំផង! ពេលនេះ យើងសាកល្បងដោះអានេះ ហើយលាងវា រៀបចំវាឡើងវិញ" ។

យើងទាំងអស់គ្នាឈ្មុសឈ្មុលរើ ហើយរៀបចំប្រព័ន្ធម៉ាស៊ីននេះ ដោយយកចិត្តទុកដាក់ ។ មុខមាត់ និងដៃជើងរបស់យើងប្រឡាក់ប្រេងម៉ាស៊ីនស្រម៉កៗ ។ យើងធ្វើការងារនេះ រហូតដល់ម៉ោងពីរអាធ្រាត្រទើបសម្រាក ។ ព្រលឹមឡើង យើងមកធ្វើទៀត ។ ងាកទៅយុទ្ធមិត្តឯទៀតដែលនៅឈរ ឬអង្គុយជួលជុលម៉ាស៊ីនដូចយើងក៏កំពុងផ្តោតអារម្មណ៍ជាប់ដៃជាប់ភ្នែកនឹងការងារនេះដែរ ។ ពេលថ្ងៃត្រង់ក្រោយហូបបាយរួច យើងមកប្រជុំគ្នាពិនិត្យពាក់ព័ន្ធលើគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់ខ្លួនយើងម្នាក់ៗ និងពិនិត្យរួមលើផ្នែកសមូហភាព ព្រមទាំងដកពិសោធលើការងារបច្ចេកទេស ហេតុអីបានជាវាគាំង វាឃឹត? ។ ថ្ងៃនេះយើងធ្វើមិនចេញ ថ្ងៃស្អែក យើងនៅតែធ្វើមិនចេញទៀត រហូតខានស្អែកក៏យើងនៅតែមិនទាន់ឃើញច្រកចេញទៀត ។ ថ្ងៃបន្ទាប់មក ដោយសារការព្យាយាម តស៊ូ មានះស្វិតស្វាញ ឈ្មុសឈ្មុល ច្នៃប្រឌិត ធ្វើបណ្តើរ ដកពិសោធជាសមូហភាពបណ្តើរ សាចុះសាឡើង យើងក៏រកឃើញគន្លឹះវា ហើយដំណើរការជួសជុល កែកុនម៉ាស៊ីននេះឲ្យឆេះឡើងវិញ បានជាបន្តបន្ទាប់ ។ យើងទាំងអស់គ្នារីករាយណាស់ ហើយសន្មតថា វាជាជ័យជម្នះមួយ ហើយយើងប្តេជ្ញាថា យកពិសោធដែលយើងដកស្រង់បានក្នុងការងារយើងកន្លងមកមករៀនសូត្រ និងកែលម្អ ដើម្បីជំរុញការងារតទៅមុខទៀតឲ្យបានលឿន និងឲ្យធានាគុណភាពម៉ាស៊ីនថែមទៀតផង ។

នៅថ្ងៃមួយ យើងខ្ញុំត្រូវទទួលភារកិច្ចជួសជុលម៉ាស៊ីនកប៉ាល់ធំមួយ ។ នេះជាលើកដំបូងហើយ តាំងពីយើងខ្ញុំចូលមកបំពេញភារកិច្ចក្នុងរោងជាងជួសជុលម៉ាស៊ីនកាណូតនេះ ។ ពេលនោះយើងខ្ញុំ មានសតិអារម្មណ៍គិតគូរច្រើន ដោយខ្លាចក្រែងធ្វើទៅរឹតតែខូចខាត បាក់បែកម៉ាស៊ីននេះកាន់តែខ្លាំងថែមទៀត រហូតទៅជាខូចអសាបង់កែលែងកើត នាំឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរួមរបស់បក្ស ព្រោះយើងក្រ មានកប៉ាល់ធំតែមួយ ពីរគ្រឿងប៉ុណ្ណោះ ។

បក្សធ្លាប់បានណែនាំយើងទាំងអស់គ្នាថា "ភារកិច្ចទាំងអស់ដែលបក្សប្រគល់ជូនសមមិត្តយើង គឺសុទ្ធតែជាភារកិច្ចធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសឲ្យបានល្អចម្រើនលោតផ្លោះឆាប់រហ័ស ។ ហេតុនេះ គឺជាភារកិច្ចថ្លៃថ្នូរឧត្តុង្គឧត្តម ជាភារកិច្ចចាំបាច់របស់យើងជាវណ្ណៈកម្មករ កសិករកម្ពុជានិងជាជនបដិវត្តន៍ ជនកុម្មុយនីស្ត ដែលដាច់ខាតត្រូវតែជ្រះថ្លាប្រយុទ្ធឈ្មុសឈ្មុល ស្រាវជ្រាវ ច្នៃប្រឌិតបំពេញភារកិច្ចនេះជូនបក្សបដិវត្តន៍ និងប្រទេសជាតិឲ្យបានដាច់ខាត ។ បដិវត្តន៍កម្ពុជាយើងគឺយើងទាំងអស់គ្នា ជាកម្មករ កសិករ ជាយុទ្ធជន យុទ្ធនារី កម្មាភិបាលបដិវត្តន៍ ជាអ្នកធ្វើទើបធានាអនាគតដ៏ក្រហមឆ្អិនឆ្អៅ ជារៀងរហូត ។ បើបណ្តោយឲ្យស្រទាប់វណ្ណៈដែលមិនបដិវត្តន៍ ឲ្យបរទេសជាអ្នកធ្វើជំនួសយើង គឺយើងរណបគេហើយ ។ បដិវត្តន៍យើងប្រែពណ៌សម្បុរហើយ ។ ប្រទេសជាតិ មាតុភូមិយើង នឹងក្លាយទៅជាខ្ញុំគេដូចមុនទៀតហើយ" ។ មកដល់ត្រង់នេះ ពាក់ព័ន្ធដល់ផ្នែកការងារយើង យើងក៏ឃើញជាក់ស្តែងដូច្នេះដែរ ។ ម៉ាស៊ីនក្តី តួកប៉ាល់ក្តីដែលខូចខាតនោះ បើយើងមិនឈ្មុសឈ្មុល ច្នៃប្រឌិតជួសជុលវាដោយដៃយើងទេ វានឹងខូចចោលអសារឥតការ តែបើយើងប្រយុទ្ធជួសជុលវា វាអាចកើត ។ ប៉ុន្តែប្រសិនបើយើងប្រឹងប្រែងអស់កម្លាំងកាយ កម្លាំងចិត្ត ដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយវានៅតែកែមិនកើតទៀត យ៉ាងហោចណាស់ ក៏យើងអាចដកពិសោធសម្រាប់អនាគតទៀតបានដែរ ។

នឹកទៅដល់ការណែនាំនេះរបស់បក្ស ធ្វើឲ្យយើងខ្ញុំរំជួលចិត្ត

យ៉ាងខ្លាំង ។ យើងទាំងអស់គ្នា ឯកភាពគ្នាថា ត្រូវតែប្តេជ្ញាប្រឡូកជួសជុលម៉ាស៊ីនកប៉ាល់ធំនេះឲ្យបាន ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ចំពោះបក្ស ប្រជាជន និងប្រទេសជាតិយើង ។ មុនដំបូងនេះ យើងជួបប្រទះការស្មុគស្មាញជាច្រើនអនេ្ធ លើសពេលណាទាំងអស់ ។ តែយើងឥតភ្ញាក់ផ្អើល ស្មុគស្មាញអ្វីឡើយ ។ ជារៀងរាល់ថ្ងៃ រាល់យប់ ពេលណាក៏ដោយ ខួរក្បាល និងដៃជើងយើង តែងតែគិតគូរជាប់នឹងម៉ាស៊ីនជានិច្ច ។ ពេលនេះហើយ ដែលការតស៊ូវណ្ណៈក្នុងការប្រជុំពាក់ព័ន្ធ ដកពិសោធ លើការងារនយោបាយ សតិអារម្មណ៍របស់មិត្តយើងម្នាក់ៗ មានលក្ខណៈកាន់តែក្តៅ កាន់តែស៊ីជម្រៅ សមស្របនឹងសំណូមពរការងារចំពោះមុខនេះ ។ ប៉ុន្មានថ្ងៃនេះ យើងនៅមិនទាន់រកគន្លឹះ ដើម្បីជួសជុលម៉ាស៊ីននេះ កើតវិញឡើយ ម៉ាស៊ីនដែលប្រើមិនកើតពេលមុនប៉ុន្មាន គឺវានៅតែប្រើមិនកើតដដែល ។ តែយើងនៅតែមិនអស់សង្ឃឹមឡើយ យើងនៅតែមានសុទិដ្ឋិនិយមបដិវត្តន៍ជាប់ជានិច្ច ថាយើងនឹងអាចកែ ជួសជុលវាបានមិនខានឡើយ ។ មិត្តលក នៅតែមានទឹកមុខរីករាយជានិច្ចទោះបីប៉ុន្មានថ្ងៃនេះ គាត់សម្រាកមិនសូវលក់ ដោយគិតគូរច្រើនក៏ដោយ ។ យប់មួយ ក្រោយពេលប្រជុំដកពិសោធរួច ខ្ញុំឃើញគាត់អង្គុយម្នាក់ឯង ភ្នែកសម្លឹងទៅក្រដាស់មួយសន្លឹក ដែលគាត់លាតសន្ធឹងនៅលើតុ ដៃកាន់ខ្មៅដៃគូសវាសលើក្រដាសនេះ ដោយយកចិត្តទុកដាក់ជាទីបំផុត ។ ខ្ញុំសង្កេតឃើញគាត់ប្រែផ្លាស់ទឹកមុខស្ងួតញញឹមៗ តែម្នាក់ឯង រួចគាត់ដើរទៅរកគ្រែមិត្តយើងដទៃទៀត ។ ពេលនោះមិត្តយើងដែលហត់ហេវពីថ្ងៃខ្លាំងពេក ក៏សម្រាកលង់លក់អស់ហើយដែរ ។ គាត់ក៏ដើរមកវកតុវិញ ។ ដោយកាត់យល់បំណងរបស់គាត់ខ្លះៗ ខ្ញុំក៏ដើរទៅរកគាត់ ។ មិត្តលក បានកេះឲ្យខ្ញុំមើលគំនូរដែលគាត់បានគូរពីប្រព័ន្ធម៉ាស៊ីនកប៉ាល់ ហើយគាត់និយាយខ្សឹបៗ បង្ហាញខ្ញុំអំពីប្រព័ន្ធនីមួយៗ ។ ខ្ញុំសួរគាត់ថា «មិត្តយល់យ៉ាងណាដែរ?» ។ ក្រោយពីបានមើលគំនូរនេះដោយយកចិត្តទុកដាក់ និងដោយទទួលការពន្យល់បញ្ជាក់ខ្លះពីមិត្តលក មកខ្ញុំហាក់ដូចជាឃើញពន្លឺ នៃសេចក្តីសង្ឃឹមថ្មីខ្លះៗថែមទៀត លើការសម្រេចភារកិច្ចជួសជុលម៉ាស៊ីនកប៉ាល់ដែលយើងកំពុងធ្វើ ព្រោះវាជាគំនូរវិទ្យាសាស្ត្រមួយ ដែលសមូហភាពក៏បានផ្តល់មតិពីព្រលប់ដែរ ។ ខ្ញុំងក់ក្បាល ។ មិត្តលក ក៏បត់ក្រដាសគំនូរនេះ ទុកស្រួលបួលវិញ ។ រួចយើងក៏នាំគ្នាទៅកាន់កន្លែងសម្រាករៀងៗខ្លួន ។ តែយប់នេះ ខ្ញុំរសាប់រសល់ សម្រាកមិនលក់សោះ ។ ផ្ទាំងគំនូរម៉ាស៊ីនកប៉ាល់ ស្ថិតនៅក្នុងខួរក្បាលខ្ញុំជានិច្ច ។ ខ្ញុំក៏ក្រោកទៅអង្គុយនៅខាងក្រៅសម្លឹងមើលទឹកទន្លេសាបដែលហូរខ្លួលខ្លាញ់ឥតចេះហត់ នាំរលកមកបោកប៉ះកប៉ាល់យើងឮសូរណ្តើរក្នុងត្រចៀកខ្ញុំជាប់មិនដាច់ ។ ពេលខ្ញុំកំពុងស្ងងគំនិត ស្រាប់តែដៃមួយមកចាប់ស្មារបស់ខ្ញុំ ។ មិត្តលក មកអង្គុយក្បែរខ្ញុំ គាត់និយាយថា «មិត្តកំពុងគិតរឿងអីឲ្យហ្នឹង? ខ្ញុំស្នើមិត្ត កុំគិតគូរវាអី ! ហើយសម្រាកទៅ ដើម្បីយើងយកកម្លាំងបន្តការងារស្អែកទៀតណាមិត្ត!» ។ ខ្ញុំឆ្លើយតបទៅមិត្តលក វិញថា «ខ្ញុំឥតគិតគូរអីទេ! តែដូចមិត្តឃើញស្រាប់ហើយការងារយើងយឺតណាស់ បើមិនចេះឆក់ឱកាសខ្លះ ដើម្បីត្រៀមគិតគូរឲ្យហើយទេនោះ យើងរឹតតែយឺតថែមទៀត» ។ ឮខ្ញុំនិយាយដូច្នេះ មិត្តលកដកដង្ហើមយ៉ាងវែង ហាក់ដូចសម្តែងការគាំទ្រតឹងលើចំណុចអ្វីមួយ ។ តែគាត់បែរជានាំខ្ញុំនិយាយពីរឿងផ្សេងៗទៅវិញ ។ គាត់និយាយថា «មិត្តដឹងទេ? ប៉ុន្មានថ្ងៃមុននេះ មិត្តសន បានបើកកប៉ាល់ដឹកជញ្ជូនអីវ៉ាន់ឡើងទៅស្ទឹងត្រែង ហើយគាត់ត្រឡប់មកវិញ ដោយសុខសប្បាយ ឥតមានគ្រោះថ្នាក់អ្វីឡើយ» ។ ឮមិត្តលក និយាយដូច្នេះ ខ្ញុំក៏មានអារម្មណ៍នឹកស្ញើចក្នុងចិត្តដល់យុទ្ធមិត្តយើង ដែលបើកបរកប៉ាល់ឡើងរហូតដល់ស្ទឹងត្រែង ដែលកាលពីសង្គមចាស់ ខ្លាំងវាមិនហ៊ានឡើងទៅដល់ទេក្នុងរដូវប្រាំងយ៉ាងនេះ ព្រោះគ្រោះថ្នាក់ណាស់ ។ ខ្ញុំនិយាយតិចៗថា «មិត្តសន ពីដើម ជាកុមារម្នាក់ដែលកំព្រាម៉ែឪ អត់បងប្អូន មាមីងនឹងគេទេ ។ ក្នុងជីវិតរបស់មិត្ត គឺមិត្តរស់តែស៊ីឈ្នួលរានចម្ការឲ្យគេ ខួបប្រាំងខួបវស្សា រស់នៅលំបាកវេទនា ងងឹតអួអាប់មួយចប់ ខ្លួនប្រាណឈឺស្គមស្លេកស្លាំង ដំបៅរមាស់ពីកពកពេញខ្លួន សល់តែស្បែកដណ្តប់ឆ្អឹង ស៊ើរស្លាប់ស៊ើររស់ ។ មិត្តដើរស៊ីឈ្នួលគេ ឆ្លងពីស្រុកមួយទៅស្រុកមួយទៀត គ្មានកន្លែងពិតប្រាកដទេ ។ តែមកដល់សម័យបដិវត្តន៍យើងនេះ មិត្តប្រែប្រួលក្រឡាប់ចាក់តែម្តង មិត្តក្លាយខ្លួនទៅជាកម្មករបើកកប៉ាល់ដ៏អង់អាចឡើងទៅដល់ស្ទឹងត្រែង ដែលត្រូវឆ្លងកាត់ផ្លូវថ្មប្រកបដោយគ្រោះថ្នាក់ជាច្រើន ។ មិត្តមានគំរូអង់អាចមោះមុត មានធាតុលះបង់ខ្លាំងណាស់ ប្រយុទ្ធស្រួចស្រាវបំផុត សម្រេចភារកិច្ចជូនអង្គការបានដោយជោគជ័យ

ធ្វើឲ្យយើងខ្ញុំរៀនសូត្រពីមិត្ត និងយុទ្ធមិត្តយើងដទៃទៀតបាន ច្រើន ។ យើងប្តេជ្ញាសម្រេចភារកិច្ចជួសជុលម៉ាស៊ីនកប៉ាល់ធំនេះ ឲ្យបានដាច់ខាត» ។ មិត្តលក ក៏និយាយថា «មែនហើយមិត្ត! អ្វី ដែលខ្លាំងធ្វើមិនកើត យើងអាចធ្វើកើតទាំងអស់ ។ ឧទាហរណ៍តួ យ៉ាងដូចជា ផ្នែកបើកបរដឹកជញ្ជូនជើងទឹកនេះ សព្វថ្ងៃ យុទ្ធមិត្តយើង ក្តាប់បានស្គាល់ទឹក ម្ចាស់ការបានក្នុងការបើកបរ ទាំងក្នុងមេគង្គ ទាំង ក្នុងទន្លេសាប យើងទៅរហូតដល់ស្ទឹងត្រែងទៀត ដោយឥតមានជួប គ្រោះថ្នាក់អ្វីទាំងអស់ ទៅទាំងរដូវប្រាំង ទៅទាំងរដូវវស្សា ។ ចំណែក ផ្នែកផ្សេងៗទៀត ក្រៅក្របខណ្ឌក្រសួងដឹកជញ្ជូនជើងទឹកយើង យុវកម្មករបដិវត្តន៍ដ៏ក្មេងខ្ចីមាននៅគ្រប់រោងចក្រ រោងក្រឡឹង ការ ដ្ឋាន ផ្នែករទេះភ្លើងជាដើម ក៏កំពុងបញ្ចេញថ្វីដៃ ច្នៃប្រឌិតយ៉ាងរស់ រវើកប្លែកៗ សម្រុកបំពេញភារកិច្ចរបស់ខ្លួន យ៉ាងខ្លាំងក្លាណាស់ដែរ ដើម្បីផ្សារភ្ជាប់ខ្លួន និងចលនាធ្វើអាងទឹក ជីកព្រែក ធ្វើប្រព័ន្ធភ្លឺ ប្រឡាយថ្មី កែប្រែមុខមាត់ជនបទយើង និងមហាចលនាបីតោន មួយហិកតា យ៉ាងសស្រោកសស្រាំ របស់បងប្អូនកសិករសហករណ៍ យើង ។ ដូច្នេះ ក្រុមយើងទាល់តែយកចលនាទាំងនេះ មករៀនសូត្រ ពាក់ព័ន្ធ ដើម្បីយើងវាយសម្រុកបំពេញភារកិច្ចយើងឲ្យខ្លាំងក្លា ឆាប់រហ័សឲ្យទាន់ចលនា» ។

មេឃក្រហមឆ្អៅនៅទិសខាងកើត ចាំងពណ៌ផ្លេកៗ ទៅលើ ផ្ទៃទន្លេសាប ។ នាឡិកាប៉ោលវាយម៉ោងប្រាំភ្លឺ ។ យុវកម្មករជួសជុល ម៉ាស៊ីនយើង ក្រោកព្រមៗគ្នា លុបមុខលុបមាត់ ហើយនាំគ្នាទៅបន្ត ការងារពីម្សិលមិញទៀត ។ មុននឹងចាប់បន្តការ មិត្តលក បានបង្ហាញ គំនូរប្រព័ន្ធម៉ាស៊ីនជូនសមូហភាព ដើម្បីមានមតិ ។ មើលគំនូរម្តងទៀត ធ្វើឲ្យខ្ញុំភ្ញាក់ព្រើត ព្រោះគំនូរនេះ មិត្តលក មិនដឹងគូរពីអង្កាល់ទេ ហើយដែលជាគំនូរមួយ ជាក់ស្តែងច្បាស់លាស់ជាងគំនូរពីយប់មិញ ទៀត ។ មិត្តលក បានឆ្លៀតនិយាយលេងជាមួយខ្ញុំថា «មេរៀន ដែលយើងរៀនជាមួយគ្នាមុននេះបន្តិច និងលទ្ធផលនៃការប្រជុំដក ពិសោធពីម្សិលមិញ បានបង្រៀនឲ្យខ្ញុំគូរយ៉ាងនេះវិញ» ។ បន្ទាប់ មក មានមិត្តយើងខ្លះ បានផ្តល់មតិកែលម្អថែមទៀត នាំឲ្យយើងកាន់ តែភ្លឺស្វាង ហើយសង្ឃឹមជឿជាក់ថា យើងប្រាកដជាសម្រេចភារកិច្ច ជួសជុលម៉ាស៊ីនកប៉ាល់ធំនេះ បានជោគជ័យដាច់ខាត ។

មែន ! ក៏ដូចជាការងារជួលជុលម៉ាស៊ីនក្នុងរយៈពេលកន្លង មកដែរ ដោយសារការបំពាក់ជាប់ នូវគោលជំហរនយោបាយ សតិ អារម្មណ៍របស់បក្សបានរឹងមាំខ្លាំងក្លា យើងក៏ជួសជុលម៉ាស៊ីនកប៉ាល់ ធំនេះបានដោយជោគជ័យ ។ ពេលនោះ មិត្តអ្នកបើកបរ ក៏បើក កប៉ាល់ធំនេះ សាកតាមដងទន្លេសាប ។ លុះសាកទៅឃើញមាន ដំណើរការស្រួលបួលហើយ ទើបមិត្តអ្នកបើកបរយើង បើកកប៉ាល់ ដ៏ធំនេះចេញទៅ ដើម្បីប្រើប្រាស់វា រួមជាមួយកប៉ាល់ កាណូតតូចៗ ដែលយើងមានមួយចំនួនមកហើយ ក្នុងការវាយសម្រុក ដឹកជញ្ជូន ផលិតផលផ្សេងៗ ជូនប្រជាជនសហករណ៍យើង ឲ្យបានទាន់ពេល វេលា ។

ពេលយើងកំពុងឈរនៅមាត់ប្រាំងទន្លេ តាមមើលកប៉ាល់ ធំរហូតផុតកន្ទុយភ្នែក បងអ្នកទទួលខុសត្រូវ ដែលឈរក្បែរយើង បានលាន់មាត់ថា «នេះជាលើកដំបូងហើយ ដែលយើងចាប់ផ្តើម មានកប៉ាល់ធំប្រើប្រាស់ ហើយដែលមិត្តយើងជាអ្នកជួលជុល ម៉ាស៊ីនវា ក៏ថ្មីថ្មោង មិត្តយើងជាអ្នកបើកបរក៏ថ្មីថ្មោងដែរ ។ យើង សម្រេចភារកិច្ចនេះបានដោយជោគជ័យ ក្នុងរយៈពេលមួយ ដែល មិនជាយឺតយូរអ្វីដែរ សមស្របនឹងជំនឿទុកចិត្តរបស់បក្ស ដែល បានប្រគល់ភារកិច្ចនេះ ជូនមិត្តយើងទាំងអស់គ្នា» ។

លុះបងនិយាយចប់ យើងនាំគ្នាចូលទៅរោងជាង បន្តការ ងាររបស់យើងតទៅទៀត ។

តាំងពីពេលនោះមក យើងខ្ញុំកាន់តែមានពិសោធ និងកាន់ តែម្ចាស់ការបានមួយកម្រិតថែមទៀត ក្នុងការងាររបស់យើង ។ បន្ទាប់មក យើងខ្ញុំបានប្រយុទ្ធជួសជុលម៉ាស៊ីនកប៉ាល់ធំមួយទៀត បានដោយជោគជ័យ ។

ក្រោយមក ខ្ញុំត្រូវបែកពួកយុទ្ធមិត្តយើង ទៅបំពេញភារកិច្ច ថ្មីមួយទៀត ដែលនៅក្នុងក្របខណ្ឌ ផ្នែកដឹកជញ្ជូនជើងទឹកដែរ ។ តាមផែនការរបស់បក្ស បក្សមានសំណូមពរពង្រីកមធ្យោបាយដឹក ជញ្ជូនជើងទឹកឲ្យបានច្រើន ។ បក្សបានណែនាំឲ្យរៀបចំកសាងរោង ចក្រដំឡើងតួកាណូត កប៉ាល់១ ។ សំណូមពរចំពោះមុខនេះ គឺដំឡើង តួកាណូត កប៉ាល់បណ្តើរផង និងសង់រោងចក្របណ្តើរផង ។

នៅលើទឹកដីដ៏ធំល្វឹងល្វើយ ដំណាំហូបផ្លែ មានដូង ចេក ជា ដើម ព្រមទាំងបន្លែបង្ការនានាកំពុងលូតលាស់បញ្ចេញពណ៌បៃតង ស្រងាត់ លាតសន្ធឹងតាំងពីមាត់ប្រាំងទន្លេសាប រហូតដល់ផ្លូវជាតិ

លេខ៥ ។ នៅជាមួយគ្នានឹងទិដ្ឋភាពបៃតងស្រងាត់នេះ ក៏មានរណ្ដៅគ្រាប់បែកស្អេកស្អះ ជាច្រើនកន្លែង ។ ដើមឈើមួយចំនួននៅទីនេះ ងាប់ខ្លោចស្លឹក ខ្លះកំបុតចុង ខ្លះដួលប្រងើងប្រងាង ធ្វើឲ្យវាលនេះ នៅតែជាទីរហោឋាន យ៉ាងស្ងាត់ជ្រងំ ។ ទាំងអស់នេះជាស្លាកស្នាមមហាវិនាសកម្មក្នុងសម័យសង្គ្រាមជាអនុស្សាវរីយ៍ដែលពោរពេញទៅដោយកំហឹងឈឺចាប់ ចំពោះពួកអាចោរចក្រពត្តិអាមេរិក និងបរិវារ ដែលពួកវាបានប្រព្រឹត្តមកលើប្រទេសជាតិប្រជាជនកម្ពុជាយើង យ៉ាងសាហាវ ឃោរឃៅ ហ្វាស៊ីស ព្រៃផ្សៃបំផុត ។

ក្រោយមក យើងក៏មកបោះទីតាំងរោងចក្រដំឡើងកប៉ាល់កាណូតនៅទីនេះ ។ ពេលចូលមកដល់ដំបូង ទាំងយុទ្ធជន ទាំងយុទ្ធនារីដែលបានទទួលការចាត់តាំងឲ្យមកធ្វើការនៅទីនេះ បានរួមគ្នាទាំងយប់ទាំងថ្ងៃ លប់រណ្ដៅគ្រាប់បែក និងបោសសម្អាតស្លាកស្នាមសង្គ្រាមទាំងអស់ ធ្វើឲ្យវាលរហោឋាន ក្លាយទៅជាទីធ្លាមួយស្អាតរាងស្មើ ស្រឡះល្អ ក្នុងរយៈពេលយ៉ាងខ្លីប៉ុណ្ណោះ ។ បន្ទាប់ពីរៀបចំទឹកដីបានស្អាតល្អហើយ កម្លាំងយើងក៏ត្រូវបែងចែកជាពីរមុខព្រួញ គឺៈ មុខព្រួញទី១ សង់រោងចក្រ និងមុខព្រួញទី២ ដំឡើងតួកប៉ាល់ ។ ក្នុងក្រុមដំឡើងតួកប៉ាល់នេះ មិត្តយើងមួយចំនួនមានភារកិច្ច ដើរប្រមែប្រមូលឈើនៅតាមរោងចក្រអារឈើភ្នំពេញ និងទៅកាប់ឈើនៅព្រៃមកបន្ថែមទៀត ។ សល់ពីនេះ គឺយើងចែកកម្លាំងគ្នាអារឈើ ច្រៀកឈើ វៀលឈើកុង ហើយដំឡើងតួកប៉ាល់ឈើ និងកប៉ាល់ដែកមួយនៅនឹងកន្លែង ។

នៅតាមបណ្ដោយមាត់ទន្លេសាប ចម្ងាយប្រហែល២០០ ម៉ែត្រ មានរោងដំឡើងតួកប៉ាល់ដែលធ្វើពីឈើ ប្រក់សង្កសីសង់ជាប់គ្នាជាហូរហែ ។ កន្លែងដំឡើងកប៉ាល់ដែក ស្ថិតនៅខាងត្បូងគេបង្អស់ ។ មិត្តយើងទាំងអស់ បានដំណើរការងាររបស់ខ្លួន ទៅជាបន្តបន្ទាប់ ជាបណ្ដើរៗ ប្រកបដោយសុទិដ្ឋិនិយមបដិវត្តន៍ ។ ម្នាក់ៗសុទ្ធតែញាប់ដៃញាប់ជើងណាស់ ធ្វើការដំឡើងតួកប៉ាល់ ដោយសេចក្ដីប្ដេជ្ញាចិត្ត ធ្វើយ៉ាងណាសម្រេចផែនការរបស់អង្គការឲ្យបានឆាប់រហ័ស ដើម្បីបម្រើមហាចលនាបីតោនមួយហិកតាឲ្យបានទាន់ពេលវេលា ។ ពេលមិត្តយើងវៀលឈើ អារឈើ ឬច្រៀកឈើ ឬលើកដាក់ ចាប់ផ្គុំតួកប៉ាល់ក្ដី មិត្តយើងតែងមានការប្រុងប្រយ័ត្នបដិវត្តន៍ជាប់ជានិច្ច ខ្លាចវាខូចខាត បាក់បែក ខាតបង់ទាំងកម្លាំងកាយ ទាំងសម្ភារ ទាំងពេលវេលា ព្រោះមិត្តយើងតែងនឹកឃើញទៅដល់យុទ្ធមិត្តរបស់ខ្លួនទាំងអស់ ដែលនៅក្នុងតំបន់ព្រៃភ្នំ កំពុងកាប់ឈើធំៗរួចដឹកពីព្រៃចម្ងាយច្រើនសិបគីឡូម៉ែត្រមកទន្លេ ហើយបណ្ដែតក្បូនមកទន្លេបិទ រាប់រយគីឡូម៉ែត្រទៀត យើងមិនដឹកមកភ្នំពេញ តាមឡានទៀត ដោយចំណាយកម្លាំងលើកដាក់ជាច្រើនដំណាក់ ។ យុទ្ធមិត្តយើង បានចំណាយកម្លាំងញើសឈាមរបស់ខ្លួនប្រយុទ្ធធ្វើការហាលសន្សើម ភ្លៀង ខ្យល់ ក្ដៅរងារ គ្រុនចាញ់ និងជំងឺដង្កាត់ផ្សេងៗ ពិសេសធាតុអាកាសនៅក្នុងព្រៃភ្នំដែលត្រជាក់ស្រើត ។

ពីមួយថ្ងៃទៅមួយថ្ងៃ ទិដ្ឋភាពនៅលើការដ្ឋានរោងចក្រដំឡើងតួកប៉ាល់ មានការប្រែប្រួល ផ្លាស់ប្ដូរជាប់ជានិច្ច ។ ខាងផ្នែកសំណង់ ក៏កំពុងតែចាក់គ្រឹះលេចជញ្ជាំង និងសសរចេញជារៀងរោងចក្រជាបណ្ដើរៗដែរ ។ សូរសំឡេងម៉ាស៊ីនត្រាក់ទ័រ ម៉ាស៊ីនកិនថ្ម រោទិ៍លាន់សូរព្រមគ្នា នឹងសំឡេងប៉ុងបាំងៗចេញពីគ្រប់ទិសនៅលើការដ្ឋានដ៏ធំល្វឹងល្វើយនេះ ។ ពាក្យស្លោក “ប្ដេជ្ញាវាយសម្រុក បំពេញភារកិច្ចបម្រើបក្សបដិវត្តន៍ប្រជាជនដោយឥតលក្ខខណ្ឌ ឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ” សរសេរជាអក្សរពណ៌លឿង នៅលើសន្ទឹកក្ដារក្រហមឆ្អៅ ដែលស្ថិតនៅប្រចងចៅពីមុខយើង បានបញ្ជាក់នូវឆន្ទៈប្រយុទ្ធស្រួចស្រាវ និងសកម្មភាពវាយសម្រុកដាច់ខាតរបស់យុវកម្មករបដិវត្តន៍យើង ដែលធ្វើការមិនចេះទំនេរស្ងៀមដៃមួយនាទីឡើយ ។ មិត្តយើងខាងវៀលឈើកុង កំពុងតែវៀលឈើ និងរណាដៃយ៉ាងស្ទាត់ជំនាញ និងយ៉ាងឆាប់រហ័សដោយស្មារតីទទួលខុសត្រូវខ្ពស់ ។ លុះបានឈើកុងហើយ មិត្តយើងក៏ចាប់តបាតកប៉ាល់ជាបណ្ដើរៗដែរ ។ មើលទៅមិត្តយើងដែលមានភារកិច្ចដំឡើងតួកប៉ាល់ដែកវិញ ក៏កំពុងប្រយុទ្ធខ្លាំងក្លាណាស់ដែរ / ក្រោមកម្ដៅថ្ងៃស្ទើរខ្លោចស្បែក មិត្តយើងកំពុងប្រយុទ្ធដំដែកថែបឆៅ ដោយផ្ទាល់ដៃ ដោយប្រើកម្លាំងបាយសុទ្ធ ដើម្បីលត់ដែកកុងធ្វើជាឆ្អឹងកប៉ាល់ និងវាយដែកបន្ទះកម្រាស់៨លី ពាសវាឲ្យចេញជារាងកប៉ាល់ជាបណ្ដើរៗ ។ មិត្តយើងប្រយុទ្ធធ្វើដោយអំណត់អត់ធន់ តស៊ូ មានៈព្យាយាមស្វិតស្វាញបំផុត ។

ខែមួយកន្លងទៅ ខែមួយទៀតក៏ចូលមកដល់ ។ រោងចក្រ

របស់យើង ក៏បានចេញជារូបរាងបានមួយចំនួនធំហើយដែរ ។ ចំណែកផ្នែកការងារដំឡើងកប៉ាល់ឈើ និងកប៉ាល់ដែកវិញ ក៏ទទួលបានលទ្ធផលសម្រេចបានពី៥០ទៅ៧០ភាគរយនៃផែនការអង្គការដែរ ។ ដំណឹងនេះ បានលេចឮផ្សព្វផ្សាយទៅដល់រោងជាងជួសជុលកាណូត កប៉ាល់ ធ្វើឲ្យយើងខ្ញុំមានអារម្មណ៍រីករាយយ៉ាងខ្លាំង ។ យើងទាំងអស់គ្នា ដែលបំពេញភារកិច្ចក្នុងរោងជាង ក៏ខិតខំរវាយសម្រុកបំពេញភារកិច្ច យ៉ាងមមាញឹកខ្លាំងក្លាណាស់ដែរ ។ ទាំងខ្ញុំទាំងមិត្តយើង រួមទាំងកុមារបដិវត្តន៍យើងផង កំពុងប្រយុទ្ធច្នៃប្រឌិតជួសជុល កែកុន រើម៉ាស៊ីនចាស់ៗ និងកំពុងដំឡើងម៉ាស៊ីនថ្មីៗថែមទៀត ត្រៀមបម្រុងសម្រាប់ដាក់កប៉ាល់ថ្មី ឲ្យបានទាន់ពេលវេលា ។ យុទ្ធមិត្ត និងក្មួយៗខាងរោងចក្រក្រឡឹង ខាងអគ្គិសនី ខាងឡស្ងដែក ក៏ប្រយុទ្ធខ្លាំងក្លាណាស់ដែរ ដើម្បីស្ងដែកចាក់ស្ពាបចក្រ ផ្ចិតបូមប្រដាប់បូមទឹក ធ្វើឌីណាម៉ូ ក្រឡឹងខ្មៅខ្ចងនានា សម្រាប់សេចក្ដីត្រូវការក្នុងក្រសួង ពិសេសសម្រាប់កប៉ាល់ថ្មី ដែលកំពុងដំឡើង ។ ហេតុនេះ បរិយាកាសប្រឡងប្រណាំងសកម្មប្រយុទ្ធរបស់យុវកម្មករផ្នែកដឹកជញ្ជូនជើងទឹកយើង គឺខ្លាំងក្លា សស្រោកសស្រាំ នៅគ្រប់មុខព្រួញទាំងអស់ ។

ចូលមកដល់ខែកញ្ញា ឆ្នាំ១៩៧៦ ខ្ញុំ និងយុទ្ធមិត្តប្រាំនាក់ទៀត ត្រូវបានអង្គការចាត់តាំង ឲ្យទៅរួមការងារដំឡើងតួកប៉ាល់ដែក ។ នៅលើការដ្ឋាន ទិដ្ឋភាពដែលយើងមើលឃើញច្បាស់ និងគួរឲ្យចាប់អារម្មណ៍ គឺតួកប៉ាល់ដែកធំនេះ ដែលកំពុងបង្ហាញរាងយ៉ាងជ្រងោងោ នៅលើមាត់ច្រាំងទន្លេសាប ។ កប៉ាល់នេះកើតចេញពីញើសឈាមរបស់យុវកម្មករបដិវត្តន៍យើង ក្រោយការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាង នៃបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង ដែលបានប្រយុទ្ធកសាងវាឡើង ទាំងយប់ទាំងថ្ងៃ អស់រយៈពេលប្រាំខែមកហើយ ។ យើងប្រយុទ្ធកសាងវា តាំងពីមានកម្លាំងតែបីនាក់ រហូតប្រាំមួយនាក់ និងរហូតមកដល់ថ្ងៃនេះ មានគ្នា១២នាក់ទៀត កសាងដោយបាតដៃផ្ទាល់ ដោយកម្លាំងបាយផ្ទាល់របស់យើង ដោយបំពាក់នូវគោលជំហរ វណ្ណៈអធនរបស់បក្ស នូវគោលជំហរធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសរបស់បក្ស ធ្វើជាអាវុធ ជាម៉ាស៊ីន ជាគ្រឿងចក្រ សម្រេចបានតួកប៉ាល់នេះឡើង ។ ផែនការរបស់យើង គឺសម្រេចទម្លាក់វាទៅក្នុងទន្លេ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៦ តួកប៉ាល់ដែកយើង បានត្រូវដំឡើងហើយស្រេចជាមូលដ្ឋាន នៅសល់តែផ្នែកខាងលើ និងដាក់ម៉ាស៊ីនប៉ុណ្ណោះ ។ នៅល្ងាចនេះ ខ្ញុំ និងយុទ្ធមិត្តយើងមួយចំនួននៅធ្វើការលើតួកប៉ាល់ដែក ។ យើងកំពុងផ្សារដែក ផ្សារក្ដិតកន្ទែងដែលនៅឆ្ងាយ ។ ឯមិត្តយុវជនឯទៀត ខ្លះកំពុងតែលីឈើកំណល់ ខ្លះគ្រីបឲ្យកប៉ាល់ហើបបាត ដើម្បីស៊កកំណាត់ដែក រនេលនៅខាងឆ្វេង និងខាងស្ដាំ តាមបណ្ដោយកប៉ាល់ ។ ឯផ្នែកយុវនារី និងកុមារវិញ ក៏កំពុងនាំគ្នាកាប់ដី ឆាយដី រៀបចំកំពង់បញ្ចុះកប៉ាល់ ។

កម្លាំងក្នុងការដ្ឋានរោងចក្រទាំងមូល គឺរវាយសម្រុកធ្វើការជុំវិញតួកប៉ាល់ដែកទាំងអស់ ។

ក្រោមពន្លឺខែមួយរោជ នៃខែភទ្របទ និងកណ្ដាលខ្យល់អាកាសត្រជាក់មកពីទន្លេ យើងទាំងអស់គ្នា ប្រឹងធ្វើការញាប់ដៃញាប់ជើង ដោយឥតឈប់ទំនេរឡើយ ។ ធាតុអាកាសត្រជាក់មែន តែញើសហូរជោកអាវយើងម្នាក់ៗ ដូចជាយើងធ្វើការក្រោមដំណក់ទឹកភ្លៀង ឬកណ្ដាលថ្ងៃក្ដៅដូច្នោះដែរ ។ យើងខិតខំប្រយុទ្ធ ធ្វើយ៉ាងណា ដើម្បីសម្រេចការងារពេលនេះ ឲ្យហើយស្រេច នៅវេលាយប់នេះ ទោះបីត្រូវហើយនៅម៉ោងប៉ុន្មានក៏ដោយ ។ នៅវេលាម៉ោងមួយអាធ្រាត្រ យើងក៏បញ្ចប់ការងាររបស់យើងបានហើយស្រេចបាច់ ទាំងផ្នែកកែលម្អតួកប៉ាល់ ថែមទាំងផ្នែកធ្វើកំពង់បញ្ចុះកប៉ាល់ ។ យើងក៏នាំគ្នាទៅសម្រាកយកកម្លាំង ដើម្បីបន្តការងារនៅថ្ងៃស្អែកតទៅទៀត ។

លុះព្រលឹមឡើង យុទ្ធមិត្តដែលមានភារកិច្ចសង់អគាររោងចក្រ និងដំឡើងតួកប៉ាល់ឈើ ក៏បានចេញទៅបន្តការងាររបស់ខ្លួនតាមមុខព្រួញរៀងខ្លួន ។ ឯក្រុមយើងខ្ញុំដែលមានគ្នាប្រមាណជាង៣០នាក់ ក៏បន្តការងារនៅខាងកប៉ាល់ដែកនេះទៀតដែរ ។ មិត្តខ្លះបាននាំគ្នាសែងឈើហ៊ុប មកដាក់សណ្ដូកបណ្ដោយពីតួកប៉ាល់ចុះទៅទន្លេ ដើម្បីសម្រួលផ្លូវបញ្ចុះថែមទៀត ។ ពេលជាមួយគ្នានោះ ត្រាក់ទ័រ និងឡានស្ទូចក៏មកដល់ដែរ ។ ដោយមិនបង្អែបង្អង់មិនរង់ចាំអ្វីទៀតឡើយ មិត្តយើងទាំងអស់ ក៏មកអង្គុយជុំវិញបាតកប៉ាល់នោះ ។ ស្នូរកញ្ចែ បន្លឺឡើង ឡានស្ទូចក៏រោទិ៍ម៉ាស៊ីន ស្ទូចគូទកប៉ាល់បង្ហើប រួចត្រាក់ទ័រ ក៏រុញតាមក្រោយ ។ កប៉ាល់យើង រំកិលទៅមុខបានបន្តិច មិត្តយើងក៏រវាសរវៃ ស៊កដែករនេលនៅខាងមុខទៀត ។

ទៅដល់កន្លែងមួយ ត្រាក់ទ័រ ក៏រុញតួកប៉ាល់យើងទៅមុខលែងកើតទៅទៀត ។ បងម្នាក់ឃើញសភាពការណ៍ដូច្នេះ ក៏ស្ទុះទៅលីដែកគ្រីប ។ មិត្តខ្លះទៀត ក៏ទៅលើកឈើមកជួយគាស់បង្អើបតួកប៉ាល់នេះ ដើម្បីស៊កដែករនេល និងតម្រង់ដែករនេលឲ្យស្មើ ។ ដោយសារការយកចិត្តទុកដាក់តាមមើលពិនិត្យ និងជួយគ្រីបបង្អើបដាក់កំណាត់ដែករនេលឲ្យរត់ស្មើល្អយ៉ាងនេះហើយ នាំឲ្យត្រាក់ទ័រ វាអាចរុញរំកិលតួកប៉ាល់យើងទៅមុខទៀត បានដោយស្រួល ។ នៅប្រហែលជា១០ម៉ែត្រពីទឹក កប៉ាល់ដែកយើង ហើបតួផុតពីដីជិតពាក់កណ្ដាលបណ្ដោយខ្លួនវា ។ ស្នូរកញ្ចែក៏បន្លឺឡើងឲ្យសញ្ញាឈប់ដែរ ។ ពេលថ្មើរណោះ ថ្ងៃក្ដៅខ្លាំងស្ទើរខ្លោចស្បែក ។ តែយើងទាំងអស់គ្នាឥតសម្រាកឡើយ យើងប្ដេជ្ញាបញ្ចុះកប៉ាល់ដែកនេះ ទៅក្នុងទន្លេ ឲ្យបានសម្រេចនៅថ្ងៃនេះដាច់ខាត ។ ពេញមួយព្រឹកមកហើយ ម្នាក់ៗបែកញើសជោកអាវគ្រប់ៗគ្នា តែវាគ្មានឥទ្ធិពលអីមករាំងរាការប្ដេជ្ញាចិត្តរបស់យើងឡើយ ។

នៅកណ្ដាលទន្លេ សាឡាង់ស្ទូចមួយរបស់កងទ័ពជើងទឹកបដិវត្តន៍យើង បានមកចតនៅទីនេះ ដើម្បីចូលរួមការងារបញ្ចុះកប៉ាល់ជាមួយយើងដែរ ។ យុទ្ធមិត្តទាំងអស់នៅលើសាឡាង់នេះ សុទ្ធតែជាយុទ្ធមិត្តដែលយើងធ្លាប់រួមការងារជាមួយគ្នា កាលពីពេលដើរស្ដាកប៉ាល់ កាណូតលិចពេលមុន ។ តែពេលនេះ ដោយយើងជាប់ធ្វើការងាររៀងខ្លួន យើងពុំបានទៅចាប់ដៃសួរសុខទុក្ខគ្នាឡើយ ។

ពេលឃើញកប៉ាល់ដែកហើបបាត គូទវាជិតដល់ទន្លេហើយ យុទ្ធមិត្តនៃកងទ័ពជើងទឹកបដិវត្តន៍យើង ក៏ទម្លាក់ដែកស្ទូចទៅថ្ពក់គូទកប៉ាល់ដែក ។ ឯមិត្តយើងដែលនៅប្រចាំការលើកប៉ាល់ដែកស្រាប់ ក៏ខំស្ទុះស្ទាញទាញខ្សែកាបឲ្យប្រសព្វមុខគ្នា ចងក្រៀកមុខកប៉ាល់ដែកយើង ហើយឡើងឈរយកទៅស៊កបញ្ចូលនឹងទម្ពក់ស្ទូច ដោយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ។ ពេលដែលសាឡាង់ស្ទូចបង្អើបគូទកប៉ាល់ដែកហើយ ត្រាក់ទ័រក៏រុញរំកិលវាទៅមុខទៀត ។ ឯមិត្តយើងដែលនៅមើលសភាពការណ៍ជុំវិញកប៉ាល់ក៏រវាសរវៃ ជួយនាំគ្នាទាញអូសឈើ និងសែងឈើកល់បាត់កប៉ាល់ដែលរត់វេប្រចេងប្រចាង នាំឲ្យទិសដំណើរយ៉ាងប្រញឹក ដោយយកឈើទាំងនេះចេញជាបន្តបន្ទាប់ ។ តួកប៉ាល់ដែក ចេះតែរំកិលទៅមុខទៀតសន្សឹមៗ ។ មិត្តយើងម្នាក់ៗកាន់តែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នខ្ពស់ជានិច្ច ដើម្បីបង្ការកុំឲ្យកប៉ាល់ដែកនេះ កាច់ចង្កេះ ឬផ្អៀងក្រឡាប់ពេលវាធ្លាក់ចុះទៅក្នុងទឹក នៅសល់តែប្រាំម៉ែត្របីម៉ែត្រ ពីរម៉ែត្រ មួយម៉ែត្រ កន្លះម៉ែត្រទៀតទេ គូទកប៉ាល់យើងនឹងធ្លាក់ប៉ះទឹកហើយ! យើងទាំងអស់គ្នាតាមសម្លឹងដំណើររបស់វាដោយទឹកចិត្តរំភើបយ៉ាងខ្លាំង ។ ពេលនោះ គូទកប៉ាល់ បានធ្លាក់ទៅដល់ទឹកហើយ! ត្រាក់ទ័រចេះតែរុញវាទៅមុខបន្តិចម្ដងៗ ឯសាឡាង់ស្ទូចក៏ទម្លាក់វាសន្សឹមៗឲ្យប៉ះទឹកដែរ ។ នៅម៉ោងជាងមួយពេលរសៀល តួកប៉ាល់ដែកយើងដែលមានបណ្ដោយជិត៤០ម៉ែត្រ និងទម្ងន់៨៧តោន បានអណ្ដែតក្នុងទន្លេដោយជោគជ័យ ក្រោមស្នូរទះដៃកងរំពង និងពោរពេញដោយទឹកចិត្តសប្បាយរីករាយរបស់យុវកម្មករបដិវត្តន៍ និងរបស់យុទ្ធមិត្តកងទ័ពបដិវត្តន៍យើង ។ មិត្តយើងខ្លះក៏ប្រញាប់ប្រញាល់លោតទៅក្នុងទឹក ឬចុះទៅក្នុងបាតកប៉ាល់ តាមពិនិត្យមើល ក្រែងមានកន្លែងណាធ្លាយទៀត ។ ពេលដែលកប៉ាល់ដែកចុះទៅដល់ក្នុងទឹកទាំងមូលហើយ ទឹកចិត្តសប្បាយរីករាយរបស់យើងម្នាក់ៗ បាននាំឲ្យយើងភ្លេចឃ្លានបាយអស់រលីង ។ ឆ្លៀតពេលនេះ យើងខ្ញុំបានចុះទៅចាប់ដៃ សួរសុខទុក្ខយុទ្ធមិត្តកងទ័ពបដិវត្តន៍យើង ដោយសេចក្ដីនឹករលឹកក្រៃលែង នៅលើសាឡាង់ស្ទូច ។ បន្ទាប់មក យើងក៏បានស្នើយុទ្ធមិត្តទាំងនោះ ទៅជួយស្ទូចម៉ាស៊ីនដាក់កប៉ាល់ដែកនោះទៀត នៅឯរោងជួសជុលកាណូត កប៉ាល់ ។ យុទ្ធមិត្តទាំងនោះ ក៏ពេលចិត្តពេលថ្លើម និងរួមការងារជាមួយយើងតទៅទៀត ។

ថ្ងៃនេះ មេឃស្រឡះល្អណាស់ ។ កាណូតមួយកំពុងសណ្ដោងកប៉ាល់ដែក ទៅកាន់រោងជាងជួសជុល ដើម្បីដាក់ម៉ាស៊ីនទៀត ។ ខ្ញុំ និងមិត្តយើងមួយចំនួន មិនទាន់បានហូបបាយទេ ។ យើងកំពុងជិះកប៉ាល់ដែកនេះ ទៅកាន់រោងជាងដែរ ។ ទឹកទន្លេសាបហូរខ្វូលខ្វាញ់បែករលកខ្ពោល ហាក់ជួយរុញច្រានកប៉ាល់ដែក ទៅកាន់រោងជាងឲ្យបានឆាប់រហ័ស ។ មួយស្របក់ប៉ុណ្ណោះ កប៉ាល់យើងក៏បានទៅដល់ទីដៅ ហើយសាឡាង់ស្ទូចក៏មកដល់ក្នុងពេលតែមួយគ្នានេះដែរ ។ យើងខ្ញុំឡើងទៅលើគោកដើម្បីជួបមិត្តយើងទាំងអស់ ព្រមទាំងក្មួយផ្នែករោងជាង ។ យើងបានចាប់ដៃឱបរឹតគ្នា សម្ដែងទឹកចិត្តរំភើបរីករាយ ចំពោះជោគជ័យនៃការបញ្ចុះកប៉ាល់ដែក ជា

លើកទីមួយ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា ជាងពីរពាន់ឆ្នាំមកហើយ ។ មិត្តលក បានបង្ហាញម៉ាស៊ីនមួយដែលស្ថិតនៅប្រផាងជាប់នឹងមាត់ច្រាំង ដោយនិយាយមកកាន់យើងខ្ញុំថា «នេះជាម៉ាស៊ីនភ្លើងកម្លាំង២៤០សេះ ដែលមិត្តយើងនៅខាងរោងជាងបានយកមកជួសជុលកែកុន ច្នៃប្រឌិត ដោយឯករាជ្យម្ចាស់ការ ដើម្បីសមស្របនឹងសំណូមពរនៃកប៉ាល់ដែកថ្មីរបស់យើងនេះ» ។ បន្ទាប់មក សាឡ្ង់ស្ទូចក៏ទម្លាក់ទម្ពក់ស្ទូចរបស់វា មកស្ទូចយកម៉ាស៊ីននេះ ទៅដាក់ក្នុងកប៉ាល់ដែក ។ យើងនាំគ្នាចុះទៅក្នុងកប៉ាល់ដែក ដើម្បីជួយទប់ទ្រតម្រង់ម៉ាស៊ីននេះ និងដាក់វាឲ្យចំដាក់ស្ដែងតាមស្លាបចក្រ និងចង្កូតវា ។ យុទ្ធមិត្តខាងរោងជាង ក៏បានជួយយើងក្នុងការចាប់ខ្ចៅ ដាក់ម៉ាស៊ីននេះដែរ ។ មិត្តលក មួលខ្ចៅបណ្ដើរ និយាយបណ្ដើរថា «ប៉ុន្មានខែនេះ ពួថាមិត្តយើងខាងណោះ សម្រុកខ្លាំងក្លាណាស់ ក្នុងការដំឡើងតួកប៉ាល់ដែកមួយនេះ ។ ជាការពិតណាស់ យុទ្ធមិត្តយើងមិនដែលធ្វើវាសោះ ហើយប្រយុទ្ធធ្វើវាក្នុងសភាពខ្វះខាតសម្ភារគ្រឿងចក្រ និងឧបករណ៍គ្រប់សព្វ ហើយប្រយុទ្ធធ្វើវាទាល់តែបានសម្រេចជោគជ័យ» ។

មិត្តម្នាក់ ដែលបានជាប់ការងារដំឡើងកប៉ាល់ដែកនេះ តាំងពីដំបូងដៃ បាននិយាយកាត់ថា «នេះដោយសារការដឹកនាំ អប់រំ ថែបំប៉នទាំងនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ។ ការដំឡើងតួកប៉ាល់ដែកនេះ ក៏ដូចជាការដំឡើងតួកប៉ាល់ឈើ ដែលយើងកំពុងដំណើរការរាល់ថ្ងៃនេះដែរ ។ និយាយរួម គឺយើងអត់ចេះធ្វើវាទេ ។ តែដោយមើលតាមទ្រង់ទ្រាយកប៉ាល់ចាស់ៗខ្លះ យើងក៏ធ្វើវាបណ្ដើរ ដកពិសោធបណ្ដើរ ។ ការដំឡើងតួកប៉ាល់នេះទៀត គឺធ្វើក្នុងលក្ខណៈសិប្បកម្មដោយប្រើកម្លាំងសុទ្ធសាធ ។ ឯវត្ថុធាតុដើមជាដែកដីងផ្សេងៗ គឺជារបស់សេសសល់ពីសង្គ្រាមទាំងអស់ ដែលយើងប្រមែប្រមូលពីនេះបន្តិច ពីនោះបន្តិច យកមកប្រើប្រាស់វា ក្នុងកិច្ចដំណើរការរបស់យើង ។ កន្លងមក យើងជួបការលំបាកស្មុគស្មាញ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្តដែរ តែវាក៏មិនលំបាកដូចកាលយើងវាយខ្មាំងសត្រូវពេលសង្គ្រាមដែរ ។ ហេតុនេះ ដោយបំពាក់ជាប់នូវគោលជំហរឯករាជ្យម្ចាស់ការ ជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ និងដោយមានការណែនាំពីបក្សយើងជាប់ជានិច្ច យើងក៏សម្រេចផែនការដំឡើងតួកប៉ាល់ដែកនេះ បានជាលើកទីមួយនៅថ្ងៃនេះតែម្ដង» ។

ក្រោយពីដាក់ម៉ាស៊ីនរួច យើងក៏នាំកប៉ាល់ដែកត្រឡប់ទៅការដ្ឋានវិញដំឡើងតួកប៉ាល់វិញ ដើម្បីធ្វើផ្នែកលើ មានធ្វើដំបូល ដាក់បំពង់ផ្សែង ដាក់ដៃចង្កូតជាដើមទៀត ។ កន្លះខែទៀត កប៉ាល់ដែករបស់យើង នឹងត្រូវធ្វើហើយសព្វគ្រប់ ។

ឯយុទ្ធមិត្តនៃកងទ័ពជើងទឹកបដិវត្តន៍យើង ក៏បាននាំសាឡ្ង់ស្ទូចលាយើងខ្ញុំ នៅរោងជាងជួសជុលត្រឡប់ទៅមូលដ្ឋានវិញ ក្នុងបរិយាកាសសាមគ្គីភាព ភាតរភាពបដិវត្តន៍យ៉ាងកក់ក្ដៅបំផុត ។

ក្រោមរស្មីបដិវត្តន៍ដ៏ក្រហមឆ្អិនឆ្អៅ និងក្រោមពន្លឺមាគ៌ាបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង សហជីពកម្មករផ្នែកដឹកជញ្ជូនជើងទឹកយើង ប្ដេជ្ញា គោរព ស្រឡាញ់ និងបម្រើបក្ស បដិវត្តន៍ និងប្រជាជនជារៀងរហូត ។ គឺយើងខិតខំវាយសម្រុក បំពេញភារកិច្ចគ្រប់ផ្នែករបស់ខ្លួនយើងម្នាក់ៗ ឲ្យបានខ្លាំងក្លាបំផុត និងជាប់ជានិច្ច ដោយគោលជំហរឯករាជ្យម្ចាស់ការរឹងប៉ឹង ច្នៃប្រឌិត កសាងរស់រវើក ។ ឆ្នាំនេះ យើងដំឡើងកប៉ាល់ កាណូតបានមួយចំនួនហើយ ក្នុងក្របខណ្ឌលក្ខណៈសិប្បកម្ម ក្នុងសភាពដែលយើង នៅខ្វះខាតសម្ភារគ្រប់សព្វ និងក្មេងខ្ចីខាងសមត្ថភាពបច្ចេកទេស ក៏ពិតមែនហើយ តែយើងនៅតែមានជំនឿជឿជាក់ថា ឆ្នាំតទៅមុខទៀត យើងនឹងដំឡើងកាណូត កប៉ាល់ ឲ្យបានច្រើន ហើយសមត្ថភាពបច្ចេកទេសគ្រប់ផ្នែករបស់យើងនឹងកាន់តែរីកចម្រើន កាន់តែរឹងដៃ រឹងជើង ដោយសារយើងមានបក្សកុម្មុយនីស្តកម្ពុជា អប់រំបំពាក់បំប៉នគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ឲ្យដល់យើងរាល់គ្នាជាប់ជានិច្ច ។ យើងប្ដេជ្ញា កៀកស្មាគ្នា ជាមួយសហជីពកម្មករផ្នែកផ្សេងៗទៀត ជាមួយសហករណ៍កសិករ និងជាមួយកងទ័ពបដិវត្តន៍នៅទូទាំងប្រទេស រួមគ្នាវាយសម្រុកបំពេញភារកិច្ចគ្រប់ផ្នែកទាំងអស់ ដើម្បីសម្រេចគ្រប់ទិសផែនការរបស់បក្ស ទាំងចំពោះមុខទាំងយុទ្ធសាស្ត្រយូរអង្វែងក្នុងភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសឲ្យបានល្អ រឹងប៉ឹង និងរីកចម្រើនឆាប់រហ័ស ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យ ។

**ឆេង ខ៉េង**

# ថៃ ម៉ុន អតីតកងឈ្លបក្រោមការគ្រប់គ្រងរបស់ តាអាន គណៈស្រុកកណ្តាលស្ទឹង

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ឆ្នាំ ១៩៧០ នៅឃុំបត់ល្ងាង និងឃុំមួយទៀត ក្នុងស្រុកកណ្តាលស្ទឹង បានក្លាយទៅជាតំបន់ប្រទាញប្រទង់រវាងទាហានសាធារណរដ្ឋខ្មែរ និងខ្មែរក្រហម ។ នៅចុងឆ្នាំ១៩៧២ ខ្មែរក្រហមបានបញ្ជូន តាអាន ឲ្យមកធ្វើជាគណៈស្រុកកណ្តាលស្ទឹង ។ នៅពេលនោះ តាអាន បានជ្រើសរើសយុវជនដែលជាកូនចៅអ្នកភូមិរាប់សិបនាក់ ឲ្យចូលធ្វើជាឈ្លប ដើម្បីបម្រើការងារនៅតាមមូលដ្ឋាន និងចូលទៅស៊ើបការណ៍នៅតាមបន្ទាយទាហាន លន់ នល់ នានាដែលបានតាំងទីនៅស្រុកកណ្តាលស្ទឹង ។



ថៃ ម៉ុន រៀបរាប់ពីប្រវត្តិតស៊ូក្នុងរបបខ្មែរក្រហម ប្រាប់ដល់ សួន ពិជិត នៅផ្ទះរបស់គាត់ ស្ថិតនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

អតីតកងឈ្លបខ្មែរក្រហមម្នាក់ឈ្មោះ ថៃ ម៉ុន ភេទប្រុស កើតនៅឆ្នាំ១៩៥២ និងមានស្រុកកំណើតនៅក្នុងឃុំបត់ល្ងាង ស្រុកកណ្តាលស្ទឹង បានរៀបរាប់ឲ្យដឹងថា កាលនៅក្មេងគាត់បានរៀនត្រឹមថ្នាក់ទី៩ពីសង្គមចាស់នៅវត្តខុទុម្ពរនៅឃុំបត់ល្ងាង ហើយគាត់បានឈប់រៀននៅអាយុ១៦ឆ្នាំ ដោយសារជីវភាពក្រីក្រ ។ បន្ទាប់ពីឈប់រៀន ម៉ុន បានទៅបួសនៅវត្តកោះបានពាវស្សាកន្លះ និងបានសឹកនៅខែមករា ឆ្នាំ១៩៧២ បន្ទាប់ពីដឹងដំណឹងថា យន្តហោះបានទម្លាក់គ្រាប់បែកចំផ្ទះឪពុកម្តាយគាត់ឆេះអស់ ។

បន្ទាប់ពីសឹកហើយ ឈ្មោះ សឿង មេឃុំបត់ល្ងាង បានយក ម៉ុន និងយុវជន៣នាក់ទៀតឈ្មោះ យ៉ា, ប៊ុនសេង និង ឈ្មោះ ជឹមជាម ឲ្យចូលធ្វើកងឈ្លបនៅស្រុកកណ្តាលស្ទឹង ។ អំឡុងពេលនោះ ស្រុកកណ្តាលស្ទឹងមានកងឈ្លបប្រមាណពី៣០ទៅ៤០នាក់ ។ កងឈ្លបមានភារកិច្ចការពារភូមិ និងយកការណ៍តាមបន្ទាយទាហាន លន់ នល់ ។ នៅពេលកងឈ្លបទទួលបានព័ត៌មានហើយ ត្រូវមករាយការណ៍ឲ្យ តាអាន ដែលជាគណៈស្រុក, តាសំបួរ អនុស្រុក និង តាសឿង មេឃុំបត់ល្ងាង ។ មន្ទីរស្រុកកណ្តាលស្ទឹងកាលនោះ មានការផ្លាស់ប្តូរច្រើនកន្លែង ។ ម៉ុន បានឲ្យដឹងទៀតថា ឈ្លបមានតែកាំភ្លើង៨ណាត់ ដែលគេហៅថា ប៊ីស្តុង មិនទាន់មានកាំភ្លើងទំនើបទេ ។

ចុងឆ្នាំ១៩៧២ ម៉ុន ត្រូវបានចាត់តាំងឲ្យទៅរៀនក្បួនយុទ្ធសាស្ត្រកងទ័ពនៅខេត្តកំពង់ឆ្នាំង ។ ពេលនោះ មានទ័ពចំនួនជាង ១០០នាក់ ។ កងទ័ពអត់មានធ្វើការអ្វីក្រៅពីការហាត់រៀនក្បួនយុទ្ធសាស្ត្រកងទ័ពឡើយ ។ កន្លែងហាត់រៀន នៅជិតវាលយន្តហោះខេត្តកំពង់ឆ្នាំង ។ ម៉ុន ហាត់រៀនបានប្រហែលជា៦ទៅ៧ខែ ។ នៅទីនោះមានឈ្មោះ សាយ ជាប្រធាន និងឈ្មោះ ធុន ជាអនុប្រធាន ។ សាយ និង ធុន ក៏ជាប្រធាន និងអនុប្រធានកងទ័ពតំបន់១៥ដែរ ។

បន្ទាប់ពីបញ្ចប់ការហាត់រៀន ខ្មែរក្រហមបានបែងចែកកងទ័ពទៅតាមអង្គភាពផ្សេងៗ រួមមាន គ១, គ២, គ៣ និង គ៤ ។ ម៉ុន ស្ថិតនៅ គ៤ វរសេនាធំលេខ៤០៣ ។ ប្រធានវរសេនាធំឈ្មោះ សូ សារឿន ។ ក្រោយមក សូ សារឿន ត្រូវបានដំឡើងជាប្រធានកងពលលេខ១៨ ។ ប្រធានគ៤ ឈ្មោះ យឹម សារឿន (ស្លាប់នៅចុងខែមករា ឆ្នាំ១៩៧៣) ។ បន្ទាប់មកឈ្មោះ ចាន់ សារិន ឡើងជាប្រធានគ៤ ជំនួស ។ សមាជិកនៅក្នុងអង្គភាព គ៤ របស់ ម៉ុន បានស្លាប់អស់ជាច្រើនពេលវាយប្រយុទ្ធនៅសមរភូមិលង្វែក ។ បន្ទាប់មក អង្គភាព គ៤ របស់ ម៉ុន ផ្លាស់ទៅវាយនៅព្រែកហូរ, តាខ្មៅ, សៀមរាបកន្ទួត និងរោងចក្របែកចានជាដើម ។

ខ្មែរក្រហមបានបង្កើតកងពល១៤ នៅឆ្នាំ១៩៧៤ ។ ដោយសារអង្គភាពគ៤ មានកងទ័ពស្លាប់ច្រើនទើបក្រោយមក ខ្មែរក្រហមរំសាយចូលជាមួយអង្គភាព គ៦ និង គ៨ ។ ម៉ុន បានឲ្យដឹងថាកងពល១៤ មាន ៣វរសេនាធំ គឺ វរសេនាធំលេខ៤០២, ៤០៣ និង ៤០៦ ។ ប្រធានកងពលឈ្មោះ សូ សារឿន និងតា ម៉ា ។ ចំណែក ម៉ុន ពេលនោះស្ថិតនៅក្នុងវរសេនាធំ៤០៣ ចំណុះកងពល១៤ ដែលប្រចាំការនៅស្រុកកណ្តាលស្ទឹង ។

ពេលចូលវាយភ្នំពេញឆ្នាំ១៩៧៥ វរសេនាធំ៤០៣ របស់ ម៉ុន បានចូលខាងពោធិចក្រកែវ តាមកន្ទួតកំណាត់ផ្លូវជាតិលេខ២ មកលិច ។ ចំណែកកងផ្សេងទៀតចូលតាមផ្លូវជាតិលេខ២មកកើត ។ កាលនោះកងទ័ពភូមិភាគពិសេស, បូព៌ា, និរតី និងឧត្តរ បានវាយចូលទៅភ្នំពេញស្របគ្នា ។

នៅពេលរំដោះទីក្រុងភ្នំពេញឆ្នាំ១៩៧៥ អង្គភាពរបស់ ម៉ុន បានបោះទីតាំងនៅជម្ពូវ័ន្ត មួយរយៈទើបចេញទៅនៅកំបូល ។ បន្ទាប់មក គណៈតំបន់១៥ ឈ្មោះ ហំ បានមកយក ម៉ុន ទៅនៅជាមួយ ។ ម៉ុន បានស្គាល់តា ហំ ជាមេខ្មែរក្រហមម្នាក់ដែលចេញចូលមកស្រុកកណ្តាលស្ទឹងញឹកញាប់ ក្នុង១ខែប្រហែល២ ឬ៣ដង ។ តាហំ ក៏ជាមនុស្សម្នាក់ដែលមានទំនាក់ទំនងជាមួយឪពុក ម៉ុន តាំងពីមុនឆ្នាំ១៩៧០មកដែរ ។

មន្ទីរតំបន់១៥ កាលនោះស្ថិតនៅបន្ទាយព្រាបក្នុងស្រុកអង្គស្នួល ។ ម៉ុន ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានអ្នកឡើងត្នោតផលិតស្ករ ដើម្បីចែកចាយនៅក្នុងតំបន់១៥ទាំងមូល ។ អង្គភាពឡើងត្នោតនេះមានសមាជិកចំនួន២៨នាក់ ។ ម៉ុន ត្រូវចូលរួមប្រជុំជាមួយតាហំ ក្នុង១ខែម្តង ឬ២ដង ដើម្បីដាក់ផែនការក្នុងការផលិតស្ករថាតើក្រុមនីមួយៗត្រូវផលិតស្ករប៉ុន្មានៗតោនជាដើម ។ ក្នុងចំណោមសមាជិក២៨នាក់ត្រូវឡើងយកទឹកត្នោតឲ្យបាន១ខ្ទះកន្លះ ទៅ២ខ្ទះក្នុង១ថ្ងៃ ។ ជាគោលការណ៍ក្នុងម្នាក់ៗត្រូវឡើងត្នោត២២ដើម ។ អ្នកខ្លះពូកែឡើងគឺចន្លោះពី១២-១៥ដើមប៉ុណ្ណោះ អាចបានទឹកត្នោតគ្រប់២ខ្ទះហើយ ។

នៅឆ្នាំ១៩៧៧ តាហំ បានប្រាប់ ម៉ុន ឲ្យរកគ្រួសារ ប្រសិនបើនៅលីវអង្គការនឹងបញ្ជូនឲ្យទៅវាយវៀតណាមនៅព្រំដែនហើយ ។ ដូច្នេះ ម៉ុន ក៏រើសគ្រួសារ តាមការណែនាំរបស់ តាហំ ។ ម៉ុន បានជិះម៉ូតូរកមើល និងឃើញនារីៗកំពុងស្ទូងក៏ចុះទៅមើល ។ ពេលនោះ ម៉ុន បាននិយាយត្រូវរ៉ូវជាមួយនារីឈ្មោះ ទូច ហើយក៏ព្រមព្រៀងធ្វើប្រវត្តិរូប សរសេរសំបុត្រស្នើទៅ តាហំ ប្រធានតំបន់ដើម្បីរៀបការតែម្តង ។

ក្រោយពេល ម៉ុន រៀបការបានប៉ុន្មានខែ អង្គការបានរំសាយអង្គភាពឡើងត្នោត ។ អ្នកដែលមានគ្រួសារ អង្គការចាត់ឲ្យទៅនៅសហករណ៍វិញ ។ ម៉ុន និងប្រពន្ធ បានកាន់សំបុត្រទៅឲ្យសហករណ៍ដែលជាស្រុកកំណើតខាងប្រពន្ធនៅស្រុកថ្ពង តំបន់៣២ ដែលមានប្រធានឃុំឈ្មោះ ម៉ៅ និងប្រធានសហករណ៍ឈ្មោះ រស់ ។ ក្រោយពេលរស់នៅសហករណ៍បាន១ឆ្នាំ ប្រធានសហករណ៍បានចាត់តាំង ម៉ុន ឲ្យឡើងត្នោតវិញ ហើយបញ្ជាឲ្យទៅកាប់បង្គោងឫស្សីឲ្យបានពី ២៥ ទៅ៥០ដើមក្នុង១ថ្ងៃ ។ ម៉ុន កាប់ឫស្សីមិនបានតាមផែនការដែលបានកំណត់ទេ ។ ដោយមានការភ័យខ្លាចប្រធានសហករណ៍យកទៅសម្លាប់ គាត់បាននាំប្រពន្ធដែលកំពុងពពោះ៦ទៅ៧ខែរត់មកនៅភ្លើងឆេះរទេះនៅក្នុងស្រុកដង្កោជាមួយឪពុកម្តាយបង្កើតរបស់ខ្លួនវិញ ។ ពេលនោះ ម៉ុន បានសរសេរសំបុត្រក្លែងក្លាយមួយច្បាប់ ប្រគល់ឲ្យទៅប្រធានសហករណ៍ថ្មី ។ ម៉ុន ធ្វើដំណើរទាំងយប់មកដល់ខត្តុង្គក៏បានជួបមិត្តចាស់នៅអង្គភាពទ័ពចាស់ដែលធ្លាប់ស្គាល់គ្នាកាលពីមុនឆ្នាំ១៩៧៥ ក៏បានហៅ ម៉ុន និងប្រពន្ធឡើងជិះឡានទៅជាមួយគ្នា ។ មកដល់កំបូល ម៉ុន និងប្រពន្ធ បានចុះពីឡានហើយបន្តដំណើរដោយថ្មើរជើងមកភ្លើងឆេះរទេះ ។ ពេលមកដល់ភ្លើងឆេះរទេះ មេឃុំបានសួររកសំបុត្រស្នាម ។ ម៉ុន បានបង្ហាញសំបុត្រក្លែងក្លាយដែលខ្លួនបានសរសេរនោះឲ្យមេឃុំ ។ ដោយមេឃុំមិនចេះអក្សរក៏សួរ ម៉ុន ថា មកពីឃុំណា? ម៉ុន បានប្រាប់ថា មកពីខាងឃុំនៅស្រុកកំណើតខាងប្រពន្ធបានធ្វើសំបុត្រអនុញ្ញាតឲ្យត្រឡប់មករស់នៅឃុំភ្លើងឆេះរទេះវិញ ។ ម៉ុន និងប្រពន្ធបានរស់នៅភ្លើងឆេះរទេះរហូតវៀតណាមចូល ទើបចេញពីភ្លើងឆេះរទេះមកនៅអូររំចេក ។

ក្រោយមកទៀត ម៉ុន និងប្រពន្ធ បាននាំគ្នាធ្វើដំណើរត្រឡប់មករស់នៅស្រុកកំណើតវិញ ហើយគាត់ក៏ស្ម័គ្រចិត្តចូលធ្វើកងឈ្លបឲ្យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រហូតដល់ឆ្នាំ១៩៨៦ ។

**ស្នួន ពិដិត**

# យឿម : ខ្ញុំមិនចង់ឃើញសង្គ្រាមម្តងទៀតទេ

យឿម អាយុ៥៩ឆ្នាំ ជាអតីតយោធារបស់ខ្មែរក្រហម ។ គាត់មានអាយុប្រហែល១៦ ឬ ១៧ ក្នុងឆ្នាំ១៩៧៥ ។ យឿម បានចូលបម្រើជាកងស្រួច ឬហៅម្យ៉ាងទៀតថា កងចល័ត ដែលមានយុវជន និងយុវនារីចូលរួមរាប់ពាន់នាក់ និងបានបែងចែកជាកង ឬជាក្រុមដាច់ពីគ្នា និងធ្វើការងារខុសគ្នា ។

យឿម មានស្រុកកំណើតនៅភូមិអូរទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងមានបងប្អូនប្រុសស្រី៧នាក់ (នៅរស់ទាំងអស់ក្រោយរបបខ្មែរក្រហម) ។ សព្វថ្ងៃ គាត់ជាប្រជាពលរដ្ឋរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ យឿម បានរៀបរាប់ថា គាត់បានចូលបម្រើក្នុងចលនាបដិវត្តន៍របស់ខ្មែរក្រហមដោយស្ម័គ្រចិត្ត ដោយដំបូងធ្វើជាសេនាជន ឬកងទ័ពឈ្លបនៅឆ្នាំ១៩៧៥ ។ យឿម បានបន្តថា មិនមែនមានតែស្រុកគាត់ទេ ដែលខ្មែរក្រហមជ្រើសរើសអ្នកស្ម័គ្រចិត្តឲ្យចូលសេនាជននោះ គឺខ្មែរក្រហមបានជ្រើសរើសអ្នកផ្សេងទៀត មកពីខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តសៀមរាប ។ ពេលនោះក្មេងៗក៏ ត្រូវបានខ្មែរក្រហមជ្រើសរើសដែរ ដោយយកទៅធ្វើការនៅតាមរោងចក្រ ឬនៅស្រែអំបិល ខាងខេត្តកំពត ។

យឿម បានឲ្យដឹងថា បន្ទាប់ពីចូលសេនាជនហើយ ខ្មែរក្រហមបានបញ្ជូនគាត់មកទីក្រុងភ្នំពេញ ដើម្បីបោសសម្អាតតាមផ្ទះដែលទើបតែរំដោះបានថ្មីៗ ។ យឿម បានស្នាក់នៅទីកន្លែងមួយជាប់នឹងវត្តភ្នំរយៈពេលមួយខែ ។ ក្រោយមក យឿម ត្រូវបានផ្លាស់ទៅធ្វើការនៅខេត្តក្រចេះវិញ ។ នៅខេត្តក្រចេះ យឿម បានទទួលការហ្វឹកហ្វឺនបច្ចេកទេសកងទ័ពរយៈពេលបីខែ ក្រោមការដឹកនាំរបស់ឈ្មោះ ណៃ ។ នៅពេលនោះ យឿម ក៏ដូចជាអ្នកដែលរស់នៅខាងភាគឦសានដែរ គឺទទួលបានរបបអាហារក្នុងមួយថ្ងៃបីពេល ព្រមទាំងមានបន្លែមហូបថែមទៀតផង ។ យឿម បានរំឭកទាំងចម្ងល់ថា គាត់បានឮប្រជាជននៅក្នុងភូមិនិយាយថា អ្នករស់នៅសមរភូមិក្រោយជួបការលំបាក ប៉ុន្តែចំពោះរូបគាត់វិញ គឺរស់នៅស្រួលមិនមានការខ្វះខាតអ្វីទេ មានទាំងសម្លៀកបំពាក់ និងការហូបចុក ជាពិសេស សម្បូរត្រីសាច់ហូបទៀតផង ។ នៅអំឡុងពេល យឿម ស្នាក់នៅខេត្តក្រចេះ អង្គការបានឲ្យក្រុមរបស់គាត់កាប់គាស់ព្រៃឈើដើម្បីរៀបចំធ្វើជាផ្លូវតភ្ជាប់ពីខេត្តក្រចេះ ទៅខេត្តមណ្ឌលគិរី ឬគេហៅថា ផ្លូវលេខ៧៥ ។



យឿម រៀបរាប់ពីប្រវត្តិតស៊ូក្នុងរបបខ្មែរក្រហមប្រាប់ដល់ ហែម ចិន្តា និស្សិតស្ម័គ្រចិត្តរបស់គម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានទៅចុះទៅធ្វើទស្សនកិច្ចសិក្សារយៈពេលបីថ្ងៃ នៅស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

បន្ទាប់ពីបានស្នាក់នៅខេត្តក្រចេះ អស់រយៈពេលបីខែមក យឿម ត្រូវបានអង្គការផ្លាស់ឲ្យទៅនៅខេត្តមណ្ឌលគិរី ដោយធ្វើដំណើរដោយថ្មើរជើងតាមផ្លូវលំលេខ៧៥ ស្ថិតនៅក្រោមការដឹកនាំរបស់គណៈតំបន់ និងគណៈភូមិភាគដែលពេលនោះឈ្មោះ ហម (បច្ចុប្បន្នស្លាប់) ។ ចំណែកអង្គភាពរបស់ យឿម ស្ថិតនៅក្រោមការដឹកនាំដោយផ្ទាល់របស់ឈ្មោះ វៀង ជាជនជាតិឡាវ (បច្ចុប្បន្ន ស្លាប់) ។

នៅពេលមកដល់ ខេត្តមណ្ឌលគិរី យឿម និងយុវជនដទៃទៀត ត្រូវបានចាត់តាំងឲ្យសាងសង់ផ្ទះ និងជំរំសម្រាប់ស្នាក់នៅ ដែលស្ថិតនៅក្នុងស្រុកពេជ្រាដា ឬអូរដាក់ដាំ តាមបណ្តោយព្រំដែនខ្មែរ-វៀតណាម ។ ពេលនោះ អង្គការឈប់ឲ្យ យឿម កាប់គាស់ព្រៃធ្វើផ្លូវដូចមុនទៀតហើយ តែខ្មែរក្រហមបានឲ្យគាត់ដាំដំណាំកប្បាសវិញ ដែលទទួលបានផលរាប់រយតោនក្នុងមួយឆ្នាំៗ ។

យឿម បានបន្តទៀតថា គាត់មិនដឹងអង្គការយកកប្បាសនោះទៅទីណា ឬយកធ្វើអ្វីនោះទេ ។ ក្រៅពីដាំដំណាំកប្បាស កងនីមួយៗត្រូវផ្លាស់ប្តូរគ្នារយៈពេលមួយខែម្តងទៅឈរជើងនៅសមរភូមិមុខនៅតាមព្រំដែនដើម្បីការពារទីតាំង ។ ក្រោយពេលរបបខ្មែរក្រហមត្រូវបានដួលរលំឆ្នាំ១៩៧៩ មេកងរបស់គាត់បានធ្វើការបំបែក ក្រុមគាត់ជាកងតូចៗទៀត ដោយស្នាក់នៅខេត្តមណ្ឌលគិរីដដែល ប៉ុន្តែត្រូវចល័តទីតាំង ។ យឿម រស់នៅក្នុងអង្គភាពរបស់គាត់ដដែល ស្ថិតនៅក្នុងព្រៃ ។

រហូតមកដល់ឆ្នាំ១៩៨២ ទើប យឿម ចាកចេញពីខេត្តមណ្ឌលគិរីមកភ្នំដងរែកវិញ ។ យឿន បានធ្វើដំណើរដោយថ្មើរជើងកាត់តាមព្រៃ ស្ទឹង ទន្លេ រយៈពេលអស់ជិតបីខែទើបមកដល់ភ្នំដងរែក ។ ការធ្វើដំណើរនៅពេលនោះ មានមនុស្សមួយចំនួនបានស្លាប់តាមផ្លូវដោយសារជំងឺ អត់អាហារ ពស់ចឹក និងគ្រោះថ្នាក់ផ្សេងៗទៀត ។ ក្នុងពេលនោះ ប្រធានកង ប្រធានភូមិភាគ បានធ្វើការទាក់ទងគ្នាដើម្បីសម្រួលដល់ប្រជាជនក្នុងការធ្វើដំណើរឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយទៀត ។

យឿម បានស្នាក់នៅលើភ្នំដងរែកចាប់ពីឆ្នាំ១៩៨២ រហូតដល់ឆ្នាំ១៩៨៥ ។ អំឡុងពេលនោះប្រជាជន ទាំងអស់ក៏ដូចជា យឿម ដែរ គឺត្រៀមខ្លួនប្រយុទ្ធជាមួយទាហានរបស់រដ្ឋាភិបាល ។ កងនារីៗត្រូវបានចាត់តាំងឲ្យដឹកជញ្ជូន កាំភ្លើង គ្រាប់បែកទៅឲ្យយុទ្ធជននៅសមរភូមិមុខ ។ សព្វាវុធទាំងនេះ យឿម មិនដឹងថា បានមកពីប្រទេសណាទេ ។ ចំណែកស្បៀងអាហារ និងសម្ភារប្រើប្រាស់មិនខ្វះទេពេលនោះ គឺក្នុងមួយខែ កងរបស់គាត់អាចបើកបានពីរទៅបីដង ។

ចាប់ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៩២ យឿម បានចូលទៅរស់នៅជំរំ ក្នុងខេត្តស៊ីសាកេត ប្រទេសថៃ ។ អំឡុងពេលរស់នៅទីនោះគាត់ទទួលរបបហូបចុកគ្រប់គ្រាន់ ចំណែករបស់របរមួយចំនួនគាត់ទទួលជំនួយពីប្រទេសថៃ ។ នៅចុងឆ្នាំ១៩៩២ យឿម បានចុះពីទឹកដីថៃមករស់នៅក្នុងតំបន់អន្លង់វែងវិញ ។ ពេលនោះ នៅតំបន់អន្លង់វែង ត្រូវបានបែងចែកជាពីរ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។ តំបន់១០០៣ គ្រប់គ្រងដោយ តាម៉ុក និងតំបន់១០០១ គ្រប់គ្រងដោយ សុន សេន ។ ចំណែក យឿម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ។ តែក្រោយមក ក៏មានការសម្លាប់ សុន សេន ព្រមទាំងគ្រួសាររបស់គាត់ ។ បន្ទាប់ពី សុន សេន ស្លាប់ យឿន និងប្រជាជនមករស់នៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់តា ម៉ុក វិញ ។ មកដល់ឆ្នាំ១៩៩៣ ជីវភាពរបស់ប្រជាជននៅអន្លង់វែងមិនខុសពីមុនទេ គឺប្រជាជនរស់នៅដោយសាររបប និងជំនួយ ។

ចាប់ពីឆ្នាំ១៩៩៣-ឆ្នាំ១៩៩៨ ការចរចាដើម្បីរកសន្តិភាពបានចាប់ផ្តើម ចំណែកយោធាខ្មែរក្រហមដែលនៅសេសសល់មួយចំនួនបានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ។ ពេលនោះ យឿម បានផ្លាស់ប្តូរទីលំនៅមកត្រពាំងប្រាសាទវិញ ដោយបានរៀបចំគ្រួសារ និងជីវភាពថ្មី ។ សព្វថ្ងៃ យឿម មានកូនចំនួន៨នាក់ (ស្រី៤នាក់ និងប្រុស៤នាក់) ។

យឿម បានមានប្រសាសន៍ថា គាត់មិនចង់ឲ្យប្រទេសជាតិកើតមានសង្គ្រាមជាថ្មីម្តងទៀតទេ ព្រោះសង្គ្រាមធ្វើឲ្យគាត់ និងប្រជាជនលំបាកវេទនា ។ គាត់ក៏ចង់ឲ្យអ្នកជំនាន់ក្រោយបានសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ប្រទេសកម្ពុជាកន្លងមក ។

**ហែម ចិន្តា**

# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# អ្វីៗដើម្បីអង្គការ

ធា រាន មានអាយុ៥៨ឆ្នាំ ជាអតីតកងចល័ត នៅក្នុងរបបខ្មែរក្រហម ។ សព្វថ្ងៃ រានរស់នៅភូមិ១០៥ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ មានមុខរបរជាអ្នកធ្វើស្រែចម្ការ រាន មានស្រុកកំណើតនៅភូមិសៀមប៉ាង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ។



ចាន់ លីខា គរុនិស្សិតស្ម័គ្រចិត្ត បានចុះធ្វើទស្សកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ខេត្តឧត្តរមានជ័យ

នៅក្នុងឆ្នាំ១៩៧៥ រាន ត្រូវបានខ្មែរក្រហមជម្លៀសទៅភូមិផុនយ៉ាងណាង ចំណែកក្រុមគ្រួសាររបស់គាត់បានជម្លៀសទៅភូមិផ្សេងទៀតស្ថិតក្នុងខេត្តស្ទឹងត្រែង ។ កាលនោះ រាន ដែលទើបមានអាយុ១៧ឆ្នាំ ត្រូវបានយោធាខ្មែរក្រហមចាត់តាំងឲ្យធ្វើការក្នុងកងចល័ត និងមានភារកិច្ចកាប់ដី រែកដី លើកទំនប់ ជាមួយសមាជិកក្នុងកងដែលមានចំនួនចាប់ពី១០០នាក់ ទៅ២០០នាក់ ហើយត្រូវធ្វើការចាប់ពីម៉ោង៧ព្រឹក ដល់ម៉ោង១២ថ្ងៃត្រង់ និងពីម៉ោង១២ ដល់ម៉ោង១០យប់ ។ ចំពោះរបបអាហារវិញ ខ្មែរក្រហមចែកជាបីផ្នែក ៖ កម្លាំងទី១ ៈ ទទួលបានបាយមួយចានចង្កឹះ សម្រាប់មនុស្សចាស់ដែលធ្វើការងារច្រើន កម្លាំងទី២ ៈ ទទួលបានបាយមួយចានតូច សម្រាប់អ្នកធ្វើការចល័ត ជួយការងារផ្សេងៗតាមការចាត់តាំងរបស់ប្រធានកង និងកម្លាំងទី៣ ៈ គឺក្មេងតូចៗដើររើសអាចម៍គោ និងបោចស្មៅ និងធ្វើការងារណាដែលស្រាលៗ ។

ពេលខ្លះ ចុងភៅបានដាំបាយលាយជាមួយនឹងដើមចេកត្រកួនឲ្យហូប ។ ចំណែកការងារ ខ្មែរក្រហមមានការរឹតបន្តឹងយ៉ាងខ្លាំង ព្រោះមានកម្មាភិបាលពីរបីទៅបួននាក់ចាំឃ្លាំមើល ហើយប្រសិនបើនរណាម្នាក់ធ្វើការយឺតយ៉ាវ ឬមិនសកម្មការងារ នឹងត្រូវរងការស្ដីបន្ទោសពីសំណាក់កម្មាភិបាលនោះមិនខាន ។ ទោះបីយ៉ាងណា រាន កម្រនឹងទទួលការការស្ដីបន្ទោសពីប្រធានកងណាស់ ព្រោះគាត់ខំស្វាហ៍ព្យាយាម ។ ប៉ុន្តែមានពេលមួយ បន្ទាប់ពីរែកដីពេញមួយថ្ងៃ និងអស់កម្លាំងខ្លាំង រាន បានទៅលួចដំឡូង និងចេកដែលដាំនៅចម្ការ ក៏ត្រូវកម្មាភិបាលតាមទាន់ និងអប់រំគាត់កុំឲ្យលួចទៀត ព្រោះអ្វីៗទាំងអស់ជារបស់អង្គការ ។ កម្មាភិបាលនោះបានប្រាប់ រាន ថា លើកនេះ អង្គការលើកលែង តែបើចាប់បាននៅពេលក្រោយទៀត នឹងមិនអត់ឱនទេ ។ ចាប់ពីពេលនោះមក រាន មិនហ៊ានលួចទេ ទោះបីជាឃ្លានខ្លាំងយ៉ាងណាក៏ដោយ ព្រោះខ្លាចអង្គការដាក់ទណ្ឌកម្ម ។

អំឡុងរបបខ្មែរក្រហម រាន មិនដែលឃើញខ្មែរក្រហមធ្វើទារុណកម្ម ឬកាប់សម្លាប់មនុស្សទេ គឺគាត់ឃើញតែការស្ដីបន្ទោសពីសំណាក់ប្រធានកងប៉ុណ្ណោះ ។ គាត់ត្រូវក្រោកធ្វើការងារចាប់ពីព្រឹកព្រលឹមស្រាងៗ ដោយដៃទាំងពីរកាន់បង្គី ក្រមារុំខ្លួនរួចដើរតម្រង់ទៅកន្លែងធ្វើការដែលបានបែងចែកការងាររួចជា

ស្រេច ហើយមុននឹងទៅធ្វើការ មានកម្មាភិបាលម្នាក់មកប្រាប់ឲ្យគ្រប់គ្នាត្រូវមានភាពស្វាហាប់មិនត្រូវស្ពឹកស្រពន់ ធ្វើការឲ្យអស់ពីចិត្ត និងស្មោះត្រង់ចំពោះអង្គការ "ព្រោះអង្គការជាឪពុកម្តាយ" និងជាអ្នកមើលការខុសត្រូវ ។ កម្មាភិបាលនោះនិយាយចប់ សមាជិកកងគ្រប់គ្នា រួមទាំង រាន ទៅកន្លែងធ្វើការរៀងៗខ្លួន ។ ការងាររាល់ថ្ងៃ ភាគច្រើនជាការងារជីកដីដែលៗធ្វើឲ្យ រាន ហេវហត់អស់កម្លាំងជាខ្លាំង ព្រោះមិនមានអាហារហូបគ្រប់គាន់ ។ ពេលខ្លះ រាន គិតថា បើមានអាហារឆ្ងាញ់ នឹងចង់ហូបឲ្យឆ្អែតម្តង ព្រោះគាត់ខានបានហូបម្ហូបឆ្ងាញ់យូរមកហើយ តែគាត់បានត្រឹមស្រមៃប៉ុណ្ណោះ ។ រាន មិនអាចបំភ្លេចបានពីអារម្មណ៍ស្រេកឃ្លាន និងការរស់នៅក្នុងសភាពភ័យខ្លាចទេ ។ អង្គការបានបំបិតសិទ្ធិគាត់គ្រប់បែបយ៉ាង សូម្បីការប្រតិបត្តិលើជំនឿសាសនា និងហាមមិនឲ្យមានកម្មសិទ្ធផ្ទាល់ខ្លួន ។ គាត់មិនដែលទទួលបានការអប់រំ ហើយជីវិតរបស់គាត់រស់នៅដោយគ្មានគោលដៅ ។

មានថ្ងៃមួយ ពេល រាន កំពុងធ្វើការ គាត់បានឃើញឡានដឹកជញ្ជូនស្រូវចេញទៅ តែគាត់មិនដឹងថាដឹកយកទៅកន្លែងណាទេ ។ ពេលនោះ គាត់បានត្រឹមឆ្ងល់ តែមិនហ៊ាននិយាយ ឬសួរអ្នកណាឡើយ ។ ប្រហែលខែតុលា ឆ្នាំ១៩៧៥ អង្គការប្រកាសរៀបចាំកម្មវិធីរៀបការឲ្យប្រជាជន ដោយរៀបចាំពី៥០គូ ទៅ១០០គូ ។ អង្គការឲ្យប្រុសៗឈរម្ខាង ស្រីឈរម្ខាង នៅទល់មុខគ្នា រួចហើយអង្គការឲ្យខាងប្រុសនិងខាងស្រីចាប់ដៃគ្នា និងឡើងប្តេជ្ញាចិត្តនៅចំពោះមុខគណអធិបតី ដោយសន្យាថា នឹងរួមរស់ជាមួយគ្នា និងស្មោះត្រង់ចំពោះអង្គការ ។ ចំពោះពិធីរៀបការ គឺមានលក្ខណៈខុសប្លែកពីប្រពៃណីខ្មែរទាំងស្រុង គឺគ្មានភ្លេង សម្លៀកបំពាក់ប្រពៃណី គ្មានឪពុកម្តាយ មេបាទាំងសងខាងចូលរួមឡើយ ។ ប្តីប្រពន្ធខ្លះមិនស្គាល់គ្នាពីមុនមកទេ គឺអ្វីៗទាំងអស់ស្រេចលើអង្គការជាអ្នកចាត់ចែង ហើយបើនរណាម្នាក់មិនពេញចិត្ត ក៏មិនហ៊ានប្រកែកដែរ ព្រោះខ្លាចអង្គការចោទថា ប្រឆាំង ។ ពេលនោះ រាន មិនត្រូវបានបង្ខំឲ្យរៀបការទេ ព្រោះគាត់ទើបមានអាយុ១៧ឆ្នាំប៉ុណ្ណោះ ។

រាន បន្តធ្វើការក្នុងកងចល័ត រហូតដល់ឆ្នាំ១៩៧៧ ទើប



រូបខាងឆ្វេង ៖ តា រាន បានផ្តល់បទសម្ភាសពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម ដល់ ចាន់ លីខា គរុនិស្សិតស្ម័គ្រចិត្តរបស់គម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានទៅចុះទៅធ្វើទស្សនកិច្ចសិក្សារយៈពេលបីថ្ងៃ នៅស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

អង្គការផ្លាស់ឲ្យទៅលើកទំនប់អូរនោង ។ ពេលនោះមានសមាជិកសរុបទាំងអស់ប្រមាណ២០០នាក់ ដោយបែកចែកជាក្រុមក្នុងមួយក្រុម មានគ្នា១២នាក់ មានប្រុសស្រីនៅលាយឡំគ្នា ។ អង្គការបានបែងចែកការងារឲ្យសមាជិក ដោយក្នុងម្នាក់ជីកដីឲ្យបានពីរទៅបីម៉ែត្រគូប ។ ចំពោះការងារថ្មីនេះរឹតតែធ្វើឲ្យ រាន ពិបាក ព្រោះរែកដីកាន់តែច្រើនជាងមុន ហើយដោយសារគាត់នឹករឭកឪពុកម្តាយ និងបងប្អូនទៀត ទើបធ្វើឲ្យគាត់ស្គមស្គាំង និងស្លេកស្លាំង ។ ចំពោះការងារលើកទំនប់នៅអូរនោងនោះ បានបញ្ចប់ក្នុងរយៈពេល៦ខែ អង្គការបានផ្លាស់គាត់ឲ្យមកធ្វើការក្នុងចល័តរហូតដល់ឆ្នាំ១៩៧៩ ។

ពេលនោះ ក្រុមគ្រួសារ រាន បានរត់ភៀសខ្លួនមកដល់ភ្នំដងរែក ។ ទោះបីប្រទេសជាតិត្រូវបានរំដោះ ហើយក៏ដោយ ក៏សង្គ្រាមស៊ីវិលរវាងកងទ័ពវៀតណាម និងខ្មែរក្រហមនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ នៅតែបន្ត ហើយប្រជាជនបានរត់គេចខ្លួនចេញពីតំបន់មួយ ទៅតំបន់មួយទៀតតាមបណ្តោយភ្នំដងរែក ។ ប្រជាជនមួយចំនួនបានជាន់មីនស្លាប់ និងអ្នកខ្លះទៀតកើតជំងឺអាសន្នរោគ អ្នកខ្លះត្រូវពស់ចឹក សត្វល្អិតខាំ ហើយប្រជាជនជាច្រើនទៀតស្លាប់ដោយសារជំងឺគ្រុនចាញ់ ។ រាន បានបន្តរស់នៅភ្នំដងរែក រហូតបានស្គាល់បុរសម្នាក់ដែលជម្លៀសមកពីខេត្តកំពត ។ ក្រោយមក គាត់ទាំងពីរបានស្រឡាញ់គ្នា និងបានរៀបការហើយរស់នៅជាមួយគ្នាមានកូនចំនួន៥នាក់ ។

រាន បានរៀបរាប់ថា ស្ថានភាពរស់នៅទីនោះមានការលំបាកខ្លាំងណាស់ ព្រោះបើដើរមិនប្រយ័ត្ននឹងត្រូវជាន់មីន ។ គាត់មិនហ៊ានចូលក្នុងភូមិទេ ព្រោះឮពាក្យនិយាយតគ្នាថា ទាហ៊ានវៀតណាមចាប់រំលោភ និងសម្លាប់ចោល បើចាប់បាន ។ នៅពេលឮស្នូរកាំភ្លើងម្តងៗ រាន តែងបន់ស្រន់ដល់គុណមាតាបិតា អ្នកតាថែរក្សាម្ចាស់ទឹកម្ចាស់ដីឲ្យជួយថែរក្សាការពារគាត់ ព្រោះគាត់បានឃើញមនុស្សជាច្រើនស្លាប់នៅចំពោះមុខ ។ រាន ក៏ធ្លាប់បានសែងមនុស្សស្លាប់យកទៅកប់ដែរ ។ ចំណែកប្តីរបស់ រាន ជាកងទ័ពនៅសមរភូមិមុខ ។ ចំពោះស្បៀងអាហារ ដូចជា អង្ករ ត្រីងៀត ទឹកត្រី ស្ករស ប្រហុក រាន បានបើកពីមេក្រុម ព្រោះមេក្រុមបានទៅបើកផ្ទាល់ពីឃ្លាំងសម្ភារ តែឃ្លាំងនោះមិននៅមួយកន្លែងទេ គឺត្រូវផ្លាស់ទីជាប្រចាំ ។

ការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហម បានកើតឡើងជាញឹកញាប់ ហើយប្តីរបស់ រាន បានរត់ជាន់មីនផ្ទុះដាច់ជើងក្នុងអំឡុងពេលវាយប្រយុទ្ធគ្នា ធ្វើឲ្យ រាន តក់ស្លុតជាខ្លាំង ។ ចាប់ពីពេលនោះមក រាន ត្រូវទទួលបន្ទុកថែមមួយកម្រិតទៀតក្នុងការចិញ្ចឹមកូន រហូតដល់ឆ្នាំ១៩៩០ ។

នៅឆ្នាំ១៩៩០ ខ្មែរក្រហមបានឲ្យប្រជាជនចុះពីភ្នំដងរែកមកនៅក្នុងភូមិវិញ ពេលនោះ រាន រួមជាមួយ កូន និងប្តីបានមកនៅក្នុងឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ រាន បានរស់នៅឃុំលំទងរហូតដល់ឆ្នាំ១៩៩៥ តែដោយសារសង្គ្រាមនៅតែបន្តកើតមាន គាត់ និងប្រជាជាច្រើនទៀត បានមករស់នៅតាមមូលដ្ឋានកងទ័ព តាមបណ្តោយព្រំដែនខ្មែរ-ថៃ និងបានផ្លាស់ទៅរស់នៅតាមជំរំជនភៀសខ្លួនវិញ ។ រាន និង គ្រួសារបានរស់នៅក្នុងជុំរំភូណយ ប្រទេសថៃ បានរយៈពេលបីឆ្នាំ រហូតដល់សង្គ្រាមត្រូវបានបញ្ចប់បន្ទាប់ពីមានការបោះឆ្នោតនៅឆ្នាំ១៩៩៨ ទើបគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ ។

នៅឆ្នាំ១៩៩៩ រាន បានមករស់នៅក្នុងឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យជាមួយកូនរបស់គាត់សរុបទាំងអស់៩នាក់ រួមជាមួយប្តីពិការ ។ ចំណែកឪពុកម្តាយ និងបងប្អូន៩នាក់របស់គាត់ នៅរស់រានមានជីវិត និងរស់នៅក្នុងស្រុកកំណើតនៅខេត្តស្ទឹងត្រែង ។ ទោះបីយ៉ាងណា នៅពេលបច្ចុប្បន្ន រាន មិនមានបំណង ទៅរស់នៅខេត្តស្ទឹងត្រែងទេ ព្រោះគាត់យល់ថា គាត់បានសុខសប្បាយ ហើយប្រទេសមានសន្តិភាពហើយ ។ គាត់អាចរស់នៅជួបជុំកូននិងប្តី និងអាចធ្វើស្រែចម្ការចិញ្ចឹមជីវិតបាន ហើយកូនៗរបស់គាត់ក៏មានគ្រួសារនៅទីនេះដែរ ។

រាន បាននិយាយថា អ្វីៗប្រៀនដូចជាសុបិនមួយដ៏អាក្រក់ ដែលនៅតែវិលវល់ៗក្នុងចិត្តរបស់គាត់ ។ គាត់បានចងចាំនូវហេតុការណ៍ដ៏ឈឺចាប់ និងលំបាកទោះបីជាបានកន្លងផុតយូរឆ្នាំហើយក៏ដោយ ។ រាន ចង់ឲ្យមានការចងក្រងនូវប្រវត្តិសាស្ត្រដ៏ជូរចត់នេះទុកឲ្យក្មេងជំនាន់ក្រោយៗសិក្សាស្វែងយល់ និងបញ្ចៀសកុំឲ្យកើតមានរបបនេះម្តងទៀត ។

**ចាន់ លីខា**

# ការមិនបានរៀនសូត្រពីរឿងរ៉ាវឪពុកម្តាយ នៅតែជាការបារម្ភ

ស្ថិតនៅក្នុងវ័យ៥៩ឆ្នាំ អ្នកគ្រូ គូ ម៉ារិន មានទីកំណើតនៅខេត្តកំពង់ស្ពឺ ។ ក្នុងនាមជានាយិការងវិទ្យាល័យ ហ៊ុន សែន ព្រែកកំពឹស និងជាគ្រូបង្រៀនប្រវត្តិវិទ្យា-ភូមិវិទ្យា អ្នកគ្រូ ម៉ារិន នៅតែព្រួយបារម្ភថា អំពើឃោរឃៅដូចរបបខ្មែរក្រហមអាចនឹងកើតឡើងម្តងទៀត ប្រសិនបើយុវជនជំនាន់ក្រោយមិនត្រូវបានបង្រៀន និងអប់រំអំពីរបបខ្មែរក្រហម ។ អ្នកគ្រូ ម៉ារិន លើកឡើង អំពីកង្វល់របស់គាត់ ដោយសារតែយុវជនជំនាន់ក្រោយមួយចំនួនហាក់ដូចជាព្រងើយកន្តើយនឹងរឿងរ៉ាវដែលឪពុកម្តាយ ឬអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិយាយប្រាប់ ។ ហេតុដូច្នេះ អ្នកគ្រូ ម៉ារិន សំណូមពរឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្តបណ្តុះបណ្តាលការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងថែរក្សាភស្តុតាងទាំងឡាយដើម្បីទុកជាមេរៀនដល់មនុស្សជំនាន់ក្រោយ ។

អ្នកគ្រូ ម៉ារិន បានរម្លឹកប្រាប់អំពីប្រវត្តិរបស់គាត់ថា គាត់បានកើតនៅក្នុងគ្រួសារមួយ ដែលមានឪពុកជាអតីតទាហានបម្រើការឲ្យសម្តេចព្រះនរោត្តម សីហនុ និងមានបងប្អូនបង្កើតប្រាំនាក់ ។ នៅពេលដែលស្ថានភាពប្រទេសកម្ពុជាស្ថិតក្នុងភាពច្របូកច្របល់ ឪពុករបស់អ្នកគ្រូ ម៉ារិន បាននាំក្រុមគ្រួសារធ្វើដំណើរចេញពីស្រុកកំណើតទៅស្នាក់អាស្រ័យជាមួយថ្នាក់លើរបស់គាត់ ដែលជានាយ



រូបខាងឆ្វេង ៖ អ្នកគ្រូ គូ ម៉ារិន នាយិការងវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ព្រែកកំពឹស បាននិយាយប្រាប់សិស្សានុសិស្សដោយសង្ខេបពីរបបខ្មែរក្រហម មុនពេលដែលសិស្សានុសិស្សទាំងនេះ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលរៀបចំដោយគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទាហានជាន់ខ្ពស់នៅទីក្រុងភ្នំពេញ នៅម្តុំទួលគោក ។ ជាអកុសល នៅដើមឆ្នាំ១៩៧៥ នៅពេលដែលសភាពការណ៍នៅទីក្រុងកាន់តែអាក្រក់ ម្តាយរបស់អ្នកគ្រូ ម៉ារិន បានបាត់បង់ជីវិតដោយសារគ្រាប់ផ្លោងចូលទីក្រុងនៅម្តុំទួលគោក នៅពេលដែលគាត់ធ្វើដំណើរទៅផ្សារ ។ នៅពេលនោះ អ្នកគ្រូ ម៉ារិន កំពុងរៀនថ្នាក់ទី១០ នៅវិទ្យាល័យបឹងកក់ ។

បន្ទាប់មក នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់អ្នកគ្រូ ម៉ារិន ដែលនៅសល់គ្នាប្រាំមួយនាក់ត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះទៅស្រុកកំណើតវិញ ។ ឪពុករបស់អ្នកគ្រូ ម៉ារិន មិនបានណែនាំឲ្យកូនៗរបស់គាត់យករបស់របរតាមខ្លួនច្រើននោះឡើយ សូម្បីតែធាតុរបស់ម្តាយគាត់ ដោយសារតែនៅពេលនោះ ខ្មែរក្រហមបានប្រាប់ថា ឲ្យចាកចេញតែពីរបីថ្ងៃប៉ុណ្ណោះ ។ ឪពុករបស់អ្នកគ្រូ ម៉ារិន ប្រមូលត្រឹមតែគ្រឿងអលង្ការ និងសំលៀកបំពាក់ប៉ុន្មានសម្រាប់ប៉ុណ្ណោះ ។ ក្រុមគ្រួសាររបស់អ្នកគ្រូ ម៉ារិន បានធ្វើដំណើរតាមផ្លូវជាតិលេខ៣ សំដៅទៅស្រុកកោះធំ ខេត្តកណ្តាល ព្រោះឪពុករបស់អ្នកគ្រូ មានបងប្អូនរស់នៅទីនោះ ។ ប៉ុន្តែ ដោយសារតែសាវតាររបស់ក្រុមគ្រួសារអ្នកគ្រូ ម៉ារិន ជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ គាត់ត្រូវបានបញ្ជូនបន្តទៅរស់នៅស្រុកលើកដែក ខេត្តកណ្តាល ។

ពេលទៅដល់ស្រុកលើកដែកដំបូង អ្នកគ្រូ ម៉ារិន បាននិយាយថា ខ្មែរក្រហមបានរៀបចំឲ្យរស់នៅជាលក្ខណៈក្រុមសាមគ្គី ។ ទៅដល់ទីនោះ ក្រុមគ្រួសាររបស់អ្នកគ្រូ ម៉ារិន តម្រូវឲ្យសង់ផ្ទះដោយខ្លួនឯង ។ ឪពុកគាត់បានលើកផ្ទះមួយខ្នងដែលមានជណ្តើរបីកាំផុតពីដី ។ ចំណែកឯរបបអាហារវិញ ខ្មែរក្រហមបានចែកអង្ករពីរកំប៉ុងក្នុងមួយគ្រួសារ ។ របបនោះមិនគ្រប់គ្រាន់ទេដូច្នេះ អ្នកគ្រូ ម៉ារិន បានដាំលាយជាមួយគល់ល្ហុង ។ មិនយូរប៉ុន្មាន ខ្មែរក្រហមចាប់ផ្តើមបំបិទសិទ្ធិប្រជាជន និងបំបែកប្រជាជនឲ្យរស់នៅ និងធ្វើការតាមកងរៀងៗខ្លួន ។ ដំណាំដែលដុះនៅជុំវិញផ្ទះ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយកមកហូបជាលក្ខណៈឯកជនទៀតទេ ។ ឪពុករបស់អ្នកគ្រូ ម៉ារិន ត្រូវបានអង្គការបញ្ជូនឲ្យធ្វើការនៅក្នុងកងផ្សេង ។ រីឯអ្នកគ្រូ ម៉ារិន ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងកងនារី ។

មិនយូរប៉ុន្មាន អ្នកគ្រូ ម៉ារិន ត្រូវបានខ្មែរក្រហមចាប់ដាក់មន្ទីរសន្តិសុខស្រុកលើកដែក ដែលនៅទីនោះអ្នកគ្រូបានជាប់ឃុំនៅក្នុងរោងសង់អំពីឈើមួយជាមួយអ្នកទោសស្រ្តីមួយចំនួនផ្សេងទៀតប្រហែលជា៥០ ទៅ៦០នាក់ ។ ចំណែកឯអ្នកទោសបុរសត្រូវបានឃុំនៅរោងមួយផ្សេងទៀត ។ អ្នកគ្រូ ម៉ារិន បានលើកឡើងថា គាត់ត្រូវបានខ្មែរក្រហមចោទប្រកាន់ថាអ្នកចេះដឹង ព្រោះចេះអានអក្សរ ។ អ្នកទោសដែលត្រូវបានចាប់មកឃុំឃាំងនៅទីនោះ ភាគច្រើនជាកូនអ្នកមូលធន អ្នកដែលរៀនចេះដឹង អ្នកដែលបានប្រព្រឹត្តកំហុសឆ្គងដូចជាធ្វើឲ្យបាត់ប៉ែល បាត់ចប ឬបាត់កណ្តៀវជាដើម ។

នៅក្នុងមន្ទីរសន្តិសុខនោះ ខ្មែរក្រហមមិនបានដាក់ឃុំអ្នកទោសនៅពេលថ្ងៃនោះទេ ពោលគឺ ខ្មែរក្រហមបានបញ្ជូនអ្នកទោសចេញក្រៅឲ្យទៅធ្វើការនៅតាមការដ្ឋានផ្សេងៗ ។ លុះដល់ព្រលប់ទើប បញ្ជូនត្រឡប់មកវិញ ។ នៅក្នុងរោងឃុំឃាំង អ្នកទោសត្រូវបានខ្មែរក្រហមដាក់ច្រវ៉ាក់ជើងជាជួរ ដោយភ្ជាប់ជាមួយរណុកដែកវែងមួយ និងសម្រាកនៅលើដី ។ អ្នកគ្រូ ម៉ារិន បានបញ្ជាក់ថា ប្រសិនបើជើងរបស់អ្នកទោសរូបណាហើម នោះរណុកដែកប្រាកដជាប៉ះដាច់សាច់ជាមិនខាន ។ ចំណែករបបអាហារវិញ អង្គការបានចែកបបរ ឬពោតស្ងោរម្នាក់មួយវែក ។

នៅថ្ងៃមួយ នៅពេលដែលអ្នកគ្រូ ម៉ារិន សម្រាកពេលយប់ គាត់ត្រូវសត្វក្អែបខាំហើមជើង ហេតុដូច្នេះ អ្នកគ្រូត្រូវបានអនុញ្ញាតឲ្យសម្រាក ដោយសារតែគាត់មិនអាចដើបទៅធ្វើការបាន ។ ប៉ុន្តែ អង្គការបានយកកន្ត្រៃមកកាត់សក់អ្នកគ្រូនៅពេលគាត់សម្រាកនៅក្នុងរោង ។ ត្បិតអ្នកគ្រូ អៀនខ្មាស់ គាត់បានយកក្រមាមកគ្របក្បាល ដើម្បីកុំឲ្យគេឃើញសក់ដាច់រញ៉េរញ៉ៃ ។ នៅពេលដែលពិសាបាយថ្ងៃត្រង់ ខ្មែរក្រហមបានបញ្ជាឲ្យអ្នកគ្រូដោះក្រម៉ារុំក្បាលចេញនៅមុខអ្នកទោសដទៃជាច្រើន ។ នៅពេលឃើញសភាព ដូច្នោះ ខ្មែរក្រហមនាំគ្នាសើចចម្អកឲ្យអ្នកគ្រូដែលធ្វើឲ្យគាត់មានភាពអាម៉ាស់ជាខ្លាំង ។ ជាអកុសល អ្នកគ្រូមិនអាចធ្វើអ្វីឆ្លើយតបវិញបាននោះទេ ។ អ្នកគ្រូបានត្រឹមតែទ្រាំតែប៉ុណ្ណោះ ។ អ្នកគ្រូបាននិយាយថា ប្រសិនបើមានជនណាម្នាក់ជួយអ្នកគ្រូឲ្យរួចរស់ជីវិតពីរបបខ្មែរក្រហម អ្នកគ្រូស្ម័គ្រចិត្តនៅតាមបម្រើជននោះអស់មួយជីវិត ដោយសារតែភាពលំបាកវេទនាទាំងផ្លូវកាយ ទាំងផ្លូវចិត្តដែលខ្មែរក្រហម

បានប្រព្រឹត្តមកលើរូបអ្នកគ្រូ ។

អ្នកគ្រូ ម៉ារិន ក៏បានរម្លឹកដែរថា នៅពេលដែលគាត់ជាប់ឃុំឃាំងនារីម្នាក់ដែលសម្រាកនៅក្បែរត្រូវបានខ្មែរក្រហមសម្លាប់នៅនឹងមុខអ្នកទោសដទៃទៀត ដោយសារតែនារីម្នាក់នោះបានលួច ដំឡូងយកមកហូប ។ មុននឹងសម្លាប់នារីម្នាក់នោះ ខ្មែរក្រហមបានចាប់គាត់ចងនឹងដើមស្វាយនៅក្បែរដើមអំពិលបារាំងមួយដើម ។ បន្ទាប់មក ខ្មែរក្រហមបានយកកាំបិតដែលខ្ទួនលីនៅលើស្មាមកវាយក្បាលនារីម្នាក់នោះរហូតដល់ស្លាប់ ។

ជាកុសល កងទ័ពរណសិរ្សបានចូលមកដល់ អ្នកគ្រូ ម៉ារិន បានរត់ត្រឡប់មកផ្ទះរបស់ម្ដាយមីងគាត់វិញ ។ នៅទីនោះអ្នកគ្រូបានជួបជុំបងប្អូនបង្កើត និងឪពុករបស់គាត់វិញ ។ ឪពុករបស់អ្នកគ្រូ ម៉ារិន បានរៀបរាប់ប្រាប់អ្នកគ្រូថា គាត់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅធ្វើការនៅភូមសំណរ នៅក្នុងកងមនុស្សចាស់ ។ មុនពេលដែលរបបខ្មែរក្រហមដួលរលំ គាត់ត្រូវបានបញ្ជាឲ្យឡើងទៅកាប់ឫស្សី ។ ដោយមិនបានប្រុងប្រយ័ត្ន ឪពុករបស់អ្នកគ្រូបានធ្លាក់ពីដើមឫស្សីបណ្ដាលឲ្យគាត់ក្លាយ ជាជនពិការមិនអាចដើរបាន ។ នៅឆ្នាំ២ ០ ០ ៦ ឪពុកអ្នកគ្រូបានទទួលមរណភាព ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ អ្នកគ្រូ ម៉ារិន បានស្ម័គ្រចូលបម្រើការជាគ្រូបង្រៀន នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៩ នៅស្រុកលើកដែក ។ អ្នកគ្រូមានចិត្តស្រឡាញ់មុខរបរជាគ្រូបង្រៀនតាំងពីតូចមកម្ល៉េះ ។ ហេតុដូច្នេះហើយនៅពេលដែលមានការជ្រើសរើសប្រមូលអ្នកចេះដឹង អ្នកគ្រូក៏បានចុះឈ្មោះចូលបង្រៀន ។ នៅពេលនោះ អ្នកគ្រូមិនបានទទួលប្រាក់ឧបត្ថម្ភអ្វីនោះទេ ក្រៅអំពីអង្ករស្រូវ ប្រេងឆា និងសាប៊ូជាការតបស្នងមកវិញ ។ អ្នកគ្រូរម្លឹកថា នៅពេលដែលអ្នកគ្រូចាប់ផ្ដើមបង្រៀនដំបូង មិនមានថ្នាក់រៀនត្រឹមត្រូវនោះទេ ។ សិស្សរៀននៅក្រោមម្លប់ឈើ ។ ដោយសារការខិតខំប្រឹងប្រែង អ្នកគ្រូត្រូវបានចាត់តាំងឲ្យក្លាយជានាយិការងសាលាបឋមសិក្សាបឹងកណ្ដាល នៅឃុំក្បាលទា ស្រុកលើកដែក ខេត្តកណ្ដាល ។ នៅទីនោះ អ្នកគ្រូបានរៀបការ និងបានកូនស្រីមួយ ។ បន្ទាប់មកអ្នកក៏បានបែកពីប្ដីរបស់គាត់ ។

នៅឆ្នាំ១៩៩៥ អ្នកគ្រូបានផ្លាស់មករស់នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដោយសារតែកូនស្រីរបស់គាត់ត្រូវបន្តការសិក្សាថ្នាក់វិទ្យាល័យនៅវិទ្យាល័យតាខ្មៅ ។ ដើម្បីការសិក្សារបស់កូនស្រីអ្នកគ្រូក៏បានសុំអ្នកស្គាល់គ្នាម្នាក់ដែលជាចៅកែឡស្នាក់អាស្រ័យ ។ អ្នកគ្រូបានដាក់ពាក្យបង្រៀននៅអនុវិទ្យាល័យព្រែកកំពឹស ។ ទំនេរពីការបង្រៀន អ្នកគ្រូបានជួយការងារម្ចាស់ផ្ទះដែលអនុញ្ញាតឲ្យគាត់ និងកូនស្រីស្នាក់នៅជាមួយ ។

សព្វថ្ងៃ អ្នកគ្រូ ម៉ារិន គឺជានាយិការងវិទ្យាល័យ ហ៊ុន សែន ព្រែកកំពឹស ។ ឆ្នាំក្រោយ ឆ្នាំ២ ០ ១៨ អ្នកគ្រូនឹងចូលនិវត្តន៍ ។ អ្នកគ្រូសង្ឃឹមថា ក្មេងជំនាន់ក្រោយនឹងមិនបំភ្លេចរឿងរ៉ាវដែល បានកើតឡើងនៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ អ្នកគ្រូ ម៉ារិន យល់ឃើញថា ការសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាការទប់ស្កាត់ប្រវត្តិសាស្ត្រប្រចាំដែល និងការទប់ស្កាត់មិនឲ្យមានការសងសឹកគ្នា ដោយសារតែការសម្លាប់គ្នា តែងតែនាំមកនូវផលវិនាសដល់ប្រទេស និងសង្គមជាតិ ។ **ម៉ែន ពិចិត្រ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការបង្រៀន ប្រ
# នៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ព្រៃក










# ទក្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នកំពីស កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧









# គេហទំព័រទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

*ទស្សនាវដ្តីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។*

*គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្តីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។*

*គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។*

*អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើងដោយស្ទេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទ្បើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលផ្តើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្តល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យ ដើម្បីសេចក្តីសុខក្នុងខ្លួនជាអមតៈដែរ ។*

*សរុបសេចក្តីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ផ្ញើសេចក្តីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទ មុនការចេញផ្សាយ ។*

*គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។*

# ក្មួយប្រុសរបស់ ប៉ុល ពត ចូលផ្តល់សក្ខីកម្ម

*សេង លីថេង (សាក្សី) ដែលត្រូវជាក្មួយប្រុសរបស់ ប៉ុល ពត និងមានតួនាទីជាកងការពារ បានចូលផ្តល់សក្ខីកម្ម ។ លោកបានប្រាប់តុលាការពីទំនាក់ទំនងរបស់លោកជាមួយ មេដឹកនាំជាន់ខ្ពស់ ដូចជា ប៉ុល ពត, ខៀវ សំផន, នួន ជា និង អៀង សារី ។ ដំបូង លោកត្រូវបានគេចាត់តាំងឲ្យទទួលស្វាគមន៍ភ្ញៀវពីភូមិភាគនានា និងគណៈប្រតិភូបរទេស ហើយក្រោយមកលោកត្រូវបានគេចាត់តាំងឲ្យធ្វើជាសន្តិសុខនៅមន្ទីរក-១ ។*

## ក្មួយប្រុសរបស់ ប៉ុល ពត

*សេង លីថេង (2-TCW-287) បានកើតនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៤៦ នៅភូមិព្រៃស្បូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ លោកគឺជាក្មួយប្រុសរបស់ ប៉ុល ពត ដែលឪពុករបស់លោកត្រូវជាបងប្រុសរបស់ ប៉ុល ពត ។ សាក្សីបានចូលចលនាបដិវត្តន៍ក្នុងឆ្នាំ១៩៧០ ក្នុងឋានៈជាទាហានមួយរូប ។ លោកបានបដិសេធជាសមាជិកបក្ស ។ ក្នុងឆ្នាំ១៩៧០ លោកនៅខាងកងទ័ពវៀតណាម ហើយគាត់បានចូលមកនៅក្នុងកងទ័ពភូមិភាគឧត្តរវិញនៅក្នុងឆ្នាំ១៩៧៣ ។ លោកបាននៅទីនោះអស់រយៈពេល៣ឆ្នាំ ។ នៅពេលដែលលោកនៅជាមួយកងទ័ពវៀតណាម ភាគច្រើនលោកបានឈរជើងនៅខេត្តកំពង់ធំ និងខេត្តសៀមរាប ដើម្បីការពារប្រាសាទអង្គរវត្ត ។*

*ប្រហែលជាក្នុងឆ្នាំ១៩៧៤ ក្រោយពេលលោកត្រូវរបួស ហើយមិនអាចចូលរួមប្រយុទ្ធនៅលើសមរភូមិបាន លោកត្រូវបានគេចាត់តាំងឲ្យធ្វើជានីរសារ និងជាកងការពារ ។ លោកបានឈរជើងនៅក្នុងស្រុកចម្ការលើ ខេត្តកំពង់កំពង់ចាម ។ មេដឹកនាំដែលស្ថិតនៅទីនោះរួមមាន ប៉ុល ពត នួន ជា អៀង សារី និង ខៀវ សំផន ។*

*សហព្រះរាជអាជ្ញាអន្តរជាតិ ឡៃសាក់ បានចោទសួរសាក្សីថា សាក្សីបានឈរជើងជិតស្ទឹងជីនិត ក្បែរព្រំប្រទល់ខេត្តកំពង់ធំ និងកំពង់ចាមឬ? សាក្សីបានតបថា លោកមិនចាំទីបញ្ជាការនោះទេ ហើយគាត់ក៏មិនស្គាល់លេខកូដសម្គាល់ការិយាល័យដែរ ។ លោក ឡៃសាក់ បានចោទសួរថា សាក្សីថា នួន ជា ខៀវ សំផន និង ប៉ុល ពត មានអាកប្បកិរិយាយ៉ាងដូចម្តេច ហើយពួកគេបានធ្វើអ្វីខ្លះ? សាក្សីបានឆ្លើយថា លោកមិនដឹងពីកិច្ចការសំខាន់ៗ នោះទេ ប៉ុន្តែពួកគេមានការប្រជុំញឹកញាប់ណាស់ដោយមានគ្នាចំនួន៤នាក់ ។*

*លោក ឡៃសាក់ បានសំដៅទៅកាន់សក្ខីកម្មរបស់សាក្សី ភីភួនកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ដែលសាក្សីរូបនោះបាននិយាយថា ខៀវ សំផន ធ្វើការក្នុងការិយាល័យជាប់នឹងការិយាល័យរបស់ ប៉ុល ពត ។ លោក ឡៃ សាក់ ចង់ដឹងថាតើ នួន ជា ប៉ុល ពត និង ខៀវ សំផន បានធ្វើការ និងហូបចុករួមគ្នាជាប្រចាំថ្ងៃមែនដែរឬទេ? សាក្សីបានបញ្ជាក់ថា ពិតមែន ។*

## ក្រោយខែមេសា ឆ្នាំ១៩៧៥

*ត្រឡប់ទៅប្រធានបទបន្ទាប់ លោក ឡៃសាក់ បានចោទសួរពីស្ថានភាពរស់នៅ ។ សាក្សីពុំអាចចងចាំបានឡើយ ។ នៅពេលដែលក្រុងភ្នំពេញត្រូវបានរំដោះ លោកស្ថិតក្នុងកងចល័តមួយ ។ បន្ទាប់មក លោកបានរើទីតាំងទៅរស់នៅជិតស្ថានទូតចិន ។ ក្រោយមក លោកក៏ត្រូវបានគេបញ្ជូនទៅកាន់ក្រសួងការបរទេសដើម្បីទទួលភ្ញៀវ ។ លោកបានជួយរក្សាចំណងមិត្តភាពរវាងប្រទេសចិន និងកម្ពុជា ។ បន្ទាប់ពីលោកចេញពីក្រសួងការបរទេស លោកបានបម្រើការជាកងសន្តិសុខនៅមន្ទីរក-១ នៅក្នុងឆ្នាំ១៩៧៨ ។ លោក ឡៃសាក់ បានអានផ្នែកមួយនៃចម្លើយរបស់សាក្សីដែលបាននិយាយថា លោកស្ថិតក្នុងកងដឹកនាំ ។ លោក ឡៃសាក់ បានសួរថា តើវាត្រឹមត្រូវដែរឬទេដែលសាក្សីធ្លាប់បានបម្រើការជាកងសន្តិសុខ និងជានីរសារ នាដើមឆ្នាំ១៩៧៥ ។ សាក្សីបានតបថា ក្នុងឆ្នាំ១៩៧៥ លោកបម្រើការនៅក្រសួងការបរទេសទទួលបន្ទុកខាងទទួលភ្ញៀវ ។ លោកបានធ្វើការនៅទីនោះមួយរយៈ មុនពេលលោកត្រូវបានគេបញ្ជូនទៅកាន់មន្ទីរក-១ ដែលសព្វថ្ងៃមានទីតាំងនៅជិតអាគារស*

ក្នុងតំបន់ទន្លេបាសាក់ ។ លោក ឡៃសាក់ បានចោទសួរសាក្សីថា លោកបានដឹងដែរឬទេថា អគារនៅជិតព្រះបរមរាជវាំង ត្រូវបានថ្នាក់ដឹកនាំប្រើប្រាស់ជាគេហដ្ឋាន ។ សាក្សីបានឆ្លើយថា លោកមិនច្បាស់ពីទីតាំងនោះទេ ។

លោក ឡៃសាក់ បានសាកសួរសាក្សីថា លោកធ្លាប់បានឃើញថ្នាក់ដឹកនាំផ្សេងទៀតដែរឬទេ ក្រៅពី ប៉ុល ពត ខៀវ សំផន នួន ជា និង អៀង សារី ។ សាក្សីបានឆ្លើយថា លេខាភូមិភាគខស្សវ៉ាហ៍មកលេងណាស់ ។ ក្នុងទីតាំងដែលគាត់ធ្វើការមានកងការពារប្រហែលជា២០នាក់ ប៉ុន្តែក៏មានកងការពារមកពីក្រៅផងដែរ ។ សាក្សីបម្រើការក្នុងទីតាំងនោះ ។

លោក ឡៃសាក់ បានបង្ហាញតារាងបុគ្គលិកមន្ទីរក-១ ហើយបានគូសចំណាំលើឈ្មោះទី៥ ថា តេង ហៅ ពូល ។ សាក្សីបានបញ្ជាក់ថា នេះគឺជាឈ្មោះហៅក្រៅរបស់លោកនៅពេលនោះ ។ មនុស្សទីមួយក្នុងតារាងនោះមានឈ្មោះថា លីន ដែលត្រូវបានគេស្គាល់ថា ជាប្រធានក្តាប់រួមរបស់មន្ទីរក-១ និងមន្ទីរក-៤ ហើយឈ្មោះនេះបានរៀបការជាមួយ សេន (សេន ក៏ធ្លាប់បានផ្តល់សក្ខីកម្មដល់តុលាការដែរ) ។ មនុស្សផ្សេងទៀតក្នុងតារាង គឺជាកងការពាររបស់មន្ទីរ ។ សាក្សីពុំដឹងថា លីន បានរៀបការក្នុងឆ្នាំណានោះទេ ។ សាក្សីធ្លាប់បានរៀបការពីមុនមក ដោយសារតែលោកពេញចិត្តស្រ្តីម្នាក់នោះ ។ គាត់បានរៀបការនៅពេលដែលលោកស្ថិតក្នុងមន្ទីរក-១ ។ ពួកគេត្រូវបានណែនាំឲ្យស្គាល់គ្នា ហើយពួកគេក៏ស្រឡាញ់ចូលចិត្តគ្នា ។ ដូច្នេះ ការរៀបការនោះត្រូវបានគេរៀបចំឡើង ។ ប្រពន្ធរបស់សាក្សីធ្វើការនៅក្រសួងសង្គមកិច្ច និងសុខាភិបាល ។ ការរៀបការរបស់ពួកគាត់ ត្រូវបានរៀបចំឡើងដោយក្រុមការពារ ហើយក៏មានកងការពារផ្សេងទៀតចូលរួមក្នុងការរៀបការរបស់សាក្សីផងដែរ ។ ពួកគេគឺជាប្តីប្រពន្ធតែមួយគូគត់ក្នុងការរៀបការនោះ ។ ពួកគេបានរៀបការមួយសប្តាហ៍ក្រោយពីពួកគេត្រូវបានណែនាំឲ្យស្គាល់គ្នា ។

កងការពារនៅមន្ទីរក-១ ស្ថិតក្រោមការគ្រប់គ្រងរបស់ពក ។ ស៊ីន មិនមែនជាគណៈលេខា ឬអនុគណៈលេខានោះទេ ។ លោក ឡៃសាក់ បានសាកសួរពីឈ្មោះទី៩ ក្នុងតារាងថា ឡេង ។ សាក្សីបានបញ្ជាក់ថា ឈ្មោះ ឡេង នេះពីមុនមក ត្រូវបានគេស្គាល់ថា ជាអ្នកបើកបររបស់ ប៉ុល ពត ។

**មន្ទីរក-៣**

កងការពារ នួន ជា អៀង សារី និង ខៀវ សំផន មានទីតាំងស្ថិតនៅមន្ទីរក-១ ដែលមានឈ្មោះដូចជា តាំង, ស៊ីន និង ឡាង ។ បញ្ជីឈ្មោះក្នុងមន្ទីរក-៣ មិនមែនជាសន្តិសុខនៅមន្ទីរក-១ នោះទេ ។ សាម៉ី ត្រូវបានគេស្គាល់ថា ជាជនជាតិចារ៉ាយ និងជាប្រធានមន្ទីរក-៣ ។ តាទូច ដែលមកពីភូមិភាគបស្ចិម ធ្វើការជាមួយ តា ម៉ុក និង សោ ភឹម ។ លោក ឡៃសាក់ បានសួរថាតើឈ្មោះ ទូច នេះគឺជា កុយ ធួន មែនឬយ៉ាងណា? បន្ទាប់មក លោកឡៃសាក់ ក៏បានចោទសួរសាក្សីថា លោកស្គាល់ សោ ភឹម និង តាម៉ុក តាមរយៈណា? សាក្សីបានឆ្លើយថា ពួកគេជាគណៈភូមិភាគ ដូច្នេះអ្នកណាក៏ស្គាល់ពួកគេដែរ ។ លោក ឡៃសាក់ បានសាកសួរសាក្សីថា ធ្លាប់បានឃើញ ឬស្គាល់ រស់ ញឹម នៅមន្ទីរក-១ ដែរឬទេ? សាក្សីបានយកសំបុត្រទៅឲ្យ សោ ភឹម ចំនួនបីដង ប៉ុន្តែលោកមិនបាននាំយកសំបុត្រផ្សេងទៀតនោះទេ ។ លោកក៏មិនដឹងថាអ្នកណាជាអ្នកសរសេរសំបុត្រទាំងនោះដែរ ។ លោកគ្រាន់តែដឹងថា ប៉ុល ពត ជាអ្នកប្រគល់សំបុត្រឲ្យលោក ។ លោក ឡៃសាក់ បានអានការដកស្រង់ពីចម្លើយដែលសាក្សីបាននិយាយថា លោកជាអ្នកប្រគល់សំបុត្រទៅឲ្យ ទូច ។ សាក្សីបានបដិសេធត្រង់ចំណុចដែលលោកបានឆ្លើយថាលោកបានប្រគល់សំបុត្រទៅឲ្យ សោ ភឹម តែម្នាក់ប៉ុណ្ណោះ ដែលរឿងនេះប្រហែលជាកើតឡើងក្នុងឆ្នាំ១៩៧៨ ។

**ការដ្ឋានទំនប់**

សាក្សីបានហែហម ប៉ុល ពត នៅពេលដែល ប៉ុល ពត ទៅពិនិត្យការដ្ឋានទំនប់ ៧ មករា និង ទំនប់ស្ទោង ក្នុងខេត្តកំពង់ធំ ។ លោក ឡៃសាក់ បានចោទសួរសាក្សីថា គាត់ធ្លាប់បានទៅទំនប់ ៦ មករា ជាមួយ ប៉ុល ពត ដែរឬទេ ។ សាក្សីបានឆ្លើយថា លោកមិនចាំទេថា លោកទៅទំនប់៧មករា ឬទំនប់៦មករា ប៉ុន្តែលោកគ្រាន់តែចាំថា ទំនប់នោះស្ថិតក្នុងខេត្តកំពង់ធំ ។ លោកមិនដឹងពីសកម្មភាពលម្អិតរបស់ ប៉ុល ពត នៅការដ្ឋានទំនប់ទេ ដោយសារតែ ប៉ុល ពត ជួបជាមួយកម្មករដោយផ្ទាល់ ។ នៅការដ្ឋានទំនប់ក៏មានកុមារមួយចំនួន ហើយសាក្សីក៏បានឃើញកងឈ្លបផងដែរ ។ លោកមិនបានចាប់អារម្មណ៍លើស្ថានភាពការងារទេ ដោយសារតែលោកតាម

ការពារ ប៉ុល ពត ។ សាក្សីបាននិយាយថា គ្មានបញ្ហាអ្វីគួរឲ្យកត់សម្គាល់រវាងពួកគេឡើយ ។

សាក្សីបាននិយាយថា នួន ជា មិនដែលឡើងថ្លែងសុន្ទរកថាឡើយ ។ ដើម្បីរំឭកដល់ការចងចាំ លោក ឡៃសាក់ បានដកស្រង់ពីសម្ភាសន៍ដែលសាក្សីបាននិយាយពីវគ្គសិក្សាដែលត្រូវបានធ្វើឡើងដោយ នួន ជា និង ប៉ុល ពត ។ ពួកគេទៅ បុរីកីឡា ដើម្បីសិក្សាវគ្គទាំងនោះ ។ សាក្សីមិនបានតាមការពារ នួន ជា នៅពេលដែល នួន ជា បង្រៀនវគ្គទាំងនោះឡើយ ។ លោក ឡៃសាក់ ចង់ដឹងថា សាក្សីដឹងដោយរបៀបណាថា នួន ជា ទៅកន្លែងនោះដើម្បីបើកវគ្គបង្រៀន ។ សាក្សីបានឆ្លើយថា លោកមិនដឹងថា នួន ជា ទៅកន្លែងណានោះទេ ប៉ុន្តែលោកដឹងថា នួន ជា បានទៅបើកវគ្គបង្រៀន ។ លោក ឡៃសាក់ បានដកស្រង់ពីចម្លើយរបស់សាក្សីដែលលោកបានឆ្លើយថា លោកបានកត់ខ្លឹមសារមេរៀននៅក្នុងវគ្គបង្រៀន ។ លោក ឡៃសាក់ ចង់ដឹងថា តើសាក្សីដឹងពីខ្លឹមសារមេរៀនតាមរបៀបណា ។ សាក្សីឆ្លើយថា លោកបានឮខ្លឹមសារមេរៀនតាមរយៈឧបករណ៍បំពងសំឡេង នៅពេលដែលលោកធ្វើជាកងការពារ ។ ទីតាំងនៃវគ្គបង្រៀននោះនៅបុរីកីឡា ។ លោកស្តាប់ឮប្រធានបទមួយចំនួន ប៉ុន្តែលោកស្តាប់មិនបានទាំងអស់នោះទេ ។

លោក ឡៃសាក់ បានសាកសួរសាក្សីថា នៅចាំទីតាំងស្ថិតក្នុងច្បារមន ខេត្តកំពង់ស្ពឺដែរឬទេ ។ សាក្សីបានបដិសេធហើយឆ្លើយថាលោកមិនបានចូលរួមព្រឹត្តិការណ៍ធំៗទាំងនោះឡើយ ដោយសារតែលោកជាកងការពារ ។

បន្ទាប់មកវេទិកាត្រូវបានប្រគល់ជូនមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការសួរដេញដោល ។ សហមេធាវីនាំមុខ ពេជ អង្គ បានសាកសួរថា មានទន្លេហូរកាត់ទំនប់៧មករាដែរឬទេ ។ សាក្សីបានតបថា ស្ទឹងជីនិតហូរកាត់ទំនប់នោះ ។ វាជាទំនប់ដ៏ធំមួយ ។

តមក លោក ពេជ អង្គ បានសាកសួរពីការរៀបការរបស់សាក្សី ។ សាក្សីបានរាយរាប់ថា ពួកគេត្រូវតែធ្វើការស្នើសុំទៅតាមអង្គភាពដែលពួកគេធ្វើការ ប្រសិនបើពួកគេចង់រៀបការ ។ ពេលខ្លះអង្គភាពលើកទឹកចិត្តឲ្យពួកគេរៀបការ ។ នៅពេលដែលអង្គភាពកំណត់ថា ពួកគេដល់ពេលរៀបការ អង្គភាពនឹងសួរពួកគេថា ពួកគេចង់រៀបការដែរឬទេ បន្ទាប់មកអង្គភាពនឹងចាត់ចែងមង្គលការឲ្យ ។ ប្រធានអង្គភាពនឹងហៅមិត្តនារីមកដើម្បីប្រាប់នាងពីការរៀបចំឲ្យរៀបការ ។ លោក ពេជ អង្គ បានសាកសួរថា នេះជាគោលនយោបាយតម្រូវឲ្យរៀបការនៅពេលគ្រប់អាយុមែនឬយ៉ាងណា? សាក្សីបានបដិសេធពីគោលនយោបាយនោះ ហើយលោកបាននិយាយថា ពួកគេអាចរៀបការលុះត្រាតែពួកគេមានភាពចាស់ទុំ ។

គ្មានមនុស្សពីអង្គភាពផ្សេងចូលរួមក្នុងពិធីរៀបការឡើយ ។ មិត្តនារីនឹងត្រូវបានគេបញ្ជូនមកអង្គភាព ប្រសិនបើភាគីស្ត្រី និងបុរសឯកភាពគ្នា ។ អង្គភាពប្រាប់ពួកគេឲ្យចាប់ដៃគ្នា កសាងជីវិតជាមួយគ្នា និងខិតខំប្រឹងប្រែងឲ្យខ្លាំងឡើងដើម្បីជួយជាតិ និងប្រជាជន ។ ជាមួយគ្នានេះដែរ លោកពេជ អង្គ បានធ្វើការសរុបការសាកសួររបស់លោក ហើយសវនាការក៏បានផ្អាកដើម្បីសម្រាក ។

### គណៈប្រតិភូចិន

ក្រោយពីសម្រាក លោកចៅក្រម និល ណុន បានប្រគល់វេទិកាជូនលោកចៅក្រម ហ្វង់ម៉ាក ឡាវ៉ែញ ដើម្បីធ្វើការសួរដេញដោល ។ សាក្សីបម្រើការនៅទីតាំងនោះ ហើយលោកបានទទួលស្វាគមន៍ភ្ញៀវជនជាតិចិនអស់រយៈពេលជិតមួយឆ្នាំ ប៉ុន្តែសាក្សីពុំធ្លាប់ទទួលថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសចិនទេ ។ លោកចៅក្រម ឡាវ៉ែញ បានលើកឈ្មោះមេដឹកនាំចិនប៉ុន្មានរូប ប៉ុន្តែសាក្សីស្គាល់តែឈ្មោះ តា ឆាយ តែប៉ុណ្ណោះ ។ ប៉ុន្តែសាក្សីមិនបានស្ថិតក្នុងដំណើរទស្សនកិច្ចរបស់ តា ឆាយ នោះទេ ។ សាក្សីបានធ្វើដំណើរទៅប្រទេសចិនចំនួនពីរដង ។ ប៉ុល ពត បានជួបថ្នាក់ដឹកនាំចិននៅទីនោះ ហើយសាក្សីក៏បានហែហម អៀង សារី ទៅកាន់ប្រទេសវៀតណាមមុនពេលដួលរលំក្រុងភ្នំពេញ ។ សាក្សីបដិសេធមិនស្វាគមន៍ភ្ញៀវមកពីលោកខាងលិច ។

លោកចៅក្រម ឡាវ៉ែញ បានសាកសួរសាក្សីថា លោកទទួលបន្ទុកក្នុងការដឹកជញ្ជូនស្រាទៅកាន់ភូមិភាគនានាមែនឬទេ? សាក្សីបានបដិសេធ ហើយឆ្លើយថា លោកជញ្ជូនតែសម្ភារទៅភូមិភាគបូព៌ា និងទៅឲ្យ សោ ភឹម តែប៉ុណ្ណោះ ។ សាក្សីបានបន្តថា សោ ភឹម និង ប៉ុល ពត មានភាពជិតស្និទ្ធនឹងគ្នាណាស់ ។

### រូបថត

វេទិកាត្រូវបានប្រគល់ជូនមេធាវីការពារក្តី នួន ជា លោក វិចទ័រ កូប៉េ ។ មេធាវីបានសាកសួរសាក្សីថា លោកបានចូលរួម

ចលនាបដិវត្តន៍មុនឆ្នាំ១៩៧០ មែនឬទេ ។ សាក្សីបានឆ្លើយថា លោកបានចូលរួមចលនាសម្ងាត់មុនរដ្ឋប្រហារ ហើយលោកបានចូលរួមជាមួយកងទ័ពវៀតណាមក្នុងឆ្នាំ១៩៧០ ។ លោកបានបញ្ជាក់ថា លោកត្រូវបានជាប់ឃុំឃាំងមុនឆ្នាំ១៩៧០ ។ ក្នុងឆ្នាំ១៩៧០ សាក្សី និងបងប្រុសរបស់លោកពុំមានទំនាក់ទំនងជាមួយ ប៉ុល ពត នោះទេ ។ សាក្សីបានសិក្សាពីការថតរូបនៅក្នុងព្រៃ ហើយលោកក៏បានរៀនថតរូបនៅប្រទេសចិន នៅពេលដែលលោកកំពុងតែធ្វើការនៅមន្ទីរក-១ ។ លោកបានថតរូប នៅពេល ប៉ុល ពត ទទួលភ្ញៀវចិន ។ មេធាវី កូប៉េ បានបង្ហាញរូបថតមួយសន្លឹក ហើយសួរសាក្សីថា នេះគឺមនុស្សក្នុងរូបថតនោះគឺជាសាក្សីមែនឬមិនមែន? សាក្សីបានបដិសេធ ហើយលោកបានឆ្លើយថា មនុស្សក្នុងរូបថតនៅខាងឆ្វេងគឺជា តា ម៉ុក ។ មេធាវី កូប៉េ បានថ្លែងថា មនុស្សម្នាក់នេះមើលទៅដូចជាមន្ត្រីជាន់ខ្ពស់ចិនម្នាក់ដែលមានឈ្មោះថា ចេង ប៉ាវ *(Geng Biao)* ។ សាក្សីបានឆ្លើយថា លោកមិនស្គាល់មនុស្សក្នុងរូបនោះទេ ។ ស្របពេលដែលមេធាវីបានបង្ហាញរូបថតមួយសន្លឹកទៀត សាក្សីបានបដិសេធថាលោកមិនបានថតរូបនោះទេ ប៉ុន្តែលោកចំណាំថានោះគឺ ប៉ុល ពត, នួន ជា និង អៀង សារី ហើយលោកក៏បានបន្ថែមថា ក្នុងរូបនោះក៏ប្រហែលជាមាន សោ ភឹម ផងដែរ ។ មេធាវី កូប៉េ បានបង្ហាញរូបថតមួយសន្លឹកទៀត ហើយសួរសាក្សីថា នេះជារូបរបស់ សោ ភឹម មែនឬមិនមែន? សាក្សីថាលោកមិនប្រាកដនោះទេ ។ លោកមេធាវី កូប៉េ បានផ្តល់ឯកសារយោងថា ក្នុងរូបថតនោះគឺ ចេង ប៉ាវ ។ សាក្សីបានបដិសេធថា លោកមិនបានថតរូបដែលបានបង្ហាញទៅគាត់ឡើយ ។ បន្ទាប់មក មេធាវី កូប៉េ ក៏បានបង្ហាញរូបថតលោក ញៀម អេន ទៅកាន់សាក្សី ។

សាក្សីបានឆ្លើយថា កងថតរូបត្រូវបានគេបំបែក ហើយលោកពុំស្ថិតក្នុងកងនោះទេ ។ មេធាវី កូប៉េ បានសាកសួរសាក្សីថា លោកបានចូលរួមក្នុងការថតកុនអ្នកទោសជនជាតិវៀតណាមម្នាក់ដែរឬទេ ។ សាក្សីបានបញ្ជាក់ថាពិតមែន ។ លោកត្រូវបានគេចាត់តាំងឲ្យផលិតកុនខ្លី ដែលជនជាតិវៀតណាមនោះគឺជាអ្នកទោសសង្គ្រាម ។ មេធាវី កូប៉េ បានអានការដកស្រង់ពីសក្ខីកម្មរបស់ ឌុច ដែលបាននិយាយថា កុននោះថតនៅមហាវិថី ម៉ៅ សេទុង ។ សាក្សីបាននិយាយថា អ្វីៗត្រូវបានរៀបចំឡើងដោយ ប៉ង់ ដើម្បីឲ្យលោកធ្វើការថតខ្សែភាពយន្តនោះ ។ សាក្សីពុំបានដឹងពីការងាររបស់ ប៉ង់ ឡើយ ប៉ុន្តែលោកដឹងថា ប៉ង់ ទទួលបន្ទុកក្នុងការចាត់តាំងការងារ និងទំនាក់ទំនងជាមួយ ប៉ុល ពត ។

សាក្សីមិនអាចចំណាំបញ្ជីសរសេរដោយដៃដែលសហព្រះរាជអាជ្ញាបានបង្ហាញលោកនោះទេ ។ លោកហៅថ្នាក់ដឹកនាំថា បង ប៉ុល, បង នួន ជា, បង ខៀវ សំផន ហើយពួកគេទាំងនោះហៅកម្មាភិបាលភាគច្រើនថា បង ។ មនុស្សមួយចំនួនទៀតហៅពួកគាត់ថា តា ឬ អ៊ំ ។ សាក្សីពុំដឹងថាពួកគេហៅគ្នាក្នុងទូរលេខយ៉ាងដូចម្តេចទេ ។ សាក្សីបានបន្តថា ឯកសារនៅមន្ទីរស-២១ ត្រូវបានធ្វើឡើងដោយ ឌុច ប៉ុណ្ណោះ ។

មេធាវី កូប៉េ បានសាកសួរសាក្សីថា លោកធ្លាប់បាននិយាយជាមួយអ្នកកាសែត ខេមបូឌា ដេលី ដែលមានឈ្មោះថា ថេត សម្បត្តិ ដែរឬទេ ។ សាក្សីបានឆ្លើយថា លោកមិនចាំនោះទេ ប៉ុន្តែមានអ្នកសារព័ត៌មានជាច្រើនបានមកសម្ភាសន៍គាត់ ។ នៅពេលដែលត្រូវបានសាកសួរពី ប៉ុល ពត សាក្សីបានរាយរាប់ថា ប៉ុល ពត ជាមនុស្សសុភាពរាបសារ ហើយរួសរាយរាក់ទាក់ជាមួយអ្នកដទៃណាស់ គាត់មិនមែនជាមនុស្សវាយឫកពារឡើយ ហើយគាត់ក៏មិនដែលប្រើប្រាស់ពាក្យមិនសមរម្យដែលអាចប៉ះពាល់ដល់អ្នកដទៃដែរ គាត់ផ្តល់យោបល់ល្អៗ ។ ខ្ញុំមើលទៅគាត់មិនដូចជាមនុស្សកាចសាហាវនោះទេ ។

នៅពេលដែលមេធាវី កូប៉េ បានចោទសួរពីការដាក់ថ្នាំបំពុល ប៉ុល ពត សាក្សីបានឆ្លើយថាលោកធ្លាប់ឮពីករណីនេះ ។ លោកបានឮថាមានមនុស្សឲ្យថ្នាំ ។ លោកមិនដឹងពីការធ្វើទស្សនកិច្ចរបស់អ្នកកាសែតជនជាតិបរទេសនោះទេ ។

មេធាវី កូប៉េ បានបង្ហាញវីដេអូមួយលើអេក្រង់ទូរទស្សន៍ ។ សាក្សីបានបដិសេធថា លោកមិនជាប់ពាក់ព័ន្ធក្នុងការថតកុននោះទេ ។ ត្រង់ចំណុចនេះ លោកមេធាវី កូប៉េ បានធ្វើការសរុបការសាកសួររបស់លោក ។ មេធាវីការពារក្តីឲ្យ ខៀវ សំផន ពុំមានសំណួរដើម្បីចោទសួរទៅកាន់សាក្សីនោះទេ ។ លោកប្រធានបានធ្វើការថ្លែងអំណរគុណទៅកាន់សាក្សី ហើយអនុញ្ញាតឲ្យលោកសម្រាក ។

**លីអូនី គីរខេស្តី**

# កម្មាភិបាលស្រីរៀបរាប់ពីការរំលូតកូន

អតីតកម្មាភិបាលស្រី ប៊ិត បឿន (សាក្សី) បានប្រាប់អង្គជំនុំជម្រះអំពីការងាររបស់គាត់នៅកន្លែងផ្សេងគ្នា ដូចជា នៅទួលទំពូង ក្រុងភ្នំពេញ និងកំពង់ឆ្នាំងជាដើម ។ សាក្សីបានរៀបរាប់អំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ និងប្តីរបស់គាត់ផងដែរ ។ នៅពេលដែលប្តីរបស់គាត់ត្រូវបានចាប់ខ្លួន ថ្នាក់លើរបស់គាត់បានបញ្ជាឲ្យគាត់រំលូតកូនចោល ។ សាក្សីបានចងចាំអំពីការបញ្ជូនខ្លួនទៅវាលយន្តហោះ និងការឈរជើងនៅកោះស្តេចផងដែរ ។

***ការងារផ្សេងៗ***

លោកស្រី ប៊ិត បឿន ហៅ ណា កើតនៅឆ្នាំ ១៩៥០ នៅខេត្តកណ្តាល ។ សហព្រះរាជអាជ្ញារងអន្តរជាតិលោក វីល្លៀម ស្មិត បានសួរលោកស្រីទាក់ទងនឹងការចូលបដិវត្តន៍ ។ សាក្សីបានឆ្លើយតបថា គាត់បានចូលបដិវត្តន៍នៅឆ្នាំ១៩៧១ នៅពេលដែលមានការប្រកាសឲ្យប្រជាជនចូលបដិវត្តន៍ប្រឆាំងនឹងរបប លន់ នល់ ។ បន្ទាប់ពីចូលបដិវត្តន៍ គាត់ត្រូវបានគេបញ្ជូនទៅខេត្តកំពង់ឆ្នាំង ដើម្បីជួយធ្វើស្រែចម្ការអ្នកមូលដ្ឋាននៅទីនោះ ។ បន្ទាប់មកទៀត អង្គការបានបញ្ជូនគាត់ទៅធ្វើការនៅមន្ទីរពេទ្យមួយ ។ ការងាររបស់គាត់នៅពេលនោះគឺ ជីកឫសឈើ យកមករំងាស់ធ្វើថ្នាំសម្រាប់ព្យាបាលជំងឺគ្រុនចាញ់ គ្រុនក្តៅ និងរាករូសជាដើម ។ ក្រោយមកទៀត អង្គការបានបញ្ជូនគាត់ទៅធ្វើស្រែនៅកំពង់ឆ្នាំងម្តងទៀត ។ នៅឆ្នាំ១៩៧៣ អង្គការបញ្ជូនកងរបស់គាត់ទៅតំបន់១៣ ។ សហព្រះរាជអាជ្ញាបានសួរសាក្សីអំពីតំបន់២៥ នៅកប់ស្រូវដែលសាក្សីបានលើកឡើងក្នុងបទសម្ភាសរបស់គាត់ ។ សាក្សីបានឆ្លើយថា គាត់ជាសមាជិកនៃកងពលតូច២២៥ ដែលមានតួនាទីដឹកជញ្ជូនគ្រាប់ទៅឲ្យយោធា ហើយពេលនោះកងរបស់គាត់ជញ្ជូនកាំភ្លើងទៅកងលេខ៨០ ។

បន្ទាប់ពីការវាយប្រយុទ្ធជាមួយទាហាន លន់ នល់ ត្រូវបានបញ្ចប់ កងរបស់គាត់បានមកដល់ក្រុងភ្នំពេញនៅពេលល្ងាច គឺបន្ទាប់ពីប្រជាជនទាំងអស់ត្រូវបានជម្លៀសចេញ ។ នៅពេលមកដល់ភ្នំពេញ កងរបស់គាត់បានតាំងមូលដ្ឋាននៅស្តាត ។ អង្គការបានបញ្ជូនកងរបស់គាត់ទៅធ្វើស្រែនៅសំរោងអណ្តែត ដែលនៅជិតពោធិ៍ចិនតុង ហើយបន្ទាប់មក ក៏បញ្ជូនគាត់ឲ្យទៅដេរខោអាវនៅគីឡូម៉ែត្រលេខ៦ផងដែរ ។ តមកទៀត កងរបស់គាត់បានផ្លាស់មូលដ្ឋានមកនៅជិតស្ពានទូតចិនទួលស្វាយព្រៃ ដើម្បីធ្វើស្រែ ។

សហព្រះរាជអាជ្ញា វីល្លៀម ស្មិត បានរំឭកសាក្សីថា បើតាមអ្នកប្រវត្តិសាស្ត្រ សម្តេចតា ត្រឡប់មកភ្នំពេញវិញនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៥ ។ តើនេះអាចធ្វើឲ្យសាក្សីនឹកឃើញពីពេលវេលាដែលសាក្សីចេញពីស្តាតដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា ពេលដែលគាត់នៅកងពលតូច២២៩ គាត់បានទៅទួលសម្តេចតាពីព្រលានយន្តហោះ ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានចាត់ឲ្យគាត់ចូលធ្វើការនៅក្រសួងពាណិជ្ជកម្ម ។

សាក្សីទទួលបន្ទុកលើការទិញទំនិញ ដូចជា គ្រាប់កាហ្វេជាដើម ។ ដំបូងគាត់ស្នាក់នៅផ្សារចាស់ ប៉ុន្តែក្រោយមកអង្គការក៏បញ្ជូនគាត់ទៅនៅវត្តទួលទំពូងវិញ ។ សហព្រះរាជអាជ្ញាបានបន្តថា តើត្រឹមត្រូវដែរឬទេដែលថា សាក្សីគឺជាប្រធានក្រុមផ្នែកផលិត? សាក្សីបានឆ្លើយទទួលស្គាល់ពីតួនាទីរបស់គាត់ក្នុងផ្នែកផលិតកម្ម ប៉ុន្តែគាត់បានបដិសេធពីតួនាទីក្នុងផ្នែកវេចខ្ចប់កប្បាស ។ សាក្សីទទួលបន្ទុកចិតសម្បកគ ដែលក្នុងគមួយបាវៗ មានទម្ងន់ជាង១០០គីឡូ ។ សហព្រះរាជអាជ្ញា បានអានសម្រង់សេចក្តីថ្លែងការណ៍របស់សាក្សីដែលថា គាត់បានធ្វើការនៅកន្លែងរើសសំឡីគ នៅតាខ្មៅ ដែលសាក្សីបានបញ្ជាក់ថា គាត់ធ្វើការនៅទីនោះរយៈពេល១ឆ្នាំ ។

សាក្សីបានស្នាក់នៅទួលទំពូង មុនពេលដែលត្រូវបញ្ជូនទៅតាខ្មៅ ហើយក្រោយមកទៀតគាត់ត្រូវបានគេបញ្ជូនទៅវត្តគោកខ្សាច់ ។ សាក្សីមិនចាំថា នៅឆ្នាំណានោះទេ ប៉ុន្តែគាត់គ្រាន់តែដឹងថា បន្ទាប់ពី សោ ភឹម ត្រូវបានចាប់ខ្លួន ។

## ការចាប់ខ្លួន

គា ហុង ធ្វើការនៅក្រសួងពាណិជ្ជកម្ម មាននាទីជាអនុប្រធានរបស់ តា រិទ្ធិ ដែលជាប្រធានក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ។ ប្តីរបស់សាក្សី គឺជាអ្នកបើកឡានឲ្យ គា ហុង ។ ប្តីសាក្សីត្រូវបានចាប់ខ្លួនបន្ទាប់ពី គា ហុង ដោយសារប្តីគាត់ក៏ធ្វើការនៅក្រសួងពាណិជ្ជកម្មដែរ ។ មុនពេលចាប់ខ្លួនប្តីរបស់សាក្សី អង្គការបានចាប់ខ្លួនប្រពន្ធ និងចៅរបស់ គា ហុង ។

នៅគោកខ្សាច់ មានមនុស្សច្រើនណាស់ ហើយសាក្សីមិនដឹងពីមូលហេតុដែលអង្គការបញ្ជូនគាត់ទៅទីនោះទេ ។ ជារៀងរាល់ថ្ងៃ មនុស្សជាច្រើនត្រូវបានគេដឹកតាមឡានចេញទៅ ។ ពេលខ្លះ គេដឹកចេញម្តងពីរឡានក៏មានដែរ ។ ស្រី និងប្រុសរស់នៅលាយឡំគ្នា ។ សាក្សីបានស្នាក់នៅទីនោះរហូតដល់រដូវច្រូតកាត់ ។ បន្ទាប់មក ខ្មែរក្រហមក៏បញ្ជូនគាត់ទៅកំពង់ឆ្នាំងតាមរថភ្លើង ។

## កម្ទេចសត្រូវ

សាក្សីត្រូវបានអង្គការបញ្ជូនទៅវាលយន្តហោះ និងបានក្លាយជាសមាជិកនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែលមាន ប៉ុល ពត ជាប្រធាន និង នួន ជា អនុប្រធាន ។ ឯ ខៀវ សំផន អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស និង អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ជាសមាជិក ។ សាក្សីបានចូលរួមវគ្គរៀនសូត្រសំខាន់ពីរ ដែលវគ្គសិក្សានីមួយៗមានរយៈពេលបីថ្ងៃ ។ ប៉ុល ពត ជាអ្នកបើកវគ្គបង្រៀន ហើយអនុប្រធាន និងសមាជិកបក្សផ្សេងទៀតអាចបញ្ចេញមតិបន្ថែម បន្ទាប់ពី ប៉ុល ពត និយាយចប់ ។ អ្នកដែលនិយាយច្រើនជាងគេគឺ ប៉ុល ពត ដែលភាគច្រើនគាត់និយាយពីការរៀបចំនយោបាយ និងភាពជាអ្នកដឹកនាំក្នុងការងារ ។ សាក្សីមិនចាំខ្លឹមសារលម្អិតនៃវគ្គបង្រៀនទាំងនោះទេ ។ គេបង្រៀនគាត់អំពីខ្លឹមសារនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍ និងនិយាយអំពីសភាពការណ៍របស់សត្រូវ ។ សាក្សីបានបន្តថា ប្រសិនបើសត្រូវនោះគឺជាឪពុកម្តាយ និងបងប្អូនរបស់យើង ហើយតើយើងហ៊ានកម្ទេចសត្រូវទាំងនោះទេ?

បន្ទាប់ពីសម្រាក សហព្រះរាជអាជ្ញាបានសួរសាក្សីអំពីអត្ថន័យពាក្យ "កម្ទេច" សាក្សីបានឆ្លើយថា គាត់មិនដឹងពីអត្ថន័យរបស់ពាក្យនេះនោះទេ ។ សហព្រះរាជអាជ្ញាបានអានការថ្លែងការណ៍របស់សាក្សីដែលថា នៅក្នុងវគ្គរៀនសូត្រដែលបង្រៀនដោយ ប៉ុល ពត នេះគេបាននិយាយអំពីការកម្ទេច ។ សហព្រះរាជអាជ្ញាបានបន្តថា តើសាក្សីធ្លាប់បានចូលរួមក្នុងពិធីជប់លៀង និងជួបជុំក្រោយពេល ប៉ុល ពត បានកាន់កាប់ទីក្រុងភ្នំពេញដែរឬទេ? ខៀវ សំផន ធ្លាប់បាននិយាយថា នៅក្នុងការតស៊ូកម្ចាត់សត្រូវនេះ គេត្រូវកម្ទេចវៀតណាម និង ភ្នាក់ងារ *CIA* ចោលឲ្យអស់ដើម្បីការពារប្រទេសជាតិ ។ សាក្សីមិនចាំនោះទេថា ពាក្យនេះ ខៀវ សំផន បាននិយាយក្នុងវគ្គរៀនសូត្រឬមិនមែន ។

សាក្សីបានទទួលស្គាល់ថា គេបានឲ្យគាត់រុករកសត្រូវនៅក្នុងកងរបស់គាត់ ។ ពួកគេនិយាយថា យើងត្រូវពង្រឹងការដឹកនាំរបស់យើង ហើយរុករកសត្រូវដែលបង្កប់នៅក្នុងកងរបស់យើង ។

សមមិត្ត តា ជាប្រធាននៅកន្លែងប្រមូលសំឡីគ ឯសាក្សីជាប្រធានកន្លែងវេចខ្ចប់ដែលមានទីតាំងនៅតាខ្មៅ ជិតស្ពានមួយ ។

សាក្សីបានបន្តថា ខ្ញុំផ្តោតតែទៅលើការងាររបស់ខ្ញុំ ខ្ញុំគ្មានពេលរកសត្រូវនោះទេ ។ នៅពេលដែលខ្ញុំត្រឡប់ទៅតាខ្មៅវិញ សិទ្ធិជាសមាជិកបក្សរបស់ខ្ញុំក៏ត្រូវបានគេដកហូត ។ សហព្រះរាជអាជ្ញាបានសួរថា ការដកសិទ្ធិនេះ ដោយសារតែសាក្សីមិនរកសត្រូវតើមែនទេ? មេធាវីការពារក្តី ខៀវ សំផន អ្នកស្រី អានតា ហ្គីស្សេ បានបដិសេធចំពោះសំណួរនេះដោយលើកឡើងថា ការដែលព្យាយាមឲ្យសាក្សីឆ្លើយតាមបែបនេះ ជាទង្វើដែលមិនអាចទទួលយកបាននោះទេ ។

ខៀវ សំផន ទទួលបន្ទុកក្រសួងពាណិជ្ជកម្ម ។ ការប្រជុំធ្វើឡើងរៀងរាល់មួយខែម្តង ប៉ុន្តែ ពីរឬបីខែម្តង ទើបមានវត្តមាន ខៀវ សំផន ចូលរួម ។ កាប្រជុំគឺពាក់ព័ន្ធទៅនឹង សីលធម៌ វិន័យ និងបញ្ហាស្រដៀងនេះផ្សេងទៀត ។ សាក្សីមិនធ្លាប់បានឮពីការលើកឡើងទាក់ទងនឹងការទប់ទល់សត្រូវនោះទេ ។

បន្ទាប់មកសាក្សីក៏បាននិយាយថា គាត់មិនដឹងថាការប្រជុំធ្វើឡើងញឹកញាប់ប៉ុណ្ណានោះទេ ។

ទាក់ទងនឹងការបញ្ជូនទៅវត្តគោកខ្សាច់ សាក្សីបានឆ្លើយថា គាត់ត្រូវបានគេបញ្ជូនទៅសម្រាកនៅទីនោះ ។ រថភ្លើងដែលដឹកគាត់ទៅកំពង់ឆ្នាំងនោះ គឺមានមនុស្សពេញណែន ។ មនុស្សរាប់រយនាក់ត្រូវបានចាប់ខ្លួន ប៉ុន្តែគាត់មិនដឹងថា ពួកគេទាំងនោះនឹងត្រូវ

បញ្ជូនទៅទីណានោះទេ ។ ភាគច្រើនអ្នកទាំងនោះគឺមកពីបូព៌ា ។ គាត់មិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួនអ្នកទាំងនោះទេ ។ ហេតុការណ៍នេះបានកើតក្រោយពីការចាប់ខ្លួន តាហ៊ុង ។

មកដល់ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញា បានផ្តល់វេទិកាដល់សហការីជនជាតិខ្មែររបស់គាត់លោក សេង លាង ។

លោក លាង បានលើកឡើងអំពីសម្តីរបស់សាក្សីដែលនិយាយប្រាប់ចៅក្រមស៊ើបអង្កេតថា អ្នកទាំងនោះប្រហែលជាត្រូវគេបញ្ជូនទៅដើង៦ក ប៉ុន្តែគាត់មិនប្រាកដនោះទេ ។ សាក្សីគ្រាន់តែឮពាក្យចចាមអារ៉ាមប៉ុណ្ណោះ ។ សាក្សីទើបតែស្គាល់គុកទួលស្លែងនាពេលថ្មីៗនេះប៉ុណ្ណោះ ។ លោក លាង បន្តថា សាក្សីបានស្គាល់គុកទួលស្លែងនៅក្នុងសម័យខ្មែរក្រហម ពីព្រោះសាក្សីធ្លាប់បានឆ្លងកាត់ទីនោះ ។ សាក្សីបានឆ្លើយថា គាត់បានទៅប្រជុំនៅទីនោះ ។ "ខ្ញុំដឹងថាវាជាគុកទួលស្លែង ដែលនៅជិតវត្តទួលទំពូង" សាក្សីមិនបានឮសំឡេងស្រែកចេញពីទីនោះទេ ប៉ុន្តែកងការពារពេលយប់ម្នាក់ប្រាប់គាត់ថា នៅពេលយប់មានសំឡេងស្រែក ។ កងការពារនោះមិនបានបញ្ជាក់ថា សំឡេងស្រែកនេះបណ្តាលមកពីអ្វីនោះទេ ប៉ុន្តែសាក្សីប៉ាន់ស្មានថា ប្រហែលជាបណ្តាលមកពីការធ្វើទារុណកម្ម ។ មានផ្លូវធំមួយដែលនៅជិតការិយាល័យរបស់សាក្សីសម្រាប់ដើរពីស្ថានទូតចិនទៅរបងស័ក្តិសីដ៏ខ្ពស់ ។

ចូលទៅដល់ប្រធានបទថ្មីមួយទៀត លោក លាង បានសួរទៅកាន់សាក្សីពីកន្លែងដែលគាត់ត្រូវទៅធ្វើការបន្ទាប់ ។ សាក្សីបានឆ្លើយថា រថភ្លើងបានឈប់នៅក្នុងព្រៃមួយ ។

## ការរៀបអាពាហ៍ពិពាហ៍

លោក លាង បានសួរទៅកាន់សាក្សីថា តើត្រឹមត្រូវដែរឬទេដែលថា សាក្សីរៀបការនៅឆ្នាំ១៩៧៨ ។ សាក្សីបានឆ្លើយថា វាដូចជានៅឆ្នាំ១៩៧៧ ឬ ១៩៧៨ ប៉ុន្តែប្រហែលជាឆ្នាំ១៩៧៧ច្រើនជាង ។ ប្តីរបស់សាក្សីបានសុំសាក្សីរៀបការ ហើយពេលនោះមានតែពួកគាត់មួយគូប៉ុណ្ណោះដែលរៀបការ ។ ជារឿយៗ គូជាច្រើនត្រូវគេបង្ខំឲ្យរៀបការក្នុងពេលតែមួយជាមួយគ្នា ។ ភាគច្រើនអ្នករៀបការទាំងនោះគឺពេញចិត្តនឹងមនុស្សដែលបានសុំគេរៀបការ ។ សាក្សីបានបន្តថា គាត់គ្មានសិទ្ធិក្នុងការបដិសេធនោះទេ ។ លោក លាង បានដកស្រង់សម្តីរបស់សាក្សីដែលថា មនុស្សធម្មតាគ្មានសិទ្ធិច្រើននោះទេ ។ សាក្សីបានបន្តថា គាត់មិនដឹងថាត្រូវឆ្លើយនឹងសំណួរនេះយ៉ាងណានោះទេ នៅពេលដែលលោក លាង សួរគាត់ថា តើគាត់គឺជាកម្មាភិបាលដែលមានសិទ្ធិប៉ុណ្ណឹងយ៉ាងណានោះ ។

## ការរលូតកូន

លោក លាង បានបន្តថា តើមានការបញ្ជាឲ្យផ្សំដំណេកជាមួយគ្នាដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា មិនចាំបាច់មានការបញ្ជានោះទេ ពីព្រោះពួកយើងបានរៀបការជាមួយគ្នា ហើយពួកយើងនៅផ្ទះជាមួយគ្នា ។ សាក្សីបានបាត់រដូវចំនួន៥ថ្ងៃ ។ ក្រោយពេលដែលប្តីរបស់សាក្សីត្រូវបានចាប់ខ្លួនសមមិត្តថា បានប្រាប់សាក្សីថា គាត់ត្រូវរំលូតកូនរបស់គាត់ចោល ។ គ្រូពេទ្យបានចាក់ថ្នាំឲ្យសាក្សី ហើយគាត់ក៏បាត់បង់កូនក្នុងពេលនោះទៅ ។ សាក្សីមិនបានដឹងពីមូលហេតុនៃការរំលូតនេះទេ គាត់គ្រាន់តែដឹងថា វាជាការបញ្ជារបស់អង្គការ ។ លោក លាង បានបន្តថា តើអង្គការមានសិទ្ធិក្នុងការបង្ខំស្ត្រីណាម្នាក់ឲ្យរៀបការដែរឬយ៉ាងណា? សាក្សីបានឆ្លើយថា គាត់មិនដឹងថានៅក្នុងក្រសួងរបស់គាត់មានការបង្ខំបែបនេះឬអត់នោះទេ ។

## វាលយន្តហោះខេត្តកំពង់ឆ្នាំង

ទាក់ទងនឹងវាលយន្តហោះខេត្តកំពង់ឆ្នាំង សាក្សីបានឆ្លើយថា មានមនុស្សច្រើនណាស់នៅទីនោះ ក្រឡេកទៅណាក៏សុទ្ធតែមនុស្សដែរ ។ វាលយន្តហោះនោះមានទំហំ១០គីឡូម៉ែត្រការ៉េ ហើយមនុស្សច្រើនដូចបុណ្យអុំទូកយ៉ាងអីចឹង ។ មនុស្សនៅទីនោះគឺស្គមខ្លាំងណាស់ ។ ភាគច្រើនជាទាហាន និងស្ត្រី មិនសូវមានកុមារនោះទេ ។ អ្នកទាំងនោះត្រូវបានគេដាក់ទោសពីបទមិនស្មោះត្រង់នឹងខ្មែរក្រហម ។ ប្រុសៗត្រូវបញ្ជូនទៅបំបែកថ្ម និងដឹកជញ្ជូនថ្ម ឯស្រីៗត្រូវបញ្ជូនឲ្យទៅធ្វើស្រែប្រាំងនៅកំពង់ឆ្នាំង ។ សាក្សីមិនបានដឹងពីមូលហេតុដែលអង្គការបញ្ជូនគាត់ទៅទីនោះទេ ។ លោក លាង បានប្រាប់ឲ្យសាក្សីរៀបរាប់ពីការរស់នៅ និងស្ថានភាពការងារនៅទីនោះ ។

សាក្សីបានឆ្លើយថា គេចែកបបររាវៗឲ្យហូប ។ គាត់សម្រាកនៅរោងវែងមួយជាមួយកម្មករផ្សេងទៀត ។ អង្គការចាប់អ្នកទាំងនោះមកពីគ្រប់ទិសទី ។ ជាមួយគ្នានេះ លោក លាង បានបញ្ចប់ការ

សាកសួររបស់គាត់ ហើយលោកប្រធានបានផ្អាកសវនាការដើម្បីឈប់សម្រាក ។

**កម្មាភិបាល**

បន្ទាប់ពីសម្រាក មេធាវីការពារក្តី នួន ជា មេធាវី វីកទ័រ កូប៉េ បានប្រាប់អង្គជំនុំជម្រះថា ក្រុមលោកគ្មានសំណួរសម្រាប់សួរសាក្សីនោះទេ ។ សវនាការក៏ផ្តល់ទៅដល់ក្រុមមេធាវីការពារក្តី ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា តាវិទ្ធិ គឺជាប្រធានតំបន់ពិសេស ។ តាវិទ្ធិ នេះមិនមែន តាវិទ្ធិ ដែលជាប្រធានក្រសួងពាណិជ្ជកម្មនោះទេ?

មានមនុស្សផ្សេងទៀតដែលហៅថា អ៊ឹ ប៉ុន្តែសាក្សីចាំមិនច្បាស់នោះទេ ។ មាន អ៊ឹខៀវ និង អ៊ឹគីក ហើយម្នាក់ទៀតដែលសាក្សីមិនចាំឈ្មោះ ។

មេធាវី ហ្គីស្សេ បានសួរថា តើសាក្សីដឹងអំពីតំណែងរបស់ ប៉ុល ពត នៅពេលដែលគាត់ឡើងនិយាយនោះដែរឬទេ? សាក្សីឆ្លើយថា ប៉ុល ពត បានប្រកាសថាខ្លួនគឺជាប្រធាន នួន ជា អនុប្រធាន ខៀវ សំផន សមាជិក និង អៀង សារី ទទួលបន្ទុកក្រសួងការបរទេស ។

ទាក់ទងនឹងការរស់នៅក្នុងវត្ត សាក្សីបានឆ្លើយថា គាត់ធ្វើការនៅក្នុងបរិវេណវត្ត ។ សាក្សីមិនចាំពីកន្លែងដែលគាត់ចូលរួមប្រជុំនោះទេ ។ នៅពេលដែលគាត់នៅគោកខ្សាច់ គាត់ជិះម៉ូតូមកចូលរួមប្រជុំជាមួយនឹងសមមិត្ត ថា "នៅពេលដែលគាត់នៅទួលទំពូង សមមិត្ត ថា ក៏បានមកចូលរួមប្រជុំជាមួយគាត់ដែរ" ។

អ្នកស្រីមេធាវី ហ្គីស្សេ បានបន្តថា សាក្សីបានចូលរួមប្រជុំជាមួយ តាអៀន និង តាវិទ្ធ ។ សាក្សីបានឆ្លើយថា បន្ទាប់ពីឈរជើងនៅទួលទំពូង គាត់ក៏ត្រូវបានគេបញ្ជូនទៅតាខ្មៅ ។ សាក្សីបានស្គាល់ពីតួនាទីរបស់ ខៀវ សំផន និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតតាមរយៈការប្រកាសរបស់ ប៉ុល ពត ។ សាក្សីបានបន្តថា អៀង សារី និង អៀង ធីរិទ្ធ មានតំណែងតូចជាង ខៀវ សំផន និង នួនជា ។ សាក្សីមិនដឹងថា គណៈអចិន្ត្រៃយ៍ជាអ្វីនោះទេ ។ សុន សេន ជាប្រធានតំបន់ពិសេស ។ សាក្សីក៏ស្គាល់ វ៉ន វ៉េត ដែរ ។

អ្នកស្រីមេធាវី បានសួរអំពីបទសម្ភាសរបស់សាក្សីទាក់ទងជាមួយ សុន សេន និង ខៀវ សំផន នៅក្នុងអង្គប្រជុំនៅបុរីកីឡា ។ លោកស្រីចង់ដឹងថា តើមានអ្នកណាធ្លាប់និយាយជាមួយសាក្សីអំពីមេដឹកនាំក្រសួងពាណិជ្ជកម្មដែរឬយ៉ាងណា? លោកស្រីក៏បានស្រង់សម្តីសាក្សីដែលគេសួរសាក្សីអំពី កុយ ធួន និង តាទូច ។ លោកស្រីចង់ដឹងថា តើសាក្សីស្គាល់ និងបានដឹងពីតួនាទីរបស់ កុយ ធួន ដែរឬទេ? សាក្សីបានឆ្លើយបដិសេធមិនស្គាល់ កុយ ធួន នោះទេ ។ លោកស្រីមេធាវីបានសួរបន្តថា តើសាក្សីបានដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំវាំង តាអន និង តាវិទ្ធិ ដែរឬទេ? សាក្សីបានឆ្លើយថា គាត់បានដឹងអំពីគោលនយោបាយបីសំខាន់ គឺគោលនយោបាយចិត្តសាស្ត្រ និងគោលនយោបាយចាត់តាំង ។

**ការប្រជុំ**

សាក្សីទទួលខុសត្រូវលើការវេចខ្ចប់ ។ គាត់ត្រូវចូលរួមប្រជុំក្នុង១ខែម្តង ដែលកិច្ចប្រជុំនេះគឺនិយាយពាក់ព័ន្ធនឹងការងាររបស់គាត់ទេ ។ សាក្សីបានជួប ខៀវ សំផន បួនដងនៅក្រសួងពាណិជ្ជកម្ម ។ ការប្រជុំនេះគឺធ្វើឡើងនៅក្រសួងពាណិជ្ជកម្ម នៅផ្សារចាស់ ហើយ ខៀវ សំផន ជាអ្នកប្រឹក្សាយោបល់ ។

សមមិត្ត ថា គឺជាប្រធានការិយាល័យ និងសមមិត្ត អឿន ជាប្រធានផ្នែក ។ លោកស្រីមេធាវីហ្គីស្សេ បានឲ្យសាក្សីបញ្ជាក់ពីការចាប់ខ្លួន តាហុង ក្រោយ សោ ភឹម ត្រូវបានចាប់ខ្លួន ។ សាក្សីបានឆ្លើយថា មានពាក្យចចាមអារ៉ាមថា សោ ភឹម ជាជនក្បត់ ហើយ តាហុង ក៏ត្រូវចាប់ខ្លួន ។ សាក្សីបានប៉ាន់ស្មានថា ហេតុការណ៍នេះកើតឡើងនៅឆ្នាំ១៩៧៨ ។ បន្ទាប់មកទៀត ប្រពន្ធ កូន និងចៅរបស់ តាហុង ក៏ត្រូវបានចាប់ខ្លួនដែរ ។ មានមនុស្សជាច្រើនត្រូវបានដកចេញពីតំណែងក្នុងពេលនោះផងដែរ ។

លោកស្រី ហ្គីស្សេ បានសួរបញ្ជាក់អំពីការបញ្ជូនសាក្សីទៅធ្វើការនៅកំពង់ឆ្នាំង ។ សាក្សីបានរៀបរាប់ថា វាលស្រែដែលគាត់ធ្វើការនោះគឺនៅជិតទន្លេមួយ ។ ប្រសិនបើដើរពីវាលយន្តហោះទៅវាមានចម្ងាយប្រហែលពាគីឡូម៉ែត្រទើបទៅដល់កំពង់ទូកសម្រាប់ជិះទៅវាលស្រែនោះ ។ សាក្សីបន្តថា កន្លែងធ្វើការរបស់គាត់នៅកន្លែងផ្សេងៗគ្នាដែលមានចម្ងាយឆ្ងាយពីកន្លែងស្នាក់នៅរបស់គាត់ ឯវាលយន្តហោះ ។ មកដល់ត្រង់ចំណុចនេះ លោកស្រី ហ្គីស្សេ បានបញ្ចប់ការសាកសួររបស់គាត់ ។

**លីអូនី គីឡេស្តី**

# គ្រួសារខ្ញុំដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ លន់ ប៊ុនណាត មានសមាជិកគ្រួសារបីនាក់ដែលត្រូវជា (បងប្រុស បងស្រី និងក្មួយស្រី) ដែលបានបាត់ខ្លួនដូចមានរៀបរាប់ខាងក្រោម៖

**១) រស់ ធីគី**

រស់ ធីគី ភេទប្រុស កើតនៅឆ្នាំ១៩៤៩ (ឆ្នាំឆ្លូវ) នៅស្រុកកោះធំ ខេត្តកណ្តាល តែគាត់ធំដឹងក្តីក្នុងវត្តមួយនៅក្រុងភ្នំពេញ ។ គាត់មានឪពុកឈ្មោះ រស់ គង់ (កើតនៅឆ្នាំ១៩២៧ ហើយស្លាប់នៅឆ្នាំ១៩៦០) និង ដុង ឆ្វូ (កើតនៅឆ្នាំ១៩២៩ ហើយស្លាប់នៅឆ្នាំ១៩៨៣) ។ គាត់មានមុខងារមន្ត្រីប៉ូលីស នៅខេត្តកំពង់ស្ពឺ (ពីចុងទសវត្សរ៍ទី៦០ ដល់ឆ្នាំ១៩៧៥) ។

គាត់កំពុងធ្វើការ នៅពេលដែលគ្រួសារខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យចេញពីក្រុងភ្នំពេញទៅកោះធំ ។ សូម្បីតែគ្រួសារខ្ញុំនៅស្រុកកោះធំ ក៏មិនដែលបានជួបគាត់ដែរ ។

**២) រស់ សុខន**

រស់ សុខន ភេទស្រី កើតនៅឆ្នាំ១៩៥៣ (ឆ្នាំម្សាញ់) នៅស្រុកកោះធំ ខេត្តកណ្តាល ប៉ុន្តែគាត់បានធំដឹងក្តីក្នុងក្រុងភ្នំពេញ ។ គាត់មានឪពុកឈ្មោះ រស់ គង់ (កើតនៅឆ្នាំ១៩២៧ ហើយស្លាប់នៅឆ្នាំ១៩៦០) និង ដុង ឆ្វូ (កើតនៅឆ្នាំ១៩២៩ ហើយស្លាប់នៅឆ្នាំ១៩៨៣) ។ គាត់ធ្វើការផ្នែកបម្រើភ្ញៀវលើយន្តហោះ (រយៈពេលពីរទៅបីឆ្នាំ នៅដើមទសវត្សរ៍ទី៧០) ។ គាត់មានប្តីឈ្មោះ នួន ប៉ូណា (ស្លាប់ក្នុងឆ្នាំ១៩៧៣) និងមានកូនស្រីឈ្មោះ នួនដាមុន្នី (កើតក្នុងឆ្នាំ១៩៧១) ។ គាត់បានបាត់ខ្លួនជាមួយកូនស្រីរបស់គាត់ក្នុង


រស់ ធីគី កាលនៅក្មេង (ត្រូវជាបងប្រុស)


រស់ ធីគី ពេលចូលធ្វើទាហាន (ត្រូវជាបងប្រុស)

ឆ្នាំ១៩៧៦ នៅកោះធំ នៅពេលដែលខ្មែរក្រហមមកប្រាប់គាត់ថា គាត់មានការងារដែលអង្គការតម្រូវឲ្យធ្វើ ។

**៣) នួន ដាមុន្នី៖**

នួន ដាមុន្នី កើតនៅឆ្នាំ១៩៧១ ក្រុងភ្នំពេញ ត្រូវជាកូនស្រីរបស់ នួន ប៉ូណា (ឪពុក) និង រស់ សុខន (ម្តាយ) ។ នួន ដាមុន្នី បានបាត់ខ្លួនក្នុងឆ្នាំ១៩៧៦ ជាមួយម្តាយ នៅពេលដែលខ្មែរក្រហមបានមកនាំអ្នកទាំងពីរចេញទៅ ។ ពេលនោះ នាងពុំមានបងប្អូនទេ ។

**សម្ព័ន្ធគ្រួសាររបស់ខ្ញុំ៖**

◆ ឪពុក៖ រស់ គង់ (១៩២៧)

◆ ម្តាយ៖ ដុង ងួ (១៩២៩)

◆ កូនទី១៖ រស់ ធីគី (កូនប្រុស ១៩៤៩)

◆ កូនទី២៖ រស់ សុខន (កូនស្រី ១៩៥៣)

◆ កូនទី៣៖ រស់ សុខុន (កូនស្រី ១៩៥៧)

◆ កូនទី៤៖ រស់ សុខេន (កូនស្រី ១៩៥៩)

◆ កូនទី៥៖ លន់ ប៊ុនណាត (កូនប្រុស ១៩៦៤) (ពេលនោះ ម្តាយខ្ញុំ ដុង ងួ បានរៀបការលើកទីពីរជាមួយឪពុកខ្ញុំ លន់ ឡាន ក្នុងឆ្នាំ១៩៦២) ។

ខ្ញុំសង្ឃឹមថាព័ត៌មាននេះនឹងជួយខ្ញុំក្នុងការស្វែងរកមនុស្សជាទីស្រឡាញ់របស់ខ្ញុំ ។ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំ ប្រសិនបើស្គាល់ឈ្មោះដូចរៀបរាប់ខាងលើ តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦០២៨ **Eberle** ផ្លូវ **Lakewood, CA** ៩០៧១៣ ទូរសព្ទលេខ (+១) (៥៦២) ៦៤៦-៦៣៥៩, (៥៦២) ៨៦៧-៨៨៩១ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ!



រស់ សុខន (ត្រូវជាបងស្រី)




ដុង ងួ ឬ ព្រំ ងួ (ត្រូវជាម្តាយ)

# ប្រវត្តិរូបរបស់ ខៀវ សេងវ៉ា និងរូបថតនៅទួលស្លែង

ខៀវ សេងវ៉ា កើតក្នុងឆ្នាំ ១៩៥៦ នៅសង្កាត់លេខ១ ភូមិឫស្សីកែវ គីឡូម៉ែត្រលេខ៣ ក្រុងភ្នំពេញ ។ ខៀវ សេងវ៉ា ជាអ្នកទោសនៅមន្ទីរស-២១ ។ នៅក្នុងប្រព័ន្ធទិន្នន័យឯកសាររូបថតលេខ១៨៨៥ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលខ្ញុំបានរកឃើញ ខៀវ សេងវ៉ា ត្រូវបានថតរូប និងពាក់ស្លាកសម្គាល់លេខ ១២៦ ។ ខាងក្រោមនេះជាប្រវត្តិរូបសង្ខេបរបស់ ខៀវ សេងវ៉ា ៖

**សមាជិកគ្រួសារ ៖**

◆ ឪពុកឈ្មោះ ខៀវ សេង (ស្លាប់ដោយសារអត់ឃ្លាន និងជំងឺ នៅក្នុងឆ្នាំ ១៩៧៨) ។

◆ ម្តាយឈ្មោះ គាន (ខ្មែរក្រហមសម្លាប់នៅស្រុកតាំងគោក ខេត្តកំពង់ធំ ឆ្នាំ ១៩៧៨) ។


ខៀវ សេវ៉ា អាយុ១២ឆ្នាំ (ក្នុងឆ្នាំ១៩៦៨)



ខៀវ សេវ៉ា អាយុ២០ឆ្នាំ (ពេលចាប់ខ្លួន)

◆ បងប្រុសឈ្មោះ ខៀវ សេងសួន (ខ្មែរក្រហមសម្លាប់នៅចុងឆ្នាំ១៩៧៥ នៅភូមិគ្មោត ស្រុកកំពង់ថ្ម ខេត្តកំពង់ធំ) ។

◆ បងស្រីឈ្មោះ ខៀវ ជុងស៊ុយ (បែកគ្នា និងសន្មតថាត្រូវបានខ្មែរក្រហមសម្លាប់ក្នុងឆ្នាំ១៩៧៨ ក្នុងខេត្តកំពង់ចាម) (ទីតាំងមិនច្បាស់លាស់) ។

◆ ប្អូនស្រី ខៀវ ជុងវណ្ណ (បែកគ្នាក្រោយការដួលរលំនៃទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ សន្មតថាស្លាប់) ។

◆ ប្អូនប្រុស ខៀវ សុខនរស់នៅរដ្ឋញូវជើស៊ីសហរដ្ឋអាមេរិក ជានាយករងផ្នែកផ្តល់ដំណោះស្រាយខាងបច្ចេកវិទ្យារបស់ក្រុមហ៊ុនហិរញ្ញវត្ថុដ៏ធំមួយ នៅតំបន់ទីប្រជុំជនក្នុងក្រុងញូវយ៉ក ។

**ការអប់រំ និងសកម្មភាព៖**

◆ ខៀវ សេងវ៉ា បានចូលរៀននៅសាលាបឋមសិក្សាពញាក្រែក បន្ទាប់មករៀននៅវិទ្យាល័យឫស្សីកែវ ។

◆ ក្នុងឆ្នាំ១៩៧៤ បានបញ្ចប់ការសិក្សាពីវិទ្យាល័យយុវជនស្រោចស្រង់ជាតិ ហើយមានគម្រោងបន្តការសិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យានៃកម្ពុជា ។

◆ គាត់បានកើតក្នុងគ្រួសារមួយដែលជឿសប់លើសាសនាកាតូលិក ក្នុងសង្កាត់ឫស្សីកែវ ។

កាលពីឆ្នាំ១៩៧០ វិហារកាតូលិកបានរើទីតាំងពីខេត្តកែបមកក្រុងភ្នំពេញ ។ ពេលនោះបងប្រុសរបស់ខ្ញុំក៏បានចូលវិហារដើម្បីបួសជាបុព្វជិត ។ ពេលដែលគាត់នៅក្នុងវិហារនោះ គាត់ប្តេជ្ញាថានឹងបម្រើព្រះ និងអ្នកក្រខ្សត់ ។ បើទោះបីជាផ្ទះគាត់នៅជិតវិហារក៏ដោយ ក៏គាត់មិនដែលបំពានច្បាប់មកលេងផ្ទះដោយគ្មានការអនុញ្ញាតដែរ ។

នៅពេលដែលគាត់កំពុងបួសនោះ គាត់ទៅរៀននៅសាលាឯកជនតាមធម្មតា ។ ក្រោយម៉ោងរៀនគាត់ចំណាយពេលក្នុងវិហារ ហើយបានប្រតិបត្តិវិន័យនៃព្រះសង្ឃកាតូលិក ។ ម្នាក់ៗ នៅទីនោះប្រើប្រាស់ភាសាបារាំងជាមួយព្រះសង្ឃកាតូលិក និងប្រើប្រាស់ភាសាខ្មែរជាមួយមនុស្សទូទៅ ពួកគេខិតខំរៀនសូត្រខ្លាំងណាស់ ។

ក្នុងរយៈពេល៣ឆ្នាំ គាត់អាចនិយាយភាសាបារាំងបានយ៉ាងល្អ ។ ជីវិតខាងក្រៅខុសប្លែកពីជីវិតក្នុងវិហារ ។

នាពាក់កណ្តាលឆ្នាំ១៩៧៣ គាត់បានចេញពីវិហារកាតូលិក ហើយត្រឡប់មកផ្ទះវិញ ។ ខ្ញុំចាំថា បងប្រុសរបស់ខ្ញុំមានភាពចាស់ទុំជាងមនុស្សដែលមានវ័យស្រករគាត់ ។ គាត់តែងតែការពារអ្នកទន់ខ្សោយ ។ គាត់ក៏និយាយដោយមានហេតុផលជាមួយឪពុកម្តាយដែរ ប្រសិនបើការទូន្មានរបស់ពួកគាត់មានចំណុចខ្វះខាត ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្នំពេញបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ យើងត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំចេញតាមផ្លូវជាតិលេខ៥ បន្ទាប់មកក៏ប្តូរទិសដៅដោយឆ្លងស្រឡាងកាត់ទន្លេតាមព្រែកក្តាម ទៅកាន់ផ្លូវជាតិលេខ៦វិញ ។

ក្រោយពីឆ្លងទន្លេផុត ខៀវ សេងវ៉ា និង បងប្រុស ខៀវ សេងឆ្លួន ត្រូវបានបំបែកចេញពីម្តាយ បងស្រី និង ប្អូនប្រុស ។ នៅពេលនោះដែរ បងប្រុស ខៀវ សេងឆ្លួន ក៏ត្រូវបែកចេញពីប្រពន្ធរបស់គាត់ដែរដែលកំពុងតែពរពោះ និងកូនប្រុសរបស់គាត់ម្នាក់ដែលទើបមានអាយុ២ឆ្នាំ ។

ប្រហែលជាបីសប្តាហ៍ក្រោយមកគាត់ (ខៀវ សេងវ៉ា) និងបងប្រុសធំ (ខៀវ សេងឆ្លួន) ត្រូវបានបង្ខំឲ្យទៅរស់នៅភូមិស្វាយភ្លើង ស្រុកតាំងគោក ។ ចំណែក ម្តាយ បងស្រី និងប្អូនប្រុស ត្រូវបានបង្ខំឲ្យរស់នៅភូមិពនរ៉ូ ស្រុកតាំងគោក ខេត្តកំពង់ធំ ។ យើងមិនត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងភូមិជាមួយគ្នាទេ ។

ក្នុងខែកក្កដា ឆ្នាំ១៩៧៥ ខៀវ សេងវ៉ា បងប្រុសធំ និងក្រុមគ្រួសារ ត្រូវបានបង្ខំឲ្យទៅរស់នៅភូមិត្នោត ស្រុកកំពង់ថ្ម ខេត្តកំពង់ធំ ។

ក្រោយមក នៅក្នុងឆ្នាំដដែល បងប្រុសធំ ខៀវ សេងឆ្លួន ត្រូវបានចោទថា ជាទាហាន លន់ នល់ ដែលទទួលការគាំទ្រពីអាមេរិក ។ គាត់ត្រូវបានចាប់ ហើយបាត់ដំណឹងរហូតមក ។ បងប្រុស ខៀវ សេងឆ្លួន បានបន្សល់ទុកប្រពន្ធគាត់ដែលកំពុងពរពោះ និងកូនប្រុសអាយុ២ឆ្នាំ ឲ្យ ខៀវ សេងវ៉ា មើលថែទាំ ។ នៅដើមឆ្នាំ១៩៧៦ បងប្រុស ខៀវ សេងវ៉ា បានព្យាយាមគេចពីអង្គការ និងកម្មាភិបាលខ្មែរក្រហម ហើយបានមកលេងម្តាយ និងប្អូនស្រីនៅភូមិពនរ៉ូ ស្រុកតាំងគោក ។

ខ្ញុំចាំបានថា គាត់មកសូមខមាលទោសពីម្តាយខ្ញុំ និងបងស្រី ប្រសិនបើគាត់បានប្រព្រឹត្តអ្វីខុសឆ្គងមកលើពួកយើង ។ គាត់បានប្រាប់ពួកយើងថា បងប្រុសធំត្រូវបានអង្គការចាប់យកទៅ ចំណែកបងស្រីថ្លៃក៏កើតជំងឺបាក់ទឹកចិត្ត ហើយមិនមានអាហារទទួលទានគ្រប់គ្រាន់ទៀត ។ គាត់ក៏ស្លាប់នៅពេលកំពុងសម្រាលកូនស្រីរបស់គាត់ ។ ក្រោយមក កូនស្រីនោះក៏បានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភទៀត ។

បងប្រុស ខៀវ សេងវ៉ា បាននិយាយថា គាត់មានគម្រោងគេចទៅថៃ ដោយរត់តាមដងទន្លេសាប ។ បន្ទាប់ពីប្រាប់ដំណឹងអកុសលពីក្រុមគ្រួសាររបស់បងប្រុសរួច គាត់ក៏បានត្រឡប់ទៅភូមិត្នោត ស្រុកកំពង់ថ្មវិញ ។ ក្រោយមក ខ្ញុំក៏លែងបានទទួលដំណឹងពីគាត់រហូត ។

ក្នុងឆ្នាំ១៩៧៧ ខ្ញុំបានជួបកងចល័តខ្លះដែលត្រូវបានបញ្ជូនទៅធ្វើការនៅទំនប់ទន្លេជីនិត ។ ខ្ញុំបានឮពីកងចល័តនៅភូមិត្នោត ថា ខៀវ សេងវ៉ា ត្រូវបានអង្គការចាប់ខ្លួន នៅពេលគាត់ប៉ុនប៉ងរត់គេចក្បែរមាត់ទន្លេសាប ។ គាត់ត្រូវបាន (ទាហាន) ចាប់ខ្លួន ហើយសម្លាប់នៅទីនោះ ។

ខ្ញុំមិនរំពឹងថា ខ្ញុំនឹងឃើញរូបថតគាត់ដាក់តាំងនៅមន្ទីរស-២១ នោះទេ ។ ខ្ញុំព្យាយាមបំភ្លេចរូបថតនោះជាច្រើនលើកច្រើនសា ប៉ុន្តែវាមិនជ្រះស្រឡះពីការគិតរបស់ខ្ញុំឡើយ ។ ពេលដែលខ្ញុំទៅមន្ទីរស-២១ ចុងក្រោយបំផុតជាមួយកូនប្រុសអាយុ៣៦ឆ្នាំរបស់ខ្ញុំ ខ្ញុំបានឮបុគ្គលិកសន្តិសុខប្រាប់អ្នកចូលទស្សនាថា រូបថតវាងទ្រវែងប្អូនជ្រុង គ្មានឈ្មោះ គឺជារូបអ្នកទោសដែលត្រូវបានគេចាប់ខ្លួនពីចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ។ ខ្ញុំមានការរន្ធត់ ព្រោះមនុស្សក្នុងរូបនោះប្រហែលជាបងប្រុសខ្ញុំ ។ ដោយសារមានការជួយ និងការលើកទឹកចិត្តពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងការិយាល័យព័ត៌មាននៃមន្ទីរស-២១ មិត្តភក្តិ និងសាច់ញាតិ ទើបខ្ញុំមានកម្លាំងប្រមូលរូបថតកាលពីក្នុងវ័យកុមាររបស់ខ្ញុំ និងបងប្រុសខ្ញុំ ដើម្បីប្រៀបធៀបជាមួយរូបថតនៅមន្ទីរស-២១ ។ រូបភាពទាំងនោះពិតជាដូចគ្នាខ្លាំងណាស់ ។

**ខៀវ សុខន**

# កេរដំណែលផេះផង់សល់ពីរបបខ្មែរក្រហម

**(តចប់)**

នៅជាប់ខាងលិចផ្ទះបាយសង្កាត់នៅលើទួលឆ្អេះ មានរោងប្រក់ស្បូវមួយខ្នងខ្លីសង់កាត់កែងគ្នាដោយមានឡចម្រាញ់ថ្នាំបុរាណឈើមួយសម្រាប់ធ្វើឱសថវេជ្ជសាស្ត្រ (ថ្នាំចាក់ត្រូវជំងឺ១០០មុខ) របស់ខ្មែរក្រហមដោយដុតអុសដែលយើងទាំងពីរនាក់អារបានរៀងរាល់ថ្ងៃ ។ មានមិត្តនារីពេទ្យសង្កាត់ពីរនាក់ធ្វើការនៅទីនោះម្នាក់ឈ្មោះ រុំាង និងម្នាក់ទៀតឈ្មោះ សួយ ដែលបាតដៃឆ្វេងស្តាំរបស់គេទាំងពីរនាក់ថ្ងៃណាក៏ឃើញមានលាបថ្នាំម៉្យាង ពណ៌រាងក្រហមលាយផ្កាឈូកដែរ ប្រហែលជាគេលាបការពារមេរោគជំនួសឲ្យស្រោមដៃក៏អាចថាបាន ។ ពេទ្យនារីខ្មែរក្រហម ស្លៀកពាក់ខ្មៅបង់កក្រមា និងកាត់សក់ខ្លីត្រឹមកញ្ចឹងកដូចគ្នាទាំងអស់មិនអាចមើលដឹងថាមួយណាជាពេទ្យ ឬមួយណាជារដ្ឋអំណាចនោះឡើយ ។ កុំថាឡើយនៅតាមកងចល័ត សូម្បីតែយើងពីរនាក់ធ្វើការបម្រើសង្កាត់កៀកជាមួយពេទ្យព្រឹកល្ងាចដោយផ្ទាល់នោះ ក៏ពុំដែលមានឱសថព្យាបាលជំងឺដែរ ។ យ៉ាងណាមិញ ទាំងអស់គ្នាបើមានជំងឺរហូតដល់វះកាត់វិញនោះ គឺគ្មានផ្លូវណាមួយដែលនឹងសង្ឃឹមថាបានរស់រានមានជីវិតឡើយ ។ ប៉ុនថា រួមជាមួយខ្ញុំទាំងពីរនាក់ ជញ្ជូនអុសដែលបានអារកាត់រួចហើយ យកទៅរៀបចំទុកដាក់នៅផ្ទះបាយសង្កាត់ដោយមិនឲ្យគេប្រើអស់ទាន់ម្តងណាឡើយ ហើយពេទ្យនារីពីរនាក់នោះតែងដើរមកយកអុសពីទីនោះ ទៅដុតឡចម្រាញ់ថ្នាំរបស់ពួកគេជាប្រចាំ ។

យើងទាំងពីរនាក់ ត្រូវបានគ្រប់គ្រងដោយផ្ទាល់ពីស្ត្រីវ័យចំណាស់ម្នាក់ មានសម្បុរសជ្រះរស់នៅភូមិប៉ាតត ឃុំគោកធ្លកក្រោម ហើយពេទ្យ សួយ បានប្តីឈ្មោះ នង ឈិត នៅភូមិអណ្តូងថ្មឃុំគោកធ្លកក្រោម ហើយប្តីរបស់ពេទ្យទាំងពីរនាក់នេះ សុទ្ធតែស្គាល់គ្នាជាមួយខ្ញុំ និង ជា ប៊ុនថា ។ ក្រោយមកទៀត ខ្ញុំមានជំងឺគ្រុនក្តៅត្រូវបាន ប៊ុនថា ធ្វើទំនាក់ទំនងសុំប្រធានក្រុមយើង ហើយថ្នាក់លើនៅទីនោះក៏បានអនុញ្ញាតឲ្យខ្ញុំទៅសម្រាកពេទ្យសង្កាត់នៅក្នុងវត្តពុទ្ធត្តេរារ៉ាម ហៅ វត្តខ្នារធ្នង់ ។

### ៤. ពេទ្យអគ្គការបដិវត្តន៍ខ្មែរក្រហម

វត្តពុទ្ធត្តេរារ៉ាម នៅវត្តខ្នារធ្នង់ ស្ថិតនៅចុងខាងលិចភូមិថ្នល់តាសិត និងខាងជើងថ្នល់ជាតិលេខ៦ ប្រមាណជា៤០០ម៉ែត្រ ។ ទីធ្លានៅក្នុងវត្តមានទំហំធំល្មម ហើយស្រឡះល្អ តែពុំឃើញមានសំណង់ពុទ្ធចក្រណាមួយធ្វើពីថ្មឡើយ សូម្បីតែព្រះវិហារក៏សាងសង់ឡើងអំពីឈើប្រក់ក្បឿង ហើយក៏សង់ផ្ទាល់នឹងដីដែរ ។ សាលាឆាន់មានទំហំធំសង់ពីឈើ ខ្ពស់ពីដីដើរផុតក្បាលប្រក់ក្បឿង ហើយនៅពេលនោះសាលាឆាន់នេះ បានក្លាយទៅជាកន្លែងស្នាក់នៅរបស់អ្នកជំងឺ ដែលមកសម្រាកព្យាបាលរោគផ្សេងៗរបស់ពេទ្យអគ្គការ ។ នៅបរិវេណទីអារាមនេះ ពុំមានរបងព័ទ្ធជុំវិញទេ និងត្រូវបានគេបោះបង់ចោលចាប់តាំងពីខ្មែរក្រហមផ្សឹកលោកសង្ឃចោលអស់ជាយូរមកហើយ ។ មានភូមិជាច្រើនស្ថិតនៅជុំវិញវត្ត មានខ្លះនៅជិត និងភូមិខ្លះទៀតនៅឆ្ងាយ ហើយពុទ្ធបរិស័ទចំណុះជើងវត្តភាគច្រើនមានជីវភាពនៅមានកម្រិតនៅឡើយ ។ ពេទ្យអគ្គការបដិវត្តន៍ខ្មែរក្រហមនៅទីនោះ គឺមានប្រុសមានស្រីប្រហែលជាប្រាំទៅប្រាំមួយនាក់ ស្លៀកខ្មៅពាក់ខ្មៅបង់កក្រមាធ្វើការនៅក្នុងកុដិឈើមួយខ្នងតូចល្មម ប្រក់ក្បឿងទាបផ្ទាល់ដីនៅទិសខាងត្បូងសាលាឆាន់ឃ្លាត់ពីគ្នាប្រហែល២៥ម៉ែត្រ ដោយមានតុឈើវែងមួយនៅពីមុខ ។ អ្នកជំងឺមកពីគ្រប់ទិសទី ក្នុងឃុំគោកធ្លកក្រោម សម្រាកព្យាបាលជំងឺនៅលើសាលាឆាន់ក្នុងវត្តខ្នារធ្នង់នេះ មានប្រហែលជា៥០នាក់ ហើយគេឲ្យអ្នកជំងឺបរិភោគរបបក្នុងម្នាក់ៗពីរពេល គឺថ្ងៃត្រង់ និងពេលល្ងាច ។ ក្នុងចំណោមអ្នកជំងឺទាំងអស់ យើងសង្កេតឃើញមេម៉ាយៗវ័យក្មេងផង និងវ័យកណ្តាលផង ប្រហែលជាបួនទៅប្រាំនាក់ មានកូនតូចៗ បើផ្អែកតាមការក្តាប់បានពួកគាត់គឺជាភរិយារបស់ទាហាន លន់ នល់ ដែល

ជាជនរងគ្រោះ ត្រូវបានអង្គការថ្នាក់លើស្នើយកទៅសម្លាប់ចោលអស់ ។ ដោយឡែកចំពោះប្រជាជនអ្នកមូលដ្ឋានចាស់មិនសូវឃើញមកសម្រាកពេទ្យនៅទីនេះទេ ។ យើងក្រាលកន្ទេលរៀងៗខ្លួនសម្រាកនៅតម្រៀបគ្នារួមជាមួយបុរសម្នាក់មានដុះពុកមាត់ តែងអង្គុយនៅលើកន្ទេល សញ្ជាប់សញ្ជឹងបង្ហុយផ្សែងបារីស្លឹកសង្កែដោយស្ងៀមស្ងាត់ម្នាក់ឯង ។ ក្រោយឆ្នាំ១៩៧៩ ទើបយើងដឹងថា បុរសដុះពុកមាត់នោះគឺជាលោក វេជ្ជបណ្ឌិត អ៊ិត គឹមដាន ។ ជំនាន់នោះ គាត់ និងក្រុមគ្រួសារបានរស់នៅជាមួយតាអាចារ្យឃិត ដ៏មានប្រជាប្រិយភាពម្នាក់ក្នុងភូមិដូនរាជដែលនៅជាប់គ្នាខាងកើតភូមិថ្នល់តាសិត ។ អ្នកជំងឺនៅក្នុងវត្តខ្នារធ្នង់ទាំងអស់គ្នាតែងកាន់ចានបបរម្នាក់មួយ ចានសម្លមួយ និងស្លាបព្រាម្នាក់មួយ ដោយឈរតម្រង់ជាជួររង់ចាំទទួលរបបអាហារនៅពីមុខរោងបាយ ។ នៅលើមាត់ទ្វារផ្ទះពេទ្យ ផ្ទះបាយ ក៏ដូចជានៅមុខសាលាឆាន់ដែរ គឺពុំមានសរសេរអក្សរ ឬក៏ស្លាកសញ្ញាសម្គាល់អ្វីមួយដើម្បីឲ្យដឹងថា នេះគឺជាកន្លែងពេទ្យនោះឡើយ ។ អ្នកជំងឺទាំងអស់គ្នា ដែលនៅសម្រាកព្យាបាលរោគាផ្សេងៗនៅទីនេះ ត្រូវតែទទួលនូវការចាក់ថ្នាំទៅតាម ការកំណត់របស់ក្រុមពេទ្យអាវខ្មៅ តែបើពុំដូច្នោះទេ គេពុំអនុញ្ញាតឲ្យដេកពេទ្យឡើយ ។ អ្នកជំងឺជាទូទៅទោះជាឈឺអ្វីក៏ដោយ គឺត្រូវចាក់ ថ្នាំជារៀងរាល់ព្រឹកមួយម្ជុលម្នាក់ តែបើអ្នកជំងឺណាឈឺធ្ងន់ត្រូវចាក់ថ្នាំនៅពេលល្ងាចម្តងទៀត ។ ថ្នាំចាក់របស់គេពុំបានផ្ញើ ការនាំចូលមកពីបរទេសទេ គឺគេផលិតដោយខ្លួនឯង ចម្រាញ់មកពីឫសឈើផ្សេងៗ សមដូចពាក្យស្លោករបស់បក្សខ្មែរក្រហមបានតែងលើកឡើយថា “ឯករាជ្យម្ចាស់ការ” ។ ថ្នាំចាក់ដែលគេចម្រាញ់បានហើយ ត្រូវច្រកដាក់ចូលទៅក្នុងដបផ្សេងៗដែលសល់មកពីសង្គមចាស់មាន ដូចជាសំបកដបទឹកក្រូចជាដើម ដោយមាន ចង់ប្លាស្ទិកគ្របមាត់ដប និងរុំកៅស៊ូកងពីលើ ។ នៅលើសំបកដបគេពុំឃើញមានដាក់ឈ្មោះប្រភេទថ្នាំបិទពីលើឡើយ ពោលគឺគេ នៅរក្សាទុកស្លាកសញ្ញា និងឈ្មោះទឹកក្រូចឲ្យនៅដដែល ។ រៀងរាល់ព្រឹកវេលាម៉ោងប្រហែល៨ តែងមាននារីពេទ្យពីរនាក់កាន់ថាសតូចម្នាក់មួយនៅដៃ ដោយមានដបទឹកថ្នាំពណ៌សចំនួន២ទៅ៣ដបនៅលើថាសដើរតម្រង់ទៅកាន់សាលាឆាន់ដើម្បីចាក់ថ្នាំឲ្យអ្នកជំងឺ ។ នៅពេលចាក់ថ្នាំម្តងៗ គឺមានការឈឺចុកចាប់យ៉ាងខ្លាំង ហើយក៏គ្មានអ្នកណាម្នាក់ស្ម័គ្រចិត្តចង់ឲ្យគេចាក់ថ្នាំឲ្យឡើយ តែគេចទៅណាពុំរួច និងមានអ្នកខ្លះហើមនៅលើស្នាមចាក់រហូតដល់គ្រុនទៀតផង ។ ដំបូងឡើយ គេយកម្ជុលទៅចាក់ទម្លុះចង់ប្លាស្ទិចនៅលើមាត់ដបទឹកក្រូច ដើម្បីបូមយកទឹកថ្នាំពីក្នុងដប សម្រាប់ចាក់ឲ្យពួកយើង ។ ម្ជុលចាក់ថ្នាំរបស់គេក្នុងមួយដើមអាចចាក់បានពីបីទៅបួននាក់ លុះត្រាណាតែម្ជុល រិលមុខចាក់រហូតដល់កោងម្ជុលទើបគេដូរយកម្ជុលមួយដើមមកទៀត ។ គេបូមទឹកថ្នាំម្តងៗ គឺបូមស្ទើរតែពេញ ស៊ីរ៉ាំង ចាក់បានជាច្រើននាក់ដោយមិនរើសជំងឺ ព្រោះយើងឮ ពួកគេអួតប្រាប់ថា ថ្នាំរបស់គេថ្វីត្បិតតែច្រក នៅក្នុងដបទឹកក្រូចក៏ពិតមែន តែពូកែណាស់គឺអាចព្យាបាលជំងឺបានរហូតដល់ទៅ១០០មុខឯណោះ ។ ក្រោយមកខ្ញុំត្រូវហើមដៃទាំងសងខាងពេលជិតដល់ម៉ោងគេចាក់ថ្នាំហើយ ខ្ញុំដើរគេចទៅមើលគេភ្ជួរស្រែនៅខាង ជើងវត្ត លុះគេចាក់ថ្នាំរួចទើបត្រឡប់មកវិញ ។ ខ្ញុំធ្វើដូចនេះមិនមែនរាល់ថ្ងៃនោះទេ ព្រោះតែមានកន្ទួលពីការកើតអាប់សែដៃរបស់ខ្លួនឯងតែប៉ុណ្ណោះ ។ អ្នកជំងឺដែលមកសម្រាកព្យាបាលនៅទីនេះ គឺច្រើនតែអ្នកដែលមានជំងឺស្រាលៗ ដូចជាៈ គ្រុនក្តៅ ក្អក ឈឺពោះរាករូស ។ បន្តិចបន្តួចតែប៉ុណ្ណោះ ។ ចំពោះអ្នកដែលមានជំងឺធ្ងន់វិញនោះ គ្រូពេទ្យទាំងនោះមិនអាចជួយព្យាបាលពួកគាត់បានឡើយ ព្រោះមានគ្រូពេទ្យខ្លះមិនចេះទាំងអក្សរទៀតផង ។

ក្រៅពី ថ្នាំចាក់ដបទឹកក្រូចត្រូវជំងឺ១០០មុខចេញ គេមានថ្នាំសូនជាដុំមូលតូចៗដែលផ្សំឡើងដោយ ពន្លៃ ទឹកឃ្មុំ ម្រេចទន្សាយ ។ សម្រាប់កែរោគឈឺពោះផ្សេងៗ ។ ថ្នាំអាចម៍ទន្សាយនេះមានរសជាតិល្វីយផ្អែម និងហើរនៅពេលពួកយើងសុំគេបានម្តងម្កាល តែងតែចែកគ្នា បៀមលេងជំនួសឲ្យស្ករគ្រាប់ ។ ពួកពេទ្យនៅទីនោះ គេបរិភោគបាយដោយស្ងាត់កំបាំងក្នុងខណៈដែលអ្នកជំងឺទាំងអស់ហូបតែបបរ គឺពុំសូវខុសគ្នាពីកន្លែងដទៃ ។ បន្ទាប់មក ពាង ជា ស្ថិតនៅក្នុងកងចល័តភូមិថ្នល់តាសិតដែរ និងប្រធានកងចល័តយុវជនភូមិគីឡូតាឈឹមម្នាក់ឈ្មោះ ភិន ស៊ាម ដែលមានមាឌមាំប្រកបដោយសាច់ដុំ ទាំងពីរនាក់នេះក៏បានចូលមកសម្រាកពេទ្យ ជាបន្តបន្ទាប់គ្នានៅ ក្នុងវត្តខ្នារធ្នង់នេះដែរ ។ យុវជនឈ្មោះ ស៊ាម តែងពាក់ស្បែកជើងឃ្លុបម៉ៃហ្វុករបស់ទាហានអាមេរិកាំង

ដើរនៅលើសាលាឆាន់ពុសូរគ្រាំងចុះគ្រាំងឡើងបង្កឲ្យអ្នកជំងឺរាល់គ្នានៅទីនោះធុញទ្រាន់ រហូតដល់អ្នកខ្លះមានការខឹងសម្បារ តែពុំហ៊ានហាមាត់ស្តីព្រោះមិត្ត ស៊ាម គេមានតួនាទីធំជាប្រធានកងចល័តយុវជនភូមិ ។

ពេលព្រលប់ថ្ងៃ មួយចូលមកដល់ឃើញឱកាសល្អហុចឲ្យខ្ញុំបានចុះដើរចូលទៅក្រោមសាលាឆាន់ឈោងដៃតាមប្រហោងក្តារមួយសន្ទឹកយកបានស្បែកជើងម៉ៅហ្វកមួយសម្រាប់នោះដាក់ចូលទៅក្នុងកំសៀវទឹកធំមួយរបស់ខ្ញុំ យួរដើរទៅលេងផ្ទះនៅភូមិថ្នល់គាសិតក្នុងពេលភ្លាមៗនោះតែម្តង ។ នៅតាមផ្លូវទៅផ្ទះ ខ្ញុំបានបោះស្បែកជើងចង្រៃមួយគូនោះ ចូលទៅក្នុងភ្នក់ភ្លើងគោដែលគេដុតនៅលើថ្នល់ជាតិលេខ៦ ឆេះឈ្ងៀមហុយផ្សែងឡើងទ្រលោម ។ នៅទិសពាយ័ព្យ គឺទិសខាងជើងឆៀងខាងលិច មានព្រៃស្មសានមួយដែលពួកពេទ្យតែងយកសពអ្នកជំងឺទៅបញ្ចុះនៅទីនោះ ។ នៅចុងឆ្នាំ១៩៧៥ ខ្ញុំធ្លាប់បានចូលរួមសែងយកសាកសពបុរសវ័យចំណាស់ម្នាក់ ដែលមនុស្សរាល់គ្នាតែងហៅឈ្មោះគាត់ថា កុងលីៗ ពីភូមិថ្នល់គាសិត ដោយរុំកន្ទេលយកទៅបញ្ចុះនៅទីស្មសាននោះបានម្តងដែរ ។ ផ្អែកទៅតាមរូបរាងកិនភាគរបស់កុងលីនោះ អាចឲ្យយើងសន្និដ្ឋានបានថា កុងលីជាកូនកាត់ចិន ប្តូឃួន គាត់ជាជាងកាត់ដេរសម្លៀកបំពាក់មានតែម្នាក់ឯង រស់នៅជាមួយឪពុកក្មេកម្តាយក្មេករបស់ឪពុកមាយើងលើទួលផ្សារឃ្លាំង ។ កុងលី មានស្រុកកំណើតនៅខេត្តកំពង់ចាម កាលពីនៅក្នុងឃុំកំពង់ឃ្លាំង ពេលដែលគាត់ចង់បានប្រពន្ធ ត្រូវបានអាណាព្យាបាលគាត់ការប្រពន្ធអ្នកភូមិទួលតាផុង ក្នុងឃុំកំពង់ឃ្លាំងឲ្យ លុះក្រោយមក កូនដែលមានតែម្នាក់គត់ នោះបានស្លាប់បាត់ទៅ គាត់ក៏បែកបាក់ប្រពន្ធ ហើយក៏បានវិលត្រឡប់ទៅនៅជាមួយអាណាព្យាបាលរបស់ខ្លួនវិញ ។ កាលដែលខ្មែរក្រហមជម្លៀសនៅឆ្នាំ១៩៧៣ ឲ្យឡើងមកលើ គាត់ក៏មកជាមួយកូនអាណាព្យាបាលរបស់គាត់ជារៀងរហូត គឺមកនៅភូមិថ្នល់គាសិតនេះឯង ។

នៅល្ងាចថ្ងៃមួយពីរនាក់ ពាង ជា យើងដើរទៅមើលគេភ្ជួរស្រែនៅខាងជើងវត្តដូចសព្វមួយដង ព្រោះបងប្រុសជីដូនមួយខ្ញុំម្នាក់ឈ្មោះ ជា សូវេត ក៏ស្ថិតនៅក្នុងក្រុមភ្ជួររាស់នោះដែរ ។ យើងឈរលេងនៅទីនោះបានបន្តិចក៏ក្រឡេកមើលទៅម្ខាងឯណោះ ស្រាប់តែឃើញសត្វត្មាតមួយក្បាល ដែលគេចងជើងបន្ទាយខ្សែហើយចងជាប់នឹងកង់រទេះមានដំបូលមួយ ហើយយើងក៏នាំគ្នាដើរទៅមើលឲ្យបានជិតបន្តិច ព្រោះកម្រនឹងបានជួបប្រទះណាស់ ។ គ្រាន់តែយើងដើរទៅមិនទាន់ទាំងបានដល់ផង ស្រាប់តែសត្វត្មាតដេះមួយក្បាលនេះ បានបោះពួយពីចម្ងាយយ៉ាងលឿនមកដេញចឹកយើងទាំងកម្រោលភ្លាមៗ តែពុំមានបញ្ហាទេ ព្រោះចំពុះវាត្រូវបានគេចងឃ្នុំ ជាប់ហាមាត់ពុំរួចឡើយ ។ សត្វត្មាតដេះនេះអ្នកភ្ជួរស្រែគាត់ចាប់បានរយៈពេលបីបួនថ្ងៃមកហើយ គឺរោមរបស់វា មានពណ៌ប្រផេះ ហើយបើសត្វត្មាតភ្លើងគឺរោមរបស់វាក៏មានពណ៌ក្រហមដូចភ្លើងដែរ ។ ពួកវាហើរទាំងហ្វូងៗ ខ្ពស់កប់អាកាស តែបើមានសត្វណាមួយស្លាប់នៅឯដី វាក៏ឆាប់ដឹងអំពីចំណីរបស់ពួកវាណាស់ដែរ ។ នៅពេលដែលយើងលាបង ជា សូវេត និងអ្នកភ្ជួររាស់នៅទីនោះដើម្បីត្រឡប់ទៅកាន់វត្តវិញ ពួកគាត់បានបើកចំហឲ្យយើងថា បើចង់បានវា (ដៃចង្អុលទៅកាន់សត្វត្មាតនោះផង) យកទៅណាក៏ស្រេចតែចិត្តពួកឯងទៅចុះ! ។

ជា សូវេត បានជិះកង់កាត់តាមស្ពានថ្មបុរាណមួយដែលគេនិយមហៅថា ស្ពាមនាគ ឆ្លងស្ទឹងជីក្រែងឆ្ពោះទៅទិសខាងកើតតាមផ្លូវជាតិលេខ៦ ដើម្បីទៅសុំថ្នាំពេទ្យពីមន្ទីរពេទ្យបដិវត្តន៍ខ្មែរក្រហមស្រុកជីក្រែង ។ ពេលជិះកង់ចេញផុតពីក្បាលស្ពាននាគប្រមាណជា៣០ម៉ែត្រ ភ្លាមៗនោះត្រូវបានទាហានអាវខ្មៅខ្មែរក្រហមមកចាប់ ជា សូវេត (អាយុ២៨ឆ្នាំ) ទាំងគ្មានកំហុសដាក់លើឡានចងបាំងធាងដូងដឹកយកទៅទិសខាងលិចបាត់ខ្លួនជារៀងរហូតមកដល់បច្ចុប្បន្ននេះ ។ ពាង ជា និងរូបខ្ញុំបានគិតគ្នាថានឹងនាំយកសត្វត្មាត មួយក្បាលនេះទៅបង្អួតអ្នកជំងឺដែលដេកពេទ្យនៅក្នុងវត្តខ្នារធ្នង់ឲ្យបានឃើញផ្ទាល់នឹងភ្នែកម្តង ។ វិធីនាំយកសត្វត្មាតនោះទៅវត្តនោះគឺ ម្នាក់ចាប់ចំពុះវាទាញបណ្តើរទៅមុខ និងម្នាក់ទៀតដើរដេញពីក្រោយដោយដៃម្ខាង កាន់រំពាត់ និងដៃម្ខាងទៀតកាន់ខ្សែវែងអូសបន្ទាយជាប់នឹងជើងម្ខាងរបស់សត្វត្មាតមកស្រាប់ ។ យើងបណ្តើរវាយក ទៅដល់មុខសាលាឆាន់ភ្លាម អ្នកជំងឺទាំងប្រុសទាំងស្រីបាននាំគ្នាចុះព្រោងព្រាត មកចោងរោមមើលសត្វត្មាត ដែលខ្លួនរបស់វាមានទំហំតូចជាងសត្វទាកាប៉ា តែចំពុះរបស់សត្វត្មាតខុបចុងចុះមកក្រោមបន្តិច ។ ក្នុងឱកាសនោះ ពុំ

ឃើញមានវត្តមានរបស់ពេទ្យខ្មែរក្រហមទេ ដែលជាហេតុនាំឲ្យពួកយើងមានសេរីភាពគ្រប់គ្រាន់ក្នុងការសាកល្បងលេងសើចជាមួយនឹងសត្វត្មាតដេះមួយក្បាលនេះ ។ វាដេញចឹកមនុស្សទាំងឡាយដែលឈរនៅជុំវិញខ្លួនវា ឲ្យរត់បែកខ្ញែកគ្នាជាច្រើនលើកច្រើនសា និងចុងក្រោយគេនាំគ្នាយកដំបងដើមពីងពុងប៉ុនកដៃកូនក្មេងវាយទៅលើក្បាលរបស់វាម្តងម្នាក់ៗ ។ សត្វត្មាតនេះ វាពងទង់កបន្តិចមែន វានៅតែមានលទ្ធភាពដេញចឹកមនុស្សបានជាបន្តទៀត ធ្វើឲ្យអ្នកឈរនៅក្បែរៗនោះ ប្តូរវេនគ្នាវាយទៅលើក្បាលវាមួយសាទៀត និងដល់ទីបំផុតវាក៏ក្រាបទាំងខ្លួនទាំងក្បាលទៅលើដីទៅ ។ មើលឃើញដូច្នេះ ម្នាក់ៗនឹកស្មានថា សត្វត្មាតបានដល់នូវក្តីមរណៈបាត់ទៅហើយ រំពេចនោះបុរសម្នាក់ក៏បានស្ទុះចូលទៅកាប់ផ្តាច់ចំពុះវាទាំងលើ និងក្រោម ទុកយកទៅចងខ្សែពាក់កក្មេងៗដើម្បីឲ្យដាច់អារ៉ុសព្រោះពួកគេនិយាយថា ក្រចកម្រាមជើងរបស់វាក៏អាចយកទៅធ្វើយ៉ាងដូច្នោះបានដែរ ។ រំពេចនោះ សត្វត្មាតងើបឈរឡើងវិញ ស្ទុះទាំងដាច់ចំពុះហូរឈាម ហក់ទៅចឹកបុរសម្នាក់ដែលកំពុងអង្គុយចោងហោង ភ្លេចខ្លួននៅពីមុខវា ចំថ្ពាល់ម្ខាងប្រឡាក់ឈាមសត្វត្មាតមានស្នាមក្រវៅ ។ ស្ថិតក្នុងស្ថានភាពបែបនេះ ក្នុងចំណោមមនុស្សទាំងអស់គ្នាដែលនៅទីនោះ បានព្រួតគ្នាវាយសម្លាប់សត្វត្មាតជា លើកទីបីម្តងទៀត រហូតដល់វាតដៃលែងកើត ។

ក្រោយពេលដឹងប្រាកដថា សត្វត្មាតពិតជាស្លាប់ហើយនោះ ។ គេយកកាំបិតវះដើមទ្រូងវាមើលទៅ ឃើញបេះដូងនៅមានចលនាខ្លាំងៗនៅឡើយ ហើយក៏នាំគ្នាកោតស្ញប់ស្ញែងនូវជីវិតរបស់សត្វត្មាតពិតជាស៊ិតស្វាញដល់ទីបំផុតគ្មានពីរមែន ។ មានអ្នកខ្លះគេនិយាយថា បើចង់ឲ្យសត្វត្មាត ឆាប់ស្លាប់មិនជាការពិបាកទេ គឺគ្រាន់តែយកដើមស្នោ (ផ្កាវាហូបជាអន្លក់) វាយទៅលើក្បាលរបស់វា បើវាយចំកន្ទែង វានឹងស្លាប់មួយរំពេច ។ ចំពោះក្រចកនៃម្រាមជើងរបស់សត្វត្មាត គេកាត់ចែកគ្នា មិនទាំងគ្រប់ផង ហើយខ្ញុំជាមួយ ពាង ជា ត្រូវបានក្រចកនោះម្នាក់មួយដែរ ។ គេនាំគ្នាភ្លាត់យកសាច់ត្មាតមួយក្បាលនោះ ចែកគ្នាជាពីរចំណែក (យើងទាំងពីរនាក់បដិសេធមិនយកទេ) និងធ្វើការចម្អិននៅសាលាឆាន់នាពេលយប់នោះទៅ ។ ចំពោះស្ត្រីមេម៉ាយ៤-៥នាក់នោះ គាត់ទទួលបានសាច់មួយចំណែកដែរ ហើយធ្វើការចម្អិនដោយឆាដាក់កន្ទះ កូនខ្ទុះ និងមួយក្រុមទៀតសុទ្ធតែប្រុសៗ គេធ្វើការចម្អិននៅឆ្ងាយពីយើង គឺនៅចុងរានហាលសាលាឆាន់ឯណោះ ។ ក្រុមស្ត្រីដែលនៅជិត ក្រោយពេលឆាសាច់ឆ្អិន ពួកគាត់បានដួសយកសាច់មកឲ្យយើងកន្ទះកូនចានដែរ តែយើងមិនយកទេ ដោយគ្រាន់តែសុំភ្លក់មើលពីរបីកូនដុំតែប៉ុណ្ណោះ ។

នៅតាមបណ្តាភូមិក៏ដូចជានៅតាមកងចល័តត្រូវបានបាត់ខ្លួនមនុស្សជាបន្តបន្ទាប់ ។ ពីភូមិមួយទៅភូមិមួយទៀត តែងតែមានភាពខុសគ្នាអំពីការហូបចុក ការកាប់សម្លាប់ សេរីភាព និងរបៀបរបបនៃការរស់នៅជាដើម ។ ចំពោះប្រធានសហករណ៍ដែលមានចិត្តសប្បុរស មានធម៌សណ្តោសមេត្តា គឺប្រជាជននៅក្នុងភូមិនោះបរិភោគអាហារបានឆ្អែត ហើយការកាប់សម្លាប់មនុស្សក៏មានចំនួនតិចទៀត ។ ប្រជាជនថ្មីអ្នក១៧មេសា ក្រៅពីមុខព្រួញដែលអង្គការត្រូវកម្ទេចចោលនោះ ក៏ទទួលរងនូវកង្វះខាតអាហារូបត្ថម្ភយ៉ាងខ្លាំងបំផុតដែរ ជាហេតុធ្វើឲ្យសុខភាពរបស់ពួកគេងាយរងនូវជំងឺជាទីបំផុត ។

## ៥.រៀបចំគ្រួសារថ្មីដោយការចាប់ផ្តើមខ្វែងគូគ្នា

សីលធម៌រស់នៅរវាងបុរស និងស្ត្រី និងជាពិសេសរវាងយុវជន និងយុវនារី ត្រូវបានអនុវត្តស្អាតស្អំ លួគួរឲ្យកត់សម្គាល់នៅក្នុងសម័យវាលពិឃាត ព្រោះតែបានឆ្លើយតបទៅនឹងប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយើង ។ ទោះបីយុវជន យុវនារី ពួកគេធ្វើការបញ្ចេញពលកម្មការងាររួមជាមួយគ្នាក្តី បរិភោគបាយជុំគ្នាក្តី ដេក នៅរោងក្បែរគ្នាក្តី តែកម្រទទួលដំណឹងថា ពួកគេខុសសីលធម៌រស់នៅរវាងក្រមុំ និងកម្លោះនោះកើតមានឡើងណាស់ ។ ព្រោះត្បិតមនុស្សជាទូទៅ ខ្លាចអង្គការរហូតដល់បាក់ស្បាតម្នាក់ៗ សូម្បីតែពួកមិត្តៗនៅក្នុងជួរខ្មែរក្រហម ក៏គេមិនលើកលែងឲ្យដែរ គឺត្រូវយកទៅកម្ទេចកាលបើបញ្ហាខុសសីលធម៌កើតមានឡើងហើយនោះ ។ ក៏ប៉ុន្តែការទំនាក់ទំនងការងាររបស់ពួកគេ ក្នុងការពឹងពាក់គ្នាទៅវិញទៅមក គឺមានជាធម្មតាមិនអាចកាត់ផ្តាច់នូវមនោសញ្ចេតនារវាងគ្នា និងគ្នាបានឡើយ ។ យុវជនខ្លះគឺជាអ្នកឡើងកាប់បណ្តូលត្នោតឲ្យទៅខាងផ្នែកនារីៗត្បាញ មួកពាក់ វេញខ្សែបង្គីរែកដី ធ្វើដងរែក ធ្វើដងចប និងដោតខ្សែស្បែកជើងកង់ឡានឲ្យនារី

ជាដើម ។ល ។ ចំណែកកងនារីខ្លះៗដែរនោះគឺ ចាក់វ័ណ្ឌមួកធ្វើពីអម្បោះខ្សែនចម្រុះពណ៌គ្នា និងប៉ះសម្លៀកបំពាក់ ។ល ។ ឲ្យទៅខាងយុវជនវិញ ។ នារីៗត្រូវបានអង្គការខ្មែរក្រហមចាត់ទុកជាកម្លាំងពលកម្មទីមួយដូចយុវជនដែរ ។ លើសពីនេះ ទៅទៀតមានកន្លែងខ្លះ គេផ្ដោតការរំលោភបំពារបំពានទៅលើពលកម្មនារីយ៉ាងធ្ងន់ទៀតផងក៏មានដែរ ។ ចំណុចដែលគួរធ្វើការកត់សម្គាល់នោះគឺកងចល័តមួយស្ថិតនៅក្នុងភូមិអន្លង់វិល ឃុំគោកធ្លកក្រោម មានឈ្មោះថាជាកងចល័តទីមួយ ដែលដឹកនាំដោយបុរសម្នាក់ឈ្មោះស៊ុំ តែដោយកងនេះមានការតឹងតែងជាងគេពេក គេនាំគ្នាលួចដាក់រហ័សនាមឲ្យថា ខ្លាស៊ុំ ឬអាខ្លាស៊ុំ ។ នារីៗដែលស្ថិតនៅក្នុងកងចល័តទីមួយនេះ ភាគច្រើនគឺជាកូនកាត់ចិត ឬយួន ហើយក៏ត្រូវបានប្រធានកងឈ្មោះ ខ្លាស៊ុំ ហ៊ឹកហ៊ឺននារីទាំងអស់នៅក្នុងកង គឺមិនខុសគ្នាពីការហ៊ឹកហាត់នូវក្បួនយុទ្ធសាស្ត្ររបស់កងទ័ពនោះប៉ុន្មានឡើយ ។ នៅលើទួលផ្អេះ ម៉ោងប្រមាណជា៤ជិតភ្លឺ គេឲ្យនារីទាំងអស់ តម្រង់ជាជួរ បញ្ឈរឲ្យធ្វើការសម្រាកប្រុងៗ លើកដៃទាំងពីរទៅលើ ទៅមុខ ឬទៅក្រោយ និងធ្វើការពត់ខ្លួនគ្រប់បែបយ៉ាងទាំងខ្លួនទទឹកជោកទៅតាមចំណង់ចិត្តរបស់ប្រធានកង ។ បន្ទាប់មកគេឲ្យរត់ផង ស្រែកហ៊ោរផង ស្ដាប់ទៅគួរឲ្យភ្ញាក់ផ្អើលសម្រុកទៅកាន់វាលស្រែ ដើម្បីដកសំណាប ឬស្ទូងស្រូវទាំងមេឃមិនទាន់ភ្លឺ ហើយយើងឃើញគេធ្វើដូច្នេះជាច្រើនថ្ងៃបន្តបន្ទាប់គ្នា ។ មានមនុស្សខ្លះដែលស្ថិតនៅកងផ្សេងគ្នា ហើយក៏ពុំដែលធ្លាប់ឃើញ គេធ្វើដូចនេះពីមុនមកនោះក៏នាំគ្នាឈរលួចមើលមកពីចម្ងាយស្ទើរភ្លេចដកដង្ហើម ។ គ្មានអ្នកណាជួយអ្នកណាបានទេ ទោះបីឪពុកម្ដាយនៅឯផ្ទះ កាលបើឮថាគេហ៊ឹកហ៊ឺនកូនស្រីរបស់ខ្លួនដូចជាទាហានយ៉ាងដូច្នេះ គឺបានត្រឹមតែប្រតិកម្មតបតយ៉ាងខ្លាំងពីចម្ងាយមកតែប៉ុណ្ណោះ ។ នៅលើទួលផ្អេះដដែល គឺនៅល្ងាចថ្ងៃមួយ យើងលួចមើលពីចម្ងាយទៅឃើញជនជាតិក្លឹង្គប្រុសៗចំនួន៤នាក់ អង្គុយនៅក្នុងស្នាក់ការកណ្ដាលរបស់កងចល័តដែលមានដើមពីងពាង់ដុះគ្របនៅពីលើ ។ ក្នុងចំណោមមនុស្សទាំងបួននាក់នោះ យើងឃើញបុរសម្នាក់ដែលមានមាឌធំជាងមាន ឈ្មោះថា យីស៊ុក អង្គុយលើកៅអីគងអន្ទាក់ខ្លា ព្រមទាំងអង្រួនជើងទៅទល់មុខគ្នាជាមួយសមមិត្ត ហម ដែលធ្វើការនៅក្នុងស្នាក់ការនោះ ។ យើងមើលពីចម្ងាយទៅបានឃើញចរិតរបស់ជនជាតិក្លឹង្គទាំងនោះ មានភាពក្រអឺតក្រទមដូចជាពុំដែលធ្លាប់ដឹងអំពីសារជាតិរបស់ពួកខ្មែរក្រហមបន្តិចណាឡើយ ។ ជនជាតិក្លឹងទាំងប៉ុន្មានគ្រួសារខាងលើនេះ ដើមឡើយពួកគេជាអ្នកលក់ទំនិញតាមបណ្ដាលហាងនានានៅផ្សារថ្មីទីក្រុងភ្នំពេញដែលអ្នកទំនិញទាំងឡាយតែងនិយាយអួតប្រាប់គ្នាថា ទិញនៅហាង ក្លឹង ។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាតិក្លឹងទាំងនេះក៏មានវាសនាមិនខុសគ្នាអំពីជនជាតិខ្មែរយើងដែរទេ គឺត្រូវបានខ្មែរក្រហមធ្វើការជម្លៀសចេញពីទីក្រុងភ្នំពេញ ឲ្យមករស់នៅក្នុងភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ។ នៅក្នុងភូមិថ្មី ជនជាតិក្លឹងទាំងប៉ុន្មានគ្រួសារនេះ គេឲ្យរស់នៅលើផ្ទះក្បឿងបីខ្នងធំមួយស្ថិតនៅជាប់ខាងជើងផ្លូវជាតិលេខ៦ ។ យើងធ្លាប់ឃើញគេឃ្វាលសត្វគោមួយក្បាលឲ្យស៊ីស្មៅតាមបណ្ដោយផ្លូវជាតិ ហើយបានឮគេរៀននិយាយភាសាខ្មែរយើង ដោយនិយាយមួយៗ និងមិនសូវច្បាស់ថា ពិបាកសម្បើមហើយ មិនដឹងជាយកគោទៅចងឯណាទេ? ។ ក្រោយមកបានបន្តិច យើងបានទទួលដំណឹងថា ជនជាតិក្លឹង្គទាំងនោះ គេបញ្ជូនឲ្យទៅរស់នៅឯភូមិតាភ្វាក្នុងឃុំគោកធ្លកលើបន្តទៀត និងទីបំផុតពួកគេទាំងអស់គ្នាត្រូវបានបាត់ខ្លួនជារៀងរហូតមក ។ ក្នុងពេលដែលមានផែនការកាប់សម្លាប់មនុស្សម្ដងៗ គឺមេភូមិ ឬប្រធានសហករណ៍ជាអ្នកមានភារកិច្ចបញ្ជូនឈ្មោះ ជនរងគ្រោះដែលអង្គការត្រូវយកទៅកម្ទេចចោលនោះ ទៅឲ្យថ្នាក់លើរបស់ខ្លួនមានដូចជា ថ្នាក់សង្កាត់ ឬថ្នាក់ស្រុកជាដើមដោយសម្ងាត់ជាទីបំផុត ។ អ្នកដែលអង្គការចាប់យកទៅហើយ ទោះចាប់ខុសលើខុស ឬចាប់ច្រឡំលើខុសក៏ដោយ គឺត្រូវតែស្លាប់ទាំងអស់ ព្រោះកន្លងមកពុំដែលឃើញនរណាម្នាក់ បានវិលត្រឡប់មកជួបជុំគ្រួសារវិញឡើយ ។ ដូច្នេះប្រធានសហករណ៍គឺជាអ្នកកំណត់អំពីជោគវាសនារបស់មនុស្សទាំងឡាយនៅក្នុងភូមិរបស់ខ្លួន តែបើមានអ្នកណាម្នាក់ហ៊ានធ្វើឲ្យប្រធានសហករណ៍ថ្នាំងថ្នាក់ចិត្តដល់ខឹងសម្បារទៀតនោះ ច្បាស់ជាគេចមិនផុតពីសេចក្ដីស្លាប់បានទេ ។

ជួនកាល ប្រជាជនថ្មីអ្នក១៧មេសាខ្លះមានពាក់ នាឡិកាដៃម៉ាក អូរីយ៉ង់ ត្រូវបានមិត្តខ្មែរក្រហមស្នើយកតែត្រូវបានម្ចាស់នាឡិកាធ្វើការបដិសេធ ក្រោយមកអ្នកនោះនឹងត្រូវគេយកទៅ

សម្ងាប់ចោលដើម្បីយកនាឡិកាដៃមិនខានឡើយ ។ ខ្មែរក្រហមបានធ្វើការលុបបំបាត់ជំនឿ និងប្រពៃណីខ្មែរយើងស្ទើរអស់ ហើយចំណែកដែលនៅសេសសល់បន្តិចបន្តួច គេបានធ្វើការកែប្រែឲ្យស្របទៅតាមទិសអន្តការបដិវត្តន៍របស់គេទាំងស្រុង ។ ជាក់ស្តែងមានដូចជាប្រពៃណីរៀបអាពាហ៍ពិពាហ៍កូនចៅប្រុសស្រី ឲ្យក្លាយទៅជាប្តីប្រពន្ធនឹងគ្នានោះ ត្រូវបានខ្មែរក្រហមធ្វើជាមីទ្ទីងជំនួសទៅវិញ ដោយឲ្យសាមីខ្លួនទាំងពីរនាក់ធ្វើការប្តេជ្ញាចិត្តនៅចំពោះមុខបក្ស ។ ប្រជាជនដែលគេបែងចែកវណ្ណៈថាជាវណ្ណៈថ្នាក់កណ្តាលនោះ អាចលើកជាសំណើផ្ទាល់មាត់ទៅកាន់ប្រធានសហករណ៍ ដើម្បីសុំការអនុញ្ញាតរៀបគ្រួសារជាមួយនឹងយុវនារីណាម្នាក់ដែលខ្លួនពេញចិត្តគ្នាទៅវិញទៅមក ហើយក៏ត្រូវមានការព្រមព្រៀងគាំទ្រពីម៉ែឪទាំងសងខាងដែរ ទើបរស់នៅប្រកបដោយសេចក្តីសុខទៅថ្ងៃអនាគត ។ មានយុវជនជាអ្នក១៧មេសាខ្លះ ក៏អាចសុំរៀបគ្រួសារបានដែរ តែអាស្រ័យ ដោយការមានបក្ខពួកមួយទៀតដែលជាបញ្ហាសំខាន់ មានគ្រប់ជំនាន់ដោយខ្វះមិនបាននៅក្នុងសង្គមខ្មែរយើង ។ ខ្មែរក្រហមបានយកពាក្យខ្មែរ យើងដែលពីមុនមក មិនដែលនិយមយកមកប្រើក្នុងការនិយាយស្តីប្រាស្រ័យទាក់ទងគ្នាទេ គឺមានតែនៅក្នុងពាក្យដែលគេសរសេរជាអក្សរតែប៉ុណ្ណោះ ។ ពាក្យដែលខ្មែរក្រហមណែនាំឲ្យប្រើថ្មី និងពាក្យប្រែក្លាយពីការសរសេរមកជាពាក្យនិយាយវិញនោះរួមមាន ៖

◆ រៀបការ ឬរៀបអាពាហ៍ពិពាហ៍ ជំនួសវិញដោយពាក្យ «រៀបគ្រួសារ» ។

◆ ប្តី ឬប្រពន្ធ ជំនួសវិញដោយពាក្យ «គ្រួសារ» ។

◆ ស៊ី ឬញ៉ាំ ជំនួសវិញដោយពាក្យ «ហូប» ។

◆ ដេក ឬគេង ជំនួសវិញដោយពាក្យ «សម្រាក» ។

◆ ក្មេងៗប្រុសស្រី ជំនួសវិញដោយពាក្យ «កុមារា កុមារី» ។

◆ កម្លោះក្រមុំ ជំនួសវិញដោយពាក្យ «យុវជន យុវនារី» ។

◆ នៅប្រទេសដែលពុំមានឲ្យធ្វើចរាចររូបិយប័ណ្ណ (ប្រាក់ចាយ) ដែលមានតែមួយគត់នៅលើពិភពលោកយើងនេះក្នុងជំនាន់នោះ គឺគេធ្វើការដោះដូរមុខទំនិញគ្នាទៅវិញទៅមកឲ្យដល់ៗផ្ទះ ដោយប្រើពាក្យថា យកមកផ្ញើជំនួសឲ្យពាក្យយកមកលក់ ។

◆ ពាក្យមួយម៉ាត់ថា «ស្នើ» នេះ គេនិយមយកមកប្រើណាស់ ទាំងក្នុងស្រទាប់ប្រជាជន ប្រធានសហករណ៍ និងក្នុងស្រទាប់ខ្មែរក្រហមគ្រប់លំដាប់ថ្នាក់ទូទាំងកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ ពាក្យថាស្នើ គឺមានន័យជាច្រើន ដូចជាៈ សុំ, ខ្ចី, យក, ដកហូត, តម្រូវការ, និងសម្ងាប់ទៀតក៏អាចថាបានដែរ ។ល ។

នៅពេលដែលយើងឮពាក្យជាដំបូង នៅតំបន់រំដោះដែលគេនិយាយថា កុមារ មិត្តនារី ស្រ្តី ។ ហួសចិត្តនឹកខ្មាស់ខ្លួនឯងបែរជាចង់សើចទៅវិញ ព្រោះត្បិតពាក្យទាំងនោះគឺជាពាក្យគេប្រើនៅក្នុងការសរសេរតែប៉ុណ្ណោះ ពុំដែលធ្លាប់ឃើញគេប្រើក្នុងការនិយាយស្តីប្រាស្រ័យទាក់ទងគ្នានៅក្នុងសង្គមខ្មែរយើងម្តងណាឡើយ ។ លុះក្រោយៗមក ដោយឮគេនិយាយរត់មាត់ពីមួយទៅមួយ និងគ្រប់ៗគ្នាទៅ ក៏បានប្រែក្លាយទៅជាធម្មតា និយាយបានដូចគេដូចឯង ពោលគឺមិនរឹងមាត់ដូចកាលពីជួបប្រទះលើកដំបូងនោះឡើយ ។ នៅពេលរៀបគ្រួសារ គេបានធ្វើនៅក្នុងសហករណ៍ ហើយបើស្នាក់ការសន្តាត់នៅជិត គឺគេធ្វើនៅក្នុងស្នាក់ការសន្តាត់តែម្តង ក្រោមអធិបតីភាពគណៈសន្តាត់ ប្រធានសហករណ៍ ឬអ្នកតំណាងឲ្យប្រធានសហករណ៍ក៏បានដែរ អាស្រ័យដោយថ្នាក់លើរបស់គេបានដឹងឮ ឬក៏យល់ព្រម ។ ភ្ញៀវចូលរួមនៅក្នុងមីទ្ទីងនោះ គឺមានចាស់ទុំនៅក្នុងសហករណ៍ហើយ ឪពុកម្តាយកូនប្រុសកូនស្រីទាំងសងខាងត្រូវមានមុខនៅក្នុងទីនោះជាការចាំបាច់ ។ កូនកម្លោះស្លៀកខោខ្មៅជើងវែងពាក់ខ្សែយឺតចង្កេះ អាវដៃវែងពណ៌ខ្មៅ និងស្បែកជើងកង់ឡាន គឺជំនួសឲ្យខោអាវធំ ស្បែកជើងយៀ ព្រមទាំងបង់កក្រមាជំនួសឲ្យក្រវ៉ាត់ក ។ ចំណែកឯកូនក្រមុំ ត្រូវកាត់សក់ឲ្យខ្លីនៅត្រឹមកញ្ចឹងក ពាក់អាវខ្មៅដៃវែង សំពត់ខ្មៅ ហើយអ្វីដែលគេមិនភ្លេចនោះ គឺបង់កក្រមា ដែលជាអត្តសញ្ញាណរបស់ខ្មែរក្រហម ។ ពួកមិត្តៗមួយចំនួន ដូនមានប្រុសមានស្រី តែងឃើញពួកគេមានបង់កក្រមាសូត្រ ហើយធ្វើឬកម៉ិម៉្ងក់ដើតបង្អួតដាក់គ្នាទៅវិញទៅមក អំពីសម្រស់ដ៏ល្អឆើតនៃកន្សែងសូត្រខ្មែរក្នុងពេលរៀបគ្រួសារថ្មីនេះ ការធ្វើមីទ្ទីងរបស់ពួកគេ គឺលើកសរសើរពីគុណបំណាច់របស់បក្ស ដែលបានរំដោះយើងទាំងអស់គ្នា ឲ្យរួចចាក ផុតពីនឹមចក្រពត្តិអាមេរិក មកកសាងសង្គមថ្មីសន្លាងមួយ គឺរបបសង្គមនិយម ដ៏ល្អដូរផង់មហាលោតផ្លោះ មហាអស្ចារ្យ ។ ជាគុណបំណាច់ដ៏ធំធេង

របស់បក្សយើងបានមើលឃើញ និងធ្វើឲ្យមានការរៀបគ្រួសារថ្មីនៅថ្ងៃនេះ ដូច្នេះចូរកុំបំភ្លេចគុណរបស់បក្សឲ្យសោះ ។ សកម្មភាពដូចនេះ ខ្ញុំធ្លាប់បានដឹង ព្រោះខ្ញុំមានប្អូនស្រី សៀវ សុវុត្ថា រៀបគ្រួសារមុនគេក្នុងគ្រួសារយើងនៅស្នាក់ការសង្កាត់គោកធ្លកក្រោមក្នុងភូមិថ្នល់តាសិត លុះនៅឆ្នាំ បន្ទាប់មក ប្អូនស្រីខ្ញុំម្នាក់ទៀត សៀវ សុវុឌ្ឍា ក៏បានរៀបគ្រួសារដូចគ្នានោះម្តងទៀតដែរ ។ ក្នុងការរៀបគ្រួសាររបស់ប្អូនស្រីខ្ញុំទាំងពីរនាក់នេះ ពួកយើងទាំងអស់គ្នាដែលត្រូវជាបង និងជាប្អូនបង្កើតរបស់កូនក្រមុំ ពួកខ្មែរក្រហម គេមិនតម្រូវឲ្យមានវត្តមានពួកយើងនៅក្នុងពិធីរៀបគ្រួសារនោះទេ ។ ចំណែកឪពុកម្តាយរបស់ពួកយើង គេឲ្យពួកគាត់មានមុខនៅទីនោះដែរ ។

គួរបញ្ជាក់ថា ក្នុងការរៀបចំគ្រួសារថ្មោងថ្មីនេះ គឺពុំមានពិធីជប់លៀង សូម្បីតែការបរិភោគបាយជុំគ្នាមួយពេលយ៉ាងសាមញ្ញក៏គ្មានដែរ ពោលគឺ ក្រោយចប់ មីទ្ទីង ទាំងអស់គ្នាត្រូវទៅទទួលទានបាយនៅតាមអង្គភាព ឬកងរៀងៗខ្លួនវិញ ។

ចំណែកប្រជាជនដែលមានប្រវត្តិរូបល្អ ស្អាតស្អំមកពីកំណើតស្រាប់នោះ គឺវណ្ណៈកម្មករ-កសិករក្រីក្រ ដែលត្រូវជាកូនចៅផ្ទាល់របស់ខ្មែរក្រហម គឺអង្គការជាអ្នកគិតគូរជ្រើសរើសគូស្រករឲ្យដោយផ្ទាល់តែម្តង ហើយក៏ជាអ្នករៀបចំគ្រួសារនៅចំពោះមុខបក្សដែរ ។ ខ្មែរក្រហមគាំទ្រវណ្ណៈទាំងពីរខាងលើនេះណាស់ ដូច្នេះហើយបានជាខ្មែរក្រហមស្លៀកពាក់ខ្មៅ គឺតំណាងឲ្យវណ្ណៈកម្មករនិងកសិករនេះឯង ។ ក្រោយពេលធ្វើការច្រូតកាត់ប្រមូលផលស្រូវរដូវវស្សាឆ្នាំ១៩៧៦ រួចអង្គការបានមើលឃើញដោយរៀបចំគ្រួសារឲ្យវណ្ណៈកសិករក្រីក្រចំនួនពីរគូនៅភូមិពីរក្បែរគ្នា ។ ក្នុងនោះយុវជន និងយុវនារីពីរនាក់ រស់នៅភូមិទ័ពសៀម ពួកគេបានស្រឡាញ់គ្នានៅក្នុងភូមិទៅវិញទៅមក និងយុវជន យុវនារីពីរនាក់ផ្សេងទៀតរស់នៅភូមិបេង (ភូមិបេងនិងភូមិទ័ពសៀមមានព្រំប្រទល់ជាប់គ្នា) ក៏ស្រឡាញ់គ្នាទៅវិញទៅមកនៅក្នុងភូមិរបស់ខ្លួនដូចគ្នាដែរ ។ អង្គការខ្មែរក្រហម គឺជាអ្នកមើលឃើញដោយមិនតម្រូវឲ្យខាងកូនប្រុសលើកជាសំណើសុំរៀបគ្រួសារមកបក្សទេ ក៏បានប្រើប្រាស់សិទ្ធិផ្តាច់ការរបស់ខ្លួន ចាប់ផ្ទឹមមនុស្សប្រុសស្រីទាំងបួននាក់ខាងលើនេះផ្ទឹមខុសគូគ្នាទាំងស្រុង ។ ដាក់ស្តែងដល់ថ្ងៃរៀបចំគ្រួសារថ្មីចូលមកដល់អង្គការបែរជាចាប់គូដាក់ខុសពីការស្រឡាញ់របស់ពួកគេ ដោយឲ្យយុវជនរស់នៅក្នុងភូមិបេងជាគូនឹងយុវនារីរស់នៅក្នុងភូមិទ័ពសៀមទៅវិញ ហើយឲ្យយុវជនរស់នៅក្នុងភូមិទ័ពសៀម ជាគូនិងយុវនារីដែលរស់នៅក្នុងភូមិបេងឯណោះវិញ គឺប្រាសគូគ្នាចុះឡើង ។ ថ្វីត្បិតតែការប្រកាសខុសគូគ្នាយ៉ាងនេះក្តី ពិធីធ្វើមីទ្ទីងក្នុងការរៀបគ្រួសារថ្មីនេះ បានដំណើរការទៅជាធម្មតា ពោលគឺពុំមានប្រតិកម្មអ្វីពីសំណាក់សាម៉ីយុវជននិងយុវនារីទាំងពីរគូនេះឡើយ ។ យើងសង្កេតឃើញថា ទោះបីត្រូវបានអង្គការខ្មែរក្រហមជឿទុកចិត្តព្រមទាំងស្រឡាញ់ទុកដូចជាកូនជាចៅយ៉ាងណាក៏ដោយ ក៏មិនអាចមើលធ្លុះដល់ជម្រៅចិត្តរបស់ពួកគេបានដែរ ។

ម៉្យាងទៀត ពួកគេក៏ស្គាល់ច្បាស់ណាស់នូវអំពើឃោរឃៅរបស់ខ្មែរក្រហម កាលបើហ៊ានប្រឆាំងនឹងបក្ស ហើយជម្រើសមានតែមួយគឺ សេចក្តីស្លាប់ ។ រយៈពេលប៉ុន្មាន ថ្ងៃបន្ទាប់មកទៀតគឺនៅពេលដែលកងចល័តភូមិថ្នល់តាសិត ក្រោកពីយប់ដើរឡើងទៅលើកទំនប់ដីកប្រឡាយដែលជាចែងធ្លាក់ចុះមកពីទំនប់ម្កាក់ក្នុងឃុំគោកធ្លកលើ ស្រាប់តែនៅលើដើមឈើ ធំមួយដើមក្នុងព្រៃក្នុងទឹកដីភូមិបេង មានធំក្លិន ព្រមទាំងឃើញសាកសពមនុស្សចងកធ្វើអត្តឃាត ដោយមើលពុំដឹងប្រុស ឬស្រីដែលមានចំនួនដល់ទៅបួននាក់ឯណោះ ។

លុះភ្លឺច្បាស់ឡើង ទើបដឹងប្រាដកថា សាកសពមនុស្សទាំងបួននាក់នោះ គឺជាយុវជន និងយុវនារីដែលអង្គការយើងរៀបចំគ្រួសារឲ្យកាលពីប៉ុន្មានថ្ងៃកន្លងមកនេះឯង ។ នៅលើដើមឈើសាកសពមនុស្សប្រុសស្រីមួយគូដែលត្រូវគូគ្នាវិញនោះ គឺចងកនៅលើមែកឈើមួយដោយបែរខ្នងទល់គ្នា និងសាកសពមនុស្សប្រុសស្រីមួយគូទៀត ក៏ត្រូវគូគ្នាដែរ បានសម្លាប់ខ្លួននៅលើមែកឈើផ្សេងដោយឡែកមួយទៀត រួមជាមួយគ្នាពីរនាក់ដែរ តែនៅទន្ទឹមគ្នាដោយបែរមុខទៅកាន់ទិសតែមួយ ។ គួរបញ្ជាក់ថា នៅមុនឆ្នាំ១៩៧៥ មានប្រជាជននៅឯភូមិបន្ទាយឈើ ក្នុងឃុំទឹកវិលស្រុកពួកជាច្រើនគ្រួសារ ប្រហែលជាខ្មែរក្រហមជម្លៀសឲ្យមករស់នៅរាយប៉ាយគ្នាក្នុងស្រុកជីក្រែង ព្រោះឃើញមាននៅក្នុងភូមិអណ្តូង តាអោនក្នុងឃុំសង្វើយខ្វះ ។ល ។ និងរស់នៅភូមិបេង

ក្នុងឃុំគោកធ្លកក្រោមខ្លះ ហើយក្នុងចំណោមសពប្រុសស្រី ទាំងពីរនាក់នៅភូមិបេងនេះ មានមនុស្សម្នាក់ជាអ្នករស់នៅភូមិបន្ទាយឈើពីអតីតកាល ។

ក្រៅពីនេះ ចំពោះយុទ្ធជនពិការកាយសម្បទានៅលើសមរភូមិរបស់ទាហានខ្មែរក្រហម ឬបុរសអ្នកមូលដ្ឋានចាស់ពោះម៉ាយប្រវត្តិរូបល្អសម្រាប់ខ្មែរក្រហមនៅក្នុងភូមិដែរនោះ អង្គការខ្មែរក្រហមតែងដាក់បន្ទុកធ្ងន់ទៅលើស្ត្រីមេម៉ាយ ឬយុវនារីប្រជាជនថ្មីអ្នក១៧មេសា ដែលមានរូបស្អាត ដោយដាក់សម្ពាធផ្សេងៗឲ្យទទួលយកមនុស្សពិការទាំងពីរប្រភេទដូចខាងលើនេះធ្វើប្តី ។ ដោយការចាប់បង្ខំយ៉ាងដូច្នេះ ក្រោយមក ស្ត្រី ឬយុវនារីប្រជាជនថ្មីអ្នក១៧ មេសាទាំងនោះ អ្នកខ្លះត្រូវបានធ្វើអត្តឃាតសម្លាប់ខ្លួន ម៉្យាងទៀត បើគេដឹងថារស់នៅមិនចុះសម្រុងនឹងគ្នា គេយកស្ត្រី ឬយុវនារីនោះទៅសម្លាប់យ៉ាងទាន់ហន់ទៀតផង ។

នៅក្នុងចំណោមជនរងគ្រោះមានចំនួនជិតពីរលាននាក់ ទូទាំងប្រទេសកម្ពុជាយើង ដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ បើគិតជាភាគរយ គឺមានតែប្រជាជនថ្មីអ្នក១៧មេសាទេ ដែលរងគ្រោះមានចំនួនច្រើនលើសលុបជាងគេ ។ ក្នុងនោះមានដូចជាៈ ទាហាន ប៉ូលីស កងអាវុធហត្ថជាតិ រដ្ឋការស៊ីវិល គ្រូបង្រៀន សិស្ស និស្សិត បញ្ញវន្ត កវីនិពន្ធ តន្ត្រីករ សិល្បករ សិល្បការិនី វិចិត្រករ កីឡាករ កីឡាការិនី ព្រះសង្ឃ កម្មករ កសិករ ខ្មែរអ៊ីស្លាម ជនបរទេស និងប្រជាជនស្លូតត្រង់ជាដើម ។ល ។ រីឯការរងគ្រោះផ្លូវកាយ និងផ្លូវចិត្តវិញរួមមានៈ ការបង្ខំឲ្យធ្វើការជាទម្ងន់ អត់បាយក្រហាយទឹក មានជំងឺគ្មានថ្នាំព្យាបាល បែកបាក់ក្រុមគ្រួសារ គ្មានសម្លៀកបំពាក់ បាប់បង្ខំឲ្យយកប្តីជាជនពិការការរស់នៅស្ថិតក្នុងសេចក្តីភ័យខ្លាច ។

**សៀវ សុផុន**

# ជំណឹងស្វែងរកពូ និងមីង



នាងខ្ញុំឈ្មោះ កប ដាវី ជាកូនរបស់លោកឪពុកឈ្មោះ ពៅ កប ។ ឪពុកខ្ញុំកើតនៅឆ្នាំ១៩៣០ នៅភូមិសូសិតក្រោម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត ។ គាត់មានឪពុកឈ្មោះ ពៅ កាន់ និងម្តាយឈ្មោះ អ៊ុំ ឆិន ។

ឪពុកខ្ញុំ ពៅ កប បានចូលរួមក្នុងចលនាខ្មែរឥស្សរៈនៅជំនាន់អាណានិគមនិយមបារាំង ។ ក្រោយមក គាត់បានទៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

នៅឆ្នាំ១៩៥៤ គាត់បានរៀបការជាមួយប្រពន្ធជនជាតិវៀតណាម និងមានកូនស្រីពីរនាក់ ។ នៅឆ្នាំ១៩៧០ គាត់បានចូលមកកម្ពុជាវិញ ដើម្បីវាយប្រឆាំងនឹងអាមេរិក ហើយក្រោយមកទៀត ខ្ញុំគ្រាន់តែដឹងថា គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ។

ជាចុងក្រោយ ខ្ញុំគ្រាន់តែដឹងថា ឪពុករបស់ខ្ញុំមានប្អូនប្រុសឈ្មោះ ពៅ ហ៊ុន និងប្អូនស្រីឈ្មោះ ពៅ ហ៊ម ។ សព្វថ្ងៃ ខ្ញុំនៅតែចង់ជួប និងសង្ឃឹមថា ពូមីង នឹងបានឃើញខ្ញុំ ហើយអាចមករកខ្ញុំ (ក្មួយ) នៅមន្ទីរពេទ្យធំ (ព្រះកេតុមាលា) ព្រោះសព្វថ្ងៃខ្ញុំជាគ្រូពេទ្យមធ្យមនៅមន្ទីរពេទ្យនេះ ។

**ពីក្មួយ កប ដាវី**

# «សល់មួយគ្រាប់»

## រឿងរ៉ាវ គ្រួសារខ្ញុំ ក្នុងរបបដឹកនាំខ្មែរក្រហម

***(តពីលេខមុន)***

### ***បងស្រីទាំងពីរ***

*ក្មេងៗដែលចាត់ចូលក្នុងក្រុមកងចល័ត ជាទូទៅមានអាយុច្រើនជាងបងស្រីរបស់ខ្ញុំ ។ ក្មេងៗដែលមានអាយុពី១៥ ទៅ២០ឆ្នាំ ត្រូវបានអង្គការបញ្ជូនឲ្យធ្វើការនៅក្នុងកងចល័ត ឆ្ងាយពីភូមិ ដូចជា ជីកប្រឡាយ លើកទំនប់ ឬការងារសំខាន់ៗដទៃទៀត ។ បងស្រីទាំងពីររបស់ខ្ញុំមានអាយុ១២ និង១៣ឆ្នាំប៉ុណ្ណោះ ប៉ុន្តែដោយសារតែគាត់ទាំងពីរមានកម្ពស់ខ្ពស់ ទើបអង្គការចាត់ចូលក្នុងកងចល័ត ។ គណៈសហករណ៍ក៏បានបញ្ជូនគាត់ទាំងពីរឲ្យធ្វើការក្នុងក្រុមកងចល័តដែរ ។*

*កងចល័តនេះមិនត្រលប់មកភូមិវិញទេ គឺអង្គការបញ្ជូនឲ្យទៅធ្វើការនៅឆ្ងាយ និងតម្រូវឲ្យសម្រាកនៅកន្លែងធ្វើការតែម្តង ។ នៅពេលដែលការងារនៅកន្លែងណាមួយចប់ កងចល័តនោះនឹងបន្តការងារនៅកន្លែងផ្សេងមួយទៀត ។*

*ខ្ញុំមិនដែលបានឃើញបងស្រីទាំងពីររបស់ខ្ញុំទៀតទេ ។ ខ្ញុំគិតថា គាត់ទាំងពីរច្បាស់ជាស្លាប់ដោយសារលក្ខខណ្ឌការងារដ៏ធ្ងន់ ការអត់អាហារ ឬជំងឺ ។ ប៉ុន្តែ ខ្ញុំមិនបានដឹងថាគាត់ស្លាប់នៅក្នុងការដ្ឋានការងារណាមួយ ឬពេលណាមួយឲ្យប្រាកដទេ ។ អ្នកដែលចេញទៅធ្វើកងចល័តនៅភូមិត្រាង មិនដែលឃើញត្រឡប់មកភូមិវិញនោះទេ ។*

### ***ការងារកងកុមារ***

*ការងារដំបូងរបស់ខ្ញុំ គឺឃ្វាលគោក្នុងសហករណ៍ត្រាង បានជាងពីរខែ ។ បន្ទាប់មក ខ្ញុំត្រូវបានគណៈសហករណ៍ចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងកុមារចល័ត ។ កុមារា កុមារីទាំងនោះ មកពីសហករណ៍ពីរដទៃទៀត គឺសហករណ៍កោះចារ និងសហករណ៍អកយំ ។ ខ្ញុំ ធ្វើការក្នុងកងកុមារចល័តនោះ ពេញមួយរបបខ្មែរក្រហម ។ នៅក្នុងកងរបស់ខ្ញុំ ក្មេងៗប្រុស-ស្រី មានអាយុពី១០ទៅ១៤ឆ្នាំ ។ កងកុមារទាំងអស់មានចំនួនប្រហែលពី៣០ទៅ៤០នាក់ ។ ជួនកាលគេហៅកងកុមារនេះថា ជា“កងកុមារឈានមុខ ឬជាក្រុមកុមារកូនអង្គការ” ។ កងយើងចាំទទួលបញ្ជាការងារពីអង្គការ ។ យើងត្រូវចល័តទីតាំងរហូត ។ មេកងពីរនាក់ ជាអ្នកដឹកនាំ មានសមមិត្តនារី កេត និងសមមិត្តយុវជន សេង ។ មិត្ត កេត និងមិត្ត សេង មានអាយុខ្ទង់១៦ឬ១៧ឆ្នាំ ។ មិត្ត កេត ជាកូនប្រជាជនចាស់មកពីភូមិជិតខាងឈាមជ័រជាកូនកាត់ចិន ។ ចំណែក មិត្ត សេង ជាកូនប្រជាជនចាស់ដែរ មកពីភូមិស្រុកកំណើតខាងឪពុកខ្ញុំដែរ ។ មិត្ត សេង ចេញពីសហករណ៍ត្រាងដូចខ្ញុំដែរ ។ សមមិត្ត សេង ជាប្រធានកងកុមារក្នុងសហករណ៍ត្រាងដែរ ។ បើសិនជាតាមអ្វីដែលខ្ញុំចាំបាន ជាទូទៅ ប្រធានកងខាងផ្នែកកុមារាមិនអាចជាប្រធានកងកុមារីបានទេ តែប្រធានកងកុមារីអាចជាប្រធានលើកងកុមារាបាន ។*

*“កងកុមារឈានមុខ” យើងទាំងអស់ធ្វើការជួនកាលនៅក្នុងភូមិ ជួនកាលទៀតនៅក្រៅភូមិ តាមការស្នើសុំពីគណៈសហករណ៍ពីអង្គការ ។ យើងរស់នៅជុំគ្នា ប្រមូលផ្តុំក្នុងទីជម្រកមួយនៅក្រៅភូមិ តាមទួលនានាជិតការដ្ឋានការងារ ។ សម្រាកនៅក្រោមរោងឬស្សីប្រក់ស្បូវពីរជិតគ្នា ។ រោងមួយសម្រាប់ក្រុមកុមារី និងមួយទៀតសម្រាប់ក្រុមកុមារា ។*

*ក្មេងៗដែលជាកូនប្រជាជនចាស់ ដែលមានអាយុប្រហែលក្រុមយើង មិនត្រូវបានចាត់ឲ្យទៅធ្វើការនៅឆ្ងាយពីភូមិឡើយ គឺរស់នៅជួបជុំគ្រួសារ និងធ្វើការក្នុងភូមិ ។*

*ពេលខ្លះមានអ្នកចូលមកថ្មីក្នុងក្រុម ហើយពេលខ្លះទៀត យើងត្រូវបានអង្គការបែងចែកជាក្រុមផ្សេងៗសម្រាប់ការងារផ្សេងៗពីគ្នា វាអាស្រ័យទៅលើការស្នើសុំតាមការចាំបាច់របស់អង្គការ ។*

មេកងទាំងពីរនាក់បានចាត់តាំងកុមារាបី-បួននាក់ធំៗឲ្យទទួលការងារដាំស្ល និងសែង បាយសម្ល ទៅការដ្ឋានការងារណាមួយដែលយើងទាំងអស់គ្នាត្រូវសម្រុកការងារខ្លាំង ។

ព្រឹកឡើងកងកុមារ ត្រូវក្រោកឡើងនៅម៉ោង៥ព្រឹក ដើម្បីធ្វើការ និងគ្មានអាហារពេលព្រឹកហូបទេ ។ ជួនកាល កុមារត្រូវដើរទៅកាន់ការដ្ឋានការងារទាំងនៅងងឹតនៅឡើយ ។ ការងារចម្រុះច្រើនមុខសម្រាប់ក្រុមយើង ដូចជា ធ្វើជី ដកសំណាប រែកសំណាប ស្ទូងស្រូវ លើកភ្លឺស្រែ ឃ្វាលគោ-ក្របី សំអាតស្មៅតាមស្រែ តាមចម្ការ ដញ្ជូនកណ្ដាប់ស្រូវ បោកស្រូវ សម្ដែងសិល្បៈបដិវត្តន៍ ។

## ការងារធ្វើជី

ព្រឹកឡើងក្រុមត្រូវរៀបចំធ្វើជីធម្មជាតិ ត្រូវដើរសំដៅទៅទីតាំងដែលបានបែងចែក តាំងពីពេលល្ងាច ។ ដើម្បីធ្វើជី យើងត្រូវកាប់មែកឈើតូចៗ ប្រមូលអាចម៍គោតាមរោង ប្រមូលកាកសំណល់ពីរោងបាយ ។ រួចយកមកចិញ្ច្រាំ ហើយលាយជាមួយផេះ បន្ទាប់មកទៀតលាយជាមួយនឹងដីដំបូក ហើយដាក់ហាលថ្ងៃពីរ ឬបីថ្ងៃ ។ បន្ទាប់មកយើងប្រមូលមកទុកនៅក្នុងរណ្ដៅមួយដើម្បីកុំឲ្យត្រូវភ្លៀង ។ ទុកចោលរហូតក្លាយជាជី រួចហើយទើបមានអ្នកមកយកទៅប្រើប្រាស់ដាក់ក្នុងស្រែ ។ ការងារ ធ្វើជី អាចចាត់ទុកថាការងារស្រួលជាងគេ ក្នុងចំណោមការងារដែលត្រូវធ្វើ ។

យើងត្រូវសម្លឹងមើលថ្ងៃ ប្រសិនបើថ្ងៃចាំងចំពីលើក្បាលយើងហើយ នោះទើបយើងអាចសម្រាកហូបអាហារពេលថ្ងៃត្រង់បាន ។ កងកុមារ គេឲ្យឈប់សម្រាកមុនមនុស្សពេញវ័យបន្តិច ។ ការងារឃ្វាលគោ-ក្របី នៅក្រោយពេលបាយថ្ងៃត្រង់ យើងត្រូវយកគោទៅឃ្វាល ។ ភារកិច្ច ត្រូវឲ្យគោស៊ីស្មៅឲ្យឆ្អែតល្អ សំអាត និងឲ្យវាសម្រាក ត្រូវប្រយ័ត្នកុំឲ្យគោចូលស៊ីដំណាំ ។ ប្រហែលជាម៉ោង៣រសៀល ត្រូវដឹកគោ-ក្របី ឲ្យក្រុមមនុស្សចាស់ កងភ្ជួររាស់ដើម្បីភ្ជួរស្រែម្ដងទៀត រហូតដល់ម៉ោង៥ល្ងាច ទើបយើងដឹកគោឲ្យស៊ីស្មៅម្ដងទៀត រហូតដល់ម៉ោងប្រាំមួយជាង យកគោមកចងក្នុងក្រោល រួចរៀបចំភ្នក់ភ្លើង ទើបខាងក្រុមយើងអាចត្រលប់ទៅរោងសម្រាកបាន ហើយហូបបាយពេលល្ងាច ។ សម្រាប់ខ្ញុំ ការងារឃ្វាលគោ-ក្របី ជាការងារលំបាក ដោយសារមូលហេតុទីមួយ ខ្ញុំមិនចំណាំគោ ជាពិសេស សត្វក្របី ដោយពណ៌ដូចៗគ្នា ទីពីរ សត្វក្របីចូលចិត្តដេកភក់ ហែលទឹក និងទីបី គោ-ក្របី ចូលក្នុងព្រៃ កន្លែងកប់ខ្មោច ខ្ញុំខ្លាចមិនហ៊ានចូលតាម ។

ការងារបោកស្រូវ នៅក្នុងរដូវប្រមូលផលកាត់ យើងត្រូវបោកស្រូវទៅនឹងបន្ទះក្ដារដំរេល គេហៅ ក្ដារបោក ដើម្បីឲ្យគ្រាប់ស្រូវជ្រុះចេញពីគួរ ។ ការបោកស្រូវភាគច្រើនបោកនៅពេលយប់ ។ យើងត្រូវបោកស្រូវ បោកហើយបោកទៀត ពេលយប់ចាប់ផ្ដើមពីម៉ោង៧យប់ អាចរហូតបន្តដល់ម៉ោង១១យប់ ។ មានចាក់ចម្រៀងបដិវត្តន៍ និងល្ខោននិយាយ ពីការតស៊ូរបស់យុទ្ធមិត្តសាយ និង យុទ្ធមិត្តដទៃទៀត ។

គេឲ្យខ្ញុំរវៃកង់ ដោយភ្ជាប់នឹងឌីណាម៉ូ ដើម្បីឲ្យមានភ្លើងអគ្គិសនី សម្រាប់យកចរន្តអគ្គិសនី ទៅប្រើម៉ាញេ ដែលមានភ្ជាប់ខ្សែភ្លើងទៅនឹងមេក្រូបំពងសំឡេងរាងផ្កាត្រកួន ។ ខ្ញុំ និងមិត្តរួមក្រុមម្នាក់ទៀត ជាអ្នកផលិតអគ្គិសនីដើម្បីឲ្យគេចាក់បទចម្រៀង និងរឿងរាវបដិវត្តន៍នានា សម្រាប់កំដរការងារបោកស្រូវ ។ ខ្ញុំចុកដៃ និងរោយដៃ ខ្ញុំត្រូវរវៃកង់រាប់ម៉ោង ។ ពេលខ្លះ ក្មេងផ្សេងទៀតមកប្ដូរវេណដែរ តែនៅតែត្រូវរវៃយូរដដែល ។ ហត់ ហើយងងុយដេកផង ណាមួយធ្វើការអស់កម្លាំងពីថ្ងៃទៀត ។ នៅពេលដែលខ្ញុំងោកម្ដងៗ ឬពេលដែលខ្ញុំរវៃមិនស្ទួវសកម្មនោះវាឮសំឡេងម៉្យាង សំឡេងដែលឮចេញមកឮស្ទូរយឺតៗ ដូចកាសែតដែលខូច ។ គេដឹងភ្លាមថា ខ្ញុំងោក ឬខ្ញុំរវៃមិនស្ទួវសកម្ម ដែលនាំឲ្យបង្វិលកង់មិនគ្រប់ កម្លាំងល្បឿនល្មមសម្រាប់ទាញម៉ូទ័រ ។ តែក៏គេមិនបន្ទោសចាប់កំហុសអ្វីដែរ ។

ការងារប្រជុំជីវភាពពេលល្ងាច បន្ទាប់ពីពេលបាយរួច មានការប្រជុំនៅក្នុងកងកុមារ ។ ម្ដងៗការប្រជុំស៊ីអស់រាប់ម៉ោង ។ យើងអង្គុយរៀងជារង្វង់មូល ។ គេប្រជុំសឹងតែជារៀងរាល់ថ្ងៃ ។ យើងអង្គុយផ្ទាល់នឹងដី ហើយនិយាយពីបញ្ហាឬចំនុចបីយ៉ាង ។

ចំនុចទីមួយដែលយើងនិយាយគឺអ្វីដែលយើងបានធ្វើកាលពីថ្ងៃៈ យើងត្រូវបញ្ចេញអារម្មណ៍របស់យើងថាយើងមានការពេញចិត្តជាមួយនឹងការងាររបស់យើងទេ ឬថាតើយើងរីករាយនឹងធ្វើការនោះដែរឬទេ? ។

ចំនុចទីពីរ គឺយើងត្រូវស្នើឲ្យក្មេងៗដទៃទៀតឲ្យធ្វើការវិនិច្ឆ័យនឹងវាយតម្លៃលើខ្លួនយើង ។ ការរៀបរាប់ពីសកម្មភាពរបស់

យើងតើមានភាពស្មោះត្រង់ដែរឬទេ? ហើយតើមានអ្វីទៀតដែលយើងមិនបានរៀបរាប់ឲ្យអស់ដែរឬទេ? ប្រសិនបើមានក្មេងៗដទៃទៀតគេទិតៀន និងរិះគន់យើង យើងត្រូវទទួលយកដោយមិនជំទាស់ ។ ក្នុងពេលប្រជុំម្តងៗ ខ្ញុំស្នើទៅក្មេងៗផ្សេងទៀតឲ្យវិនិច្ឆ័យខ្ញុំដោយនិយាយថា "អ្នកទាំងអស់គ្នាគឺដូចទៅនឹងកញ្ចក់ឆ្លុះមុខ អ៊ីចឹងខ្ញុំមិនអាចមើលឃើញកំហុស និងធ្វើការវាយតំលៃខ្លួនឯងបានទេ" ។ ជាឧទាហរណ៍ យើងអាចរៀបរាប់ពីកំហុសដែលយើងបានប្រព្រឹត្ត ។ ថ្ងៃមួយខ្ញុំបានសារភាពថាខ្ញុំបានធ្វើឲ្យជ្រុះសំណាបខ្លះៗ ហើយខ្ញុំមិនបានប្រមូលឲ្យបានអស់ទេ ទុកចោល ។ សំណាបត្រូវបានចងជាកណ្តាប់ខ្សែដែលចងកណ្តាប់នោះបានដាច់ ហើយសំណាបក៏បានធ្លាក់ខ្លះទៅដី ។ ក្មេងៗផ្សេងទៀតក៏រិះគន់មកយើងដែរនៅពេលដែលយើងមិនបានរៀបរាប់ឲ្យអស់ទេនោះ ដូចជាថាយើងបាន "ឈប់សម្រាកយូរ" ជាដើម ។ បន្ទាប់មកយើងក៏ត្រូវរិះគន់ពួកគេវិញម្តង ។ ហើយពេលខ្លះទៀត គេឲ្យយើងរៀបរាប់ពីសកម្មភាពរបស់ឪពុកម្តាយយើង ពេលដែលប្រធានកងអនុញ្ញាតឲ្យទៅលេងផ្ទះម្តងៗ ។

អ្នកដែលប្រើប្រាស់ពាក្យជាភាសាបារាំង ឬអង់គ្លេសក៏នឹងត្រូវគេធ្វើការរិះគន់ដែរ ។ ថ្ងៃមួយខ្ញុំបានឃើញមាន់ដាំងដុងធំមួយ-មាន់ទូគី ។ ប្រធានកងរបស់ខ្ញុំបានរិះគន់ខ្ញុំថាបានប្រើប្រាស់ពាក្យបរទេស "ដាំងដុង" ។ វាចំលែកដែរដោយសារតែពួកខ្មែរក្រហមខ្លួនឯង និងប្រធានកងកុមារទាំងពីរនាក់ប្រើពាក្យ " មីទីង" រាល់ថ្ងៃ ជំនួសឲ្យពាក្យថាការប្រជុំ ។ រឿងនោះមិនបានជះឥទ្ធិពលអ្វីផ្សេងមកលើខ្ញុំទេ ។ ផ្ទុយទៅវិញ ប្រសិនបើជាមនុស្សធំវិញ គេមុខជានឹងធ្វើការតាមដាន ឬមុខជានឹងត្រូវគេយកទៅកសាងឬអាចសម្លាប់ក៏ថាបាន ។

ចំនុចទីបី នៅក្នុងពេលប្រជុំនេះ ខ្មែរក្រហមតែងតែនិយាយដដែលៗថាយើងជាកូនរបស់អង្គការ ។

"ឪពុកម្តាយរបស់យើងគ្រាន់តែបានបង្កើតយើងដើម្បីសប្បាយតែប៉ុណ្ណោះ ។ ដូច្នេះពួកគេគឺគ្មានប្រយោជន៍ទេ" ។ គេរិះគន់ឪពុកម្តាយយើងបន្តិចម្តងៗ យើងក៏ចាប់ផ្តើមគិតថាឪពុកម្តាយយើងពិតជាគ្មានបានការមែន ។

នៅក្នុងពេលប្រជុំមួយ កុមារម្នាក់បានធ្វើការរៀបរាប់ថាឪពុកម្តាយខ្លួនបានលួចដំឡូង និងលួចសម្លាប់មាន់ដើម្បីហូប ។ ពីរឬបីថ្ងៃក្រោយមក យើងបានឃើញឪពុកម្តាយក្មេងនោះត្រូវបានគេចងដើម្បីយកទៅ "រៀនសូត្រ" ។ អ្នកដែលត្រូវបានគេយកទៅរៀនសូត្រមិនដែលឃើញត្រឡប់មកភូមិវិញឡើយ ។

ការផ្សារហាត់សិល្បៈបដិវត្តន៍ នៅថ្ងៃខ្លះទៀត បន្ទាប់ពីប្រជុំរួច ក្មេងៗត្រូវរៀនរាំ និងហាត់ច្រៀងចម្រៀងបដិវត្តន៍ទៀត ។ ខ្ញុំចងក្រមារនៅចង្កេះ ឬជួតក្បាលក្រមារទៅតាមទំនុក និងបែបបទរបាំ ។ ប្រធានបទសំខាន់ៗនៃបទចម្រៀងទាំងនោះគឺនិយាយពីកសិកម្ម និងកងទ័ព ។ វាមានលក្ខណៈដូចនឹង "ពួកកូរ៉េញ៉ុងយ៉ាង" ចង្វាក់ និងចម្រៀងជោគជ័យរបស់អង្គការ ។ ប្រធានក្រុមជាអ្នកបង្រៀនពួកយើងពីសិល្បៈបដិវត្តន៍នេះ ។

របបហូបចុកក្នុងកងរបស់ខ្ញុំ ក្មេងៗ ៣ ឬ ៤ នាក់ បានទទួលបញ្ជាឲ្យរៀបចំអាហារពេលថ្ងៃ និងពេលល្ងាច សម្រាប់សមាជិកក្រុមផ្សេងៗទៀត ។ ភាគច្រើនបំផុតនោះ យើងញ៉ាំបបរយូរៗម្តងទើបអាចបានញ៉ាំបាយ ។ ជាញឹកញាប់បំផុតនោះ យើងញ៉ាំបាយជាមួយសម្លត្រកួន ដំឡូងឈ្វា សម្លកកូរ ឬ សម្លប្រហើរ ។ ប៉ុន្តែយើងមិនអាចញ៉ាំបានមួយចម្អែតទេ ។ យើងចង់ញ៉ាំបាយឲ្យបានច្រើនជាងនេះ ប៉ុន្តែយើងអត់បានតាមចិត្តចង់ទេ ។ ពេលខ្លះទៀតយើងមិនទាំងញ៉ាំសម្លឲ្យអស់ផង ដោយសារតែវាគ្មានជាតិចូវអីសោះ ។ យើងអង្គុយជារង្វង់តូចៗ មានគ្នា ៥-៦នាក់ លើដីផ្ទាល់ម្នាក់ៗមានចាននិងស្លាបព្រារៀងៗខ្លួន ហើយរក្សាទុកដោយខ្លួន ។ ក្រុមក្មេងៗ ចម្អិនអាហារ ដួសបាយ ឬ បបរចែកយើងទាំងអស់គ្នាតាមរបបគេកំណត់ ដ៏តិចតួច ហើយចែក សម្ល តាមក្រុម ។ ក្មេងៗធ្វើការលំបាកណាស់ និងគ្មានអ្វីហូបឲ្យបានគ្រប់គ្រាន់ទេ ។ យើងលែងអាចស្តាប់ឮសំលេងក្មេងៗសើចលេងទៀតហើយ ។ ពួកយើងម្នាក់ៗធ្លាក់ខ្លួនឈឺ និងហេវហត់អស់កម្លាំងជាខ្លាំង ។ មេកងពីរនាក់មិនទាន់ហូបភ្លាមៗទេ គេរង់ចាំមើលទាល់តែក្មេងៗទាំងអស់ឈប់ហូប ហើយបញ្ជាឲ្យចូលរោងសម្រាក ។ មេកងពីរនាក់មានរបបបាយ សម្ល ហូប ពិសេសដាំឆ្នាំងដោយឡែក ។ ក្រុមក្មេងៗដែលទទួលបន្ទុក ចម្អិនអាហារហូបក្រោយ ។

ការរស់នៅ និងសម្រាក ក្មេងៗគេងបានប្រហែល៦ម៉ោងក្នុងមួយថ្ងៃ ។ ខ្ញុំមានរូបរាងស្គមស្គាំងជាខ្លាំង ។ ខ្ញុំមិនបានដឹងថា

មុខមាត់ និងសក់ក្បាលរបស់ខ្ញុំដូចទៅនឹងអ្វីទេ ដោយសារតែយើងគ្មានកញ្ចក់ឆ្លុះមើលរូបខ្លួន ។ យូរៗមានគេមកកាត់សក់ឲ្យម្តង ។ ខ្ញុំរើសសំលៀកបំពាក់ ដែលប្រជាជនចាស់បោះចោល ឬស្លៀកពាក់សំលៀកបំពាក់ដែលគេប្រើប្រាស់រួច ហើយមានតែមួយសម្រាប់តែប៉ុណ្ណោះ ។ ជួនកាល ជាសំលៀកបំពាក់ដែលមេកង ឬគណៈសហករណ៍ យកមកចែកឲ្យមកពួកយើងម្តងៗ ។ ប្រហែលជាយើងប្រើប្រាស់សំលៀកបំពាក់របស់អ្នកដែលត្រូវគេសម្លាប់ផងក៏មិនដឹង ។ មានតែកូនៗរបស់អ្នកមូលដ្ឋានទេដែលមានសំលៀកបំពាក់ថ្មីៗពាក់ចេញពីរោងចក្រ ។ ក្មេងៗភាគច្រើន មិនមានទ្រនាប់ជើង ពាក់ទេ ។

យើងផឹកទឹកមិនថានៅទឹកន្លែងណាទេ មិនថាទឹកអ្វីជាអ្វីទេ ។ អាចជាទឹកបឹងបួរ ដែលសត្វ និងមនុស្សផឹករួមគ្នា ។

យើងទាំងអស់ត្រូវដេកនៅក្នុងរោងឬស្សី ប្រក់ ស្បូវ ដេកផ្ទាល់នឹងដី ក្រាលចំបើង ឬ សម្ភារអ្វីៗ ដែលអាចយកមកក្រាលបាន ។ ក្មេងៗដេកជាជួរៗ ជាពីរជួរ ជើងទល់គ្នា ។ យប់ខ្លះ ខ្ញុំដេកនៅក្នុងពំនូកចំបើង ដោយមិនដឹងខ្លួន ។ នៅរដូវក្តៅ យើងក្រោកពីដំណេកនៅម៉ោងប្រាំព្រឹក រួចសំដៅទៅធ្វើការ ។ ក្នុងរដូវភ្លៀង ខ្លាំងមេកង អាចឲ្យយើងក្រោកនៅព្រឹកបន្តិចបាន ។ ក្រុមមនុស្សចាស់ៗបានមកធ្វើ ផ្ទើរ ខ្ពស់ផុតពីដី ពីរនាបកូនឈើឲ្យពួកយើងដេក ពីលើនៅ រដូវភ្លៀង ។

ជីវភាពរស់នៅ របស់ក្មេងៗមានសភាពដូចទៅនឹងសត្វដែលត្រូវគេបោះបង់ចោល ។ យើងឥតមានអ្វីទាំងអស់ គ្មានទាំងសំលៀកបំពាក់ ហើយត្រូវដេកដូចគោក្របី ។ រស់នៅ ហូបចុក គ្មានទាំងអនាម័យផង គ្មានសាប៊ូសម្រាប់ដុសខ្លួន កក់សក់ ។ យើងរស់នៅក្នុងភាពភ័យខ្លាច និងតក់ស្លុត ។ ខ្ញុំមិនហ៊ាននិយាយប្រាប់អ្នកណាថា ខ្ញុំជាកូនអ្នកណាទេ ឬមកពីណាទេ ។ ខ្ញុំមិនអាចឲ្យក្មេងៗណាមួយ ក្នុងក្រុមដឹងប្រវត្តិពិតរបស់ខ្ញុំឡើយ ។

ពេលយប់ ខ្ញុំយល់សប្តិឃើញសាលារៀន និង មិត្តរួម ថ្នាក់របស់ខ្ញុំ ។ ខ្ញុំស្រម័យថាបានចូលរៀនដូចពេលមុន ។ ខ្ញុំស្រម័យថាបានជួបជុំគ្រួសារខ្ញុំវិញ និងស្រមើស្រម័យថាបានហូបម្ហូបអាហារឆ្ងាញ់ៗ ។

វាសំណាងធំណាស់ ដែលខ្ញុំមិនធ្លាក់ខ្លួនឈឺ ។ វាពិតជាគួរឲ្យឆ្ងល់ដែរ ប្រហែលជាគុណបុណ្យឪពុក ទឹកដោះម្តាយថ្ងៃជួយ ។

ទទួលអង្គការ ពេលល្ងាចថ្ងៃមួយ ប្រហែលឆ្នាំ១៩៧៦ ។ មេកងទាំងពីរ បានប្រាប់ថា ក្រុមយើងត្រូវទៅទទួលអង្គការថ្នាក់លើ ។ដូច្នេះមិត្តទាំងអស់ ត្រូវត្រៀមឲ្យបានដាច់ខាត ។ ស្អែកឡើង មានក្រុមចាស់ៗ មកកាត់សក់ឲ្យពួកយើងទាំងអស់ និងចែកសាប៊ូដុះសម្រាប់ដុះខ្លួន ។ ចុងភៅបានឲ្យបាយ យើងហូបឆ្អែតគ្រាន់បើ ថែមទាំងមានបបរដំឡូង ស្ករ ឲ្យថែមទៀត ។ យើងត្រូវចេញដំណើរតាំងពីថ្ងៃជ្រេ រហូតយប់ទើបដល់ទីតាំង ដែលយើងត្រូវរង់ចាំ ។ ប្រហែល ឃុំស្វាយដូនកែវ ជាប់ថ្នល់ជាតិ ។ ម្នាក់ៗសប្បាយចិត្ត ពេលឃើញ ថ្នល់ជាតិ ហើយខ្លះបានដេកលេង លើថ្នល់កៅស៊ូនោះ ។ ជិតភ្លឺ មេកងយកអាវ ខោ ពណ៌ខ្មៅ ថ្មីៗ មកឲ្យពួកយើងពាក់ ។ យើងរង់ចាំរហូតដល់ថ្ងៃត្រង់ តែមិនឃើញអង្គការថ្នាក់លើណាមកទេ ។ មេកងប្រមូល ខោ អាវ ពណ៌ខ្មៅ ថ្មីៗទុកវិញ ។

មិត្តរួមក្រុមម្នាក់ស្លាប់ នៅល្ងាចមួយ ក្រោយពេលបាយរួចមានក្មេងប្រុសម្នាក់ ឈ្មោះ មិត្ត ធី នៅក្នុងក្រុមបានប្រាប់ខ្ញុំឲ្យទៅប្រាប់ទៅប្រធានកងថា វាឈឺពោះខ្លាំងណាស់ ។ ប្រធានកងបានឆ្លើយមកវិញថាវាមិនមានធ្ងន់អ្វីទេ ។ ខ្ញុំបានត្រឹមតែរឹតប្រាប់ពោះវាប៉ុណោះ ។ លុះព្រឹកស្អែកឡើង នៅពេលដែលគេដាស់ពួកយើងឲ្យក្រោកទៅធ្វើការ ក្មេងនោះបានស្លាប់បាត់ទៅហើយ ។ មិត្ត ធី ដេកជាប់នឹងខ្ញុំ ។ ជាទូទៅ នៅពេលដែលយើងប្រាប់គេថាឈឺប្រធានកងខ្មែរក្រហមភាគច្រើន តែងតែគិតថា យើងបន្លំ និងធ្វើពុតជាឈឺ ។ ក្មេងប្រុសនោះមិនបានកុហកទេ វាស្រែកដោយការឈឺចាប់ពេញមួយយប់ដោយការចុកពោះ ។ ប៉ុន្តែប្រធានកងបើទុកជាគេទទួលស្គាល់ថាក្មេងនោះឈឺពិតប្រាកដមែន ក៏គ្មានថ្នាំសង្កូវ ជួយ ឬថាគេមិនដឹងត្រូវនាំកុមារនោះទៅណាដែរ ដោយសារតែយើងដេកក្នុងរោង ខ្ទមនៅកណ្តាលវាលស្រែ យើងមិនស្ថិតនៅក្នុងភូមិឯណា ។ ខ្ញុំមិនបានដឹងថាគេយកក្មេងនោះទៅកប់នៅទីណាទេ ។ មិត្ត ធី ពេលនោះ មាន អាយុប្រហែល ដប់ពីរ ឬដប់បី ឆ្នាំ ។ ខ្ញុំមិនដឹង ថា ឪពុកម្តាយជាអ្នកណាទេ ។

មិត្តរួមក្រុមម្នាក់ត្រូវសម្លាប់ ថ្ងៃមួយ ខ្ញុំត្រូវឃ្វាលក្របីជាមួយក្មេងៗផ្សេងទៀតនៅឆ្ងាយពីភូមិ ។ ក្មេងប្រុសម្នាក់ឈ្មោះមិត្ត ទ្រី ជាកូនកាត់ចិន ។ ក្រោយពេលបាយល្ងាចរួច បានចូលទៅ

ក្នុងព្រៃមិនឆ្ងាយប៉ុន្មានពីរោងយើងដេក ។ នៅពេលដែលមិត្ត ទ្រី ត្រលប់មកវិញ ទ្រី បានយួរដុំសាច់មួយដុំធំកាន់នៅនឹងដៃ ។ ទ្រី បានយកឆ្នាំងដើម្បីចម្អិនសាច់ ហើយបានចែករំលែកដុំសាច់ចម្អិនជាមួយក្មេងផ្សេងៗទៀត ។ ខ្ញុំ និងក្មេងៗ ប្រហែលជាជាងដប់នាក់ អង្គុយហូបជុំវិញជាមួយគ្នា ។

ប្រហែលជាឈ្លបបានឃើញពួកយើងកំពុងតែអង្គុយហូបសាច់នោះហើយមើលទៅ ទើបក្រុមគេបានដើរសំដៅមក ។ គេភ្ជង់កាំភ្លើងមកលើពួកយើង ហើយបានសួរថាតើអ្នកណាគេជាអ្នកលួចសម្លាប់កូនគោយកសាច់មកហូប ។ ម្នាក់ៗភ័យញ័រខ្លួន ។ តែមិត្ត ទ្រី បានឆ្លើយថា គាត់តែម្នាក់ឯងគត់ដែលបានយកសាច់ ដោយសារតែគាត់ឃើញកូនគោនោះ ស្លាប់នៅក្នុងព្រៃ ហើយគិតថាប្រហែលជាកូនសត្វព្រៃស្លាប់ ។ ប៉ុន្តែ ខ្មែរក្រហមបានឆ្លើយថា វាមិនមែនជាសាច់សត្វព្រៃទេ ប៉ុន្តែជាកូនគោដែលគេបានបាត់ ។ ពួកខ្មែរក្រហមបានចង មិត្តទ្រី ផ្អោបទៅនឹងគល់ឈើមួយក្នុងពេលយប់នោះ ។

លុះស្អែកភ្លឺឡើង ខ្ញុំឃើញ មិត្ត ទ្រី នៅចងភ្ជាប់ជាមួយនឹងគល់ឈើដដែល គេចងទ្រី ទុកមួយយប់របៀបនេះ ។ ខ្មែរក្រហមបានប្រាប់ទៅក្មេងៗឯទៀតកុំឲ្យធ្វើត្រាប់តាមមិត្តទ្រី កុំឲ្យយកគំរូតាមមិត្រ ទ្រី បើមិនអីចឹងទេគេនឹងកម្ទេចចោលទាំងអស់ ។ ខ្មែរក្រហមមិនប្រើពាក្យ "សម្លាប់" ឲ្យចំទេ ។ គេប្រើពាក្យ "កម្ទេច" ដែលមានន័យស្មើនឹងសម្លាប់ ។

ដល់ពេលបាយថ្ងៃត្រង់ ខ្មែរក្រហមបានស្រាយចំណងមិត្តទ្រី ហើយនាំគាត់ចូលទៅក្នុងព្រៃ ។ ទ្រី បានលើកដៃជាសញ្ញាលាមកកាន់ពួកយើង ។ ទ្រី បានទុកស្បែកជើងរបស់ខ្លួនឲ្យពួកយើង ។ ខ្ញុំគិតថា ទ្រី ច្បាស់ជាបានយល់ថាគាត់មុខជានឹងត្រូវគេសម្លាប់ហើយ ។ ពួកយើងមិនបានដឹងពីទីកន្លែងដែលគេសម្លាប់ ទ្រី ទេ ប៉ុន្តែគ្រាន់តែបានឃើញថា ខ្មែរក្រហមត្រលប់មកវិញដោយគ្មាន ទ្រី មកជាមួយ ។ ក្មេងៗផ្សេងទៀត បន្ទាប់ពីបាយថ្ងៃត្រង់រួចបានទៅស្វែងរកក្រែងលោឃើញសាកសពមិត្ត ទ្រី ប៉ុន្តែមិនបានរកឃើញទាល់តែសោះ ។

ទ្រី មានមាឌរៀងធំខ្ពស់ ហើយមានអាយុប្រហែលជាដប់បួន ឬដប់ប្រាំឆ្នាំកាលនោះ ។ គាត់ច្រៀងចម្រៀងបដិវត្តន៍បានពីរោះណាស់ ។ ពេលនោះបើសិនណា មិត្តទ្រី បានឆ្លើយថា ពួកយើងបានចូលរួមក្នុងសកម្មភាពនោះ ហើយថាខ្លួនមិនបានចូលទៅយកសត្វក្នុងព្រៃតែឯងទេ នោះមុខជាយើងនឹងត្រូវគេសម្លាប់ដូច ទ្រី ជាមិនខានទេ ។

ខ្ញុំបានឮគេនិយាយថា ខ្ញុំឮសួរក្មេងៗនៅក្នុងកងរបស់ខ្ញុំនិយាយថាពួកខ្មែរក្រហមនៅពេលដែលគេសម្លាប់មនុស្សហើយពួកគេយកថ្លើមអ្នកនោះទុកស៊ី ។ ហើយយើងចំណាំអ្នកដែលស៊ីថ្លើមនោះដឹងបាន ដោយសារ ពួកគេមានភ្នែកក្រហម ដូចឈាម ។ ខ្ញុំបានសួរថាតើហេតុអ្វីបានជាពួកគេស៊ីថ្លើមមនុស្ស? គេបានប្រាប់ខ្ញុំថា ការដែលធ្វើយ៉ាងដូច្នោះគឺដើម្បីឲ្យចិត្តមុត ហ៊ានសម្លាប់មនុស្ស ។

មេកងម្នាក់ប្រាប់ឲ្យលាក់ប្រវត្តិ ថ្ងៃមួយ កំពុងដឹកគោទៅឃ្វាល ស្រាប់តែមានកម្មាភិបាលម្នាក់ ជិះសេះ ស្ពាយកាំភ្លើងតម្រង់មកក្រុមខ្ញុំ ។ ពួកយើងភ័យខ្លាចមានរឿងអ្វីអាក្រក់កើតមកលើពួកយើង ។ កម្មាភិបាលនោះបានសាកសេះកាន់តែជិតខ្ញុំហើយឲ្យខ្ញុំឈប់ ។ ខ្ញុំគ្មានព្រលឹងក្នុងខ្លួនបន្តិចសោះ គិតថា ត្រូវគេយកទៅសម្លាប់ថ្ងៃនេះ ។ រួចគាត់បញ្ជាឲ្យក្មេងៗដទៃទៀត ដឹកគោទៅមុខ ។ កម្មាភិបាលនោះចាប់ផ្តើមនិយាយ ដោយស្រទន់មកកាន់ខ្ញុំ ។ គាត់ថា ស្គាល់ឪពុកម្តាយខ្ញុំច្បាស់ណាស់ ធ្លាប់ចេញចូលទៅហូបបាយ គេងសម្រាកនៅផ្ទះខ្ញុំ ។ ក្មួយត្រូវលាក់ប្រវត្តិរូបខ្លួន កុំឲ្យអ្នកណាដឹងឲ្យសោះ ។ ត្រូវដាំដើមគ-កុំនិយាយស្តី កុំសួរ កុំនាំកុំទៅលេងបងប្អូន-ម្តាយ ក្នុងភូមិឲ្យសោះ ចាប់ពីពេលនេះតទៅ ។ ពូឈប់នៅសហករណ៍គ្រាងនេះទៀតហើយ ។ ក្មួយត្រូវ ចាំកុំឲ្យភ្លេចណា ។ ជួបគ្នា ថ្ងៃណាមួយ ។ គាត់ក៏បំបោលសេះចេញទៅ ។ ខ្ញុំនៅតែនឹកមិនឃើញ រហូតដល់សព្វថ្ងៃ ថាគាត់ជានរណា? ឈ្មោះ អ្វី ហើយធ្វើអ្វី ? ។ ម្តាយខ្ញុំក៏ធ្លាប់ប្រាប់ពាក្យទាំងប៉ុន្មាននោះ ដែរ នូវពេលខ្ញុំចូលក្នុងភូមិបានជួបគាត់ម្តងៗ ។

## ការស្លាប់ម្តាយ និងបងប្អូនរបស់ខ្ញុំ

ប្រហែលចុងឆ្នាំ១៩៧៧ ។ នៅពេលដែលក្រុមខ្ញុំត្រឡប់មកធ្វើការក្នុងភូមិវិញមួយរយៈ ។ ខ្ញុំមិនបានឃើញបងប្អូនប្រុសស្រីរបស់ខ្ញុំបួននាក់ទៀតទេ ឃើញតែប្អូនស្រីពៅម្នាក់គត់ ។ ខ្ញុំបានសួរម្តាយរបស់ខ្ញុំ ប៉ុន្តែគាត់មិនបានឆ្លើយតបមកខ្ញុំវិញទេ ។ គាត់បានប្រាប់ខ្ញុំកុំឲ្យសុំគេត្រឡប់មកភូមិទៀត ហើយកុំឲ្យប្រាប់គេថា

នរណាជាឪពុកម្តាយរបស់ខ្ញុំ ។ ម្តាយខ្ញុំប្រាប់ទៀតថា ប្រសិនបើមានគេសួរ ខ្ញុំត្រូវនិយាយថានៅមុនសម័យខ្មែរក្រហម ខ្ញុំគឺជាអ្នកសុំទាន ឬជាអ្នករត់តុនៅក្នុងហាងគុយទាវ ។ ម្តាយខ្ញុំចង់ឲ្យខ្ញុំនិយាយថាខ្ញុំអត់មានបងប្អូនសាច់ញាតិទេ ហើយមិនត្រូវនិយាយថានរណាជាឪពុករបស់ខ្ញុំទេ ។ ខ្ញុំអាចនិយាយថាពុកម៉ែខ្ញុំគឺជាកម្មករ ហើយខ្ញុំមិនដឹងជាពួកគាត់នៅទីណាឡើយ ។ ម្តាយខ្ញុំប្រាប់ឲ្យខ្ញុំលាក់ប្រវត្តិរូប ។ គាត់គិតថាបើខ្ញុំមិនត្រឡប់មកភូមិទេ ប្រហែលជាខ្ញុំអាចរស់បាន ។ គាត់ចង់ឲ្យខ្ញុំចេញពីភូមិគ្រាន់ដើម្បីកុំឲ្យគេស្គាល់ ។

ខ្ញុំមិនបានដឹងថាបងប្អូនប្រុសស្រីរបស់ខ្ញុំទាំងអស់ស្លាប់យ៉ាងណាទេ ។ ខ្ញុំក៏មិនបានដឹងថាពួកគេស្លាប់ដោយសារអ្វីដែរ ។ ខ្ញុំគ្រាន់តែបានឮអ្នកភូមិនិយាយថាពួកគេស្លាប់អស់ហើយ ។ លុះក្រោយមកទៀត ម្តាយខ្ញុំស្លាប់ក្រោយគេ ។ ប្រហែលជាដោយសារការអត់ឃ្លាន ជំងឺ ឬប្រហែលជាដោយសារការឈឺចាប់ខ្លាំងពេក ។

ពេលចុងក្រោយបង្អស់ដែលខ្ញុំបានឃើញប្អូនស្រីពៅរបស់ខ្ញុំ-ឆវីន ។ បន្ទាប់ពី ម្តាយខ្ញុំស្លាប់ ។ ប្អូនស្រីឆវីន ត្រូវបានគេបញ្ជូនទៅដាក់នៅក្នុងកន្លែងមួយដែលពួកខ្មែរក្រហម ដាក់ក្មេងៗដែលគ្មានអ្នកណាគេមើលថែ។ ប្អូនស្រី ខ្ញុំមានអាយុប្រហែលជាបី ឬបួនឆ្នាំកាលនោះ ។ នៅពេលដែលខ្ញុំឃើញប្អូនស្រី នាងមានតែខោខ្លីមួយប៉ុណ្ណោះ គ្មានអាវពាក់ ស្គមខ្លាំង ។ នៅពេលដែលខ្ញុំឃើញនាងក្នុងសភាពបែបនេះ ខ្ញុំមានការអាណិតអាសូរនាងជាខ្លាំង ចង់ស្រែកយំ ។

គឺជាពេលមួយដែលខ្ញុំមិនអាចបំភ្លេចបានទាល់តែសោះក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំបានឃើញប្អូនស្រីខ្ញុំនៅក្នុងស្ថានភាពជិតស្លាប់ ។ ប៉ុន្តែខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់ ។ ខ្ញុំចង់មើលថែរក្សានាង ប៉ុន្តែមិនដឹងជាធ្វើតាមរបៀបណា ។ ខ្ញុំមានអារម្មណ៍ថាខ្លួនឯងឥតប្រយោជន៍ ពីព្រោះខ្ញុំមិនអាចជួយនរណាបានទាំងអស់ក្នុងចំណោមបងប្អូនទាំងអស់ ។ (ទឹកភ្នែកហូរមិនឈប់នឹកដល់រឿងនេះ) ។ ខ្ញុំនៅចំណាំប្អូនស្រីពៅខ្ញុំបាន ហើយនាងបានសំឡឹងមើលមកខ្ញុំក្នុងគោលបំណងចង់ឲ្យខ្ញុំជួយនាង ។ ខ្ញុំបានឃើញប្អូនស្រីប្រហែលជាប្រាំនាទីប៉ុណ្ណោះ ពីព្រោះខ្ញុំត្រូវបន្តដំណើរទៅតាមក្រុមរបស់ខ្ញុំ ។ កាលពីមុននៅពេលដែលខ្ញុំត្រលប់មកភូមិ ខ្ញុំឃើញប្អូនស្រីម្តងម្កាលដែរ ។ ពេលចុងក្រោយដែលខ្ញុំបានឃើញប្អូនស្រី ខ្ញុំមានអាយុប្រហែលជាជាង់បីឆ្នាំ ។ ខ្ញុំមានអារម្មណ៍ថា នៅពេលដែលប្អូនស្រីបានឃើញខ្ញុំ ។ ប្អូនស្រីដូចជាអង្វរខ្ញុំឲ្យជួយ ។ ខ្ញុំគិតថាប្រសិនណាបើខ្ញុំបាននៅជាមួយប្អូនស្រីខ្ញុំ ហើយស្លាប់ជាមួយប្អូនស្រី វាប្រហែលជាធូរស្រាល មិនឈឺចាប់លំបាកដូចដែលខ្ញុំបានបន្តរស់មកដល់សព្វថ្ងៃនេះ ម្នាក់ឯងយ៉ាងនេះឡើយ ។ តាមការពិតទៅខ្ញុំក៏មិនបានដឹងដែរថាតើប្អូនស្លាប់ឬរស់យ៉ាងណាទេ? ។ ប៉ុន្តែបើទោះជាប្អូននៅរស់ក៏ប្អូនមិនស្គាល់ឈ្មោះឪពុកម្តាយ និងឈ្មោះខ្លួនឯងផងទេដែរ ។ ពីព្រោះនាងមានអាយុត្រឹមតែបី-បួនឆ្នាំប៉ុណ្ណោះកាលនោះ ។

## ការវាយចូលរបស់កងទ័ពវៀតណាម

ព័ត៌មានពីការវាយលុកចូលរបស់កងទ័ពវៀតណាម មិនមានផ្សព្វផ្សាយប្រាប់ប្រជាជនទេ ។ ក្រុមកុមារយើង ក៏មិនដឹងដែរ ។ ប៉ុន្តែយើង កត់សម្គាល់ថា មានការប្រែប្រួលក្នុងចំណោមប្រជាជនចាស់ ។ ពួកគេខ្សឹបខ្សៀវគ្នាចំឡែក ។ មេកង ក្រុមកុមារយើងទាំងពីរថា ទៅប្រជុំនៅភូមិ ក៏មិនឃើញត្រឡប់មកវិញ ។ កងឈ្លបធ្លាប់ដើរស៊ើបការណ៍ចុះឡើង ក៏បាត់ទៅណាអស់ ។ គ្មាននរណាប្រាប់ផែនការការងារថ្មីអ្វីទៀត ។ ពួកយើងសម្រាក ។ ពូមីង អ៊ំ ចាស់ៗ ប្រជាជនថ្មីមកយកកូនគេរៀងៗខ្លួន ។ អ្នកខ្លះ លួចប្រាប់ យើងឲ្យរត់ទៅរកឪពុកម្តាយ ។ ខ្ញុំ និងមិត្តរួមក្រុម ប្រហែល ១០នាក់ មិនទៅណាទេ ព្រោះគ្មានឪពុកម្តាយ បងប្អូននឹងគេ ។ យើងចាប់ត្រីដាំបាយហូបឆ្អែត បានបី-បួនពេលដែរ ។យប់ឡើងក៏និយាយពីនេះពីនោះ សប្បាយៗ និងហាក់មានសង្ឃឹម ។

ប្រហែល យប់ទីបី មានកងយុទ្ធជនឈ្លបមួយក្រុមតូច បានមកយកក្រុមយើង ដែលសេសសល់ឲ្យដើរទៅតាមគេទាំងយប់ងងឹត ។យើងប្រើអស់ពេលពីរយប់ បីថ្ងៃ កាត់ព្រៃ ។ ក្រុមយើងបានទៅដល់តំបន់មួយ មានទីតាំង ជាប់ទំនប់ទឹកដ៏ធំ វែង ។ ទំនប់ទឹកដ៏ធំនោះ បានសាងសង់ឡើង ដោយក្រុមយុវជនយុវនារី កងចល័តជាច្រើន មកពីគ្រប់ទិសទី ។ ក្រុមខ្ញុំ គេឲ្យស្នាក់នៅក្នុងរោងធំ វែងមួយ ជាមួយ មិត្តបងៗ យុទ្ធជនកងទ័ព ។ មិត្តបងៗ យុទ្ធជនកងទ័ពទាំងនោះ រួសរាយរាក់ទាក់ពួកយើងណាស់ មិនកាចដូច ក្រុមកងឈ្លបតាមភូមិ ដែលយើងធ្លាប់ជួបពីមុនទេ ។ បងៗខ្លះ ចង់ឲ្យពួកយើងចូលក្រុមកងទ័ពជាមួយគាត់ ។ គាត់ឲ្យបាយយើងហូបឆ្អែតៗ មិនដែលនិយាយពីការបែងចែក រវាងប្រជាជនចាស់ និងប្រជាជនថ្មី

ឡើយ ។ កងទ័ពវៀតណាមមិនទាន់វាយទៅដល់តំបន់នោះទេ ។ ខ្មែរក្រហមផ្សព្វផ្សាយពីសត្រូវយួនឈ្លានពាន និងក្រុមក្បត់ បានសម្លាប់យុទ្ធមិត្ត និងប្រជាជនខ្មែរស្លូតត្រង់ ក្នុងមួយថ្ងៃ ពី៣ទៅ៤ដង ។ ពូ-មីង អ៊ីចាស់ៗ ជាប្រជាជនថ្មី ពីសហករណ៍គ្រាង និងសហករណ៍ផ្សេងៗ ក៏បោះទីតាំងរស់នៅជិតៗរោងនោះដែរ ។ ខ្លះមិនទាន់បានជួប ជុំ ប្តី-ប្រពន្ធ កូន-ចៅ គាត់នៅឡើយទេ ។ ពូមីងអ៊ីចាស់ៗ ដឹង យើងគ្មាន ឪពុក-ម្តាយ សុំឲ្យពួកយើងធ្វើជាកូនចិញ្ចឹមគាត់ ។

អំឡុង ខែមេសា ឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់ទៅភូមិគ្រាងម្តងទៀត ជាមួយ ពូៗពីរនាក់ ។ គាត់លះបង់ពេលវេលាជូនដំណើរជួយខ្ញុំ ដើម្បីស្វែងរកប្អូនស្រីពៅ ។ ប៉ុន្តែជាការឥតប្រយោជន៍ដូចរកម្ជុលក្នុងសមុទ្រ ។ ក្នុងចិត្តខ្ញុំបន្សល់នូវតែការឈឺចាប់ខ្លោចផ្សាឯកោ និងបាក់ទឹកចិត្ត ។ ប៉ុន្តែ ខ្ញុំខិតខំប្រេជ្ញា តាំងចិត្តប្រឹងតស៊ូដើម្បីរស់បន្ត សង្ឃឹមជួបប្អូនស្រីថ្ងៃណាមួយ ។

ពេលចុះមកដល់ថ្នល់ជាតិ ទើបឃើញកងទ័ព និង រថយន្តកងទ័ពវៀតណាមធំៗជាច្រើន គ្រប់ដំបូលជិតៗ បើកបរចេញពីខេត្តបាត់ដំបងឆ្ពោះទៅទិសដៅខាងកើត ។ ប្រជាជននិយាយថា កងទ័ពវៀតណាមដឹករបស់របរមានតម្លៃ ដែលគេដណ្តើមបានពីខ្មែរក្រហម ។

សម្រាប់មនុស្សភាគច្រើនការដួលរលំនៃរបបខ្មែរក្រហមគឺជាការជួបជុំឪពុកម្តាយ បងប្អូនញាតិមិត្ត ។ ពួកគេមានការសប្បាយរីករាយ ។ រឿងខ្ញុំខុសពីគេ ខ្ញុំឥតមានបានជួបជុំអ្នកណាទាំងអស់ ។ ខ្ញុំបានសច្ចាក្នុងចិត្តថា « បើសិនជាមានជាតិមុខពិត ខ្ញុំប្រាថ្នាកើតជាកូនរបស់ឪពុកម្តាយខ្ញុំ និងជួបជុំបងប្អូនប្រុសស្រីរបស់ខ្ញុំទាំង៧នាក់ម្តងទៀត» ។

## ក្រោយរបបខ្មែរក្រហម

ភូមិគ្រាង ពេលនោះ ស្ងាត់ជ្រងំ មានប្រជាជន បន្តរស់នៅប្រហែល៤-៥ខ្ទមតែប៉ុណ្ណោះ ។ ស្រូវទុំពេញស្រែ គ្មានអ្នកច្រូតទៀតទេ ។ ស្រូវ សណ្តែក ពោត នូវពេញៗ ស៊ីងគ្រប់ជង្រុក ។ មាន់ទា ជ្រូក គោ ក្របី ដើរ សេរី ពាសវាល ពាសកាល ។ រោងបាយរួមគ្មាន មនុស្ស ចូលហូប ដូចមុន ទៀតទេ ។ ស្ងាត់ជ្រងំដូចភូមិខ្មោច ។ មនុស្សម្នាទាំងឡាយ ដែលបានជួប ចិត្តល្អរកគ្នាណាស់ ។

ចេញពីភូមិគ្រាង ពូៗទាំងពីរនាក់ នៅតែបន្តជួយខ្ញុំ មកខេត្តពោធិ៍សាត់ទៀត ។ តែមកដល់ថ្នល់ជាតិ មុំស្វាយដូនកែវ ពូម្នាក់ត្រូវបែកទៅបាត់ដំបង ដោយគាត់ឮដំណឹងថា គេឃើញប្រពន្ធគាត់នៅរស់នៅឡើយ ។

ខ្ញុំបានដើរបន្តទៅដល់ផ្ទះកំណើតបស់ខ្ញុំដែលនៅក្នុងទីរួមខេត្តពោធិ៍សាត់ ជាមួយពូម្នាក់ទៀត ។ ដល់មុខផ្ទះ ខ្ញុំបានជួប អ្នកជិតខាងផ្ទះខ្ញុំ កាលពីមុន ដែលសល់ពីការស្លាប់ របប ប៉ុល ពត ។ គេទាំងអស់ មកឱរីត ហើយគ្រប់គ្នាៗ យំដោយក្តីនឹករលឹក និងអាណិតអាសូរ ។ គេមិនបានសួររឿងរ៉ាវ ឪពុកម្តាយខ្ញុំទេ ។ គេសួរតែខ្ញុំ ថាតើខ្ញុំនៅសល់បងប្អូនប៉ុន្មាននាក់? ។ ទាំងអស់គ្នា ចង់ឲ្យខ្ញុំរស់នៅក្នុងក្រុមគ្រួសាររបស់គេ ។ អ្នកជិតខាងបានប្រឹងប្រែងសុំឲ្យអ្នកដែលកាន់កាប់ផ្ទះខ្ញុំនោះ ឲ្យប្រគល់ផ្ទះនោះមកខ្ញុំវិញ ប៉ុន្តែគេបដិសេធ ។ គេបានប្រាប់ថា រដ្ឋត្រូវការផ្ទះនេះ សម្រាប់កិច្ចការជាតិ ។ គេប្រាប់ឲ្យខ្ញុំទៅរកផ្ទះផ្សេងនៅ ជំនួសវិញទៅ ។

ផ្ទះនេះលែងជារបស់ខ្ញុំទៀតហើយ ។ ដូច្នេះ ខ្ញុំត្រូវតែចាកចេញពីទី កន្លែងកំណើត ពីទីកន្លែងដែលខ្ញុំសុបិនទាំងថ្ងៃ ទាំងយប់ ថាបានមកនៅទីនេះម្តងទៀត ។ ខ្ញុំត្រូវតែចាកចេញ ដោយគ្មានទិសដៅម្តងទៀតតែម្នាក់គត់ ខ្ញុំចង់ទៅកន្លែងណាឲ្យឆ្ងាយ តាមតែអាចធ្វើបានព្រោះឈឺចាប់ ស្រងេះស្រងោចខ្លាំងពេក ។ រាងកាយទាំងមូលដូចមិនជាប់នឹងដី ស្រាលដូចសំឡី ។

ខ្ញុំបានស្នាក់នៅផ្ទះអ្នកជិតខាងពីរថ្ងៃ ដើម្បីរង់ចាំសមាជិកខាងគ្រួសារអ៊ំស្រីរបស់ខ្ញុំ ។ ក្រែងលោមានអ្នកណាម្នាក់ ជាសាច់ឈាមខ្ញុំនៅរស់ ។ ទោះជាដឹងថា ខ្ញុំមកដល់ភូមិផ្ទះកំណើតរបស់ខ្ញុំក្រោយគេក៏ដោយ ។ តែគ្មានបានឃើញអ្នកណាខាងគ្រួសារ អ៊ំស្រីរបស់ខ្ញុំត្រលប់មកវិញសោះ ។

ខ្ញុំសុំគេចូលក្នុងផ្ទះ ដើម្បីជាការនឹករឭក និងលាជាចុងក្រោយ ។ ទ្វារចូលខាងមុខពីរផ្ទាំងធំៗ ធ្វើពីឈើត្រូវបានកាប់បំផ្លាញ ។ កន្លែងតាំងតុទូចំកណ្តាលផ្ទះ មានស្នាមបំបែកការ៉ូ ជីកកកាយដី ដើម្បីរកអ្វីមួយ ។ ក្នុងបន្ទប់ឪពុកម្តាយខ្ញុំ ក៏មានស្នាមកាប់កកាយដែរ ។ គ្មានឃើញ គ្រែ តុ ទូ កែវកង មានតម្លៃដែលធ្លាប់តាំងទាំងឡាយ ដូចពីមុនទៀតទេ ។ **(តទៅលេខក្រោយ)**

**រ៉ែហម សុខណ្ណារិទ្ធិ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 207, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.